# អ្នកតស៊ូមតិ
# ប្រឆាំងនឹងរដ្ឋាភិបាលឬ?

ស្រាវជ្រាវ និងរៀបរៀងដោយ

លោក ញឹក សារិន

នាយកប្រតិបត្តិអង្គការកម្ពុជា

**កែសម្រួលដោយ លោកស្រី ធីដា ឃិះ**

**នាយិកាអង្គការសីលការ និងជា**

**ប្រធានគណៈកម្មការប្រតិបត្តិរបស់ស៊ីកា**

**គាំទ្រថវិកាដោយ DFID តាមរយៈ គណៈកម្មការអាស៊ីអភ្ញ្ញយ៍ដើម្បីតស៊ូមតិ**

**បោះពុម្ពលើកទី ២ ចំនួន ៣០០០ក្បាល នៅឆ្នាំ២០០៥**

---

**អង្គការសីលការៈ** លេខ៦S ផ្លូវលេខ២១ សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន ភ្នំពេញ

ទូរស័ព្ទលេខៈ ៨៥៥-០២៣-២១-៧៨៧២ ហ្វាក់លេខៈ ៨៥៥-០២៣-២១-៣១០៨

E-mail: Silaka@silaka.org ; Website: www.silaka.org

# **បុព្វកថា**

សៀវភៅដែលមានឈ្មោះថា "**អ្នកតស៊ូមតិ ប្រឆាំងនឹងរដ្ឋាភិបាលឬ?**" ជាស្នាដៃនិពន្ធរបស់លោក **ញឹក សារិន** នាយកប្រតិបត្តិ **អង្គការស្ពានកម្ពុជា** ដែលមានបទពិសោធន៍ ទៅលើប្រធានបទនេះ ។ លោកបានឆ្លងកាត់ និងអនុវត្តការងារ **តស៊ូមតិ** នេះដោយផ្ទាល់ និងបានធ្វើការបណ្តុះបណ្តាលពង្រឹងសមត្ថភាពដល់អង្គភាពនានា អំពីជំនាញនេះកន្លងមក ។ យើងខ្ញុំបានធ្វើការផ្តួចផ្តើម រៀបចំចងក្រងសៀវភៅនេះឡើង និងបោះពុម្ពលើកទី១ មានចំនួន ៨០០ក្បាល ដែលយើងបានចែកជូនដល់អាជ្ញាធរ អង្គការមិនមែនរដ្ឋាភិបាល ទាំងនៅភ្នំពេញ ទាំងនៅមូលដ្ឋានមួយចំនួន ព្រមទាំងសហគមន៍ ជាពិសេសនៅក្នុងខេត្តកំពង់ចាម ស្វាយរៀង និងកំពង់ធំ ។ សៀវភៅនេះទទួលបានជោគជ័យ ដោយយើងបានទទួលការស្នើសុំបន្ថែមទៀត ហើយដែលយើងសម្រេចបោះពុម្ពជាលើកទី ២ នេះ មានចំនួន ៣០០០ ក្បាល ។ ពាក្យ **តស៊ូមតិ** ឬ **ការស្វែងរកការគាំទ្រ** បានត្រូវគេប្រើប្រាស់កាន់តែច្រើនទៅៗ ។

**ការតស៊ូមតិ** ជំនាញថ្មី ដែលជនគ្រប់រូប និងស្ថាប័ននានា ត្រូវតែយល់ដឹង និងចេះប្រើប្រាស់ក្នុងការអនុវត្តន៍ភារកិច្ចរបស់ខ្លួននៅក្នុងសង្គមប្រជាធិបតេយ្យ ព្រោះថាការធ្វើផែនការ និងការអនុវត្តន៍គម្រោងនានារបស់ក្រុមហ៊ុន ឬការអនុវត្តន៍គោលនយោបាយនានារបស់រដ្ឋាភិបាល ក្រោមរូបភាពវិនិយោគទុន ដើម្បីអភិវឌ្ឍសេដ្ឋកិច្ច តែងមានផលប៉ះពាល់ដល់មនុស្សភាគច្រើនផ្សេងៗគ្នា ពិសេសចំពោះប្រជាពលរដ្ឋ ។ នៅពេលកម្ពុជាចូលក្នុងអង្គការពាណិជ្ជកម្មពិភពលោក WTO ទម្រង់នៃប្រព័ន្ធគ្រប់គ្រងរដ្ឋរបស់យើងកាន់តែចុះខ្សោយក្នុងការការពារផលប្រយោជន៍ផលិតករក្នុងស្រុក ហើយគោលការណ៍នៃ WTO តម្រូវឱ្យបើកចំហដើម្បីឱ្យហូរចូលនូវផលិតផលបរទេសនោះ ដូច្នេះ **ការតស៊ូមតិ** ជាជំនាញចាំបាច់មិនអាចខ្វះបាន ដើម្បីក្រុមនីមួយៗទាមទារ និងការពារផលប្រយោជន៍រៀងៗខ្លួន ។ ការតស៊ូមតិមិនមែនមានតែរវាងសង្គមស៊ីវិល នឹងរដ្ឋាភិបាលប៉ុណ្ណោះទេ តែនៅមានរវាងប្រភេទក្រុមនឹងលំដាប់ថ្នាក់ផ្សេងៗគ្នាទៀត ។ ក្រុមអ្នកបច្ចេកទេសនៅក្នុងរាជរដ្ឋាភិបាល ក៏ត្រូវការធ្វើ **ការតស៊ូមតិ** ជាមួយអ្នកមានសិទ្ធិអំណាច ដើម្បីទាមទារឱ្យមានការអនុវត្តន៍មានស្តង់ដារ និងក្បួនខ្នាតបានត្រឹមត្រូវ ។ **ការតស៊ូមតិ** ជាដំណើរការមួយ ដែលជួយឱ្យមានការសម្រេចចិត្តបានល្អ ក្នុងការអនុវត្តន៍គម្រោងផែនការ ឬគោលនយោបាយរបស់រដ្ឋាភិបាល ព្រោះថាតាមរយៈឥទ្ធិពលនៃ **ការតស៊ូមតិ** ការអនុវត្តន៍គម្រោងផែនការ ឬគោលនយោបាយទាំងនោះ ធ្វើឱ្យការប៉ះពាល់ជាអវិជ្ជមានតិចបំផុតលើជនរងគ្រោះ ។ ក្នុងលទ្ធិប្រជាធិបតេយ្យ និងក្នុងការអភិឌ្ឍន៍រាល់គម្រោងការធ្វើផែនការ ការធ្វើគោលនយោបាយទាំងឡាយ តែងតែមានផលប្រយោជន៍ចំពោះប្រជាពលរដ្ឋភាគច្រើន ហើយការផ្តល់យោបល់ សំរាប់ការអនុវត្តន៍ពីអ្នកទាំងនោះ គឺជាការចូលរួមមួយដ៏ចាំបាច់ ។ យើងជឿជាក់ថា មនុស្សគ្រប់រូបត្រូវតែមានការចេះដឹងអំពី **ការតស៊ូមតិ** ក្នុងការប្រើសិទ្ធិ សេរីភាពបញ្ចេញមតិទាមទារសំរាប់ការរស់នៅ

របស់ខ្លួន ។

ខ្ញុំនៅតែស្វាគមន៍ នូវរាល់មតិកែលំអ អំពីលោក-អ្នក ដើម្បីធ្វើឱ្យសៀវភៅនេះកាន់តែមានប្រសិទ្ធភាព ។

ឆ្លៀតឱកាសនេះ ខ្ញុំសូមថ្លែងអំណរគុណដល់ចក្រភពអង់គ្លេស ដែលបានផ្តល់ការគាំទ្រដល់អង្គការស៊ីកា (SEACA) សូមអរគុណដល់អង្គការ IPD នៅប្រទេសហ្វីលីពីន និងសូមអរគុណដល់លោក **ញ៉ឹក សារិន** ដែលបានផ្តល់ចំណេះដឹងបច្ចេកទេស និងបទពិសោធន៍ ផ្តល់ឱកាសដល់យើងខ្ញុំ ក្នុងការផលិតឯកសារនេះឡើង ។

ខ្ញុំសូមជូនពរដល់មាតុភូមិកម្ពុជាជាទីស្នេហារបស់យើង ឱ្យពោរពេញទៅដោយប្រជាពលរដ្ឋ ដែលចេះអនុវត្តភារកិច្ចរបស់ខ្លួន និងមានអ្នកដឹកនាំគ្រប់លំដាប់ថ្នាក់ ដែលស្គាល់នូវកាតព្វកិច្ចរបស់ខ្លួន ក្នុងការគិតគូរពីផលប្រយោជន៍របស់ប្រជាពលរដ្ឋជាធំ ។

**នាយិកាប្រតិបត្តិ អង្គការសីលការ និងជា**
**ប្រធានគណៈកម្មការប្រតិបត្តិ ស៊ីកា**

**ធីដា ឃិះ**

# អារម្ភកថា

ការតស៊ូមតិ បានផ្ដើមចេញពីការងារអភិវឌ្ឍន៍ នៃប្រទេសអ្នកក្រីក្រ ហើយជាការងារថ្មីមួយ សំរាប់ប្រទេសមួយចំនួននៅក្នុងតំបន់អាស៊ីអាគ្នេយ៍យើងនេះ ។ នៅកម្ពុជា ចលនានេះបានចាប់ផ្ដើមមានសកម្មភាពឡើងវិញនៅឆ្នាំ១៩៩៣ បន្ទាប់ពីអវត្តមានស្ទើរតែទាំងស្រុង នៅក្នុងរបបប្រល័យពូជសាសន៍ខ្មែរក្រហម និងរបបកុម្មុយនីស្ត (១៩៧៥ ដល់ចុង ឆ្នាំ១៩៩២) ។ ពេលនោះមានតែអង្គការមិនមែនរដ្ឋាភិបាលមួយចំនួនតូចតែប៉ុណ្ណោះ ដែលបានចាប់ផ្ដើមធ្វើការតស៊ូមតិស្របពេលជាមួយគ្នា នឹង អង្គការមិនមែនរដ្ឋាភិបាលមួយចំនួនធំ ដែលកំពុងតែផ្ដោតការយកចិត្តទុកដាក់របស់ខ្លួនទៅលើការអភិវឌ្ឍន៍ ដើម្បីចូលរួមចំណែកក្នុងការស្ដារឡើងវិញ នូវហេដ្ឋារចនាសម្ព័ន្ធជាតិ ដែលខ្ទេចខ្ទាំ ដោយ សង្គ្រាមរ៉ាំរ៉ៃជាងពីរ ទសវត្សរ៍កន្លងមកនេះ ។

រយៈពេលនៃការតស៊ូមតិដ៏ខ្លីនេះ ខ្ញុំសង្កេតឃើញថា បុគ្គលិកអង្គការមិនមែនរដ្ឋាភិបាល សមាជិកសហគមន៍ ប្រជាពលរដ្ឋ និងមន្ត្រីមួយចំនួន ពុំទាន់បានយល់ដឹងជ្រួតជ្រាបច្បាស់លាស់ថា តើការតស៊ូមតិនោះមានន័យយ៉ាងដូចម្ដេច ? កង្វះខាតនេះ ធ្វើឱ្យពួកគេពុំអាចប្រើយុទ្ធសាស្ត្រតស៊ូមតិ ដែលជាយុទ្ធសាស្ត្រមួយប្រកបដោយសន្តិវិធី ដើម្បីដោះស្រាយបញ្ហាដែលកើតមានឡើង ។ ជូនកាល គេប្រើអំពើហិង្សា ដើម្បីធ្វើជាដំណោះស្រាយបញ្ហាទៅវិញ ។

សៀវភៅនេះ ជាគំនិតផ្ដួចផ្ដើម របស់អង្គការសីលការ ហើយអាចដំណើរទៅបានជោគជ័យ ដោយសារមានការឧបត្ថម្ភ ថវិកាពីអង្គការស៊ីកា (គណៈកម្មការ ដើម្បីការតស៊ូមតិ នៅអាស៊ីអាគ្នេយ៍) ។ ខ្ញុំសង្ឃឹមថា ស្នាដៃដ៏តូចស្ដួចស្ដើងនេះ នឹងបានជាប្រទីបមួយ ដើម្បីជួយបំភ្លឺដល់រដ្ឋអំណាច អង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក សមាគម និងប្រជាពលរដ្ឋ អំពីការធ្វើផែនការតស៊ូមតិប្រកបដោយប្រសិទ្ធភាព ដែលក្នុងនោះមានការរៀបចំយុទ្ធនាការ ការបង្កើតយុទ្ធសាស្ត្រ ការចងក្រងបណ្ដាញការប្រើប្រាស់បណ្ដាញព័ត៌មាន ការត្រួតពិនិត្យ និងការវាយតម្លៃនៃការតស៊ូមតិជាដើមជាក់ជាពុំខានឡើយ ។ លើសពីនេះទៀត ខ្ញុំសង្ឃឹមថាលោកអ្នក នឹងអាចយល់ដឹងអំពីប្រវត្តិខ្លះៗ នៃការតស៊ូមតិរបស់សង្គមស៊ីវិល និងគោលនយោបាយសាធារណៈ នៅប្រទេសខ្មែរយើងបន្ថែមទៅលើអ្វី ដែលលោកអ្នកធ្លាប់បានយល់ដឹងរួចមកហើយ ។

ដើម្បីឆ្លើយតបទៅនឹងតម្រូវការខាងលើនេះ ដោយមានការគាំទ្រពីអង្គការសីលការ តាមរយៈការឧបត្ថម្ភ ខ្ញុំបានរៀបចំសៀវភៅណែនាំដែលមានចំណងជើងថា **អ្នកតស៊ូមតិប្រឆាំងនឹងរដ្ឋាភិបាលឬ?** ក្នុងគោលបំណងពីរ ។ ទី១ ដើម្បីផ្ដល់ជាចំណេះដឹង បន្ថែមដល់បុគ្គលិក អង្គការមិនមែនរដ្ឋាភិបាលជា ពិសេស

អង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក និងសហគមន៍ប្រជាពលរដ្ឋ ដែលលោកពុំទាន់មានសមត្ថភាពគ្រប់គ្រាន់ក្នុងការតស៊ូមតិ ដើម្បីជាប្រយោជន៍ខ្លួនឯង ក៏ដូចជាប្រជាពលរដ្ឋទូទៅផងដែរ ។ ទី២ ចង់ឱ្យរដ្ឋអំណាច និងសាធារណជនទូទៅ លោកបានយល់ដឹង អំពីនិយមន័យនៃការតស៊ូមតិ ដើម្បីឱ្យលោកបានចូលរួមជាមួយសង្គមស៊ីវិលក្នុងការ កសាងលទ្ធិប្រជាធិបតេយ្យនៅកម្ពុជា ឱ្យមានសន្ទុះឆ្ពោះទៅរកសង្គមមួយដែលមានការចម្រើន ជឿនលឿន ដូចបណ្តាប្រទេសអភិវឌ្ឍន៍នានាលើសាកលលោក ។

ជាទីបញ្ចប់ សូមថ្លែងអំណរគុណចំពោះ អង្គការសីលការ ស៊ីកា ដែលបានជួយផ្តល់ជាមតិយោបល់ និងថវិកាសំរាប់ការចងក្រងសៀវភៅនេះ និងសូមអរគុណចំពោះសហការីមួយចំនួន ដែលបានជួយផ្នែកបច្ចេកទេស ដើម្បីឱ្យសៀវភៅកើតជារូបរាងឡើង និងសូមថ្លៃអំណរគុណដល់ម្ចាស់ឯកសារដទៃៗទៀត ដែលខ្ញុំបានស្រង់យកនូវគំនិត និងខ្លឹមសារមួយចំនួន ដូចដែលមានលេខយោងមកជាមួយស្រាប់ ដើម្បីបន្ថែមទៅលើសំណេររបស់ខ្ញុំ ឱ្យកាន់តែមានភាពប្រសើរឡើង ។

ខ្ញុំពេញចិត្ត នឹងទទួលនូវការរិះគន់ ដើម្បីស្ថាបនា និងកែលំអលើស្នាដៃដ៏ស្តួចស្តើងនេះ ហើយនិងសូមអភ័យទោសផងដែរនូវរាល់កំហុសឆ្គងទាំងឡាយ ដែលកើតមានដោយចេតនាក្តី និងអចេតនាក្តី ទាំងខ្លឹមសារក៏ដូចជាអក្ខរាវិរុទ្ធ ។ ជាមួយគ្នានេះដែរ ខ្ញុំសូមឧទ្ទិសនូវស្នាដៃដ៏តូចនេះ ចំពោះបុព្វការីជន និងវីរបុព្វបុរសខ្មែរ សូមអស់លោកទាំងអស់នោះមកសណ្ឋិតក្នុងដួងព្រលឹងខេមរបុត្រគ្រប់ៗរូប ឱ្យមានសាមគ្គីភាព និងឯកភាពជាតិជាធ្លុងមួយ ដើម្បីរួមចំណែកកសាងមាតុភូមិឱ្យ ឆ្ពោះទៅរកសន្តិភាព ភុជិស្សភាព និងអភិវឌ្ឍនភាព ។

ភ្នំពេញ, ថ្ងៃទី ១០ ខែមិថុនា ឆ្នាំ ២០០៤

**ញឹក សារិន**

**នាយកប្រតិបត្តិអង្គការស្តារកម្ពុជា**

# មាតិការឿង


ផ្នែកទី១ : ទំព័រ

**អំពីការតស៊ូមតិ**

១- និយមន័យនៃការតស៊ូមតិ ..... ១

២- ប្រវត្តិនៃការតស៊ូមតិ ..... ៣

២.១. ប្រវត្តិនៃការតស៊ូមតិនៅកម្ពុជា ..... ៣

២.២. ប្រវត្តិនៃការតស៊ូមតិនៅប្រទេសថៃ ..... ៣

ផ្នែកទី២ :

**សង្គមស៊ីវិល** ..... ៦

១-តើសង្គមស៊ីវិលជាអ្វី? ..... ៦

២- ប្រភេទនៃសង្គមស៊ីវិល ..... ៧

២.១. អង្គការសង្គមស៊ីវិលវិជ្ជាជីវៈ ..... ៧

២.២. អង្គការសង្គមស៊ីវិលពង្រឹងសីលធម៌សង្គម ..... ៧

២.៣. អង្គការសង្គមស៊ីវិលជួយអ្នករងគ្រោះ ..... ៧

២.៤. អង្គការគាំទ្រអង្គការ ..... ៧

៣- តួនាទីរបស់សង្គមស៊ីវិលនៅកម្ពុជា ..... ៨

៤- ការរីកលូតលាស់នៃសង្គមស៊ីវិលនៅប្រទេសកម្ពុជា ..... ៨

៥- តើសង្គមស៊ីវិល បាននិងកំពុងប្រឈមមុខបញ្ហាអ្វីខ្លះ? ..... ១០

៦- តើសង្គមស៊ីវិលគួរតែមានគណបក្សដែរ ឬទេ? ..... ១២

ផ្នែកទី៣ :

**ការធ្វើឱ្យមានលទ្ធិប្រជាធិបតេយ្យ** ..... ១៣

១- ហេតុអ្វីបានជាសង្គមស៊ីវិលធ្វើការតស៊ូមតិ លើគោលនយោបាយ? ..... ១៣

២- ការយល់ដឹងអំពីគោលនយោបាយ ..... ១៣

៣- តួនាទីច្បាប់នៅក្នុងសង្គម ..... ១៤

៤- ប្រភេទនៃច្បាប់ ..... ១៥

៤.១. នីតិសាធារណៈ ..... ១៥

៤.២. នីតិឯកជន ..... ១៥

៥- ចរិតលក្ខណៈនៃច្បាប់ ..... ១៦

៥.១. ព្រះមហាក្សត្រអាស្រ័យរដ្ឋធម្មនុញ្ញ ..... ១៦

៥.២. ប្រជាធិបតេយ្យសេរី ..... ១៧

៥.៣. ពហុបក្ស ..... ១៨

៦- ការបែងចែកអំណាច ..... ១៩

៧- ទ្រឹស្តីនៃការបែងចែកអំណាច ..... ២០

- រចនាសម្ព័ន្ធរបស់រដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ..... ២១

- អំណាចនៃរដ្ឋាភិបាលកម្ពុជា ..... ២២

៨- តើអ្វីខ្លះដែលត្រូវអនុវត្តដោយអង្គទាំង៣? ..... ២៣

៨.១. នីតិបញ្ញត្តិ ..... ២៣

៨.២. នីតិប្រតិបត្តិ ..... ២៤

៨.៣. អង្គតុលាការ ..... ២៤

៩- តើប្រជាពលរដ្ឋអនុវត្តអំណាចរបស់គេតាមអង្គទាំង៣ខាងលើនេះយ៉ាងដូចម្តេច? ..... ២៤

៩.១. រដ្ឋសភា ..... ២៤

៩.២. រាជរដ្ឋាភិបាល ..... ២៥

៩.៣. តុលាការ ..... ២៥

១០- ដំណើរការនៃការអនុម័តិច្បាប់នៅកម្ពុជា ..... ២៥

១០.១. ការយល់ដឹងជាទូទៅអំពីការផ្តួចផ្តើមការធ្វើច្បាប់ ..... ២៥

១០.១.១. សេចក្តីព្រាងច្បាប់ -ស្នើដោយរាជរដ្ឋាភិបាល ..... ២៥

១០.១.២. សេចក្តីស្នើច្បាប់ -ស្នើឡើងដោយសមាជិករដ្ឋសភា ..... ២៦

១០.១.៣. សេចក្តីស្នើច្បាប់ -ស្នើឡើងដោយព្រឹទ្ធសភា ..... ២៦

១០.២. ដំណើរការពិភាក្សា និងអនុម័តលើសេចក្តីព្រាងច្បាប់ និងសេចក្តីស្នើ
ច្បាប់នៃរដ្ឋសភា ........ ២៦
១០.៣. ដំណើរការពិភាក្សា និងអនុម័តលើសេចក្តីព្រាងច្បាប់និងសេចក្តីស្នើ
ច្បាប់នៃព្រឹទ្ធសភា ........ ២៧
១០.៤. ដំណើរការពិនិត្យលើធម្មនុញ្ញភាពនៃច្បាប់របស់ក្រុមប្រឹក្សាធម្មនុញ្ញ ........ ២៨
១១- អំពីព្រឹទ្ធសភា និងរដ្ឋសភា ........ ២៩
១១.១. ព្រឹទ្ធសភា ........ ២៩
១១.១.១. ការបង្កើតព្រឹទ្ធសភា ........ ៣០
១១.២. រដ្ឋសភា ........ ៣៣
១១.២.១. មន្ត្រីដឹកនាំព្រឹទ្ធសភា ........ ៣៣
១១.២.២. គណៈកម្មាធិការអចិន្ត្រៃយ៍ ........ ៣៤
១១.២.៣. គណៈកម្មាធិការទាំង៩នៃរដ្ឋសភា ........ ៣៤
១១.២.៤. អគ្គលេខាធិការដ្ឋាន ........ ៣៤
១១.៣. អំពីរាជរដ្ឋាភិបាល ........ ៣៦
១១.៣.១. រចនាសម្ព័ន្ធ និងអង្គការចាត់តាំងរាជរដ្ឋាភិបាល ........ ៣៦
១១.៣.២. ទទួលនាទីរបស់គណៈរដ្ឋមន្ត្រី ........ ៣៦
១២- សមាជជាតិ ........ ៣៦
១៣- រចនាសម្ព័ន្ធថ្នាក់ជាតិ និងមូលដ្ឋាន ........ ៣៦
១៤- ការយល់ដឹងអំពីស្ថាប័នហិរញ្ញវត្ថុអន្តរជាតិ ........ ៤៣
១៤.១. មូលនិធិរូបិយវត្ថុអន្តរជាតិ ( អាយ អឹម អេហ្វ) ........ ៤៣
១៤.២. ធនាគារជាតិពិភពលោក ( វើល បែង) ........ ៤៣
១៤.៣. មូលនិធិអភិវឌ្ឍន៍អាស៊ី ........ ៤៤
១៤.៤. គោលនយោបាយនៃស្ថាប័នទាំងបីខាងលើ ........ ៤៤
១៥- តើប្រទេសកម្ពុជាយើងជំពាក់ប្រាក់ប្រទេសណាខ្លះ? ........ ៤៦
១៦- ម្ចាស់មូលនិធិ ឬម្ចាស់អំណោយ ........ ៤៧
១៦.១. អង្គការអន្តរជាតិ ........ ៤៧

១៦.២. ទីភ្នាក់ងារទ្វេភាគី ..... ៤៧
១៦.៣. ទីភ្នាក់ងារពហុភាគី ..... ៤៨
១៦.៤. មូលនិធិគណៈបក្សនយោបាយ ..... ៤៨
ផ្នែកទី៤ :
**ការតស៊ូមតិលើគោលនយោបាយ** ..... ៤៩
១- ការធ្វើផែនការសំរាប់ការតស៊ូមតិលើគោលនយោបាយ ..... ៤៩
២- ការធ្វើផែនទីនយោបាយសំរាប់សការតស៊ូមតិលើគោលនយោបាយ
ផែនទីនយោបាយជាអ្វី? ..... ៥០
៣- ជំហាននៃការធ្វើផែនទីនយោបាយ ..... ៥០

**ជំហានទី១.** ធ្វើការប៉ាន់ប្រមាណលើគោលនយោបាយដែលប៉ះពាល់ដល់ផលប្រយោជន៍សាធារណៈ ..... ៥០
១.១. សិក្សាអំពីគោលនយោបាយ ..... ៥០
១.២. ការវិភាគទៅលើបញ្ហា ..... ៥១
១.៣. ការប្រមាណនូវបញ្ហាដែលអាចកើតឡើង និងរៀបចំគម្រោងផែនការសកម្មភាព ..... ៥១
១.៤. ការបង្កើតគោលបំណង និងចាត់អាទិភាពលើសកម្មភាពដែលបានគ្រោង ..... ៥១

**ជំហានទី២.** ការវិភាគទៅលើកម្លាំងក្នុងការសម្រេចចិត្តលើគោលនយោបាយ និងការកំណត់នូវមនុស្ស ឬស្ថាប័នសំខាន់ៗ ..... ៥១
២.១. ការវិភាគលើអ្នកដែលមានសិទ្ធិសម្រេចលើគោលនយោបាយ ..... ៥១
២.២. ការធ្វើវិភាគលើក្រុមដែលពាក់ព័ន្ធ ..... ៥២
**ជំហានទី៣.** ការធ្វើវិភាគដំណើរការនៃការរៀបចំបង្កើតគោលនយោបាយ ..... ៥២
**ជំហានទី៤.** ការប៉ាន់ស្មានលើអ្វីដែលនឹងអាចមានការប្រែប្រួល ..... ៥៣
**ជំហានទី៥.** យុទ្ធសាស្រ្តតស៊ូមតិគោលនយោបាយ ..... ៥៣

ផ្នែកទី៥ :

**យុទ្ធសាស្ត្រនៃការតស៊ូមតិ** ........ ៥៤
១- ហេតុអ្វីបានជាយើងត្រូវធ្វើការតស៊ូមតិ? ........ ៥៤
២- ការតស៊ូមតិនៅអាស៊ីអាគ្នេយ៍ ........ ៥៤
២.១. តើការតស៊ូមតិបែបប្រឆាំងតវ៉ាផ្ទុយទៅនឹងការតស៊ូមតិបែបកែលំអ
ទម្រង់នយោបាយឬ? ........ ៥៤
២.២. ការតស៊ូមតិដើម្បីឱ្យមានការកែប្រែគោលការណ៍ច្បាប់ ឬទម្រង់នយោបាយ ........ ៥៥
២.៣. យុទ្ធសាស្ត្រក្នុងការផ្លាស់ប្តូរឥរិយាបថនៃជនមានអំណាច ក្រុម ឬស្ថាប័ននានា
ដែលរំលោភលើអ្នកដទៃ ........ ៥៧
៣- ទស្សនៈលើការរៀបចំផែនការតស៊ូមតិ ........ ៥៩
៤- ជំហាននៃការធ្វើផែនការតស៊ូមតិ ........ ៦០
៤.១. ទិសដៅ និងគោលបំណង ........ ៦០
៤.២. ការកំណត់ក្រុមគោលដៅ ........ ៦១
តារាងទី១. ការបែងចែកក្រុមគោលដៅតស៊ូមតិ ........ ៦១
តារាងទី២. ចំណាត់ថ្នាក់ក្រុមគោលដៅតស៊ូមតិ ........ ៦២
តារាងទី៣. ការវាយតម្លៃលើក្រុមគោលដៅតស៊ូមតិ ........ ៦២
តារាងទី៤. ការប្រៀបធៀបរវាងអ្នកមានសិទ្ធិសម្រេច និងអ្នកជួយដាក់សម្ពាធ ........ ៦២
៤.៣. ការវិភាគលើបរិស្ថានខាងក្រៅ ........ ៦៣
៤.៤. ការប៉ាន់ប្រមាណលើសមត្ថភាព និងធនធានរបស់យើង ........ ៦៤
៤.៥. ការវាយតម្លៃលើយុទ្ធសាស្ត្រ ........ ៦៤
៤.៦. ការកំណត់នូវអ្វីដែលយើងនឹងទាមទារ ........ ៦៥
៤.៧. ការធ្វើផែនការសកម្មភាព ........ ៦៥
៤.៨. ការវាយតម្លៃលើសកម្មភាព ........ ៦៥
- តារាងផែនការយុទ្ធសាស្ត្រការតស៊ូមតិ ........ ៦៦
៥. ការប្រើប្រាស់បណ្តាញព័ត៌មាន និងបណ្តាញដើម្បីធ្វើការតស៊ូមតិ ........ ៦៦

៥.១. ទស្សនៈទូទៅលើបណ្តាញព័ត៌មាន ........ ៦៧
៥.២. បណ្តាញព័ត៌មាន និងអ្នកសម្រេចចិត្តលើគោលនយោបាយ ........ ៦៧
៥.៣. អង្គការមិនមែនរដ្ឋាភិបាល និងព័ត៌មាន ........ ៦៨
៥.៤. តើអ្វីទៅដែលហៅថា ការតស៊ូមតិតាមរយៈបណ្តាញព័ត៌មាន? ........ ៦៨
៦- ប្រភេទនៃបណ្តាញព័ត៌មាន ........ ៦៩
៦.១. ព័ត៌មានពាក់កណ្តាលបច្ចេកវិទ្យាទំនើប ........ ៦៩
៦.២. វេទិកាសាធារណៈ ឬសន្និសីទសារព័ត៌មាន ........ ៦៩
៦.៣. ព័ត៌មានតាមប្រព័ន្ធអេឡិចត្រូនិច ........ ៧០
- ព័ត៌មានបោះពុម្ពផ្សាយ ........ ៧០
- ទូរទស្សន៍ ........ ៧០
- វេទិកាសាធារណៈ សន្និសីទសារព័ត៌មាន និងការសង្ខេបសន្និសីទព័ត៌មាន ........ ៧១
- ការតស៊ូមតិតាមទូរស័ព្ទ ........ ៧២
- ការផ្ញើសារតាមទូរស័ព្ទ ........ ៧២
- ការតស៊ូមតិតាមប្រព័ន្ធបច្ចេកវិទ្យាទំនើប ........ ៧២
៧- ការតស៊ូមតិដោយប្រើសកម្មភាព ........ ៧៣
៨- ការធ្វើផែនការព័ត៌មាន ........ ៧៤
៩- ការតវ៉ាបញ្ចុះបញ្ចូល ........ ៧៤
១០- តើយើងត្រូវធ្វើការតវ៉ាបញ្ចុះបញ្ចូលដើម្បីអ្វី? ........ ៧៦
១១- តម្រូវការរបស់អ្នកតវ៉ាបញ្ចុះបញ្ចូល ........ ៧៦
- លក្ខណសម្បត្តិ ........ ៧៧
- ចំណេះដឹង ........ ៧៧
១២- យុទ្ធសាស្ត្រនៃការតវ៉ាបញ្ចុះបញ្ចូល ........ ៧៧
- ការជួបជាផ្លូវការ ........ ៧៨
- ការជួបមិនផ្លូវការ ........ ៧៨

## ផ្នែកទី៦ :


**ការត្រួតពិនិត្យ និងវាយតម្លៃ** ........ ៧៩

១- ហេតុអ្វីយើងត្រូវធ្វើការត្រួតពិនិត្យ និងវាយតម្លៃ ........ ៧៩

២- តើការត្រួតពិនិត្យ និងការវាយតម្លៃផ្តល់ផលប្រយោជន៍អ្វីខ្លះដល់យើង? ........ ៨០

ក- ការត្រួតពិនិត្យ និងការវាយតម្លៃជួយឱ្យរបាយការណ៍ថវិកា យើងមានភាពគួរឱ្យជឿជាក់បាន ( មិនភូតភរ) ........ ៨០

ខ- បង្ហាញថា ការតស៊ូមតិរបស់អ្នកមានប្រសិទ្ធភាពក្នុងការកែលំអជីវភាពក្រុមគោលដៅ ........ ៨០

គ- រៀនសូត្រពីបទពិសោធន៍ ........ ៨០

៣- តើការត្រួតពិនិត្យ និងវាយតម្លៃខុសគ្នាយ៉ាងដូចម្តេច? ........ ៨១

៤- ការត្រួតពិនិត្យ ........ ៨៣

- សន្ទស្សន៍នៃការត្រួតពិនិត្យ ........ ៨៣

៤.១. ការត្រួតពិនិត្យក្រុមគោលដៅរបស់អ្នក ........ ៨៣

៤.២. ការត្រួតពិនិត្យនូវទំនាក់ទំនងរបស់អ្នក ........ ៨៤

៤.៣. ការត្រួតពិនិត្យលើបណ្តាញព័តិមាន ........ ៨៤

៤.៤. ការត្រួតពិនិត្យលើកិត្តិស័ព្ទ ........ ៨៤

៤.៥. ការត្រួតពិនិត្យលើមតិសាធារណៈ ........ ៨៤

៥- ការវាយតម្លៃ ........ ៨៤

៥.១. របៀបនៃការវាយតម្លៃ ........ ៨៤

៥.១.១. ការវាយតម្លៃលើដំណើការ ........ ៨៥

៥.១.២. ការវាយតម្លៃលើលទ្ធផល ........ ៨៦

៥.១.៣. ការវាយតម្លៃលើឥទ្ធិពល ........ ៨៦

៥.២. សន្ទស្សន៍ដែលគួរប្រើសំរាប់វាយតម្លៃការតស៊ូមតិ ........ ៨៧

៥.២.១. សន្ទស្សន៍លទ្ធផល និងឥទ្ធិពល ........ ៨៧

- សំនួរសំរាប់សន្ទស្សន៍ការកសាងលទ្ធិប្រជាធិបតេយ្យ ........ ៨៧

- សំនួរសំរាប់សន្ទស្សន៍ការរួមចំណែកក្នុងការជួយពង្រឹងសង្គមស៊ីវិល ........ ៨៨

- សំនួរសំរាប់សន្ទស្សន៍ការរួមចំណែកធ្វើឱ្យមាននិរន្តរភាព ..... ៨៨
- សំនួរសំរាប់សន្ទស្សន៍ការកែប្រែគោលនយោបាយ ..... ៨៨
៥.២.២. សន្ទស្សន៍ការគ្រប់គ្រង ..... ៨៩
៦- តើអ្វីដែលយើងគួរធ្វើត្រួតពិនិត្យ និងវាយតម្លៃ? ..... ៨៩
៧- បញ្ហាមួយចំនួនដែលគួរពិចារណាលើការត្រួតពិនិត្យ និងការវាយតម្លៃ ..... ៩០
៨- ចំនុចសំខាន់ដែលជួយឱ្យការត្រួតពិនិត្យ និងការវាយតម្លៃប្រព្រឹត្តទៅបានល្អ ..... ៩១

**ផ្នែកទី៧ :**

**យុទ្ធសាស្ត្រការតស៊ូមតិដែលមានជោគជ័យ** ..... ៩២
១- សភាអ្នកក្រីក្រប្រទេសថៃ ..... ៩២
២- ការតស៊ូមតិរបស់បណ្តាញអង្គការមិនមែន រដ្ឋាភិបាលខេត្តកំពង់ចាម ..... ៩៣
២.១. ដំណើររឿងសង្ខេប ..... ៩៣
២.២. យុទ្ធសាស្ត្ររបស់បណ្តាញតស៊ូមតិខេត្តកំពង់ចាមក្នុងការដោះស្រាយបញ្ហានេះ ..... ៩៤

**ឯកសារយោង** ..... ៩៦

**ឧបសម្ព័ន្ធ :**

១- ប្រវត្តិរបស់ គណៈកម្មការតស៊ូមតិអាស៊ីភាគអគ្នេយ៍ (SEACA)
២- ប្រវត្តិរបស់ អង្គការសីលការ (SILAKA)
៣- ប្រវត្តិរបស់ អង្គការស្តារកម្ពុជា
៤- ប្រវត្តិសង្ខេបតបស់លោក ញឹក សារិន ( អ្នកស្រាវជ្រាវ និងរៀបរៀងសៀវភៅ)
៥- តារាងឈ្មោះអង្គការដៃគូរបស់ស៊ីកា (SEACA) ដែលមានចូលរួម ក្នុងសកម្មភាព គំរោង CAT ឆ្នាំ២០០៣-២០០៤
៦- អាសយដ្ឋាន សំរាប់ទំនាក់ទំនង ស្ថាប័នរដ្ឋាភិបាល
៧- បញ្ជីរាយព្រះនាម និងនាមអ្នកតំណាងរាស្ត្រអាណត្តិទី៣ តាមមណ្ឌល

# ផ្នែកទី២

# អំពី

# ការតស៊ូមតិ

# ផ្នែកទី១
# អំពីការតស៊ូមតិ

## ១- និយមន័យនៃការតស៊ូមតិ

ពាក្យ "**ការតស៊ូមតិ**" មានដើមកំណើតមកពីពាក្យ អង់គ្លេសថា អាវ៉ូកាស៊ី[១] ។ នៅឆ្នាំ១៩៩៥ អង្គការពន្លឺខ្មែរ បានបកប្រែពាក្យអាវ៉ូកាស៊ីថា "**ការតវ៉ាបញ្ចុះបញ្ចូល**" ហើយក្រោយមកមានអង្គការមួយចំនួនទៀត បានបកប្រែពាក្យនេះថា **ការតស៊ូមតិ** ការស្វែងរកការគាំទ្រមតិ ការតវ៉ាបញ្ចុះបញ្ចូល ស្វែងរកការគាំទ្រគំនិតជាដើម ។ ដោយយល់ឃើញថា ពុំមែនមានតែពាក្យ "**ការតស៊ូមតិ**" ប៉ុណ្ណោះទេ ដែលមានការបកប្រែពុំឯកភាពគ្នា ជាពិសេសនៅក្នុងចំណោមអង្គការមិនមែនរដ្ឋាភិបាល អង្គការស្តារកម្ពុជា ក្រោមការឧបត្ថម្ភរបស់បណ្តាញកម្ពុជា គាំទ្រអង្គការមិនមែនរដ្ឋាភិបាល[២] បានរៀបចំឱ្យមានសន្និបាតអង្គការមិនមែនរដ្ឋាភិបាលមួយ នៅឆ្នាំ១៩៩៩ ដើម្បីដោះស្រាយបញ្ហានេះ ។ ពេលនោះ ពាក្យ "តស៊ូមតិ" ត្រូវបានឯកភាព ឱ្យប្រើជំនួសពាក្យ "ដែលបានបកប្រែខាងលើ"[៣] ។

និយាយអំពីនិយមន័យ នៃការតស៊ូមតិក៏ដូច្នេះដែរ នៅប្រទេសកម្ពុជាក៏ដូចជានៅលើបណ្តាប្រទេសផ្សេងៗ លើសកលលោកផង ដែរគេឱ្យនិយមន័យវាទៅតាមការយល់ដឹង និងការអនុវត្តន៏ជាក់ស្តែងរបស់ពួកគេរៀងៗខ្លួន ។ កាលពីឆ្នាំ១៩៩៨ នៅពេលដែលអង្គការស្តារកម្ពុជា បានផ្តួចផ្តើមរៀបចំ ឱ្យមានបណ្តាញតស៊ូមតិនៅតាមខេត្ត-ក្រុង ចំនួន ៤ គឺ ខេត្តកំពង់ចាម ក្រុងព្រះសីហនុ ខេត្តពោធិ៍សាត់ និងខេត្តស្វាយរៀង មានអង្គការមិនមែនរដ្ឋាភិបាលមួយចំនួនធំ



[១] Advocacy
[២] Cambodian Network Support NGOs (CNSN)
[៣] សន្និបាតអង្គការមិនមែនរដ្ឋាភិបាល បោះពុម្ព នៅឆ្នាំ១៩៩៩

មានការស្ទាក់ស្ទើរ ក្នុងការប្រើពាក្យ **ការតស៊ូមតិ** ពីព្រោះគេយល់ថា ការតស៊ូមតិជាសកម្មភាពមួយដែលប្រឆាំងទៅនឹងរដ្ឋាភិបាល ។ ប៉ុន្តែ បច្ចុប្បន្ននេះពាក្យ **ការតស៊ូមតិ** ត្រូវបាន គេទទួលស្គាល់ និងប្រើប្រាស់ជាទូទៅស្ទើរតែទូទាំងប្រទេសកម្ពុជា ។

តាមឯកសាររបស់អង្គការស្តារកម្ពុជា[៤] "ការតស៊ូមតិ គឺជាការចូលរួមរបស់ក្រុម ឬបុគ្គល ដើម្បីបញ្ចុះបញ្ចូលឱ្យមានការកែប្រែពីអ្វី ដែលមិនសមស្របឱ្យទៅជាការសមស្រប" ។ រីឯសៀវភៅ "**ណែនាំអំពីយុទ្ធសាស្ត្រការតស៊ូមតិ : ដើម្បីពង្រីកបរិយាកាស** ប្រជាធិបតេយ្យនៅកម្ពុជា" បានឱ្យនិយមន័យនៃការតស៊ូមតិថា ជាការរៀបចំនូវសកម្មភាព ជាបន្តបន្ទាប់ដើម្បីបញ្ចុះបញ្ចូល និងធ្វើឱ្យមានឥទ្ធិពលចំពោះបុគ្គលទាំងឡាយ ដែលមានតួនាទីសំខាន់ៗនៅក្នុងជួររដ្ឋាភិបាល អ្នកនយោបាយ ឬអ្នកដែលមានឥទ្ធិពលខាងសេដ្ឋកិច្ច ដើម្បីឱ្យពួកគេអនុវត្តតាមគោលនយោបាយសាធារណៈក្នុងគោលបំណងផ្តល់ប្រយោជន៍ ចំពោះប្រជាពលរដ្ឋ ដែលគ្មានអំណាចផ្នែកនយោបាយ និងមានធនធានសេដ្ឋកិច្ចតិចតួច[៥] ។ ចំណែកអង្គការមិនមែនរដ្ឋាភិបាលមួយចំនួនទៀត ឱ្យនិយមន័យលើការតស៊ូមតិថា ជាសកម្មភាពបញ្ចុះបញ្ចូល ដើម្បីឱ្យគេគាំទ្រនូវគំនិត ឬយោបល់របស់ខ្លួន[៦] ។ តាមកិច្ចសម្ភាសន៍ជាមួយនឹងអ្នកភូមិតើន ឃុំតើន នៅខេត្តរតនគិរី នៅឆ្នាំ ២០០៣ ពួកគាត់បានឱ្យនិយមន័យ នៃពាក្យតស៊ូមតិថា ជាការតវ៉ា ដើម្បី ឱ្យគេគោរពសិទ្ធិរបស់ពួកគាត់ និងធ្វើឱ្យជីវភាពរបស់គាត់មានភាពប្រសើរឡើង ។ យោងតាមនិយមន័យខាងលើ លោកអ្នកអាចយល់ដឹង និងកំណត់បានថា ដូចម្តេចទៅដែលហៅថាការតស៊ូមតិ ។ យើងអាចសរុបឱ្យខ្លីថា : **ការតស៊ូមតិ គឺជាកម្លាំងរួមមួយ ដើម្បីឱ្យមានការផ្លាស់ប្តូរពីអ្វីដែលមិនល្អឱ្យទៅជាល្អ** ។

វិទ្យាស្ថានតស៊ូមតិនៅប្រទេសឥណ្ឌា បែងចែកការតស៊ូមតិជាពីរផ្នែក **ការតស៊ូមតិលើបញ្ហាសង្គម** និង **ការតស៊ូមតិលើគោលនយោបាយ** ហើយជាទូទៅសកម្មភាពតស៊ូមតិលើបញ្ហាសង្គមមាន ច្រើនជាងសកម្មភាពការតស៊ូមតិ លើគោលនយោបាយ[៧] ។

---

[៤] ឯកសារមេរៀន "ការតស៊ូមតិ" របស់អង្គការស្តារកម្ពុជា បោះពុម្ពនៅ ឆ្នាំ១៩៩៩

[៥] សៀវភៅណែនាំអំពី យុទ្ធនាការតស៊ូមតិ បោះពុម្ពនៅឆ្នាំ ២០០៣ សសេរដោយ លោកស្រី គ្រីស្ទីនណា មែនហ្វីល លោក ឃីត ម៉ាកឡៅដ៍

[៦] ការផ្តួចផ្តើមការសិក្សាអំពីការតស៊ូមតិ កម្មវិធីអង្គការ អុកស្វាម អាមេរិក បោះពុម្ពនៅឆ្នាំ ១៩៩៩

[៧] ឯកាសារអីនធឺណែត ឆ្នាំ២០០៤




## ២- ប្រវត្តិនៃការតស៊ូមតិ

### ២.១. ប្រវត្តិនៃការតស៊ូមតិនៅកម្ពុជា

នៅប្រទេសកម្ពុជាយើង ការតស៊ូមតិត្រូវបានចាប់ផ្តើមអនុវត្ត ដោយក្រុមអ្នកនយោបាយមួយចំនួននៅរវាងឆ្នាំ១៩៣០ និងក្រោយមកទៀត ដោយអ្នកសារព័ត៌មានពីឆ្នាំ១៩៧០ ដល់១៩៧៥ ។ ជាអកុសលចលនាតស៊ូមតិត្រូវបាត់បង់ទៅវិញទាំងស្រុង នៅពេលដែលប្រទេសកម្ពុជា ស្ថិតនៅក្រោមរបបគ្រប់គ្រងរបស់ខ្មែរក្រហម ពីឆ្នាំ ១៩៧៥-១៩៧៩ ហើយបានបន្តអវត្តមានក្នុងរបបកុម្មុយនីស្ត ពីឆ្នាំ ១៩៨០-១៩៩២ ។ ចាប់ពីឆ្នាំ១៩៩៣មក ការតស៊ូមតិត្រូវបានបន្តឡើងវិញ ដែលភាគច្រើនដោយ អង្គការមិនមែនរដ្ឋាភិបាលអង្គការមហាជន និងអ្នកជំនាញការខាងតស៊ូមតិមួយចំនួន ។

### ២.២. ប្រវត្តិការស៊ូមតិនៅប្រទេសថៃ

នៅប្រទេសថៃ ចលនាតស៊ូមតិភាគច្រើនផុសចេញពីអង្គការសង្គមស៊ីវិល ។ ការកើតឡើងនូវអង្គការសង្គមស៊ីវិលដ៏សន្ធឹកសន្ធាប់នេះ ដោយសារប្រទេសថៃមានការផ្លាស់ប្តូរអ្នកដឹកនាំ និងរបបនយោបាយ ជាបន្តបន្ទាប់ ជាពិសេសចាប់ពីឆ្នាំ១៩៣២ (សង្គ្រាមលោកលើកទីពីរ) ជាពេលដែលរបបរាជានិយមបានចាប់ផ្តើមផ្លាស់ប្តូរទៅជារបបរាជាធិបតេយ្យ ហើយបន្តផ្លាស់ប្តូរមកជាលទ្ធិប្រជាធិបតេយ្យ ដូចយើងបានឃើញនាពេលបច្ចុប្បន្ននេះ ។ ក្នុងរយៈពេលអន្តរកាលខាងលើនេះ ប្រទេសថៃភាគច្រើនត្រូវបានគ្រប់គ្រងដោយរបបយោធា ទោះបីជាអ្នកដឹកនាំអះអាងថា គេបានផ្លាស់ប្តូរពីរបបរាជានិយមផ្តាច់ការមកជាលទ្ធិប្រជាធិតេយ្យក៏ដោយ ។ ការគ្រប់គ្រងបែបផ្តាច់ការពុំបានធ្វើឱ្យជីវភាពប្រជាជនថៃមានភាពប្រសើរឡើងឡើយ ។ ជាក់ស្តែងនៅឆ្នាំ ១៩៦១ រដ្ឋាភិបាលថៃ បានទទួលជំនួយពីសហរដ្ឋអាមេរិក និងខ្ចីលុយពីធនាគារពិភពលោក ដើម្បីអភិវឌ្ឍ ប្រទេសដែលសេដ្ឋកិច្ចកំពុងធ្លាក់ដុនដាប[៨] ។

[៨] របាយការណ៍ទស្សនកិច្ចសិក្សានៅប្រទេសថៃ ឆ្នាំ១៩៩៨ និងឯកសារទទួលបានពីក្រសួងការបរទេសនៃព្រះរាជាណាចក្រកម្ពុជា

ការទទួលជំនួយ និងការខ្ចីលុយពីបរទេស ដើម្បីអភិវឌ្ឍប្រទេស ពុំបានធ្វើឱ្យជីវភាពប្រជាពលរដ្ឋថៃបានធូរស្រាលឡើយ ។ ផ្ទុយទៅវិញ រដ្ឋាភិបាលបានកាប់ព្រៃឈើ សាងសង់ទំនប់ទឹក ធ្វើវារីអគ្គិសនី ដែលនាំឱ្យប៉ះពាល់ដល់លំនៅស្ថាន ដីស្រែប្រជាពលរដ្ឋដ៏ច្រើន ។ មិនត្រឹមតែប៉ុណ្ណោះ អ្នកភូមិ ត្រូវបង្ខំឱ្យចាកចោលលំនៅស្ថាន ទៅរស់នៅតំបន់ថ្មី ដែលជាដីគ្មានជីជាតិ និងគ្មានត្រីសាច់ ម្ហូបអាហារថែមទៀត ។ ដោយយល់ឃើញថាជីវភាពនៅឯតំបន់ជនបទកាន់តែមានការលំបាក ចាប់ពីឆ្នាំ១៩៧០-១៩៨០ និស្សិតដែលបានបញ្ចប់ការសិក្សានៅមហាវិទ្យាល័យទីក្រុងបាងកក បានរួមគ្នាជាកម្លាំងធ្វើចលនាដើម្បីស្តារ និងអភិវឌ្ឍន៍ជនបទដែលផ្ទុយគ្នាទៅនឹងគោលនយោបាយរបស់រដ្ឋាភិបាលថៃ ។ ចលនាតស៊ូមតិនេះគឺជាចលនាសង្គមស៊ីវិលលើកទី១ នៅប្រទេសថៃ ដែលក្រុមនិស្សិតទាំងនោះ បានបូជាកម្លាំងកាយចិត្តរបស់ពួកគេ ដោយសុខចិត្តទៅរស់នៅជាមួយប្រជាពលរដ្ឋ បង្រៀនប្រជាពលរដ្ឋ តាមជំនាញរបស់ពួកគេ ហើយពន្យល់ប្រជាពលរដ្ឋ អំពីមូលហេតុដែលបណ្តាលឱ្យពួកគាត់ក្រីក្រ តើភាពក្រីក្រវាបណ្តាលមកពីហេតុអ្វី? ហើយពួកគេក៏ចាប់ផ្តើមបង្រៀនប្រជាពលរដ្ឋ ឱ្យចេះចងក្រងគ្នាជាបណ្តាញ ។ សកម្មភាពនេះ បានផ្សារភ្ជាប់ទៅនឹងចលនាមួយដែលធ្វើឡើងដើម្បីប្រឆាំងនឹងរបបផ្តាច់ការ ។ ដោយមានការចូលរួមពីប្រជាពលរដ្ឋ នៅថ្ងៃទី១៤ ខែតុលា ឆ្នាំ១៩៧៣ ប្រជាពលរដ្ឋថៃរាប់ពាន់នាក់ បានងើបឡើងទាមទារឱ្យមានលទ្ធិប្រជាធិបតេយ្យពិត។ ទាំងនៅក្នុងទីក្រុងបាងកក និងជនបទ ។ ចលនានេះធ្វើឡើង ដើម្បីបណ្តេញចេញនូវមន្ត្រីពុករលួយ និងជនផ្តាច់ការមួយចំនួន ដែលប្រជាជនថៃឱ្យឈ្មោះថា **"ចលនាយុគមាសនៃលទ្ធិប្រជាធិបតេយ្យ"** ។

ដោយចលនាតស៊ូមតិ និងបទពិសោធន៍របស់ពួកគេនៅមានកម្រិត ចលនានេះពុំអាចទម្លាក់រដ្ឋាភិបាលដ៏មានអំណាចនេះឡើយ ហើយនៅថ្ងៃទី៦ ខែតុលា ឆ្នាំ១៩៧៦ ចលនាយុគមាសនេះ ត្រូវបានបង្ក្រាបដោយរដ្ឋាភិបាល ហើយសកម្មជន និងនិស្សិតមួយចំនួនត្រូវតាមចាប់ខ្លួន ដែលជាហេតុធ្វើឱ្យអ្នកទាំងអស់នោះ ត្រូវភៀសខ្លួនទៅរស់នៅជនបទ និងខ្លះទៀតត្រូវលាក់ខ្លួន ។ ឃើញសភាពការណ៍យ៉ាងនេះ នៅឆ្នាំ១៩៧០ អង្គការសង្គមស៊ីវិលថៃមួយឈ្មោះ **ធីអអម**[៥] ដែលចលនា អង្គការមិនមែនរដ្ឋាភិបាលទី១ បានសហការជាមួយនិស្សិតដើម្បីអភិវឌ្ឍន៍ និងស្តារប្រទេសថៃ ហើយចលនានេះបានផ្តល់២៥ភាគរយ លើសម្ភារៈ អភិវឌ្ឍន៍ និង៧៥ភាគរយ លើធនធានមនុស្សសំរាប់ចលនានិស្សិតធ្វើការអភិវឌ្ឍន៍ ។ ទោះបីជាយ៉ាងណាក៏ដោយក៏អង្គការ **ធីអអម** នៅតែពុំទាន់មានកម្លាំង សមត្ថភាព និងធនធានមនុស្សគ្រប់គ្រាន់ ដើម្បីធ្វើការពង្រឹងសមត្ថភាពដល់សហគមន៍ និងចលនានិស្សិតបានឡើយ ។ នៅពេលនោះ អង្គការមិនមែនរដ្ឋាភិបាល ឈ្មោះ

[៥] ចលនាស្តារជនបទប្រទេសថៃ TRRR Thailand Rural Requiem Reconstruction Movement

**ធីវីអេស**[១០] ក៏បានបង្កើតឡើង ដើម្បីជួយហ្វឹកហ្វឺន និងបង្កើនសមត្ថភាពដល់និស្សិត និងអង្គការមហាជន ថែមទៀត ហើយអង្គការនេះបានរួមគ្នាបង្កើតជា អិនហ្សេអូខូដ[១១] ដែលមានបណ្តាញនៅប្រាំតំបន់ ភាគខាងជើង ភាគឦសាន ភាគខាងត្បូង ភាគកណ្តាល និងទីក្រុងបាងកក ។ តាមរយៈកម្មវិធីនេះ នៅឆ្នាំ១៩៧៨ ចលនាតស៊ូមតិ អង្គការមិនមែនរដ្ឋាភិបាលមួយចំនួន បានរួមកម្លាំងជាមួយនិស្សិត និងសហគមន៍ ចាប់ផ្តើមចលនាតស៊ូមតិរបស់ខ្លួន ដោយចាប់ផ្តើមពីភូមិភាគឦសានមុនគេ ។ ទន្ទឹមនឹងប្រទេសថៃ កំពុងជួបប្រទះនូវស្ថានភាពសេដ្ឋកិច្ចក្រីក្រដ៏ធ្ងន់ធ្ងរ ហើយមានមនុស្សជាច្រើនបានភៀសខ្លួនទៅជនបទ និងចលនាអង្គការមិន មែនរដ្ឋាភិបាល ចលនានិស្សិត និងសហគមន៍រីកខ្លាំងឡើងៗជាបន្តបន្ទាប់ ហើយមានការគាំទ្រ ពីសហគមន៍អន្តរជាតិ និងអភិបាលក្រុងបាងកកផងនោះ ទោះបីជាមានការបង្ក្រាបយ៉ាងព្រៃផ្សៃ និងបង្ហូរឈាមពីសំណាក់យោធាដ៏សាហាវ យ៉ាងណាក៏ដោយ ក៏ចលនាតស៊ូមតិនេះ ទទួលបានជោគជ័យដោយព្រះមហាក្សត្រថៃ ស្នើសុំ ឱ្យលោក ស៊ុចិន្តា ក្រាប្រាយូន ចុះចេញពីតំណែងនាយករដ្ឋមន្ត្រី នៅខែវិច្ឆិកា ឆ្នាំ១៩៩២ ។



[១០] អង្គការសេវាកម្មស្ម័គ្រចិត្តប្រទេសថៃ TVS Thai Volunteer Service

[១១] បណ្តាញអង្គការមិនមែនរដ្ឋាភិបាល NGO CODE

# ផ្នែកទី២

## អំពី

# លក្ខមន្ទីរពិល

# ផ្នែកទី២
## សង្គមស៊ីវិល

### ១- តើសង្គមស៊ីវិលជាអ្វី ?

មានការឱ្យនិយមន័យ និងការយល់ឃើញខុសគ្នាទៅលើពាក្យសង្គមស៊ីវិល ។ តាមឯកសារ របស់អង្គការស្ពារកម្ពុជា សង្គមស៊ីវិលជាក្រុមមួយនៅចន្លោះគ្រួសារ និងរដ្ឋ[១២] ។ សង្គមស៊ីវិលមិនស្ថិតនៅក្រោមស្ថាប័នរដ្ឋាភិបាល ឬស្ថាប័នឯកជនឡើយ ។ សង្គមស៊ីវិល ទោះបីជាក្រុមប្រជាពលរដ្ឋ អង្គការ សមាគម ឬក៏សហគមន៍ក្តី តែងតែធ្វើការដោយឯករាជ្យ មិនទទួលប្រាក់បៀវត្សពីរដ្ឋ ហើយភាគច្រើននៃក្រុមនេះ ជាអ្នកធ្វើការដោយស្ម័គ្រចិត្ត ហើយគោរពយ៉ាងខ្ជាប់ខ្ជួនតាមក្រមសីលធម៌របស់ខ្លួន ។ ក្រុមសង្គមស៊ីវិល ធ្វើការតស៊ូមតិដោយមិនប្រើអាវុធ តែប្រើអំណាចស្របច្បាប់ ហើយមិនមានបំណង ចង់បានអំណាចពីរដ្ឋាភិបាលពោលគឺធ្វើការដើម្បីប្រយោជន៍ទៅតាមក្រុមគោលដៅរបស់គេជាពិសេស ដើម្បីប្រយោជន៍របស់សង្គមទាំងមូល ។




យោងតាមឯកសារមួយចំនួនបានឱ្យដឹងថា សង្គមស៊ីវិលនៅកម្ពុជាកើតឡើងចាប់តាំងពីសម័យអាណានិគមបារាំងមកម្ល៉េះ ប៉ុន្តែសង្គមស៊ីវិលដែលលេចធ្លោជាងគេ គឺអង្គការសង្គមស៊ីវិល (ក្រុមអង្គការមិនមែនរដ្ឋាភិបាល) ដែលបានចាប់កំណើតនៅឆ្នាំ ១៩៩៣ នៅពេលដែលប្រទេសកម្ពុជាចាប់ផ្តើមអនុវត្តលទ្ធិប្រជាធិបតេយ្យ ។ អង្គការសង្គមស៊ីវិលភាគច្រើន អាចដំណើរការសកម្មភាពរបស់ពួកគេទៅបានអាស្រ័យដោយជំនួយបរទេស និងជំនួយសប្បុរសជន ។

[១២] ឯកសារស្តារកម្ពុជា បោះពុម្ព នៅឆ្នាំ ១៩៩៩

## ២- ប្រភេទនៃសង្គមស៊ីវិល

សង្គមស៊ីវិលចែកចេញជាបួនផ្នែក[១៣] :

### ២.១.អង្គការសង្គមស៊ីវិលវិជ្ជាជីវៈ

អង្គការសង្គមស៊ីវិល នេះ តែងតែប្រើវិជ្ជាជីវៈ ដើម្បីអនុវត្តនូវសកម្មភាព របស់ខ្លួន ។ ក្រុមនេះមានអ្នក កាសែត មេធាវី និងគ្រូ បង្រៀន ។ល ។



### ២.២. អង្គការសង្គមស៊ីវិលពង្រឹងសីលធម៌សង្គម

ក្រុមនេះធ្វើការយ៉ាងសកម្ម ក្នុងការចូលរួមចំណែកពង្រឹងគុណតម្លៃ និងសីលធម៌សង្គម ក្នុងនោះមាន សមាគមព្រះសង្ឃ ពុទ្ធសាសនិក គណៈកម្មាធិការវត្ត និងគណៈកម្មការអាចារ្យវត្តជាដើម ។

### ២.៣. អង្គការសង្គមស៊ីវិលជួយអ្នករងគ្រោះ

ក្រុមនេះរៀបចំកម្មវិធីរបស់ខ្លួន ដើម្បីជួយប្រជាពលរដ្ឋដែលកំពុងទទួលរងគ្រោះ ឬងាយនឹងរងគ្រោះ ដោយធម្មជាតិ ឬដោយអ្នកមានអំណាច ។ ក្រុមនេះរួមមានអង្គការការពារបរិស្ថាន រក្សាវប្បធម៌ លើកតម្កើង សិទ្ធិមនុស្ស លទ្ធិប្រជាធិបតេយ្យ ការអភិវឌ្ឍន៍ជាដើម ។

### ២.៤. អង្គការគាំទ្រអង្គការ

ជាអង្គការរឹងមាំ ដែលមានកម្មវិធីជួយអង្គការផ្សេងៗ ដើម្បីមានលទ្ធភាពធ្វើការជួយជនរងគ្រោះ ។ ក្រុមនេះ ពេលខ្លះគាំទ្រតែលើការពង្រឹងសមត្ថភាព ពេលខ្លះជួយផ្ដល់តែថវិកា និងពេលខ្លះ គាំទ្រទាំងលើការ ពង្រឹងសមត្ថភាព និងថវិកា ។ ក្រុមនេះមានអង្គការអន្តរជាតិ ម្ចាស់មូលនិធិ និងបណ្ដាញអង្គការមិនមែន រដ្ឋាភិបាលជាដើម ។

[១៣] ឯកសារស្តារកម្ពុជា បោះពុម្ពឆ្នាំ១៩៩៩

## ៣- តួនាទីរបស់សង្គមស៊ីវិលនៅកម្ពុជា

សង្គមស៊ីវិលនៅកម្ពុជា កំពុងធ្វើការលើវិស័យផ្សេងៗ ដូចជាការកាត់បន្ថយភាពក្រីក្រ លើកស្ទួយលទ្ធិប្រជាធិបតេយ្យ ការគោរពសិទ្ធិមនុស្ស ការធានាឱ្យមានការបោះឆ្នោតត្រឹមត្រូវ និងយុត្តិធម៌ ការតស៊ូមតិ តវ៉ាបញ្ចុះបញ្ចូលលើបញ្ហាផ្សេងៗ ។ល។ និង ។ល។ សង្គមស៊ីវិល មានកម្មវិធីនេះ ស្ទើរតែទូទាំងប្រទេស ហើយកម្មវិធីនេះកំពុងតែរួមចំណែកយ៉ាង



សកម្ម ក្នុងការស្តារប្រទេសកម្ពុជាឡើងវិញ បន្ទាប់ពីសង្គ្រាមរ៉ាំរ៉ៃជាងពីរទសវត្សរ៍កន្លងទៅនេះ ។ ក្រុមសង្គមស៊ីវិលខ្លះ ធ្វើការដើម្បីអ្នកទីពីរ ក្រុមខ្លះធ្វើការ ដើម្បីផលប្រយោជន៍របស់ក្រុមខ្លួនផ្ទាល់ ក្រុមខ្លះធ្វើការសហការជាមួយនឹងរដ្ឋាភិបាល និងក្រុមខ្លះទៀតធ្វើការឃ្លាំមើលការអនុវត្តន៍របស់រដ្ឋាភិបាល ។ ដូច្នេះកម្មវិធីរបស់គេមិនផ្តាច់ចេញឆ្ងាយពីរដ្ឋាភិបាលឡើយ ។ សង្គមស៊ីវិលដែលជាអង្គការមិនមែនរដ្ឋាភិបាល ជាអង្គការឯករាជ្យ មិនស្ថិតនៅក្រោមគណបក្សនយោបាយ ឬស្ថាប័នណាមួយឡើយ ។

## ៤- ការវិវត្តលូតលាស់នៃសង្គមស៊ីវិលនៅប្រទេសកម្ពុជា

ប្រហាក់ប្រហែលទៅនឹងប្រទេសមួយចំនួននៅលើពិភពលោក ប្រទេសកម្ពុជាបានឆ្លងកាត់នូវដំណាក់កាលនយោបាយយ៉ាងច្រើន ។ គ្រប់ដំណាក់កាលនីមួយៗ ចលនាសង្គមស៊ីវិលច្រើនបានផុសឡើង ដើម្បីប្រឆាំងនឹងរបបផ្តាច់ការជិះជាន់ អាណានិគមកុម្មុយនីស្ត និងរបបសក្តិភូមិជាដើម ។ ជាក់ស្តែងពីឆ្នាំ ១៩១៦ ដល់១៩៤៥ មានចលនាសង្គមស៊ីវិលជាច្រើន ដែលបានងើបឡើងប្រឆាំងនឹងរបបអាណានិគមបារាំង ហើយត្រូវបានបង្ក្រាបដោយរបបនេះ[១៤] ។ ពេលនោះសកម្មជនមួយចំនួន ត្រូវជាប់ពន្ធនាគារ និងមួយចំនួនទៀត ត្រូវ

[១៤] ប្រវត្តិសាស្ត្រនៃកម្ពុជា សរសេរដោយលោក ដាវីដ ឆានដល័រ បោះពុម្ពនៅឆ្នាំ ១៩៩៨

បានគេប្រហារជីវិតទៀតផង តួយ៉ាងដូចជា ក្រឡាហោមគង់ លោកគ្រូអាចារ្យ ហែម ចៀវ លោក អៀវ កើស ជាដើម ។ល។និង។ល។ អ្នកទាំងនោះត្រូវបានគេចោទថា ជាក្រុមប្រឆាំង ទោះបីជាធ្វើការតវ៉ា ដោយសន្តិវិធីក៏ដោយ ។ បន្តបន្ទាប់មកទៀត នៅពេលដែលប្រទេសកម្ពុជាស្ថិតនៅក្រោមរបបសង្គមនិយម សមាគម គណៈកម្មាធិការវត្ត ក្រុមសហករណ៍ បានបង្កើតឡើងយ៉ាងផុលផុស ។ ក្រុមនេះធ្វើការដើម្បីការពារសិទ្ធិរបស់ក្រុមខ្លួន និងធ្វើការ ដើម្បីចូលរួមចំណែកក្នុងការអភិវឌ្ឍន៍ និងពង្រឹងសីលធម៌ ដែលជាប្រភពនៃសន្តិភាពនៅក្នុងសង្គម ។ ទន្ទឹមនឹងនេះ ក្រុមមួយចំនួនទៀត បានតវ៉ាចំពោះភាពអយុត្តិធម៌សង្គមតាមរយៈការសុំឱ្យមានការកែប្រែរដ្ឋធម្មនុញ្ញ និងពាំនាំនូវលទ្ធិប្រជាធិបតេយ្យចូលមកកម្ពុជា។ ជាអកុសល សកម្មជន មួយចំនួនត្រូវបានទទួលការគំរាមកំហែង កាប់សម្លាប់យ៉ាងសាហាវព្រៃផ្សៃ ពីសំណាក់អ្នកដឹកនាំរដ្ឋ ។ នៅឆ្នាំ ១៩៧០-១៩៧៥ មានចលនាសង្គមស៊ីវិល ជាពិសេសក្រុមនិស្សិត ធ្វើចលនាដើម្បីកែប្រែនយោបាយរបបសាធារណរដ្ឋ និងមានសមាគមវិជ្ជាជីវៈមួយចំនួនដូចជា សមាគមអ្នកកាសែត មេធាវី ដែលធ្វើការ ដើម្បីបំរើផលប្រយោជន៍សង្គមជាដើម ។ ក្រុមសង្គមស៊ីវិល ត្រូវបាត់វត្តមានទាំងស្រុងក្នុងរបបខ្មែរក្រហម ពីឆ្នាំ ១៩៧៥-១៩៧៩ និង ពីឆ្នាំ ១៩៨៩-១៩៩២ ដែលគ្រប់គ្រងដោយរបបរដ្ឋកម្ពុជា សង្គមស៊ីវិល មានចលនាឡើងវិញ គឺចលនានិស្សិតសាកលវិទ្យាល័យភ្នំពេញ ទន្តសាស្ត្រ ចំការដូង វិទ្យាស្ថានគ្រប់គ្រង និងសកម្មជនមួយចំនួន ដែលទាមទារឱ្យរដ្ឋ



ផ្តល់ចំពោះពួកគេនូវសិទ្ធិសេរីភាពក្នុងការបញ្ចេញមតិយោបល់ និងសិទ្ធិក្នុងការរួមប្រជុំ ។

ចំណែកសង្គមស៊ីវិល ដែលជាអង្គការមិនមែនរដ្ឋាភិបាល គេឃើញមានអង្គការអន្តរជាតិ ចំនួន១៥ ដែលមកកម្ពុជាមុនគេ ដើម្បីបំពេញតួនាទីរបស់ខ្លួនលើកម្មវិធីជួយសង្គ្រោះបន្ទាន់ និងស្តារឡើងវិញនូវហេដ្ឋា

រចនាសម្ព័ន្ធ ដែលទ្រុឌទ្រោមដោយសារសង្គ្រាមជាងពីរទសវត្សរ៍កន្លងទៅនោះ ។ ក្រុមសង្គមស៊ីវិលនេះ ធ្វើការតាមលក្ខខណ្ឌពហុភាគី( ភាគីច្រើន) និងទ្វេភាគី( ភាគីពីរ) ដោយមិនប្រកាន់គណបក្សនយោបាយ មិនស្វែងរកកម្រៃផ្ទាល់ខ្លួន ហើយផ្តោតទៅលើតែការងារអភិវឌ្ឍន៍តែប៉ុណ្ណោះ ។

លុះដល់ឆ្នាំ១៩៨៧ អង្គការមិនមែនរដ្ឋាភិបាលបានកើនចំនួនរហូតដល់២៧ ។ អង្គការទាំងអស់នេះបានចំណាយទឹកប្រាក់ប្រមាណ ១០លានដុល្លារ ដើម្បីធ្វើការអនុវត្តន៍កម្មវិធីរបស់ខ្លួន នៅតាមខេត្តចំនួន ៩ ។ បច្ចុប្បន្ននេះ មានអង្គការ សង្គមស៊ីវិលរហូតដល់៩០៦ ដែលបានចុះឈ្មោះនៅក្រសួងមហាផ្ទៃ ។[១៥] ចំនួននេះមិនរាប់បញ្ចូលគណបក្សនយោបាយ និងសហជីពកម្មករទេ ។

## ៥- តើសង្គមស៊ីវិល បាននឹងកំពុងប្រឈមមុខបញ្ហាអ្វីខ្លះ ?

អង្គការសង្គមស៊ីវិលនៅកម្ពុជាមានការរីកដុះដាលហួសពីការស្មាន បន្ទាប់ពីការរៀបការបោះឆ្នោតនាឆ្នាំ១៩៩៣ ។ មូលហេតុនេះ ធ្វើឱ្យអង្គការសង្គមស៊ីវិលមួយចំនួនបាន និងកំពុងប្រឈមមុខទៅនឹងបញ្ហានិរន្តរភាពថវិកា និងសមត្ថភាព ។ អង្គការសង្គមស៊ីវិលខ្លះ ពឹងផ្អែកទៅលើតែអ្នកដឹកនាំតែម្នាក់ ឬថវិកាមកពីម្ចាស់មូលនិធិតែមួយ ។ ពេលអ្នកដឹកនាំនោះចេញទៅបំរើការនៅស្ថាប័នផ្សេង ឬម្ចាស់មូលនិធិនោះផ្តាច់ជំនួយ អង្គការនោះហាក់បីដូចជាពុំមានភាពប្រក្រតី ឬអាចផ្អាកដំណើរការសកម្មភាពរបស់ខ្លួនទាំងស្រុង ។ សង្គមស៊ីវិលមួយចំនួនទៀត មាននិន្នាការលំអៀងលើគណបក្សនយោបាយ ដែលធ្វើឱ្យរាជរដ្ឋាភិបាលមានលេសបង្ក្រាបសកម្មភាពរបស់ខ្លួន ហើយម្ចាស់មូលនិធិពុំអាចបន្តការផ្តល់ថវិកាថែមទៀតផង ។ ទាក់ទងទៅនឹងសមត្ថភាពការងារ ជាពិសេសសមត្ថភាពក្នុងការតស៊ូមតិ អង្គការសង្គមស៊ីវិលពុំទាន់មានសមត្ថភាពគ្រប់គ្រាន់ដើម្បីតវ៉ា ឬចរចាជាមួយរដ្ឋាភិបាលឡើយ[១៦] ។ បញ្ហានេះ បណ្តាលមកពីមន្ត្រីសង្គមស៊ីវិលភាគច្រើនចេញពីប្រជាជនសាមញ្ញ ដែលមានកម្រិតសិក្សាទាប ប៉ុន្តែមានឆន្ទៈស្រឡាញ់ភាពយុត្តិធម៌ចង់ឱ្យសង្គមមានលទ្ធិប្រជាធិបតេយ្យ ។ ម្យ៉ាងវិញទៀត អ្នកចេះដឹងដែលមានសញ្ញាបត្រខ្ពង់ខ្ពស់ ច្រើនតែបំរើការងារនៅក្នុងជួររដ្ឋាភិបាល ឬគណបក្សនយោបាយ ដែលផ្តល់ឱកាសឱ្យពួកគេទទួលបាននូវបុណ្យសក្តិធំដុំ ។ លើសពីនេះ សង្គមស៊ីវិលនៅកម្ពុជាយើង ក៏នៅមានសមត្ថភាពទាបក្នុងការតស៊ូមតិកម្រិតអន្តរជាតិ និងតំបន់ផងដែរ តួយ៉ាងដូចជា សាកលភាវូបនីយកម្ម លទ្ធិប្រជាធិបតេយ្យពិភពលោក អភិបាលកិច្ចពិភពលោក អាស៊ីអាគ្នេយ៍ជាដើម ។ ប៉ុន្តែទោះបីជាយ៉ាងណាក៏ដោយ អង្គការសង្គមស៊ីវិលបានទទួលការយកចិត្តទុកដាក់យ៉ាងខ្លាំងលើ

[១៥] ស្ថិតិអង្គការសមាគមអង្គការមិនមែនរដ្ឋាភិបាល បោះពុម្ព នៅឆ្នាំ ១៩៩៩

[១៦] ឯកសារស្រាវជ្រាវ ស្តីពីអង្គការមិនមែនរដ្ឋាភិបាលនៅកម្ពុជា រៀបរៀងដោយលោកស្រីធីតា ឃីះ បោះពុម្ព នាឆ្នាំ ២០០០

ការពង្រឹងសមត្ថភាពការងារពីម្ចាស់មូលនិធិ ជាពិសេសលើការងារតស៊ូមតិ ហើយឥឡូវនេះត្រូវបានគេផ្តល់សិទ្ធិសេរីភាព ឱ្យចូលរួមក្នុងការងារនយោបាយ និងផ្តល់ឱកាសឱ្យធ្វើការ ដើម្បីទាមទារឱ្យមានភាពត្រឹមត្រូវ យុត្តិធម៌ និងសមភាពនៅក្នុងសង្គម ជាពិសេសក្រោយពីពេលដែលលទ្ធិប្រជាធិបតេយ្យបានចាប់ផ្តើមនៅកម្ពុជា ។

ស្រដៀងគ្នាទៅនឹងការអភិវឌ្ឍន៍ខាងលើនេះ សង្គមស៊ីវិលនៅអាស៊ីអាគ្នេយ៍ ក៏បានធ្វើឱ្យមានការរីកចម្រើនលើការតស៊ូមតិ គួរឱ្យកត់សំគាល់ ។ ឧទាហរណ៍ វិបត្តិសេដ្ឋកិច្ចនៅអាស៊ីអាគ្នេយ៍ឆ្នាំ ១៩៩៧ សង្គមស៊ីវិល បានចូលរួមយ៉ាងសកម្ម ដើម្បីដោះស្រាយបញ្ហានេះ ជាពិសេសសង្គមស៊ីវិលនៅប្រទេសឥណ្ឌូនេស៊ី និង ម៉ាឡេស៊ី ។

ដោយឡែក នៅប្រទេសថៃឆ្នាំ១៩៩៧ សង្គមស៊ីវិល បានដើរតួយ៉ាងសំខាន់ក្នុងការចូលរួមកែប្រែច្បាប់រដ្ឋធម្មនុញ្ញ ហើយនៅប្រទេសហ្វីលីពីនឯណោះវិញ សង្គមស៊ីវិលបានធ្វើយុទ្ធនាការទម្លាក់ លោក **ហ្សូស៊ីប អាស្ត្រាដា** ពីអំណាចនៅដើមឆ្នាំ ២០០១ ។

ដោយសារបរិបទនយោបាយ និងវប្បធម៌សង្គម នៃបណ្តាប្រទេសនៅអាស៊ីអាគ្នេយ៍មានភាព ខុសៗគ្នា ចលនាសង្គមស៊ីវិល ក៏មានភាពខុសគ្នាដែរ ។ តួយ៉ាងដូចជា ប្រទេសទីម័រ ដែលកំពុងកសាងប្រទេសជាតិបន្ទាប់ពីទទួលបានឯករាជ្យពីប្រទេសឥណ្ឌូនេស៊ី ។ ប្រទេសភូមាស្ថិតនៅក្រោមអំណាចផ្តាច់ការ កម្ពុជាមានលទ្ធិប្រជាធិបតេយ្យពុំទាន់បរិបូរណ៍ និងវៀតណាម កាន់លទ្ធិកុម្មុយនីស្ត សង្គមស៊ីវិលពុំទាន់មានបទពិសោធន៍ច្បាស់លាស់ចំពោះការតស៊ូមតិ ។ តាមរយៈសិក្ខាសាលា ដែលបានរៀបចំនៅឆ្នាំ១៩៩៩ ដោយ**វិទ្យាស្ថានកាតូលិកដើម្បីទំនាក់ទំនងអន្តរជាតិ** តាមរយៈកម្មវិធីរបស់ខ្លួន ឈ្មោះថា ការពង្រឹងសមត្ថភាព ការតស៊ូមតិនៅអាស៊ី បានកំណត់ថា ក្រុមសង្គមស៊ីវិល ត្រូវការចាំបាច់នូវការអភិវឌ្ឍន៍យុទ្ធសាស្ត្រ និងបច្ចេកទេសនៃការតស៊ូមតិ ។ ការកំណត់នេះ ត្រូវបានគេផ្អែកទៅលើកត្តាថា សង្គមស៊ីវិលទាំងអស់នៅអាស៊ីអាគ្នេយ៍ ត្រូវការពង្រឹងសមត្ថភាព ដើម្បីយល់ដឹងអំពីដំណើរការនៃការសម្រេចចិត្តរបស់រាជរដ្ឋាភិបាល និងការអនុវត្តន៍ ហើយធ្វើយ៉ាងណាឱ្យរដ្ឋាភិបាលទទួលយកសង្គមស៊ីវិលឱ្យចូលរួមក្នុងការពង្រឹងលទ្ធិប្រជាធិបតេយ្យ ។ ម្យ៉ាងវិញទៀត ក្រុមនេះបានកំណត់ថា សង្គមស៊ីវិលត្រូវតែយល់ដឹងអំពីគោលនយោបាយសេដ្ឋកិច្ចតាមកម្រិតទ្វេភាគី និងពហុភាគី ដែលជាប្រយោជន៍ដ៏សំខាន់ដល់សង្គមស៊ីវិលក្នុងការធ្វើអន្តរាគមន៍ ឬចូលរួមក្នុងការវិវឌ្ឍន៍នៃសាកលភាវូបនីយកម្ម ។

## ៦- តើសង្គមស៊ីវិលគួរតែមានគណបក្សដែរ ឬទេ ?

នៅក្នុងប្រទេសមួយចំនួន នៅតំបន់អាស៊ីអាគ្នេយ៍យើងនេះ ដូចជាប្រទេសប្រេស៊ីល ម៉ាឡេស៊ី និង ហ្វីលីពីន សង្គមស៊ីវិលបានសម្រេចចិត្ត ដើម្បីធ្វើការតស៊ូមតិទៅលើផ្នែកនយោបាយដោយផ្ទាល់ ។ មានន័យថា គេចូលរួមក្នុងការធ្វើសេចក្ដីសម្រេចចិត្តលើគោលនយោបាយ ជាជាងធ្វើការតស៊ូមតិឱ្យអ្នកនយោបាយធ្វើការ សម្រេចចិត្តជំនួសពួកគេ ។ គេបង្កើតឱ្យមានគណបក្សនយោបាយ ដែលមានគោលនយោបាយច្បាស់លាស់ តំណាងឱ្យប្រជាពលរដ្ឋទូទៅ ។ សហជីពកម្មករ ថ្នាក់ដឹកនាំសហគមន៍របស់ប្រទេសខាងលើនេះ កំពុងតែមាន ចលនាឃោសនាប្រកួតប្រជែងរកសន្លឹកឆ្នោតជាមួយអ្នកនយោបាយ ។ រីឯប្រទេសកម្ពុជាយើងវិញ ការធ្វើបែប នេះអាចមានគ្រោះថ្នាក់ ព្រោះកម្លាំងសង្គមស៊ីវិលនៅទន់ខ្សោយអាចឱ្យក្រុមសង្គមស៊ីវិលនឹងទទួលរងការ គាបសង្កត់ពីអ្នកនយោបាយដែលមានអំណាច ។ សកម្មជនសង្គមស៊ីវិលយល់ឃើញថា សង្គមស៊ីវិលត្រូវនៅឱ្យ ដាច់ពីអ្នកនយោបាយ ។ ការធ្វើបែបនេះ អាចជួយឱ្យអង្គការសង្គមស៊ីវិលមានភាពឯករាជ្យ ស្វយ័ត និងរឹងមាំ ក្នុងការតាមដានត្រួតពិនិត្យ និងកែលំអកម្មវិធីនយោបាយរបស់រដ្ឋាភិបាល ។

# ផ្នែកទី៣

## អំពី

# ការធ្វើឱ្យមានលទ្ធិ

# ប្រជាធិបតេយ្យ

# ផ្នែកទី៣
# ការធ្វើឱ្យមានលទ្ធិប្រជាធិបតេយ្យ

## ១- ហេតុអ្វីបានជាសង្គមស៊ីវិលធ្វើការតស៊ូមតិលើគោលនយោបាយ ?

ដើម្បីឱ្យមានលទ្ធិប្រជាធិបតេយ្យ អង្គការសង្គមស៊ីវិលមិនមែនធ្វើការតស៊ូមតិត្រឹមតែទៅលើគោលនយោបាយរបស់រដ្ឋាភិបាលតែប៉ុណ្ណោះទេ សង្គមស៊ីវិលក៏ធ្វើការតស៊ូមតិលើបញ្ហាផ្សេងៗទៀតដែរ ដូចជាជម្លោះសាសនា ការអភិវឌ្ឍន៍ សុខភាព សន្តិភាព ដោះមីនជាដើម ។ ដោយប្រធានបទនេះ ផ្តោតទៅលើតែគោលនយោបាយសាធារណៈ ដែលមានន័យថា គោលនយោបាយរបស់រដ្ឋាភិបាល យើងសូមលើកអំពីមូលហេតុអ្វីដែលជំរុញសង្គមស៊ីវិលឱ្យធ្វើការលើបញ្ហានេះ ។ មូលហេតុពីរយ៉ាង ដែលសង្គមស៊ីវិលធ្វើការលើគោលនយោបាយសាធារណៈ ១-សង្គមស៊ីវិលដែលជាអ្នកតំណាងឱ្យប្រជាពលរដ្ឋ មានសិទ្ធិធ្វើអន្តរាគមន៍ និងចូលរួមក្នុងដំណើរការ នៃការពង្រឹងលទ្ធិប្រជាធិបតេយ្យ តាមរយៈការចូលរួមបង្កើតគោលនយោបាយសាធារណៈដើម្បីធានាឱ្យគោលយោបាយនោះបំរើសេចក្តីត្រូវការរបស់ប្រជាជន តាមរយៈការតវ៉ា បញ្ចុះបញ្ចូលអ្នកដំណាងរាស្ត្រ និងមន្ត្រីរដ្ឋាភិបាលដែលបោះឆ្នោតដោយប្រជាជន ។ ២-គោលនយោបាយរដ្ឋាភិបាល នឹងធ្វើឱ្យមានការប៉ះពាល់ដល់ប្រយោជន៍សង្គមដ៏ធំធេង ប្រសិនបើប្រជាពលរដ្ឋចាំតែអនុវត្ត ឬក៏គោរពតាមតែគោលនយោបាយ ដែលធ្វើដោយរដ្ឋាភិបាលតែម្នាក់ឯងនោះ ។ ចំពោះក្រុមហ៊ុនធំៗ ទោះបីសេចក្តីសម្រេចចិត្តរបស់គេអាចមានផលប៉ះពាល់ចំពោះប្រជាជនរាប់ពាន់នាក់ក៏ដោយ អ្នកដែលប៉ះពាល់នោះមិនតម្រូវឱ្យត្រូវតែគោរពទៅតាមសេចក្តីសម្រេចរបស់ក្រុមហ៊ុននោះទេ ។ ចំណែកឯបណ្តាញព័ត៌មាន ក៏យ៉ាងដូច្នេះដែរ ទោះបីជាសំណេររបស់គេមានឥទ្ធិពល ឬទទួលយកជាការពិតដោយប្រជាជនរាប់លាននាក់ក៏ដោយ ក៏ពួកគេពុំមានអំណាចដាក់ទោសទៅលើអ្នកដែលពុំបានគោរពទៅលើសំណេរនោះឡើយ ។ ប៉ុន្តែគោលនយោបាយរបស់រដ្ឋាភិបាល ប្រជាពលរដ្ឋត្រូវតែគោរព ហើយបើមិនគោរព ប្រជាពលរដ្ឋនោះ នឹងត្រូវទទួលទោស ។

## ២- ការយល់ដឹងអំពីគោលនយោបាយសាធារណៈ

### តើអ្វីទៅជាវិធាន ?

វិធានគឺជាក្បួនច្បាប់ ឬបទដ្ឋានដែលគេបង្កើតឡើងដើម្បីបង្ហាញផ្លូវដល់មនុស្សឱ្យប្រព្រឹត្តតាមគន្លងដ៏ប្រពៃ ។ វិធានមានពីរប្រភេទគឺ **វិធានដែលមានកម្លាំងច្បាប់ និងវិធានដែលគ្មានកម្លាំងច្បាប់** ។ **វិធានដែលមាន**

កម្លាំងច្បាប់ គឺជាវិធានដែលតម្រូវឱ្យមានការដាក់ទណ្ឌកម្មដោយរដ្ឋ នៅពេលណាវិធានទាំងនោះ ត្រូវបានបំពាន ។ (ឧទាហរណ៍ ជនណាម្នាក់ចូលលំនៅស្ថានគេ ដោយគ្មានការអនុញ្ញាត ជននោះត្រូវផ្តន្ទាទោស ។ នេះគឺជាវិធានតាមផ្លូវច្បាប់) ។ វិធានដែលគ្មានកម្លាំងច្បាប់ គឺជាបទដ្ឋានដែលគេបានបង្កើត និងការទទួលយល់ព្រមដោយក្រុម ឬសង្គមមួយ ដើម្បីណែនាំ ឬតម្រង់តិរិយាបថនៃសមាជិករបស់ក្រុម ឬសង្គមនោះ ។ យើងអាចនិយាយបានថា វាជាក្រមសីលធម៌ដែលក្រុមនោះស្មោះស្ម័គ្រគោរពតាម ។ វិធានមិនតាមផ្លូវច្បាប់ គ្មានកម្លាំងច្បាប់ឡើយ ។ នេះមានន័យថាគេទទួលស្គាល់វិធានទាំងនោះថា ជាវិធីសមរម្យមួយដើម្បីអនុវត្ត ប៉ុន្តែអ្នកទាំងនោះ នឹងមិនត្រូវបានដាក់ទណ្ឌកម្មដោយរដ្ឋ ប្រសិនបើពួកគេមិនដើរតាមវិធានទាំងនោះ ។ ឧទាហរណ៍ ដូចជាគ្មាននរណាម្នាក់ត្រូវពាក់មួកនៅក្នុងវត្តទេ កូនត្រូវចូលផ្ទះមុនម៉ោងប្រាំបួនជាដើម ។ មានវិធានច្រើនប្រភេទខុសប្លែកពីគ្នាដូចជា វិធានខាងសាសនា វិធានសាលា វិន័យប្រចាំគ្រួសារ ក្រមសីលធម៌អង្គការមិនមែនរដ្ឋាភិបាល ។ល។




### ៣- តួនាទីច្បាប់នៅក្នុងសង្គម

#### តើអ្វីទៅជាច្បាប់ ?

ច្បាប់ គឺជាវិធានដែលរដ្ឋ ឬប្រទេសជាតិបានតាក់តែង និងដាក់កម្រិតឱ្យអនុវត្ត និងជាវិធានដែលកំណត់បទបញ្ជា ឬរបៀបរៀបរយនៃការប្រព្រឹត្តរបស់ប្រជាពលរដ្ឋនៅក្នុងសង្គម និងថែរក្សារបៀបរៀបរយសង្គម ។ ជាទូទៅ ច្បាប់ឆ្លុះបញ្ចាំងឱ្យឃើញពីតម្លៃខាងសីលធម៌ សេដ្ឋកិច្ចសង្គម និងនយោបាយរបស់សង្គម ។ ដោយហេតុផលនេះហើយ ទើបច្បាប់មានលក្ខណៈខុសប្លែកគ្នា រវាងប្រទេសមួយទៅប្រទេសមួយទៀត ។ ឧទាហរណ៍ ប្រទេសដែលកាន់សាសនាអ៊ីស្លាម ដូចជាប្រទេសអ៊ីរ៉ង់ជាដើម មានគុណតម្លៃខុសប្លែកគ្នាទៅនឹងគុណតម្លៃនៃសហរដ្ឋអាមេរិក ។ កត្តានេះហើយដែលធ្វើឱ្យច្បាប់មានលក្ខណៈខុសប្លែកគ្នា ពីព្រោះថាគេធ្វើច្បាប់ឱ្យស្របទៅតាមគុណតម្លៃទាំងនោះ ។ និយាយជារួមច្បាប់គឺជាវិធាននានា ដែលធ្វើឡើងយោងទៅលើ

វប្បធម៌ សាសនា ទំនៀមទម្លាប់ប្រពៃណីនៃសង្គមនោះ ។

## ៤- ប្រភេទនៃច្បាប់

ច្បាប់ចែកចេញជាច្រើនប្រភេទដោយឡែកៗពីគ្នា អាស្រ័យទៅតាមគោលបំណងនៃច្បាប់ទាំងនោះ ។ ជាទូទៅ ច្បាប់ត្រូវបានគេចាត់ចេញជាពីរក្រុម **គឺនីតិសាធារណៈ** និង **នីតិឯកជន** ។

### ៤.១. នីតិសាធារណៈ

នីតិសាធារណៈ គឺជាផ្នែកដ៏សំខាន់នៃបណ្ដានីតិទាំងឡាយ ដែលពាក់ព័ន្ធជាមួយបទបញ្ជា និងឥរិយាបថរបស់រដ្ឋ និងការគ្រប់គ្រងនៃទំនាក់ទំនងរវាងរដ្ឋ និងប្រជាពលរដ្ឋ ។ ឧទាហរណ៍ នីតិរដ្ឋបាល គឺជាអង្គនៃច្បាប់ដែលពាក់ព័ន្ធជាមួយការអនុវត្តន៍នៃអំណាច និងបុព្វសិទ្ធិរបស់នីតិប្រតិបត្តិ ដូចជាក្រសួង ស្ថាប័នសាធារណៈ និងស្ថាប័ននានា ដែលបង្កើតឡើងដោយច្បាប់ ដូចជាក្រុមប្រឹក្សាសំរាប់អភិវឌ្ឍន៍កម្ពុជា ធនាគារជាតិ ក្រសួងនានា ។ល។ នីតិព្រហ្មទណ្ឌគ្រប់គ្រងឥរិយាបថសាធារណជន និងបង្កើតភារកិច្ចនានា ដែលពាក់ពន្ធ័ដោយបុគ្គលម្នាក់ៗចំពោះសង្គម ។ រឿងក្ដីព្រហ្មទណ្ឌមានទណ្ឌកម្ម ដែលតម្រូវឱ្យអ្នកប្រព្រឹត្តបទល្មើសជាប់គុក ពិន័យជាប់ឃុំ ឬដាក់ទោស តាមវិធីផ្សេងៗទៀត ។ ច្បាប់ស្ដីអំពីការបោះឆ្នោត ជ្រើសរើសតំណាងរាស្ត្រ ក៏ជានីតិសាធារណៈផងដែរ ។ ច្បាប់នេះផ្ដល់សិទ្ធិឱ្យប្រជាពលរដ្ឋបោះឆ្នោតជ្រើសរើសតំណាងរបស់ខ្លួន ដើម្បីធ្វើការក្នុងរដ្ឋាភិបាល ។

### ៤.២. នីតិឯកជន

នីតិឯកជន គឺជាផ្នែកមួយដ៏សំខាន់ផងដែរនៃបណ្ដានីតិទាំងឡាយ ដែលគ្រប់គ្រងទំនាក់ទំនងរវាងបុគ្គលនឹងបុគ្គល ឬមនុស្សមួយក្រុម និងមួយក្រុមទៀត ។ បណ្ដឹងរដ្ឋប្បវេណី ជួយការពារសិទ្ធិស្របច្បាប់របស់ជនណាម្នាក់ ដែលត្រូវបានគេរំលោភបំពាន ។ តុលាការអនុវត្តសិទ្ធិស្របច្បាប់របស់បុគ្គលទាំងនោះដោយផ្ដល់សំណងជំងឺចិត្តជាទឹកប្រាក់ឱ្យជនរងគ្រោះ ជាថ្នូរចំពោះការបង់ខាត ដោយអំពើខុសឆ្គង ឬដោយបញ្ជាឱ្យជនដែលប្រពឹត្តអំពើខុសឆ្គងរដ្ឋប្បវេណី សងតាមវិធីផ្សេងៗទៀត ។ ច្បាប់កិច្ចសន្យា ច្បាប់គ្រួសារ ច្បាប់ទ្រព្យសម្បត្តិ គឺជាផ្នែកតូចមួយនៃនីតិឯកជន ព្រោះវាទាក់ទងទៅនឹងការលែងលះគ្នា កិច្ចសន្យា អចលនទ្រព្យ ការធានារ៉ាប់រង កិច្ចការពារអតិថិជន និងការឆ្ងេសប្រហែសជាដើម ។

## ៥- ចរិតលក្ខណៈនៃច្បាប់

យើងបានសិក្សារួចមកហើយ អំពីតួនាទីនៃច្បាប់ និងប្រភេទនៃច្បាប់ជារួម ។ ឥឡូវនេះ យើងក្រឡេកមើលជាពិសេសទៅលើច្បាប់ និងរចនាសម្ព័ន្ធច្បាប់កម្ពុជាវិញម្តង ។ ដូចដែលបានគូសបញ្ជាក់ពីខាងលើស្រាប់មកហើយ ច្បាប់គឺជាវិធានដែលដាក់ឱ្យអនុវត្ត ដើម្បីឆ្លុះបញ្ចាំងឱ្យឃើញពីតម្លៃសីលធម៌ សេដ្ឋកិច្ចសង្គម និងនយោបាយរបស់សង្គម ។ ដើម្បីប៉ាន់ស្មាន ឬវាយតម្លៃនូវចរិតលក្ខណៈ រចនាសម្ព័ន្ធ និងប្រព័ន្ធច្បាប់ នៃប្រទេសជាតិណាមួយ ដំបូងយើងត្រូវពិនិត្យមើលរដ្ឋធម្មនុញ្ញនៃប្រទេសនោះជាមុនសិន ។ តួយ៉ាងប្រទេសកម្ពុជា បានផ្លាស់ប្តូររបប ចរិត និងរចនាសម្ព័ន្ធរបស់ខ្លួនច្រើនលើកច្រើនសា ។ នៅពេលមានការផ្លាស់ប្តូរម្តងៗ ចរិត និងរចនាសម្ព័ន្ធនៃរដ្ឋាភិបាលកម្ពុជា ត្រូវបានឆ្លុះបញ្ចាំងនៅក្នុងរដ្ឋធម្មនុញ្ញនៃសម័យកាលនោះ ។ ឧទាហរណ៍ រដ្ឋធម្មនុញ្ញ ឆ្នាំ១៩៨១ បានបង្កើតប្រជាជាតិមួយដោយឈរលើគោលការណ៍លទ្ធិសង្គមនិយម ហើយរដ្ឋាភិបាលក៏បានបង្កើតឱ្យមានរចនាសម្ព័ន្ធស្របទៅតាមនោះដែរ ។ ស្រដៀងគ្នានេះនៅឆ្នាំ ១៩៧០ រដ្ឋធម្មនុញ្ញកម្ពុជា បានបង្កើតរបបសាធារណរដ្ឋមួយ ដែលឆ្លុះបញ្ចាំងឱ្យឃើញអំពីការផ្លាស់ប្តូររចនាសម្ព័ន្ធ និងចរិតនៃរបបនោះ ។ ឥឡូវនេះយើងក្រឡេកមើលរដ្ឋធម្មនុញ្ញកម្ពុជា ១៩៩៣ [១៧] ដើម្បីសាកល្បងវិភាគ ចរិតលក្ខណៈនៃប្រជាជាតិកម្ពុជា ។ មាត្រាទីមួយនៃរដ្ឋធម្មនុញ្ញ ឆ្នាំ១៩៩៣ ចែងពីចរិត និងរចនាសម្ព័ន្ធកម្ពុជាថា ប្រទេសកម្ពុជា ជាព្រះរាជាណាចក្រ ដែលព្រះមហាក្សត្រប្រតិបត្តិតាមរដ្ឋធម្មនុញ្ញ និងលទ្ធិប្រជាធិបតេយ្យសេរីពហុបក្ស" ។ ដូច្នេះយើងអាចសន្និដ្ឋានបានថាចរិតលក្ខណៈនៃប្រជាជាតិកម្ពុជាបច្ចុប្បន្នគឺ ៖

(១) ព្រះមហាក្សត្រអាស្រ័យរដ្ឋធម្មនុញ្ញ

(២) ប្រជាធិបតេយ្យសេរី

(៣) ពហុបក្ស

### ៥.១. ព្រះមហាក្សត្រអាស្រ័យធម្មនុញ្ញ

តាមប្រវត្តិសាស្ត្រពីបុរាណកាល ក៏ដូចជាកម្ពុជាយើងបច្ចុប្បន្ន ព្រះមហាក្សត្រ (ព្រះរាជា) ត្រូវបានប្រជាពលរដ្ឋខ្មែរគោរព និងចាត់ទុកថា ជាអ្នកដែលមានអំណាច និងប្រាជ្ញាលើសគេ ឬអាចនិយាយបានថា ជាអធិបតេយ្យនៃប្រទេស ឬជាប្រមុខរដ្ឋ ។ តាមរដ្ឋធម្មនុញ្ញ ព្រះរាជាគឺជាអំណាចប្រតិបត្តិដ៏ខ្ពង់ខ្ពស់បំផុត ដែលតំណែងនេះជាតំណែងតពូជពង្ស ឬដោយការជ្រើសរើស ។ ប្រទេសកម្ពុជា ក្រោយពីមានការផ្លាស់ប្តូររបបច្រើនលើកច្រើនសាមក នៅឆ្នាំ១៩៩៣ ប្រទេសកម្ពុជាត្រូវក្លាយជាព្រះរាជាណាចក្រ ដែលជារដ្ឋមួយមាន

[១៧] រដ្ឋធម្មនុញ្ញ ឆ្នាំ ១៩៩៣ អនុម័តដោយសភាធម្មនុញ្ញនៅថ្ងៃទី ២១ និងប្រកាសឱ្យប្រើប្រាស់ជាផ្លូវការ នៅថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ១៩៩៣។ រដ្ឋធម្មនុញ្ញនេះត្រូវបានធ្វើវិសោធនកម្មចំនួនបីលើកហើយ មកដល់បច្ចុប្បន្ននេះ

ព្រះមហាក្សត្រ (ឬព្រះមហាក្សត្រត្រីយ៍) ជាប្រធាន និងជាអ្នកអនុវត្តអំណាច ជាអធិបតេយ្យ ទោះបីជាក្នុងសមត្ថកិច្ចដាច់ខាត ឬមានកម្រិតក៏ដោយ ។ នៅពេលដែលប្រទេសមួយមានព្រះមហាក្សត្រមួយអង្គ និងរដ្ឋធម្មនុញ្ញមួយនៅក្នុងប្រទេស ត្រូវជារដ្ឋធម្មនុញ្ញព្រះមហាក្សត្រអាស្រ័យរដ្ឋធម្មនុញ្ញ ។ នេះមានន័យថា អំណាចព្រះមហាក្សត្រនៅកម្ពុជា គឺកម្រិតនៅត្រឹមអ្វី ដែលបានអនុញ្ញាតនៅក្រោម "ខ" ទាំងឡាយដែលមានចែងក្នុងរដ្ឋធម្មនុញ្ញ ។ ដូច្នេះនៅកម្ពុជាយើងដឹងថា ព្រះមហាក្សត្រសព្វថ្ងៃមានអំណាចមានព្រំដែនកំណត់ មិនមែនអំណាចដាច់ខាតទេ ។ ចំណុចនេះអាចឃើញមាននៅក្នុងមាត្រា ១ និងមាត្រា ៧ នៃរដ្ឋធម្មនុញ្ញ ។ មាត្រា ១ ប្រទេសកម្ពុជាជាព្រះរាជាណាចក្រ ដែលព្រះមហាក្សត្រទ្រទ្រង់ប្រតិបត្តិតាមរដ្ឋធម្មនុញ្ញ.... ។ ព្រះមហាក្សត្រកម្ពុជា ទ្រង់គ្រងរាជសម្បត្តិ ប៉ុន្តែទ្រង់មិនកាន់អំណាចឡើយ..... ។ យោងតាមមាត្រានេះ យើងឃើញថា រដ្ឋធម្មនុញ្ញកម្ពុជាបានកំណត់ អំណាចព្រះមហាក្សត្រមកត្រឹម "គ្រងរាជ្យ" ឬ "ដឹកនាំ" ប៉ុន្តែទ្រង់មិនកាន់អំណាចទេ ។ នៅក្នុងរបបរាជានិយមអាស្រ័យរដ្ឋធម្មនុញ្ញ ព្រះមហាក្សត្រ ឬព្រះមហាក្សត្រីយានីក៏ជាផ្នែកមួយនៃសង្គម និងស្ថិតនៅក្រោមដំបូលនៃច្បាប់តែមួយ ដូចជាពលរដ្ឋដទៃទៀតដែរ ។ ដូច្នេះ ព្រះមហាក្សត្របច្ចុប្បន្នពុំមានអំណាចដូចព្រះមហាក្សត្រសម័យបុរាណកាលឡើយ ។

## ៥.២. ប្រជាធិបតេយ្យសេរី

ប្រជាធិបតេយ្យមានន័យថា ការយកប្រជាពលរដ្ឋជាធំក្នុងការដឹកនាំប្រទេស ឬប្រជាពលរដ្ឋជាប្រភពនៃអំណាចរបស់ប្រទេស ។ មាត្រា៥១ នៃរដ្ឋធម្មនុញ្ញចែងថា "ប្រជាពលរដ្ឋខ្មែរជាម្ចាស់វាសនា នៃប្រទេសជាតិខ្លួន ។ អំណាចទាំងអស់ជារបស់ប្រជាពលរដ្ឋ ។ ប្រជាពលរដ្ឋ ប្រើអំណាចរបស់ខ្លួន តាមរយៈរដ្ឋសភា រាជរដ្ឋាភិបាល និងសាលាជំរះក្តី ។

ប្រជាធិបតេយ្យ គឺជារបៀបនៃការគ្រប់គ្រងដោយ អ្នកតំណាងដែលមានន័យថា បើពុំមានការគាំទ្រដោយសម្លេងភាគច្រើន ពីប្រជាពលរដ្ឋដែលសំដែងឡើងតាមការបោះឆ្នោតទេ រដ្ឋាភិបាលនោះ នឹងគ្មានអំណាចដឹកនាំប្រទេសជាតិឡើយ ។ លើសពីនេះទៅទៀត នៅក្នុងលទ្ធិប្រជាធិបតេយ្យ អ្នកដែលនៅក្នុងក្រុមភាគតិច ក៏មានសិទ្ធិសំដែងពីទស្សនៈរបស់ខ្លួនដែរ ហើយរដ្ឋាភិបាលត្រូវការពារសិទ្ធិរបស់សមាជិកសង្គមម្នាក់ៗស្មើៗគ្នា ។ ប្រសិនបើរដ្ឋាភិបាលប្រើអំណាចបំបាត់សម្លេងរបស់គណបក្សប្រឆាំង ឬដោយមិនយកចិត្តទុកដាក់ចំពោះអ្នកតំណាងដែលជាប់ឆ្នោតទេនោះ យើងអាចចាត់ថា ប្រទេសនោះពុំមានការគោរពលទ្ធិប្រជាធិបតេយ្យឡើយ ។ ត្រង់ចំណុចនេះ យើងអាចចោទសួរបានថា តើវាមានភាពខុសគ្នាយ៉ាងណា រវាងប្រជាធិបតេយ្យ នឹងប្រជាធិបតេយ្យសេរី ? ពាក្យថា ប្រជាធិបតេយ្យសេរី ដូចដែលមានចែងនៅក្នុង

រដ្ឋធម្មនុញ្ញកម្ពុជា ទំនងដូចជាយោងទៅលើកិច្ចព្រមព្រៀងសន្តិភាពក្រុងប៉ារីសឆ្នាំ១៩៩១ ។ កិច្ចព្រមព្រៀងនេះ បានកំណត់ឱ្យមានការបោះឆ្នោតជាតិនៅឆ្នាំ១៩៩៣ និងបែបបទណែនាំការរៀបចំរដ្ឋធម្មនុញ្ញ ដែលយើងកំពុងប្រើបច្ចុប្បន្ននេះ ។ អ្នកវិភាគច្បាប់យល់ថា ព្រះមហាក្សត្រនរោត្តមសីហនុ ទ្រង់បានស្នើសុំឱ្យអនុម័តទទួលយកប្រជាធិបតេយ្យសេរី ទោះបីពាក្យនេះមិនមានចែងច្បាស់លាស់ក្នុងកិច្ចព្រមព្រៀងក្រុងប៉ារីសក៏ដោយ ។ យោងទៅលើកិច្ចព្រមព្រៀងនេះប្រជាធិបតេយ្យសេរី ដែលចែងក្នុងរដ្ឋធម្មនុញ្ញកម្ពុជាតម្រូវឱ្យរដ្ឋាភិបាលបំពេញនូវកាតព្វកិច្ច ទាំងប្រាំបីចំណុច ដូចខាងក្រោម ៖

១. ការបោះឆ្នោតតាមការកំណត់ទៀងទាត់

២. ការបោះឆ្នោតត្រឹមត្រូវឥតក្លែងបន្លំសន្លឹកឆ្នោត

៣. មានសិទ្ធិឈរឈ្មោះឱ្យគេបោះឆ្នោត

៤. ការបោះឆ្នោតជាសកល (ផ្តល់សិទ្ធិបោះឆ្នោតចំពោះជនគ្រប់រូប លើកលែងតែមានការ ហាមឃាត់តាមច្បាប់រដ្ឋធម្មនុញ្ញ)

៥. ការបោះឆ្នោតមានតម្លៃស្មើគ្នា មានន័យថា សម្លេងឆ្នោតរបស់បុគ្គលម្នាក់ៗមានតម្លៃស្មើគ្នា

៦. ការបោះឆ្នោតដោយសម្ងាត់

៧. ផ្តល់ឱកាសពេញលេញ និងត្រឹមត្រូវក្នុងការបង្កើតគណបក្សនយោបាយ ដើម្បីចូលរួមក្នុងដំណើរការបោះឆ្នោត ។

សរុបសេចក្តីមក ប្រជាធិបតេយ្យសេរីរបស់កម្ពុជា តម្រូវឱ្យមានរាជរដ្ឋាភិបាលមួយដឹកនាំដោយតំណាងប្រជាពលរដ្ឋ ហើយអាណត្តិអ្នកតំណាងរាស្ត្រ និងសមាជិករដ្ឋាភិបាល ត្រូវបានកំណត់តាមរយៈការបោះឆ្នោតឡើងវិញ ឬត្រូវជ្រើសរើសឡើងវិញដោយឈរលើមូលដ្ឋាន នៃពេលវេលាមួយទៀងទាត់ ។

### ៥.៣. ពហុបក្ស

ពហុបក្សមានន័យថា រាល់ការបោះឆ្នោតរើសតំណាងប្រជាពលរដ្ឋ ត្រូវតែមានការចូលរួមប្រកួតប្រជែងពីច្រើនគណបក្សនយោបាយដូចរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជាជំពូក៣ មាត្រា៣៤ ចែងថា **ប្រជាពលរដ្ឋទាំងពីរភេទមានសិទ្ធិបោះឆ្នោត និងឈរឈ្មោះឱ្យគេបោះឆ្នោត** និងមាត្រា៤២ចែងថាប្រជាពល**រដ្ឋខ្មែរមានសិទ្ធិបង្កើតសមាគម និងគណបក្សនយោបាយ** ។

## ៦- ការបែងចែកអំណាច :

ពុំមានអ្វីប្លែក ពីប្រទេសដែលកាន់លទ្ធិប្រជាធិបតេយ្យដទៃៗទៀតទេ ប្រទេសកម្ពុជាបែងចែកអំណាចដាច់ពីគ្នារវាង អង្គនីតិបញ្ញត្តិ នីតិប្រតិបត្តិ និងអង្គតុលាការ ដូចមានចែងនៅក្នុងមាត្រា៥១ នៃរដ្ឋធម្មនុញ្ញកម្ពុជា ។ រដ្ឋធម្មនុញ្ញនៃប្រទេសកម្ពុជា ក៏បានបែងចែកលំអិតផងដែរ អំពីអង្គនៃអំណាចទាំងបីនោះ ( ជំពូក៧-៩នៃរដ្ឋធម្មនុញ្ញ) ។

អង្គនីតិប្រតិបត្តិ គឺសំដៅលើរាជរដ្ឋាភិបាលកម្ពុជា ដោយរួមបញ្ចូលទាំងនាយករដ្ឋមន្ត្រី និងក្រសួងនានា ។ នីតិប្រត្តិបត្តិ មានអំណាចកំណត់នយោបាយ ( នៅក្នុងកម្រិតព្រំដែន ដែលអនុញ្ញាតដោយច្បាប់របស់អង្គនីតិប្បញ្ញត្តិ) ។ អង្គនីតិបញ្ញត្តិ គឺសំដៅទៅលើរដ្ឋសភា និងគណៈកម្មការផ្សេងៗ របស់រដ្ឋសភា ។ អង្គនីតិប្បញ្ញត្តិមានអំណាចធ្វើច្បាប់ ហើយត្រូវប្រគល់ភារកិច្ចទៅឱ្យអង្គនីតិប្រតិបត្តិជាអ្នកអនុវត្ត ។ អង្គតុលាការ គឺនិយាយយោងទៅលើសាលាជំរះក្តី និងចៅក្រម ។ តុលាការប្រើសិទ្ធិអំណាចរបស់ខ្លួន យោងទៅតាមច្បាប់ដើម្បីដោះស្រាយវិវាទ និងផ្តន្ទាទោសជនទាំងឡាយណា ដែលរំលោភច្បាប់ ។ គួរតែកត់សំគាល់ផងដែរថា នៅប្រទេសកម្ពុជាមានស្ថាប័នពីរផ្សេងទៀត ដែលមានឥទ្ធិពលចំពោះគ្នាទៅវិញទៅមក ក្នុងរចនាសម្ព័ន្ធនៃរដ្ឋាភិបាល ជាពិសេសតុលាការ ។ អង្គទាំងពីរនោះគឺ ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម និងក្រុមប្រឹក្សាធម្មនុញ្ញ ។ ស្ថាប័នទាំងពីរនេះ មិនមែនជាផ្នែកនៃអំណាចណាមួយនៅក្នុងអង្គទាំងបីនៃរដ្ឋាភិបាលទេ ។

នៅក្នុងមាត្រា ១៣៦ នៃរដ្ឋធម្មនុញ្ញ បានចែងថា "ក្រុមប្រឹក្សាធម្មនុញ្ញមានសមត្ថកិច្ចធានាការពារ ការគោរពរដ្ឋធម្មនុញ្ញ បកស្រាយរដ្ឋធម្មនុញ្ញ និងច្បាប់ដែលរដ្ឋសភាបានអនុម័ត និងព្រឹទ្ធសភាបានពិនិត្យចប់សព្វគ្រប់ហើយ ។

ក្រុមប្រឹក្សាធម្មនុញ្ញ មានសិទ្ធិពិនិត្យ និងសម្រេចអំពីករណីវិវាទកម្មទាក់ទងនឹងការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ និងការបោះឆ្នោត ជ្រើសតាំងសមាជិកព្រឹទ្ធសភា ។

ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម សម្រេចដាក់វិន័យទៅលើចៅក្រម ដែលបានប្រព្រឹត្តខុស ( មាត្រា ១៣៣) ។

ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ស្ថិតនៅក្រោមព្រះរាជាធិបតីភាព នៃព្រះមហាក្សត្រ ( មាត្រា ១៣៤) ។

## ៧- ទ្រឹស្ដីនៃការបែងចែកអំណាច :

យើងបានឃើញហើយថា មាត្រា៩១ នៃរដ្ឋធម្មនុញ្ញបានចែងថា អង្គនៃអំណាចទាំងនោះ ត្រូវតែដាច់ដោយឡែកពីគ្នា ។ ការផ្ដួចផ្ដើមនៃ "ការបែងចែកអំណាចនេះ" គឺជាទស្សនៈដ៏ល្អបំផុត ហើយមានលក្ខណៈស្របទៅនឹងប្រទេសភាគច្រើន ដែលកាន់លទ្ធិប្រជាធិបតេយ្យនៅលើពិភពលោក ។ គោលបំណងនៃការបែងចែកអំណាចគឺធ្វើយ៉ាងណាឱ្យមានការធានានូវ :

(១) កំណើត និងការថែរក្សាសេរីភាពខាងនយោបាយ

(២) ទប់ស្កាត់ការប្រើអំណាចតាមទំនើងចិត្តរបស់រដ្ឋាភិបាលដោយបុគ្គលណាម្នាក់ ឬដោយក្រុមណាមួយ ។

ដើម្បីឱ្យអង្គនីមួយៗ មិនអាចរំលោភគ្នាទៅវិញទៅមកបាន នីតិវិធី និងវិធាននានា ត្រូវបង្កើតឡើងដើម្បីបង្ហាញផ្លូវដល់អង្គនៃអំណាចទាំងបីរបស់រដ្ឋាភិបាល និងដើម្បីការពារនូវអំណាចនៃអង្គនីមួយៗ ឱ្យមានប្រសិទ្ធភាព ។ លើសពីនេះទៅទៀត ជនណាម្នាក់ដែលជាសមាជិកនៃអង្គណាមួយ មិនត្រូវអនុញ្ញាតឱ្យធ្វើជាសមាជិកនៃអង្គណាមួយនៃសាខាពីរទៀត ក្នុងពេលជាមួយគ្នានោះទេ ។ ធ្វើតាមរបៀបនេះ គេជឿថាអង្គនីមួយៗ នឹងមានស្វយតភាពទាំងស្រុង ហើយអាចធ្វើជាអ្នកត្រួតពិនិត្យទៅលើសកម្មភាពរបស់អង្គផ្សេងៗទៀត ហើយពុំមានក្រុមណាមួយ នឹងធ្វើការត្រួតត្រា ក្បាលម៉ាស៊ីនរដ្ឋ បានតែម្នាក់ឯងបានទេ ។ ដើម្បីឱ្យយល់កាន់តែច្បាស់ថែមទៀត សូមមើលតារាងសង្ខេបនៃស្ថាប័នទាំងបី ដូចមាននៅខាងក្រោម :

## តារាងទី១- រចនាសម្ព័ន្ធរបស់រដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា



តារាងទី២- អំណាចនៃរដ្ឋាភិបាលកម្ពុជា

| អង្គនីតិបញ្ញត្តិ | |
|---|---|
| **អង្គដែលអនុវត្តអំណាច** | រដ្ឋសភា និងព្រឹទ្ធសភា |
| **សមាសភាព** | រដ្ឋសភាបច្ចុប្បន្នមានសមាជិកទាំងអស់១២៣រូប និងសមាជិកព្រឹទ្ធសភាមាន ៦៣រូប |
| **ការជ្រើសរើសសមាជិក** | ដំណាងរាស្ត្រត្រូវជ្រើសតាំងដោយការបោះឆ្នោតជាសកល ដោយសេរី ដោយស្មើភាព ដោយចំពោះ និងតាមវិធីជ្រើសរើសឆ្នោតជាសម្ងាត់(មាត្រាទី៧៦) ។ មុនចាប់ផ្ដើមការងាររបស់ខ្លួន រដ្ឋសភាត្រូវអនុម័ត បទបញ្ជាផ្ទៃក្នុងសម្រេចអំពីសុពលភាពនៃអាណត្តិ របស់សមាជិកនីមួយៗ និងត្រូវបោះឆ្នោតដាច់ដោយឡែកពីគ្នានូវប្រធាន អនុប្រធាន រដ្ឋសភា និងសមាជិកទាំងអស់នៃគណៈកម្មការនានារបស់រដ្ឋសភា ដោយមតិភាគច្រើន២/៣ នៃសមាជិករដ្ឋសភាទាំងមូល (មាត្រា៨២) សមាជិកព្រឹទ្ធសភាចំនួន២រូប ត្រូវបានចាត់តាំងដោយព្រះមហាក្សត្រ ។ សមាជិកព្រឹទ្ធសភាចំនួន ២រូបត្រូវបានរដ្ឋសភាជ្រើសតាំងតាមមតិភាគច្រើនដោយប្រៀប ។ រីឯសមាជិកព្រឹទ្ធសភាឯទៀតត្រូវបានជ្រើសតាំងបោះឆ្នោតជាអសកល (មាត្រា១០០) ។ |

| អង្គនីតិប្រតិបត្តិ | |
|---|---|
| **អង្គដែលត្រូវអនុវត្តអំណាច** | រដ្ឋាភិបាល |
| **សមាសភាព** | គណៈរដ្ឋមន្ត្រី មាននាយករដ្ឋមន្ត្រី ឧបនាយករដ្ឋមន្ត្រី ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី និងរដ្ឋលេខាធិការ (មាត្រា ១១៨) |

| | |
|---|---|
| **ការជ្រើសរើសសមាជិក** | គណបក្សដែលឈ្នះឆ្នោត ត្រូវបង្កើតរាជរដ្ឋាភិបាល ដែលមានការយល់ព្រមពីរដ្ឋសភា ។ ព្រះមហាក្សត្រ ចេញព្រះរាជក្រឹត្យតែងតាំងរាជរដ្ឋាភិបាល ។( មាត្រា ១១៩) |

| **អង្គតុលាការ** | |
|---|---|
| **អង្គដែលត្រូវអនុវត្តអំណាច** | **តុលាការ** |
| **សមាសភាព** | អំណាចតុលាការជាអំណាចឯករាជ្យ ។ តុលាការគ្របដណ្តប់ លើរឿងក្តីទាំងអស់ រួមទាំងរឿងក្តីរដ្ឋបាលផង ( មាត្រា ១២៨) ។ មានតែអង្គការអយ្យការទេ ដែលមានសិទ្ធិធ្វើបណ្តឹងអាជ្ញា ( មាត្រា ១៣១) |
| **ការជ្រើសរើសសមាជិក** | ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ត្រូវបានបង្កើតឡើង ដោយច្បាប់មួយ ដែលបានអនុម័តដោយរដ្ឋសភា ( មាត្រា១៣៤) ។ ព្រះមហាក្សត្រទ្រង់ជាព្រះរាជអធិបតី នៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ។ ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមដាក់សំណើបញ្ជីឈ្មោះអ្នកដែលត្រូវតែងតាំងជាចៅក្រម និងព្រះរាជអាជ្ញា ។ ព្រះមហាក្សត្រ ទ្រង់ជាអ្នកតែងតាំង( មាត្រា ១៣៤) ។ |

## ៨- តើអំណាចអ្វីខ្លះដែលត្រូវអនុវត្តដោយអង្គទាំង៣ ?

### ៨.១. នីតិបញ្ញត្តិ - (ស្ថាប័នរដ្ឋសភា)

រដ្ឋសភាមានអំណាចអនុម័តច្បាប់ ( មាត្រា ៩០ និង៩១) ។ សមាជិករដ្ឋសភា ព្រឹទ្ធសភា អាចផ្តួចផ្តើមធ្វើសំណើច្បាប់ ( មាត្រា ៩១) ។ រដ្ឋសភាគ្មានអំណាចតុលាការទេ ប៉ុន្តែអាចអនុម័តច្បាប់ ដើម្បីកំណត់សមាសភាព និងមុខងាររបស់ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម និងមុខងារតុលាការ ( មាត្រា ១៣៤ និង ១៣៥ ) ។ រដ្ឋសភាក៏គ្មានអំណាចនីតិប្រតិបត្តិដែរ ប៉ុន្តែមានអំណាច អនុម័តច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី ( មាត្រា ១២៧) និងច្បាប់ដទៃទៀតស្តីពីមុខងាររបស់រដ្ឋាភិបាលស្របតាមរដ្ឋធម្មនុញ្ញ ។

រដ្ឋសភាអនុម័តច្បាប់សំរាប់រៀបចំ និងការប្រព្រឹត្តទៅនៃសមាជិក (ជំពូក ១៤) ។ រដ្ឋសភាមិនអាចអនុវត្ត អំណាចរបស់ខ្លួនជាសម្ងាត់បានទេ ។ ជាទូទៅសម័យប្រជុំត្រូវធ្វើឡើងជាសាធារណៈ (មាត្រា ៨៨) ។ ច្បាប់ ដែលអនុម័តដោយរដ្ឋសភា ត្រូវតែដាក់ថ្វាយព្រះមហាក្សត្រឡាយព្រះហស្តលេខា ហើយបន្ទាប់មកចុះផ្សាយ ក្នុងរាជកិច្ច (មាត្រា៩៣) ។

### ៨.២. នីតិប្រតិបត្តិ- (ស្ថាប័នរាជរដ្ឋាភិបាល)

រាជរដ្ឋាភិបាលអនុវត្តនូវអំណាចរបស់ខ្លួនស្របទៅតាមរដ្ឋធម្មនុញ្ញ និងច្បាប់ដែលបានអនុម័ត ដោយរដ្ឋសភា ។ គណៈរដ្ឋមន្ត្រីជួបប្រជុំគ្នារាល់សប្តាហ៍ និងត្រូវជូនកំណត់ហេតុនៃការប្រជុំរបស់ខ្លួន ថ្វាយ ព្រះមហាក្សត្រទ្រង់ជ្រាប (មាត្រា១២៣) ។ នាយករដ្ឋមន្ត្រីមានសិទ្ធិផ្តួចផ្តើម (ធ្វើសំណើ) នីតិកម្ម (មាត្រា ១៩) ។ គណបក្សដែលឈ្នះឆ្នោត ត្រូវបង្កើតរាជរដ្ឋាភិបាល ដែលត្រូវទទួលការយល់ព្រមពីរដ្ឋសភា ។ ព្រះមហាក្សត្រចេញព្រះរាជក្រឹត្យតែងតាំងរាជរដ្ឋាភិបាល (មាត្រា ១១៩) ។

### ៨.៣. អង្គតុលាការ- (ស្ថាប័នតុលាការ)

មានតែអង្គតុលាការទេ ដែលមានអំណាចផ្លូវតុលាការ ។ អង្គនីតិបញ្ញត្តិ និងអង្គនីតិប្រតិបត្តិ មិនអាច អនុវត្តអំណាចតុលាការឡើយ (មាត្រាទី១៣០) ។ តុលាការ និងចៅក្រមមានអំណាចសម្រេចលើ វិវាទតាម ផ្លូវច្បាប់ស្របតាមរដ្ឋធម្មនុញ្ញ និងច្បាប់ ដែលបានអនុម័តដោយរដ្ឋសភា (ជំពូក ១១) ។ មានតែអង្គការ អយ្យការទេ ដែលមានសិទ្ធិធ្វើពាក្យបណ្តឹងអាជ្ញា (មាត្រា១៣១) ។ ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ត្រូវ បានបង្កើតឡើងដោយច្បាប់មួយ ដែលបានអនុម័តដោយរដ្ឋសភា ។ (មាត្រា ១៣៤) ព្រះមហាក្សត្រ ទ្រង់ជា ព្រះរាជាធិបតេយ្យនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ។ ឧត្តមក្រុមប្រឹក្សា នៃអង្គចៅក្រមដាក់សំណើបញ្ជី ឈ្មោះអ្នកដែលត្រូវតែងតាំងជាចៅក្រម និងព្រះរាជអាជ្ញា ។ ព្រះមហាក្សត្រទ្រង់ជាអ្នកតែងតាំង (មាត្រា ១៣៤) ។

## ៩- តើប្រជាពលរដ្ឋអនុវត្តអំណាចរបស់គេតាមអង្គទាំងបីខាងលើយ៉ាងដូចម្តេច?

### ៩.១. រដ្ឋសភា

សមាជិករដ្ឋសភា ត្រូវតំណាងឱ្យប្រជាជន (មាត្រា ៧៧) ។ អាណត្តិសមាជិករដ្ឋសភាមានរយៈ ពេល ៥ឆ្នាំ (មាត្រា៧៨) ។ បើសមាជិកសភាមួយណាមិនបានបំពេញលក្ខខណ្ឌជាសមាជិកភាព ប្រជាពលរដ្ឋអាច ជ្រើសរើសសមាជិកថ្មីតាមរយៈការបោះឆ្នោតនៅពេលបន្ទាប់ ។ ដូច្នេះសមាជិករដ្ឋសភាទទួលខុសត្រូវដោយ

ផ្ទាល់ចំពោះប្រជាជនតាមរយៈដំណើរការបោះឆ្នោត ។ រដ្ឋសភាអនុម័តច្បាប់សំរាប់រៀបចំ និងការប្រព្រឹត្តិទៅនៃសមាជជាតិ ។

### ៩.២. រាជរដ្ឋាភិបាល

គណៈបក្សដែលឈ្នះឆ្នោត បង្កើតរាជរដ្ឋាភិបាល (ការបោះឆ្នោត ជាថ្មីរៀងរាល់៥ឆ្នាំម្តង)។ ដូចនេះ ប្រជាជនត្រូវបោះឆ្នោតជ្រើសរើសគណៈបក្សដឹកនាំរាជរដ្ឋាភិបាលរៀងរាល់ ៥ឆ្នាំម្តង ។ សមាជិកទាំងឡាយនៃរាជរដ្ឋាភិបាល ទទួលខុសត្រូវរួមចំពោះរដ្ឋសភា អំពីនយោបាយទូទៅរបស់រដ្ឋាភិបាល (មាត្រា ១២១) ។ សមាជិកនៃរដ្ឋាភិបាលទទួលខុសត្រូវរៀង១ខ្លួន ចំពោះនាយករដ្ឋមន្ត្រី និងរដ្ឋសភាសំរាប់អាកប្បកិរិយា (មាត្រា១២១) ។ រដ្ឋសភាអនុម័តច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់គណៈរដ្ឋមន្ត្រី (មាត្រា១២៧) ។ នាយករដ្ឋមន្ត្រីត្រូវកោះអញ្ជើញឱ្យមានការរៀបចំ សមាជជាតិក្នុងមួយឆ្នាំម្តងនៅដើមខែធ្នូ (មាត្រា ១៤៨) ។

### ៩.៣. តុលាការ

ប្រជាជនបោះឆ្នោតជ្រើសរើសសមាជិករដ្ឋសភា ដែលជាអ្នកអនុម័តច្បាប់ ដើម្បីកំណត់ សមាសភាព និងមុខងាររបស់ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម និងមុខងាររបស់តុលាការ (មាត្រា១៣៤ និង១៣៥ ) ។ ព្រះមហាក្សត្រធានាឯករាជភាពនៃតុលាការ ដោយមានជំនួយពីឧត្តម ក្រុមប្រឹក្សានៃអង្គចៅក្រម (មាត្រា ១៣២) ។ ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម សម្រេចចិត្តដាក់វិន័យ លើចៅក្រម និងព្រះរាជអាជ្ញាដែលល្មើសនឹងច្បាប់ (មាត្រា១៣៤) ។

## ១០- ដំណើរការនៃការអនុម័តច្បាប់នៅកម្ពុជា

### ១០.១. ការយល់ដឹងជាទូទៅអំពីការផ្តួចផ្តើមការធ្វើច្បាប់

នៅប្រទេសកម្ពុជាយើង **សមាជិកព្រឹទ្ធសភា សមាជិករដ្ឋសភា និងនាយករដ្ឋមន្ត្រី មានសិទ្ធិផ្តួចផ្តើមគំនិតធ្វើច្បាប់** (មាត្រា៩១) ។ បើនិយាយពីស្ថាប័នវិញ **គឺស្ថាប័ននីតិប្រតិបត្តិ** (រាជរដ្ឋាភិបាល) និង**គឺស្ថាប័ននីតិបញ្ញត្តិ** (រដ្ឋសភា និងព្រឹទ្ធសភា) ។ ច្បាប់ដែលរៀបរៀងដោយ ស្ថាប័ននីតិប្រតិបត្តិហៅថា "សេចក្តីព្រាងច្បាប់" ។ច្បាប់ដែលរៀបចំដោយ ស្ថាប័ននីតិបញ្ញត្តិ ហៅថា "សេចក្តីស្នើច្បាប់" ។

### ១០.១.១. សេចក្តីព្រាងច្បាប់ -ស្នើដោយរាជរដ្ឋាភិបាល

ក្រសួងពាក់ព័ន្ធផ្តួចផ្តើមធ្វើសេចក្តីព្រាងច្បាប់ តាមរយៈការពិភាក្សានៅក្នុងនាយកដ្ឋានជំនាញរបស់

ខ្លួន។ នៅពេលសេចក្តីព្រាងច្បាប់បានរៀបចំចប់សព្វគ្រប់ សាមីក្រសួងផ្ញើទៅក្រុមប្រឹក្សាអ្នកច្បាប់នៃគណៈរដ្ឋមន្ត្រីដើម្បីពិនិត្យ និងពិភាក្សា ។ នៅពេលក្រុមប្រឹក្សាអ្នកច្បាប់បានពិនិត្យរួចរាល់លើសេចក្តីព្រាងច្បាប់នោះហើយ ក្រុមប្រឹក្សាអ្នកច្បាប់ត្រូវបញ្ជូនទៅអន្តរក្រសួង (ប្រជុំគណៈរដ្ឋមន្ត្រី) ដើម្បីអនុម័ត ។ រាល់កិច្ចប្រជុំនៃគណៈរដ្ឋមន្ត្រីរដ្ឋមន្ត្រី ឬរដ្ឋលេខាធិការនៃសាមីក្រសួងត្រូវបានអញ្ជើញ ទៅការពារសេចក្តីព្រាងច្បាប់នោះ ។

ពេលដែលគណៈរដ្ឋមន្ត្រី បានអនុម័តសេចក្តីព្រាងច្បាប់នោះរួចហើយ សេចក្តីព្រាងច្បាប់នោះ ត្រូវបញ្ជូនទៅគណៈកម្មាធិការអចិន្ត្រៃយ៍រដ្ឋសភា ដើម្បីចាត់បញ្ជូនទៅគណៈកម្មាធិការជំនាញនៃរដ្ឋសភា ដើម្បីពិនិត្យមុននឹងដាក់បញ្ជូនទៅសភាពេញអង្គអនុម័ត ។

### ១០.១.២. សេចក្តីស្នើច្បាប់ - ស្នើឡើងដោយសមាជិករដ្ឋសភា

មាត្រាទី២២ នៃបទបញ្ជាផ្ទៃក្នុងនៃរដ្ឋសភាបានចែងថា **សេចក្តីស្នើច្បាប់ដែលអ្នកតំណាងរាស្ត្រ ធ្វើនោះត្រូវធ្វើជាលាយលក្ខណ៍អក្សរ ចែកមាត្រា ហើយមានសេចក្តីថ្លែងហេតុនៅខាងដើម ភ្ជាប់មកជាមួយផង** ។ សេចក្តីស្នើច្បាប់នេះ ត្រូវបញ្ជូនទៅគណៈកម្មាធិការអចិន្ត្រៃយ៍នៃរដ្ឋសភា ដើម្បីបញ្ជូនទៅគណៈកម្មការជំនាញពិនិត្យ និងពិភាក្សាមុននឹងបញ្ជូនទៅសម័យប្រជុំ ពេញអង្គដើម្បីអនុម័ត ។

### ១០.១.៣. សេចក្តីស្នើច្បាប់ - ស្នើឡើងដោយព្រឹទ្ធសភា

ជំពូកទី៦ មាត្រាទី២៤ នៃបទបញ្ជាផ្ទៃក្នុងនៃព្រឹទ្ធសភាចែងថា **សេចក្តីស្នើច្បាប់ ដែលសមាជិកព្រឹទ្ធិសភាជាអ្នកធ្វើត្រូវសរសេរជាលាយលក្ខណ៍អក្សរ ចែកមាត្រា ហើយមានសេចក្តីថ្លែងហេតុនៅខាងដើម ភ្ជាប់មកជាមួយផង** ។ សេចក្តីស្នើច្បាប់នេះ ត្រូវបញ្ជូនទៅគណៈកម្មការជំនាញព្រឹទ្ធសភា ដើម្បីពិនិត្យ និងផ្តល់យោបល់មុននឹងបញ្ជូនទៅគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា ។ បន្ទាប់ពីគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា បានពិនិត្យរួចរាល់ហើយ សេចក្តីស្នើច្បាប់នេះ ត្រូវបញ្ជូនទៅសម័យប្រជុំពេញអង្គរដ្ឋសភា ដើម្បីធ្វើការអនុម័តជាចុងក្រោយ ។

### ១០.២. ដំណើរពិភាក្សា និងអនុម័តលើសេចក្តីព្រាងច្បាប់ និងសេចក្តីស្នើច្បាប់នៃរដ្ឋសភា

រដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជាពិភាក្សា និងអនុម័តសេចក្តីស្នើច្បាប់ ឬសេចក្តីព្រាងច្បាប់ តាមនីតិវិធីនៃច្បាប់ដូចខាងក្រោម ៖

ក្រោយពីទទួលសេចក្តីស្នើច្បាប់ ឬសេចក្តីព្រាងច្បាប់ ពីគណៈរដ្ឋមន្ត្រី ឬអ្នកស្នើច្បាប់ គណៈកម្មាធិការអចិន្ត្រៃយ៍នៃរដ្ឋសភា មានតួនាទីពិនិត្យលើគោលបំណង និងសេចក្តីត្រូវការនៃសេចក្តីស្នើច្បាប់ ឬសេចក្តីព្រាង

ច្បាប់នេះ រួចបញ្ជូនទៅគណៈកម្មការជំនាញរបស់ខ្លួន ដើម្បីពិភាក្សាលំអិត ។ កាលបើ គណៈកម្មការនេះបាន ពិនិត្យហើយ ប្រធាននៃគណៈកម្មការនេះ ត្រូវនាំយកយោបល់របស់គណៈកម្មការ មកជំរាបជូនរដ្ឋសភា ។ គណៈកម្មការអាចៈ

- សូមឱ្យរដ្ឋសភា លើកចោលពុំពិចារណាលើសេចក្តីស្នើច្បាប់ ឬសេចក្តីព្រាងច្បាប់នោះ ។
- សូមឱ្យរដ្ឋសភាបញ្ចេញមតិជាមុន ថាតើគួរទទួលពិចារណាលើសេចក្តីស្នើច្បាប់ ឬសេចក្តីព្រាងច្បាប់នោះ ឬទេ ។
- សូមឱ្យរដ្ឋសភា ទទួលពិចារណា លើសេចក្តីស្នើច្បាប់ ឬសេចក្តីព្រាងច្បាប់នោះ ហើយនិងទុកជាការប្រញាប់ផងក៏បាន ។

## ១០.៣. ដំណើរពិភាក្សា និងអនុម័តលើសេចក្តីព្រាងច្បាប់ និងសេចក្តីស្នើច្បាប់នៃព្រឹទ្ធសភា

ជំពូកទី ៦ មាត្រា ២៣ ចែងថា សេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់ ដែលរដ្ឋសភាអនុម័ត យល់ព្រមដំបូងរួចហើយ ព្រមទាំងបញ្ហានានាដែលរដ្ឋសភាបានដាក់ពិនិត្យ ត្រូវបញ្ជូនមកគណៈកម្មាធិការអចិន្ត្រៃយ៍រដ្ឋសភា ។ សេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់ ឬបញ្ហានានានោះត្រូវធ្វើជាលាយលក្ខណ៍អក្សរ ហើយចែកជូនសមាជិកព្រឹទ្ធសភាទាំងអស់ ដោយភ្ជាប់សេចក្តីថ្លែងហេតុមកជាមួយផង ។ គណៈកម្មការអចិន្ត្រៃយ៍ព្រឹទ្ធសភាបញ្ជូនសេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់ ឬបញ្ហានានានោះ ទៅឱ្យគណៈកម្មការតាមមុខជំនាញពិនិត្យ ។ កាលបើពិនិត្យរួចហើយ ប្រធាននៃគណៈកម្មការនោះ ត្រូវនាំយកយោបល់របស់គណៈកម្មការមកជំរាបជូនព្រឹទ្ធសភា ។

គណៈកម្មការដែលបានទទួលពិនិត្យសេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់ដែលរដ្ឋសភាបានអនុម័តដំបូង ឬបញ្ហានានា អាចស្នើសុំឱ្យព្រឹទ្ធសភាៈ

- មិនគួរពិចារណាលើ សេចក្តីស្នើច្បាប់ ឬសេចក្តីព្រាងច្បាប់នោះទេ ។
- បញ្ចេញមតិជាមុនថា គួរពិចារណា ឬមិនគួរពិចារណាលើសេចក្តីស្នើច្បាប់ ឬសេចក្តីព្រាងច្បាប់នោះ ។
- ទទួលពិចារណាលើសេចក្តីស្នើច្បាប់ ឬសេចក្តីព្រាងច្បាប់នោះ ហើយនឹងទុកជាការប្រញាប់ក៏បាន ។

សេចក្តីស្នើច្បាប់ ឬសេចក្តីព្រាងច្បាប់នោះ ដែលពិនិត្យដោយព្រឹទ្ធសភា ត្រូវបញ្ជូនទៅរដ្ឋសភាវិញ ។ រដ្ឋសភាជាតិ មានសិទ្ធិទទួលយក ឬមិនទទួលយកសំណើពីព្រឹទ្ធសភា ហើយត្រូវអនុម័តលើសេចក្តីព្រាង ឬសេចក្តីស្នើច្បាប់នោះម្តងទៀត ។

## ១០.៤. ដំណើរពិនិត្យលើធម្មនុញ្ញភាពនៃច្បាប់របស់ក្រុមប្រឹក្សាធម្មនុញ្ញ

ក្រុមប្រឹក្សាធម្មនុញ្ញ មានអំណាចត្រួតពិនិត្យមើលធម្មនុញ្ញភាពនៃច្បាប់ទាំងឡាយដែលអនុម័តដោយរដ្ឋសភា និងពិនិត្យដោយព្រឹទ្ធសភា ។ សេចក្ដីស្នើច្បាប់ ឬសេចក្ដីព្រាងច្បាប់អាចបដិសេធ ប្រសិនបើច្បាប់នោះនឹងធ្វើឱ្យប៉ះពាល់ដល់សម្បត្តិសាធារណៈ ឬប៉ះពាល់ដល់សិទ្ធិសេរីភាព និងប្រយោជន៍របស់ប្រជាពលរដ្ឋ ។ បន្ទាប់ពីក្រុមប្រឹក្សាធម្មនុញ្ញពិនិត្យឃើញថា សេចក្ដីស្នើច្បាប់ ឬសេចក្ដីព្រាងច្បាប់នេះស្របទៅនឹងស្មារតីរដ្ឋធម្មនុញ្ញហើយ រដ្ឋសភាបញ្ជូនច្បាប់នោះទៅព្រះមហាក្សត្រ ដើម្បីចុះព្រះហស្តលេខាលើព្រះរាជក្រឹត្យប្រកាសឱ្យប្រើទូទាំងប្រទេស ។

**តារាងសង្ខេបស្ថាប័នដែលចូលរួម ក្នុងការធ្វើច្បាប់នៅព្រះរាជាណាចក្រកម្ពុជា ៖**



### ជំហានក្នុងការធ្វើច្បាប់នៅព្រះរាជាណាចក្រកម្ពុជា




**ជំហានទី៧:** ក្រុមប្រឹក្សាធម្មនុញ្ញ មានសមត្ថកិច្ចធានា ការពារការគោរពរដ្ឋធម្មនុញ្ញ និងបកស្រាយច្បាប់រដ្ឋធម្មនុញ្ញ និងច្បាប់ដែលរដ្ឋសភាបានអនុម័ត និងព្រឹទ្ធសភាបានពិនិត្យចប់សព្វគ្រប់ហើយ (មាត្រា១៣៦) ។

## ១១. អំពីព្រឹទ្ធសភា និងរដ្ឋសភា

### ១១.១. ព្រឹទ្ធសភា

ព្រឹទ្ធសភា ជាអង្គនីតិបញ្ញត្តិទីពីរនៃព្រះរាជាណាចក្រកម្ពុជា ។ ព្រឹទ្ធសភាត្រូវបានបង្កើតឡើង តាមរយៈការធ្វើវិសោធនកម្ម រដ្ឋធម្មនុញ្ញនៅក្នុងឆ្នាំ១៩៩៩ ។ មុខងារជាបឋមរបស់ព្រឹទ្ធសភា គឺត្រូវពិនិត្យច្បាប់ដែលបានអនុម័ត ដោយរដ្ឋសភា និងឱ្យយោបល់ថា តើច្បាប់នោះត្រូវទទួលយក ឬបដិសេធ ឬក៏កែប្រែ ។ រដ្ឋសភាមិនអាចបញ្ជូនច្បាប់ សំរាប់ប្រកាសឱ្យប្រើមុនទទួលបានការពិចារណាពីព្រឹទ្ធសភាជាដំបូងសិនបានឡើយ ។

ជាការបន្ថែមទៅលើអំណាច "ពិនិត្យច្បាប់សាឡើងវិញ" ព្រឹទ្ធសភាក៏មានភារកិច្ចសម្របសម្រួលការងាររវាងរដ្ឋសភា និងរាជរដ្ឋាភិបាលផងដែរ ហើយដូចបានពោលពីមុនរួចមកហើយ ប្រធានព្រឹទ្ធសភា នឹង

ក្លាយជាប្រមុខរដ្ឋស្តីទី ក្នុងកាលៈទេសៈជាក់លាក់មួយចំនួន ។

នៅក្នុងផ្នែកនៃអត្ថបទនេះ យើងនឹងក្រឡេកមើលទៅអំណាច និងមុខងាររបស់ព្រឹទ្ធសភា រចនាសម្ព័ន្ធនៃព្រឹទ្ធសភា របៀបជ្រើសរើសសមាជិកព្រឹទ្ធសភា កាតព្វកិច្ច និងការទទួលខុសត្រូវរបស់សមាជិកព្រឹទ្ធសភា និងរបៀបបំពេញកិច្ចការរបស់ព្រឹទ្ធសភា តាមរយៈសមាសភាពផ្សេងៗរបស់ខ្លួន ។

### ១១.១.១ ការបង្កើតព្រឹទ្ធសភា

#### ចំនួនសមាជិកព្រឹទ្ធសភា

មាត្រា ៩៩ នៃរដ្ឋធម្មនុញ្ញចែងថា ចំនួនសមាជិកព្រឹទ្ធសភា មានមិនច្រើនជាងពាក់កណ្តាល នៃចំនួនតំណាងរាស្ត្រនៅក្នុងរដ្ឋសភាទេ ។ ចំណុចនេះមានន័យថា ខណៈដែលចំនួនតំណាងរាស្ត្រមាន ១២២ រូប ចំនួនសមាជិកព្រឹទ្ធសភាមិនអាចលើសពី ៦១ រូបទេ ។ ចំនួនសមាជិកព្រឹទ្ធសភាអាចតិចជាង ៦១ រូប ប៉ុន្តែមិនច្រើនជាងចំនួននោះបានទេ លើកលែងតែចំនួន តំណាងរាស្ត្រកើនឡើងបន្ទាប់ពីមានការបោះឆ្នោតអាណត្តិក្រោយៗទៀត) ។

#### ការបែងចែកអាសនៈ

ទោះបីជារដ្ឋធម្មនុញ្ញចែងអំពីចំនួនអាសនៈអតិបរមានៅក្នុងព្រឹទ្ធសភាក៏ដោយ ក៏រដ្ឋធម្មនុញ្ញ មិនមានលក្ខខណ្ឌតម្រូវថាអាសនៈចាំបាច់ត្រូវតែចែករំលែក តាមវិធីពិសេសណាមួយ ក្នុងចំណោមបណ្តាខេត្តនានាឡើយ ។ តាមពិតដូចគ្នាជាមួយនឹងការបោះឆ្នោតជ្រើសរើសតំណាងរាស្ត្រ ។ រដ្ឋធម្មនុញ្ញទុកបញ្ហានេះ ឱ្យរដ្ឋសភាសម្រេចនៅក្នុងច្បាប់មួយ ។

#### អំណាចនៃព្រឹទ្ធសភា

ព្រឹទ្ធសភា ជាអង្គការដែលមានអំណាចនីតិបញ្ញត្តិ ហើយបំពេញភារកិច្ចរបស់ខ្លួន ដូចមានកំណត់នៅក្នុងរដ្ឋធម្មនុញ្ញ និងច្បាប់ជាធរមាន (មាត្រា ៩៩) ។ ទាក់ទងនឹងការតាក់តែងច្បាប់ ព្រឹទ្ធសភាមានតួនាទីផ្តល់យោបល់ ឬផ្តល់អនុសាសន៍ ចំពោះច្បាប់ទាំងឡាយដែលអនុម័តដោយរដ្ឋសភា ។ សមាជិកព្រឹទ្ធសភាពិតជាមានអំណាចផ្តួចផ្តើមច្បាប់ ប៉ុន្តែមិនមានអំណាចទាំងស្រុង នៅក្នុងការសម្រេច ថាតើច្បាប់ទាំងនោះនឹងចូលជាធរមាន ឬមិនចូលជាធរមានយ៉ាងណានោះឡើយ ។ មានតែរដ្ឋសភាប៉ុណ្ណោះ ដែលមានអំណាចនោះ បន្ថែមលើនេះទៀត គេបានប្រគល់ឱ្យសមាជិកព្រឹទ្ធសភានូវមុខការ "សម្របសម្រួលការងាររវាងរដ្ឋសភា និងរដ្ឋាភិបាល" ។

## ការរៀបចំ និងការប្រព្រឹត្តទៅនៃព្រឹទ្ធសភា

ប្រធានព្រឹទ្ធសភា
អនុប្រធាន ២ រូប
អគ្គលេខាធិការ ១ រូប អគ្គលេខាធិការរង ១ រូប
( មិនមែនជាសមាជិកព្រឹទ្ធសភា)
សមាជិក ៦១ រូប

### គណៈកម្មាធិការអចិន្ត្រៃយ៍នៃរដ្ឋសភា

**ប្រធាន១រូប អនុប្រធាន ២ រូប**
ប្រធានគណៈកម្មាធិការទាំង ៩ រូប

**គណៈកម្មការ**
ប្រធានគណៈកម្មការ, អនុប្រធានគណៈកម្មការ, លេខាធិការសមាជិកយ៉ាងតិច ៥ រូប

- ហិរញ្ញវត្ថុ និង ធនាគារ
- នីតិកម្ម
- អប់រំ ធម្មការ វប្បធម៌ ទេសចរណ៍
- សាធារណៈការ ដឹកជញ្ជូន ទូរគមនាគមន៍ ប្រៃសណីយ៍
- ការពារសិទ្ធិមនុស្ស និង ទទួលពាក្យបណ្តឹង
- សេដ្ឋកិច្ច ផែនការ វិនិយោគ កសិកម្ម អភិវឌ្ឍន៍ជនបទ បរិស្ថាន
- សុខាភិបាល សង្គមកិច្ច ការងារ កិច្ចការនារី
- កិច្ចការបរទេស សហប្រតិបត្តិការ អន្តរជាតិ ព័ត៌មាន
- មហាផ្ទៃ ការពារជាតិ ស៊ើបអង្កេត

## មន្ត្រីដឹកនាំព្រឹទ្ធសភា

មន្ត្រីបីរូបរបស់ព្រឹទ្ធសភាគឺ ប្រធាន អនុប្រធានទី១ និង អនុប្រធានទី២ ត្រូវបានជ្រើសរើសដោយសម្លេងឆ្នោត ២ ឬ ៣ នៃសមាជិកព្រឹទ្ធសភា ។

ប្រធានព្រឹទ្ធសភាធ្វើជាអធិបតីនៃអង្គប្រជុំរបស់ព្រឹទ្ធសភា ទទួលសេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើ ច្បាប់ និងដំណោះស្រាយ អនុម័តដោយព្រឹទ្ធសភា ចាត់ចែងទំនាក់ទំនងព្រឹទ្ធសភា និងប្រទេសក្រៅ ហើយនិងធ្វើឱ្យប្រាកដថា មានការអនុវត្តន៍បទបញ្ជាផ្ទៃក្នុងនៃនីតិវិធី ។

ជាទូទៅអនុប្រធានទាំងពីរជាជំនួយការឱ្យប្រធានព្រឹទ្ធសភា ។ អនុប្រធានទី១ មានភារកិច្ចជាប្រធានព្រឹទ្ធសភា កាលណាប្រធានក្លាយជាប្រមុខរដ្ឋស្តីទី ឬក៏មិនអាចបំពេញភារកិច្ចរបស់ខ្លួនបាន អនុប្រធានទី២ ពេលនោះ ក៏ក្លាយជាអនុប្រធាន ទី១ ស្តីទីផងដែរ ។

យោងតាមមាត្រា ៣០ បានចែងថា "ក្នុងរយៈពេលព្រះមហាក្សត្រទ្រង់អវត្តមាន ប្រធានរដ្ឋសភា ត្រូវទទួលភារកិច្ចជាប្រមុខរដ្ឋស្តីទី ។ ក្នុងករណីដែលប្រធានព្រឹទ្ធសភា ពុំមានលទ្ធភាពបំពេញភារកិច្ចជាប្រមុខរដ្ឋស្តីទី ជំនួសព្រះមហាក្សត្រ ពេលព្រះអង្គទ្រង់អវត្តមាន ការទទួលភារកិច្ចជាប្រមុខរដ្ឋស្តីទី ត្រូវអនុវត្តតាមវាក្យខណ្ឌទី២ និងទី៣ នៃមាត្រា១១ ថ្មី ។

## គណៈកម្មាធិការអចិន្ត្រៃយ៍

ព្រឹទ្ធសភាបើកសម័យប្រជុំ ពីរដងក្នុងមួយឆ្នាំ ប្រហែលជា៣ខែក្នុងមួយលើកៗ ។ កាលណាព្រឹទ្ធសភាមិនបើកសម័យប្រជុំ គណៈកម្មាធិការអចិន្ត្រៃយ៍ទទួលខុសត្រូវក្នុងការចាត់ចែងការងាររបស់ព្រឹទ្ធសភា ។ គណៈកម្មាធិការអចិន្ត្រៃយ៍មាន : ប្រធានព្រឹទ្ធសភា អនុប្រធានព្រឹទ្ធសភាពីររូប និងប្រធានគណៈកម្មការទាំង ៩ រូប ។

## គណៈកម្មការរបស់ព្រឹទ្ធសភា

មាត្រា ៦ នៃបទបញ្ជាផ្ទៃក្នុងបានកំណត់ឱ្យព្រឹទ្ធសភា មានគណៈកម្មការទាំងអស់ចំនួន ៩ ។ គណៈកម្មការទាំង៩ នោះ ត្រូវមានប្រធាន អនុប្រធាន និងលេខាធិការ ហើយយ៉ាងហោចណាស់មានសមាជិក ៥ រូបទៀត ដែលជ្រើសរើសដោយព្រឹទ្ធសភា ។

យោងតាមមាត្រា ១២ នៃបទបញ្ជាផ្ទៃក្នុងរបស់ព្រឹទ្ធសភា គណៈកម្មការនីមួយៗត្រូវតែកំណត់តួនាទី និងភារកិច្ចរបស់ខ្លួនផ្ទាល់ក្នុងរង្វង់មុខការទទួលខុសត្រូវ ហើយដាក់វិស័យទាំងនោះ ទៅគណៈកម្មាធិការអចិន្ត្រៃយ៍ ដើម្បីសុំសេចក្តីយល់ព្រម ។

### អគ្គលេខាធិការដ្ឋាន

អគ្គលេខាធិការដ្ឋាន ជាផ្នែករដ្ឋបាលរបស់ព្រឹទ្ធសភា មានមន្ត្រីដឹកនាំពីររូបគឺ អគ្គលេខាធិការ និង អគ្គលេខាធិការរង ព្រមទាំងបុគ្គលិកផងដែរ ។ មន្ត្រីដឹកនាំ និងបុគ្គលិករបស់អគ្គលេខាធិការដ្ឋាន មិនមែនជាសមាជិកព្រឹទ្ធសភាទេ ហើយមន្ត្រីដឹកនាំទាំងនោះ ក៏មិនមែនជាមេដឹកនាំនៃគណបក្សនយោបាយណាមួយដែរ។ មន្ត្រីដឹកនាំទាំងពីររូបត្រូវបានចាត់តាំងដោយប្រធានព្រឹទ្ធសភា ហើយត្រូវបានតែងតាំង ដោយព្រះរាជក្រឹត្យ ។ បុគ្គលិកដែលនៅសល់ត្រូវបានចាត់តាំងដោយអគ្គលេខាធិការហើយតែងតាំង ដោយប្រធានព្រឹទ្ធសភា ។

អគ្គលេខាធិការដ្ឋានទទួលខុសត្រូវក្នុងការរក្សាឯកសារ កំណត់ហេតុអង្គប្រជុំ និងកំណត់ត្រានានា របស់ព្រឹទ្ធសភា និងគណៈកម្មាធិការអចិន្ត្រៃយ៍ ព្រមទាំងគណៈកម្មការនានាទាំង៩ ហើយចាត់ចែងកិច្ចការរដ្ឋបាល និងការទាក់ទងទាំងអស់ខាងក្រៅព្រឹទ្ធសភា ។

### ១១.២. អំពីរដ្ឋសភា

ចេញពីឆន្ទៈពិត។ប្រជាពលរដ្ឋខ្មែរស្ទើរតែ ៩០ភាគរយ នៃចំនួនជាង៤លាន៧សែននាក់ ដែលបានទៅបោះឆ្នោតបញ្ចេញមតិដើម្បីជ្រើសរើសតំណាងរបស់ខ្លួនស្របច្បាប់ដោយសេរី និងយុត្តិធម៌ចាប់ពី ថ្ងៃទី២៣ ដល់ទី២៨ ខែឧសភា ឆ្នាំ១៩៩៣ ក្នុងការជ្រើសរើសសភាធម្មនុញ្ញ និងរដ្ឋសភាដើម្បីឆ្ពោះទៅរកការបង្កើតរដ្ឋាភិបាលប្រជាធិបតេយ្យមួយពេញលេញ[១៨] ។

បន្ទាប់ពីរដ្ឋធម្មនុញ្ញបានអនុម័ត សភាធម្មនុញ្ញបានក្លាយជារដ្ឋសភា ដូចដែលមានសមាសភាព នៃថ្នាក់ដឹកនាំ និងសមាជិកដូចខាងក្រោមៈ

### ១១.២.១ មន្ត្រីដឹកនាំរដ្ឋសភា

មន្ត្រីដឹកនាំរដ្ឋសភាមានបីរូបគឺ ប្រធាន អនុប្រធានទីមួយ និងអនុប្រធានទីពីរត្រូវបានជ្រើសតាំង ដោយសមាជិករដ្ឋសភា ។ ប្រធានរដ្ឋសភា មានភារកិច្ចដូចខាងក្រោមៈ

✠ ធានាការប្រព្រឹត្តទៅនៃរដ្ឋសភាឱ្យបានត្រឹមត្រូវ

✠ ធ្វើជាអធិបតីនៃអង្គប្រជុំរដ្ឋសភា

✠ បើក ឬលើកពេលប្រជុំរដ្ឋសភា

✠ ចាត់ចែងពិភាក្សា និងចុះហត្ថលេខាលើបទបញ្ជាផ្ទៃក្នុងនៃរដ្ឋសភា

---

[១៨] ទិនានុលេខន៍២០០៤-២០០៦ រៀបរៀងដោយ ក្រុមហ៊ុន អ៊ីមបីអិនអាយ បោះពុម្ពនៅឆ្នាំ២០០៣

✠ រក្សាការពារសណ្ដាប់ធ្នាប់ ក្នុងរដ្ឋសភា និង

✠ តំណាងរដ្ឋសភាក្នុងការទាក់ទងជាមួយព្រះមហាក្សត្រ និងអាជ្ញាធរសាធារណៈ

ប្រធានរដ្ឋសភាជាអ្នកបំពេញភារកិច្ច ជាប្រមុខរដ្ឋស្ដីទី ក្នុងករណីដែលប្រធានព្រឹទ្ធសភា ពុំមានលទ្ធភាពបំពេញភារកិច្ច ជាប្រមុខរដ្ឋស្ដីទីជំនួសព្រះមហាក្សត្រក្នុងឋានៈជាព្រះរាជានុសិទ្ធិ ពេលព្រះអង្គទ្រង់ប្រឈួនជាទម្ងន់ ( យោង ជំពូកទី២ មាត្រា១១) ។

អនុប្រធានទាំងពីរជាទូទៅ ជួយប្រធានរដ្ឋសភា ។ អនុប្រធានទីមួយ ជំនួសប្រធានរដ្ឋសភា នៅពេលដែលប្រធានរដ្ឋសភាត្រូវទៅបំពេញតួនាទីជាប្រមុខរដ្ឋស្ដីទី ឬនៅពេលដែលប្រធានរដ្ឋសភាពុំអាចបំពេញករណីយកិច្ចរបស់ខ្លួនបាន ។ នៅពេលនោះអនុប្រធានទីពីរក្លាយជាអនុប្រធានទីមួយស្ដីទី ។ រដ្ឋសភាបច្ចុប្បន្នមានសមាជិកចំនួន ១២៣ រូបមកពីគណបក្សធំ៧ចំនួន ៣ ក្នុងនោះ មានសមាជិកជាស្ត្រី ចំនួន ១៥ រូប ។

### ១១.២.២. គណៈកម្មាធិការអចិន្ត្រៃយ៍

រដ្ឋសភាបើកសម័យប្រជុំពីរលើកក្នុងមួយឆ្នាំ ក្នុងរយៈពេលប្រហែលជាបីខែក្នុងមួយលើក។ ។ កាលណារដ្ឋសភាមិនបើក សម័យប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ ត្រូវបានទទួលបន្ទុកចាត់ចែងកិច្ចការ របស់រដ្ឋសភា ។

គណៈកម្មាធិការអចិន្ត្រៃយ៍ មានសមាសភាពដូចខាងក្រោម :

ប្រធានរដ្ឋសភា អនុប្រធានទាំងពីរ និងប្រធានគណៈកម្មការទាំង ៩ រូប ។

### ១១.២.៣. គណៈកម្មការទាំង៩ នៃរដ្ឋសភា

គណៈកម្មការទាំង ៩ ត្រូវបានរៀបរាប់នៅក្នុងអង្គការលេខរបស់រដ្ឋសភា ។ គណៈកម្មការ នីមួយ។ត្រូវជ្រើសរើស ប្រធានមួយរូប អនុប្រធានមួយរូប លេខាធិការតាមរូបភាពបោះឆ្នោត ។ គណៈកម្មការនីមួយ។ មានសមាជិកយ៉ាងហោចណាស់ ៧ រូប ។ សមាជិកគណៈកម្មការនីមួយ។ ត្រូវមានឯកទេសជាពិសេសក្នុងវិស័យច្បាប់ ឬក្នុងមុខងាររបស់រដ្ឋាភិបាល ព្រោះសមាជិកទាំងនេះ មានភារកិច្ចពិនិត្យមើលក្រសួងមួយ ឬច្រើនរបស់រាជរដ្ឋាភិបាល ។ ឧទាហរណ៍ គណៈកម្មការខាងកិច្ចការហិរញ្ញវត្ថុ និងធនាគារមានភារកិច្ចត្រួតមើលក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងសកម្មភាពនៃធនាគារជាតិកម្ពុជា ។

រដ្ឋសភាមានការិយាល័យតំណាងរបស់ខ្លួន នៅគ្រប់ខេត្ត-ក្រុង ទាំង២៣ ។ ប្រជាពលរដ្ឋអាចដាក់ពាក្យបណ្ដឹងរបស់ខ្លួនតាមរយៈការិយាល័យនេះ ។

### ១១.២.៤. អគ្គលេខាធិការដ្ឋាន

អគ្គលេខាធិការដ្ឋាន ជាផ្នែករដ្ឋបាលរបស់រដ្ឋសភា មានអ្នកដឹកនាំពីររូប គឺអគ្គលេខាធិការ និងអគ្គលេខា

ធិការរង ព្រមទាំងមន្ត្រីបុគ្គលិកជាច្រើនរូបទៀត ។ ថ្នាក់ដឹកនាំ និងមន្ត្រី បុគ្គលិក នៃអគ្គលេខាធិការដ្ឋាន មិនមែនជាសមាជិកជាប់ឆ្នោតរបស់រដ្ឋសភាទេ និងជាមនុស្សអព្យាក្រឹត ហើយក៏មិនមែនជាអ្នកដឹកនាំនៃគណបក្សនយោបាយណាមួយឡើយ ។ ថ្នាក់ដឹកនាំពីររូប ត្រូវបានចាត់តាំង ដោយប្រធានរដ្ឋសភា ហើយត្រូវតែងតាំងដោយព្រះរាជក្រឹត្យ ។ បុគ្គលិកដែលនៅសល់ត្រូវបានជ្រើសតាំងដោយអគ្គលេខាធិការ ហើយតែងតាំងដោយប្រធានរដ្ឋសភា ។ អគ្គលេខាធិការដ្ឋានទទួលខុសត្រូវក្នុងការរក្សាទុកឯកសារ និងកំណត់ហេតុនានារបស់រដ្ឋសភា និងគណៈកម្មការនានា ដោយរៀបចំកំណត់ហេតុដែលតម្រូវដោយរដ្ឋសភា ហើយចាត់ចែងកិច្ចការរដ្ឋបាល និងការទាក់ទងទាំងអស់ ខាងក្រៅរដ្ឋសភា ។

**អង្គការលេខរបស់រដ្ឋសភា**

ប្រធានរដ្ឋសភា
អនុប្រធានរដ្ឋសភា ២ រូប
សមាជិក ១២៣ រូប មកពីខេត្ត ក្រុងទាំង ២៣
អគ្គលេខាធិការ ១ រូប និងអគ្គលេខាធិការរង ១ រូប
(មិនមែនជាសមាជិករដ្ឋសភា)

**គណៈកម្មាធិការអចិន្ត្រៃយ៍នៃរដ្ឋសភា**

ប្រធាន
អនុប្រធាន ២ រូប
ប្រធានគណៈកម្មាធិការទាំង ៩ រូប

**គណៈកម្មការ**

**គណៈកម្មការ**
ប្រធានគណៈកម្មការ, អនុប្រធានគណៈកម្មការ, លេខាធិការសមាជិកយ៉ាងតិច ៧ រូប

| | | | | | | | | |
|---|---|---|---|---|---|---|---|---|
| ហិរញ្ញវត្ថុ<br>និង<br>ធនាគារ | នីតិកម្ម | អប់រំ<br>ធម្មការ<br>វប្បធមិ<br>ទេសចរណ៍ | សាធារ<br>ណៈការ<br>ដឹកជញ្ជូន<br>ទូរគមនា<br>គមន៍<br>ប្រៃសណីយ៍ | ការពារ<br>សិទ្ធិមនុស្ស<br>និង<br>ទទួល<br>ពាក្យ<br>បណ្ដឹង | សេដ្ឋកិច្ច<br>ផែនការ<br>វិនិយោគ<br>កសិកម្ម<br>អភិវឌ្ឍន៍<br>ជនបទ<br>បរិស្ថាន | សុខា<br>ភិបាល<br>សង្គមកិច្ច<br>ការងារ<br>កិច្ចការ<br>នារី | កិច្ចការ<br>បរទេស<br>សហប្រតិ<br>បត្តិការ<br>អន្តរជាតិ<br>ព័ត៌មាន | មហាផ្ទៃ<br>ការពារជាតិ<br>ស៊ើបអង្កេត |

### ១១.៣. អំពីរាជរដ្ឋាភិបាល

### ១១.៣.១. រចនាសម្ព័ន្ធ និង អង្គការចាត់តាំងរាជរដ្ឋាភិបាល

មាត្រា ១១៨ នៃរដ្ឋធម្មនុញ្ញ មាត្រាទី ១១៨ ថ្មី ចែងថា គណៈរដ្ឋមន្ត្រី ជារាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា ។ គណៈរដ្ឋមន្ត្រីត្រូវបានដឹកនាំដោយនាយករដ្ឋមន្ត្រីមួយរូប អមដោយ ឧបនាយករដ្ឋមន្ត្រី ព្រមទាំងមានទេស រដ្ឋមន្ត្រី រដ្ឋមន្ត្រី និងរដ្ឋលេខាធិកាជាសមាជិក ។

សមាសភាពនៃគណៈរដ្ឋមន្ត្រីដែលបានតែងតាំងដោយព្រះរាជក្រឹត្យចុះថ្ងៃទី ២៤ ឆ្នាំ១៩៩៨ មានដូចតទៅ:

- ✠ នាយរដ្ឋមន្ត្រី ១ រូប
- ✠ សហឧបនាយករដ្ឋមន្ត្រី២ រូប
- ✠ ទេសរដ្ឋមន្ត្រី ៨ រូប
- ✠ មានប្រមុខក្រសួង ២៧ រូប សំរាប់ក្រសួង ២៥ (ក្រសួងការពារជាតិ និងក្រសួងមហាផ្ទៃ មានរដ្ឋមន្ត្រីពីរ រូប) ។
- ✠ រដ្ឋលេខាធិការ ៥៥ រូប ដោយរួមមានរដ្ឋលេខាធិការដ្ឋានចំនួន២

### ១១.៣.២.តួនាទីរបស់គណៈរដ្ឋមន្ត្រី

សមាជិកទាំងឡាយ នៃរាជរដ្ឋាភិបាលទទួលខុសត្រូវរួមគ្នា ចំពោះរដ្ឋសភាអំពីនយោបាយទូទៅ របស់រាជរដ្ឋាភិបាល ។

សមាជិកមួយរូបៗ នៃរាជរដ្ឋាភិបាល ទទួលខុសត្រូវរៀងៗខ្លួនចំពោះនាយករដ្ឋមន្ត្រី និងចំពោះរដ្ឋសភាអំពីការដែលខ្លួនបានប្រព្រឹត្ត

## ១២- សមាជជាតិ

ជំពូកទី ១៤ នៃរដ្ឋធម្មនុញ្ញ កំណត់ឱ្យមានសមាជជាតិ ។ ទោះបីជាសមាជជាតិនោះ តាមផ្លូវបច្ចេកទេសមិនមែនជាផ្នែកមួយនៃអង្គនីតិបញ្ញត្តិក៏ដោយ ក៏គេចាត់ទុកថាជា "គណៈកម្មាធិការផ្តល់យោបល់របស់ប្រជាពលរដ្ឋ" ដូចរដ្ឋសភាដែរ ។ គោលបំណងនៃសមាជជាតិគឺ ដើម្បីធ្វើឱ្យពលរដ្ឋបានជ្រាប ដោយផ្ទាល់អំពីកិច្ចការដែលជាប្រយោជន៍ជាតិ និងផ្តល់វេទិកាឱ្យដល់ប្រជាពលរដ្ឋម្នាក់ៗ ដើម្បីលើកបញ្ហា និងសំណូមពរព្រមទាំងជួយឧបត្ថម្ភពីរដ្ឋាភិបាល ។ សមាជជាតិត្រូវបើកធ្វើរៀងរាល់ខែធ្នូ តាមការកោះអញ្ជើញ របស់នាយករដ្ឋមន្ត្រីហើយស្ថិតនៅក្រោមព្រះរាជាធិបតីភាពនៃព្រះមហាក្សត្រ។ សមាជជាតិមិនអាចធ្វើច្បាប់ទេ ប៉ុន្តែអាច

អនុម័តសេចក្តីស្នើយោបល់សំរាប់ឱ្យរាជរដ្ឋាភិបាល ឬរដ្ឋសភា ឬក៏ព្រឹទ្ធសភាធ្វើការពិចារណា ។ ទោះបីជារដ្ឋធម្មនុញ្ញសុំឱ្យមានច្បាប់ ស្តីពីការរៀបចំ និងការប្រតិបត្តិរបស់សមាជជាតិក៏ដោយ ក៏ច្បាប់នេះមិនទាន់អនុម័តនៅឡើយដែរ ។ ដោយហេតុនេះហើយបានជាមានការបើកប្រជុំសមាជជាតិ ។

## ១៣.រចនាសម្ព័ន្ធថ្នាក់ជាតិ និងមូលដ្ឋាន

យោងតាមមាត្រា១៤៥ ទឹកដីនៃព្រះរាជាណាចក្រកម្ពុជា ចែកជាខេត្ត និងក្រុង ។ ខេត្តចែកជាស្រុក ស្រុកចែកជាឃុំ ។ ក្រុងចែកជាខណ្ឌ ខណ្ឌចែកជាសង្កាត់ (សូមមើលរចនាសម្ព័ន្ធខាងក្រោម) ។ កម្ពុជាយើងមានប្រជាពលរដ្ឋទាំងអស់ ១៣,០៩៩,៤៧២នាក់ ក្នុងនោះ ស្រីចំនួន ៥,៩២៦.២៤៨នាក់ និងបុរសចំនួន ៥,៥១១.៤០៨នាក់ ។[១៩]

### ១៣.១. ប្រព័ន្ធនយោបាយនិង ប្រព័ន្ធសេដ្ឋកិច្ចនៅកម្ពុជា[២០]

ប្រទេសកម្ពុជាយើងបានផ្លាស់ប្តូរបបនយោបាយ និងប្រព័ន្ធសេដ្ឋកិច្ចជាច្រើនលើក ច្រើនសាជាពិសេសចាប់ពីឆ្នាំ ១៩៤៧ មក ។សូមមើលតារាងខាងក្រោម ។

| ប្រព័ន្ធនយោបាយ | | ប្រព័ន្ធសេដ្ឋកិច្ច |
|---|---|---|
| ព្រះរាជាណាចក្រកម្ពុជា (១៩៤៧-៧០) | ព្រះមហាក្សត្រអាស្រ័យធម្មនុញ្ញ | ផ្សារសេរី |
| សាធារណៈរដ្ឋខ្មែរ (១៩៧០-៧៥) | របបប្រធានាធិបតីអាស្រ័យធម្មនុញ្ញ | ផ្សារសេរី |
| កម្ពុជាប្រជាធិបតេយ្យ (១៩៧៥-៨៩) | កុម្មុយនីស្ត | សេដ្ឋកិច្ចផែនការ |
| សាធារណរដ្ឋប្រជាមានិតកម្ពុជា (១៩៧៩) | កុម្មុយនីស្ត | សេដ្ឋកិច្ចផែនការ |
| រដ្ឋកម្ពុជា (១៩៨៩-៩៣) | កុម្មុយនីស្ត | សេដ្ឋកិច្ចផែនការ |
| ព្រះរាជាណាចក្រកម្ពុជា (១៩៩៣ ដល់បច្ចុប្បន្ន) | ព្រះមហាក្សត្រអាស្រ័យធម្មនុញ្ញ | ផ្សារសេរី |

[១៩] សេរីសៀវភៅច្បាប់ ស្តីពីរដ្ឋធម្មនុញ្ញ សរសេរដោយ លោក ម៉ាស់ធ្យូរ វិនដល មជ្ឈមណ្ឌលអប់រំសហគមន៍ បោះពុម្ពនៅឆ្នាំ២០០០

[២០] The Bretton Woods

ប្រព័ន្ធអភិបាលកិច្ចនៅកម្ពុជា ឆ្នាំ២០០១ ឯកសារក្រសួងមហាផ្ទៃឆ្នាំ ២០០២



ការរៀបចំរដ្ឋបាលកម្ពុជាក្រោយឆ្នាំ ២០០១ ឯកសារក្រសួងមហាផ្ទៃឆ្នាំ ២០០២






របៀបគ្រប់គ្រង

របៀបគ្រប់គ្រងពីក្រោមឡើង



របៀបគ្រប់គ្រងពីលើចុះ



រចនាសម្ព័ន្ធក្រុមប្រឹក្សាឃុំ-សង្កាត់



## ១៤- ការយល់ដឹងអំពីស្ថាប័នហិរញ្ញវត្ថុអន្តរជាតិ

កិច្ចព្រមព្រៀងប្រិតុនវូតនៅ[២១] ខែមិថុនាឆ្នាំ១៩៤៤ បានសម្រេចបង្កើតស្ថាប័នពីរ ដើម្បីពង្រឹងហិរញ្ញវត្ថុពិភពលោក តាមប្រព័ន្ធមូលធននិយម ដើម្បីស្តារសេដ្ឋកិច្ចនៅអឺរ៉ុប ក្រោយសង្គ្រាមលោកលើកទីពីរ ។ ស្ថាប័ននោះឈ្មោះថា មូលនិធិរូបិយវត្ថុអន្តរជាតិ[២២] និងធនាគារពិភពលោក[២៣] ។ ស្ថាប័នពីរនេះ ក៏បានរួមគ្នាបង្កើតធនាគារអភិវឌ្ឍន៍អាស៊ី ដើម្បីធ្វើការនៅក្នុងតំបន់អាស៊ីទាំងមូលផងដែរ ។ ស្ថាប័នទាំងបីខាងលើផ្តល់ប្រាក់កម្ចីទៅបណ្តាប្រទេសក្រីក្រ ។ ស្ថាប័នទាំងបីនេះ មានសមាជិកមកពីប្រទេសនានាដូចជា ប្រទេសអ្នកមាននៃភូមិភាគខាងត្បូង និងប្រទេសអ្នកមាន ភូមិភាគខាងជើង ។

### ១៤.១. មូលនិធិរូបិយវត្ថុអន្តរជាតិ (អាយ អឹម អេហ្វ)

មូលនិធិរូបិយវត្ថុអន្តរជាតិមានប្រទេស និងរដ្ឋជាសមាជិកចំនួន១៨៤ ។ មានប្រាំប្រទេសធំ៧ ដែលមានភាគហ៊ុនច្រើនជាងគេដូចជា សហរដ្ឋអាមេរិក ជប៉ុន អាល្លឺម៉ង់ បារាំង អង់គ្លេស អារ៉ាប៊ីសាអូឌីត ចិន និងរុស្ស៊ី ។ ប្រទេសទាំងនេះ មានសម្លេងសន្លឹកឆ្នោតស្មើនឹង ៤៨ភាគរយ នៃសមាជិកទាំងអស់ ។ មូលនិធិរូបិយវត្ថុ មានទីស្នាក់ការនៅទីក្រុងវ៉ាស៊ីនតោន ឌីស៊ី សហរដ្ឋអាមេរិក ។

### ១៤.២. ធនាគារពិភពលោក (វើល បែង)

ធនាគារពិភពលោកមានប្រទេស និងរដ្ឋជាសមាជិកចំនួន ១៨៤ ក្នុងនោះមានប្រទេសធំៗរួមមានសហរដ្ឋ អារមរិក ជប៉ុន អាល្លឺម៉ង់ បារាំង អង់គ្លេស អារ៉ាប៊ីសាអូឌីត និងរុស្ស៊ី ។ ប្រទេសធំ៧ទាំងនេះ មានសម្លេងឆ្នោត ៤៦ ភាគរយនៃសម្លេងឆ្នោតរួម ។




[២១] International Monetary Funds

[២២] World Bank

[២៣] Poverty Reduction Growth Faciliy¬PRGF

## ១៤.៣. មូលនិធិអភិវឌ្ឍន៍អាស៊ី

មូលនិធិអាស៊ី មានប្រទេស និងរដ្ឋជាសមាជិកចំនួន៦១ ក្នុងនោះមានប្រទេសធំចំនួន ៥ ដែលមានសម្លេងឆ្នោត ៤២ភាគរយនៃសម្លេង នៃសន្លឹកឆ្នោតរួម ។ ប្រទេសទាំង៥ នោះមាន សហរដ្ឋអាមេរិក ជប៉ុន ចិន ឥណ្ឌា និងអូស្ត្រាលី ។

## ១៤. ៤. គោលនយោបាយនៃស្ថាប័នទាំងបីខាងលើ

ឥឡូវនេះ វាក្លាយទៅជាទម្លាប់ទៅហើយ ដែលប្រធានធនាគារពិភពលោក គឺជាសហរដ្ឋអាមេរិក រីឯប្រធានរូបិយវត្ថុពិភពលោក គឺក្រុមប្រទេសខាងអឺរ៉ុប ហើយប្រធានធនាគារអភិវឌ្ឍនីអាស៊ី គឺប្រទេសជប៉ុន ។ រូបិយវត្ថុពិភពលោក និងធនាគារពិភពលោកត្រូវបានគេដាក់ទីតាំង នៅទីក្រុងវ៉ាស៊ីនតោនឌីស៊ី ហើយនៅជិតនឹងរតនាគាររបស់សហរដ្ឋអាមេរិក ព្រោះជីវិតគេត្រូវពឹងផ្អែកទៅលើរតនាគារនេះ ។ ធនាគារអភិវឌ្ឍន៍អាស៊ីមានការិយាល័យធំនៅទីក្រុងម៉ានីល ប្រទេសហ្វីលីពីន ។

ប្រព័ន្ធនៃការបោះឆ្នោតរបស់ស្ថាប័នខាងលើនេះមិនដូចប្រព័ន្ធអង្គការសហប្រជាជាតិទេ ។ ប្រព័ន្ធអង្គការសហប្រជាជាតិ ប្រទេសជាសមាជិកមួយមានសម្លេងមួយស្មើគ្នា ប៉ុន្តែប្រទេសសមាជិក នៃស្ថាប័នមូលនិធិអន្តរជាតិនេះ មានអំណាចសម្លេងមិនស្មើគ្នាទេ ។ អំណាចនៃសម្លេងឆ្នោតផ្អែកលើទុន ដែលប្រទេសនីមួយៗវិនិយោគនៅក្នុងស្ថាប័ន ។ ដូច្នេះប្រទេសណាដែលដាក់ទុនចូលច្រើនមានអំណាចសន្លឹកឆ្នោតច្រើន ។ ប្រទេសដែលដាក់ភាគហ៊ុនច្រើនជាងគេនៅក្នុងធនាគាពិភលោក និងមូលនិធិរូបិយវត្ថុអន្តរជាតិ ហើយស្មើនឹងភាគហ៊ុនរបស់ប្រទេសជប៉ុន នៅក្នុងធនាគារអភិវឌ្ឍន៍អាស៊ី គឺសហរដ្ឋអាមេរិក ។ ដោយកត្តានេះហើយ ទើបនៅឆ្នាំដំបូងៗស្ថាប័នប្រិដតុនវូត ធនាគារពិភលោក និងមូលនិធិរូបិយវត្ថុអន្តរជាតិ ត្រូវបានគ្របដណ្តប់ដោយរតនាគារសហរដ្ឋអាមេរិក ។ ដូច្នេះការដាក់សម្ពាធនយោបាយលើប្រទេសដទៃៗ និងគំនិតផ្តួចផ្តើមផ្សេងៗទៀត ភាគច្រើនចេញពីទីក្រុងវ៉ាស៊ីនតោន ទោះបីជាគំនិតនោះផ្ទុយនឹងឆន្ទៈប្រទេសដទៃក៏ដោយ ។ ធនាគារពិភពលោក និងមូលនិធិរូបិយវត្ថុអន្តរជាតិ បានក្លាយទៅជាស្ថាប័ន ដែលមានឥទ្ធិពលខ្លាំងដោយគោលនយោបាយសហរដ្ឋអាមេរិក ។ លោក ចន ភីលជើ បានពិពណ៌នាថា អាមេរិកត្រួតត្រាលើភូមិសាស្ត្រជាច្រើន ឧទាហរណ៍ ដូចជាកិច្ចព្រមព្រៀង ប្រិដតុនវូដ បានផ្តល់សិទ្ធិដ៏ធំធេងដល់សហរដ្ឋអាមេរិក ក្នុងការបង្កើតមូលដ្ឋានកងទ័ព បង្កើតក្រុមហ៊ុនសាជីវកម្ម រុករករ៉ែប្រេង និងដណ្តើមទីផ្សារ លើបណ្តាប្រទេសមួយចំនួនលើពិភពលោក ។ លោក យ៉ូសេប ស្ទីហ្គលីតស្ស អតីតអ្នកសេដ្ឋកិច្ច នៃធនាគារពិភពលោក បានមានប្រសាសន៍ថា សព្វថ្ងៃនេះ ទំនាក់ទំនងរវាងរតនាគារ របស់សហរដ្ឋអាមេរិក និងមូលនិធិរូបិយវត្ថុអន្តរជាតិមានភាពជិតស្និទ្ធយ៉ាងខ្លាំង ហើយពុំអាចកាត់ផ្តាច់ពីគ្នាបានឡើយ ។ បច្ចុប្បន្ននេះ ស្ថាប័នទាំងពីររួមទាំងធនាគារអភិវឌ្ឍន៍អាស៊ី

ផងដែរ បានសម្រេចឈប់ផ្តល់ប្រាក់កម្ចីដល់ប្រទេសដែលមានការអភិវឌ្ឍន៍ ហើយផ្តោតការយកចិត្តទុកដាក់លើប្រទេសក្រីក្រវិញ ។ បុគ្គលមួយចំនួនមានជំនឿថា គោលនយោបាយរបស់មូលនិធិរូបិយវត្ថុអន្តរជាតិ និងធនាគារពិភពលោក គឺមានតួនាទីយ៉ាងសំខាន់ក្នុងការជួយកាត់បន្ថយភាពក្រីក្ររបស់គេ ។

មានចំនុចមួយចំនួន ដែលគួរឱ្យកត់សំគាល់នូវភាពខុសគ្នានៃស្ថាប័នទាំងពីរនេះ ទាក់ទងទៅនឹងជំនួយដែលត្រូវផ្តល់ឱ្យប្រទេសក្រីក្រ ។ ជាទូទៅ មូលនិធិរូបិយវត្ថុអន្តរជាតិបានផ្តល់ប្រាក់កម្ចីបន្ទាន់ រយៈពេលខ្លីទៅប្រទេសទាំងឡាយ ដែលជួបប្រទះនូវអស្ថិរភាពសេដ្ឋកិច្ចដូចជា អតុល្យភាពនៃការចំណាយរបស់គេ ឬអតុល្យភាពសារពើពន្ធ ។ ដូច្នេះប្រាក់កម្ចីនេះមានឥទ្ធិពល និងសារៈសំខាន់ណាស់ ចំពោះប្រទេសដែលខ្ចីប្រាក់ ។ ឧទាហរណ៍ នៅពេលថ្មីៗនេះ ជាពិសេសវិបត្តិហិរញ្ញវត្ថុឆ្នាំ ១៩៩៧-១៩៩៨ ការពន្យារពេលផ្តល់ប្រាក់កម្ចីរបស់មូលនិធិរូបិយវត្ថុអន្តរជាតិ បានធ្វើឱ្យវិបត្តិសេដ្ឋកិច្ចកាន់តែធ្ងន់ធ្ងរ និងតានតឹងឡើង តួយ៉ាងដូចជាប្រទេសកូរ៉េខាងត្បូងជាដើម ។ ធនាគារអភិវឌ្ឍន៍អាស៊ីផ្តល់ប្រាក់កម្ចីរយៈពេលវែង ដែលអាចជួយឱ្យប្រទេស ឬរដ្ឋជាសមាជិកអាចរៀបចំកែទម្រង់រចនាសម្ព័ន្ធ សេដ្ឋកិច្ចរបស់ខ្លួនតាមរយៈការអភិវឌ្ឍន៍ ។ ធនាគារអភិវឌ្ឍន៍អាស៊ីឱ្យខ្ចីលុយកម្ចីសំរាប់ការកសាងផ្លូវ កសាងទំនប់ទឹក ការអប់រំ និងកម្មវិធីផ្សេងៗទៀត ដែលស្រដៀងគ្នានេះដែរ ។ ប៉ុន្តែនៅ ឆ្នាំ១៩៨០ ធនាគារអភិវឌ្ឍន៍អាស៊ី បានចាប់ផ្តើមឱ្យប្រាក់កម្ចីដល់ប្រទេសផ្សេងៗ ដើម្បីកែលំអរចនាសម្ព័ន្ធរបស់ពួកគេ ។ ធនាគារនេះបានពង្រីកប្រាក់កម្ចីទៅដល់ប្រទេសជាសមាជិក ដែលមានអតុល្យភាពលើចំណាយ ឬឱនភាព លើសារពើពន្ធ ។ តាមរយៈប្រាក់កម្ចីនេះ ធនាគារទាមទារឱ្យប្រទេសទាំងនោះបង្កើត ឬកែសម្រួលនូវគោលនយោបាយសេដ្ឋកិច្ចរបស់ពួកគេ ។ ធនាគារអភិវឌ្ឍន៍អាស៊ី ក៏បានពង្រីកប្រាក់កម្ចីរយៈពេលវែង លើគម្រោងរចនាសម្ព័ន្ធធំៗដូចជា ផ្លូវថ្នល់ ផ្លូវសំខាន់ៗ ព្រលានយន្តហោះ ទំនប់ទឹកជាដើម ។ល។ ធនាគារអភិវឌ្ឍន៍អាស៊ី ធ្វើតាមរបៀបដែលធនាគារពិភពលោកបានធ្វើ ។

ប្រទេសទាំងឡាយ ដែលមានកម្មវិធីរបស់ខ្លួនណាមួយបានអនុម័តដោយមូលនិធិរូបិយវត្ថុអន្តរជាតិ ហើយប្រទេសនោះមានលទ្ធភាព អាចទទួលប្រាក់កម្ចីពីស្ថាប័នផ្សេងៗទៀត ។ ប៉ុន្តែដើម្បីឱ្យមានការយល់ព្រម និងទទួលស្គាល់ដោយមូលនិធិរូបិយវត្ថុអន្តរជាតិ ប្រទេសដែលខ្ចីប្រាក់ ពីមូលនិធិនេះ ត្រូវធ្វើយ៉ាងណាឱ្យគេមានការពេញចិត្តលើកម្មវិធីរបស់ខ្លួន ។ អ្នកនយោបាយមួយចំនួនបានបកស្រាយថា ដើម្បីទទួលបានប្រាក់កម្ចីពីមូលនិធិរូបិយវត្ថុអន្តរជាតិ វាប្រៀបបីដូចជាយើងលេបថ្នាំ ឬវត្ថុអ្វីម្យ៉ាងដែលល្វីងហើយខានពុំបាន ។ គិតមកត្រឹមថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ២០០៤ មូលនិធិរូបិយវត្ថុអន្តរជាតិ មានប្រាក់កម្ចី ដែលពុំទាន់សងចំនួន ៦៩,៦២៧ លាន[២៤] ។ ប្រទេសដែលជាប់បំណុលរួមមាន ទួរគី ប្រេស៊ីល អាហ្សង់ទីន ឥណ្ឌូនេស៊ី រុស្ស៊ី ប៉ាគីស្ថាន

---

[២៤] Poverty Reduction Growth Faciliyt¬PRGF

ហ្វីលីពីន ហ្សាមបៀរ យេហ្គោស្លាវី និងថៃ ។ ក្នុងចំណោមប្រទេសទាំងអស់ខាងលើ ប្រទេសឥណ្ឌូនេស៊ី និង ហ្វីលីពីន ជំពាក់មូលនិធិរូបិយវត្ថុអន្តរជាតិ ស្មើនឹង ៨០% នៃកម្ចីសរុប ។ ចំណែកឯធនាគារពិភពលោក បានឱ្យប្រទេសជាសមាជិកខ្ចីប្រាក់ចំនួន ៥០៦.៥៤៥.៣ លាន[២៥] គិតត្រឹមថ្ងៃទី ៣០ ខែមិថុនា ឆ្នាំ២០០២ ។ ចំពោះធនាគារពិភពលោក ប្រាក់កម្ចីសំរាប់ធ្វើការកែប្រែរចនាសម្ព័ន្ធបានក្លាយជាយានដ៏សំខាន់សំរាប់ចាប់បង្ខំឱ្យប្រទេសអ្នកខ្ចីប្រាក់ទទួលយករបៀបមួយ ដែលថា "ព្រមព្រៀងគ្នាដោយគ្មាន ការបង្ខិតបង្ខំរបស់ទីក្រុងវ៉ាស៊ីនតោន" ។ ដើម្បីឱ្យគោលនយោបាយរបស់ខ្លួនមានប្រសិទ្ធភាព ធនាគារពិភពលោក បានឱ្យប្រទេសដែលខ្ចីប្រាក់នោះ ទទួលយល់ព្រមដោយមូលនិធិរូបិយវត្ថុអន្តរជាតិសិន មុនពេលដាក់ឱ្យសុំខ្ចីលុយពីខ្លួន ។ ជាគោលការណ៍ មូលនិធិរូបិយវត្ថុអន្តរជាតិក្តី ធនាគារពិភពលោកក្តីប្រើសិទ្ធិអំណាចរបស់គេតែមួយគត់ តាមរយៈការគំរាម ឬប្រាក់ដកកម្ចី និងលក្ខខណ្ឌដែលទាក់ទងនឹងប្រាក់កម្ចីនេះតែប៉ុណ្ណោះ ។

## ១៥. តើប្រទេសកម្ពុជារបស់យើងជំពាក់ប្រាក់ប្រទេសណាខ្លះ?

នៅរវាងឆ្នាំ ១៩៧០ កម្ពុជាបានខ្ចីលុយពីប្រទេសក្រៅ ជាពិសេសសហរដ្ឋអាមេរិក នៅពេលនោះ របប លន់ នល់ ជំពាក់អាមេរិកចំនួន ៣០៦លានដុល្លារ[២៦] (ឥឡូវសល់២៩៤លានដុល្លារ ដែលត្រូវសងសហរដ្ឋអាមេរិក) ។ ប្រាក់កម្ចីនេះ លោក លន់ នល់ បានយកទៅទិញអាវុធគ្រាប់រំសេវដើម្បីធ្វើសង្គ្រាមពីឆ្នាំ ១៩៧០-១៩៧៥ ដែលគាំទ្រដោយសហរដ្ឋអាមេរិក ប្រឆាំងជាមួយខ្មែរក្រហមដែលគាំទ្រដោយចិនកុម្មុយនីស្ត ។ ទន្ទឹមគ្នានេះដែរ ប៉ុល ពត (ខ្មែរក្រហម) ក៏បានខ្ចីលុយចិន តែពុំមានតួលេខ ច្បាស់លាស់ទេ ។ នៅឆ្នាំ ១៩៧៩ ប្រទេសកម្ពុជាបានខ្ចីលុយពីប្រទេសរុស្ស៊ី តាមស្ថិតិបានបង្ហាញថាមានចំនួនរហូតដល់ ១.៣២៨ លាន ដុល្លារ[២៧] ។ ប្រាក់នេះត្រូវបានខ្ចីដោយអតីតរដ្ឋកម្ពុជា ដើម្បីទិញគ្រឿងសព្វាវុធគ្រាប់រំសេវ ធ្វើសង្គ្រាមប្រឆាំងនឹងខ្មែរសេរី ខ្មែរក្រហម និងក្រុមផ្សេងទៀត ។ ទន្ទឹមនឹងនេះ រដ្ឋកម្ពុជាយើងក៏បានខ្ចីប្រាក់ពីប្រទេសសង្គមនិយមផ្សេងទៀត តែយើងពុំមានតួលេខច្បាស់លាស់ ។ ក្រៅពីនេះ ប្រទេសកម្ពុជាបានខ្ចីលុយពីប្រទេសពហុភាគី ដូចជា មូលនិធិរូបិយវត្ថុអន្តរជាតិ ធនាគារពិភពលោក ធនាគារអភិវឌ្ឍន៍អាស៊ី ។

ចាប់ពីឆ្នាំ ១៩៩២ មកទល់នឹងបច្ចុប្បន្ន ប្រទេសកម្ពុជា បានខ្ចីលុយពីធនាគារពិភពលោក សំរាប់ការសាងសង់ប្រទេសចំនួន ៦៩២.៨លាន ដុល្លារសហរដ្ឋអាមេរិក ។ ក្នុងពេលជាមួយគ្នានោះដែរ មូលនិធិរូបិយវត្ថុ

[២៥] ឯកសារអង្គការស្តារកម្ពុជា បោះពុម្ពនៅឆ្នាំ២០០០

[២៦] កែសំរួលពីឯកសារមេរៀនតស៊ូមតិនៃអង្គការស្តារកម្ពុជា បោះពុម្ពឆ្នាំ១៩៩៩ និងសៀវភៅ ការណែនាំអំពីការតស៊ូមតិ យុទ្ធសាស្ត្រតស៊ូមតិ និងបច្ចេកទេសអភិវឌ្ឍន៍

[២៧] សៀវភៅណែនាំ ស្តីពីយុទ្ធសាស្ត្រ នៃការតស៊ូមតិ និងបច្ចេកទេសអភិវឌ្ឍន៍ បោះពុម្ពនៅឆ្នាំ ២០០៣

អន្តរជាតិ បានផ្តល់ប្រាក់កម្ចីចំនួន ៧១[២៨] លានដុល្លារសំរាប់គម្រោងការកាត់បន្ថយភាពក្រីក្រ ។ លើសពីនេះទៀត នៅឆ្នាំ ១៩៩២-២០០២ កម្ពុជាបានខ្ចីលុយពីធនាគារអភិវឌ្ឍន៍អាស៊ីសំរាប់ គម្រោងការផ្សេងៗស្រដៀងគ្នាទៅនឹងកម្មវិធី មានទឹកប្រាក់ចំនួន ៦៧៦.៩៨[២៩] ដុល្លារសហរដ្ឋអាមេរិក ។ បំណុលសរុបដែលកម្ពុជាជំពាក់គេមកទល់បច្ចុប្បន្នចំនួន ៣.០២២,៧៨[៣០] លានដុល្លារសហរដ្ឋអាមេរិក ។ តួលេខនេះ មិនរាប់បញ្ចូលបំណុលដែលកម្ពុជាយើងបានខ្ចីពីប្រទេសមួយចំនួនដូចជា ចិន កូរ៉េ ជប៉ុន និងប្រទេសដទៃៗទៀតទេ ព្រោះពុំមានតួលេខច្បាស់លាស់[៣១] ។

## ១៦- ម្ចាស់មូលនិធិ ឬម្ចាស់អំណោយ

ម្ចាស់មូលនិធិ ឬម្ចាស់អំណោយ គឺជាអ្នកផ្តល់ថវិកាផ្សេងៗដល់ប្រទេសក្រីក្រ ឬអង្គការមិនមែនរដ្ឋាភិបាល សហគមន៍ដើម្បីធ្វើសកម្មភាពជួយចំពោះជនក្រីក្រ ឬជនរងគ្រោះ ។ ម្ចាស់មូលនិធិមានគោលបំណង និងទិសដៅរបស់គេរៀងៗខ្លួន ។ នៅប្រទេសកម្ពុជាយើងមានម្ចាស់មូលនិធិជាច្រើន ដែលពេលបច្ចុប្បន្ននេះ កំពុងតែជួយគាំទ្រអង្គការមិនមែនរដ្ឋាភិបាល ឱ្យធ្វើការលើវិស័យផ្សេងៗដូចជាគម្រោងអភិវឌ្ឍន៍ (ក្នុងនោះមានកសិកម្ម ឥណទានសុខភាព) លទ្ធិប្រជាធិបតេយ្យ (សិទ្ធិមនុស្ស ការតស៊ូមតិ តុលាការ) និងការ អប់រំជាដើម ។ ម្ចាស់មូលនិធិចែកចេញជា :

### ១៦.១. អង្គការអន្តរជាតិ

អង្គការអន្តរជាតិ ជាអង្គភាពមួយ ដែលទទួលជំនួយពីប្រទេស ឬស្ថាប័នមួយ ឬច្រើន ឬថវិកា ដែលបរិច្ចាគដោយសប្បុរសជន ហើយផ្តល់ជំនួយទៅអង្គការសង្គមស៊ីវិល ដើម្បីធ្វើសកម្មភាព ។ អង្គការអន្តរជាតិនៅកម្ពុជារួមមានជាមូលនិធិអាស៊ី សេវាជំនួយកាតូលិក អង្គការអុកស្វាមអង់គ្លេស អុិស្វាមហុងកុង អង្គការអុកស្វាមអាមេរិក អង្គការស៊ីដសេ អង្គការហ្វ្រុមស៊ីដ អង្គការណូវីប អង្គការរ៉េដបាណា មូលនិធិកុមារអន្តរជាតិ អង្គការអាយកូ អុីអុីឱ អង្គការជំនួសគ្រីសស្ទានជាដើម ។

### ១៦.២. ទីភ្នាក់ងារទ្វេភាគី

ទីភ្នាក់ងារទ្វេភាគីជាម្ចាស់មូលនិធិទទួលថវិកាពីប្រទេសមួយហើយផ្តល់ឱ្យប្រទេស ឬសង្គមស៊ីវិល ។ ក្រុមនេះមានយូសែដ ចាយកា ដានីដា ស៊ីដា អូអេដ ស៊ីទីហ្សែត ជាដើម ។

---

[២៨] ដកស្រង់ពីសៀវភៅ " ការបង្កើតផែនការសំរាប់ការតស៊ូមតិ " របស់លោក ព្រីសគ្រូសប្រ៊ូ

[២៩] The Prevention Research Center

[៣០] លោក ឡូរី ដរហ្វមែន និងលោក វ៉ាឡេក អ្នកស្រាវជ្រាវ បណ្ណាញព័ត៌មាន ប៊ើកកាឡេ សាកលវិទ្យាល័យ កានីហ្វនី ១៩៩៦

[៣១] People Power II

### ១៦.៣. ទីភ្នាក់ងារពហុភាគី

ទីភ្នាក់ងារ ដែលជាសាខារបស់អង្គការសហប្រជាជាតិៈ ដូចជា យូអិនឌីភី យូអ៊ីនអេហ្វភីអេ យូនីសេហ្វ យូនីសស្កូ អង្គការពលកម្មអន្តរជាតិ ជំនួយអង្គការសហប្រជាជាតិ ។ល។

### ១៦.៤. មូលនិធិគណបក្សនយោបាយ

ក្រុមនេះ ផ្តល់ថវិការបស់គេដោយតម្រូវឱ្យអ្នកទទួល ធ្វើតាមគោលនយោបាយរបស់គេ ។ រួមមាន សាធារណរដ្ឋអន្តរជាតិលទ្ធិប្រជាធិបតេយ្យជាតិ ហ្វេដឌ្រីកអេប៊ើដ ស្ទីហ្វហ្វាំង ខុនរ៉ាដអាដេ ណូអើ ស្ទីហ្វាំង ។

# ផ្នែកទី៤

# អំពី

# ការតស៊ូមតិលើ

# គោលនយោបាយ

# ផ្នែកទី៤
# ការតស៊ូមតិលើគោលនយោបាយ

## ១- ការធ្វើផែនការយុទ្ធសាស្ត្រតស៊ូមតិលើគោលនយោបាយ

មុននឹងឈានដល់ការពិភាក្សាលំអិត អំពីការធ្វើផែនការយុទ្ធសាស្ត្រ ការតស៊ូមតិលើគោលនយោបាយ ខ្ញុំសូមជំរាបជូនបន្តិចថា ដូចម្តេចទៅដែលហៅថាការតស៊ូមតិលើគោលនយោបាយ ។ **ការតស៊ូមតិលើគោលនយោបាយ** គឺជាការតស៊ូមតិដោយផ្ទាល់ទៅលើគោលនយោបាយតែមួយ ឬគោលនយោបាយច្រើន ដែលជាប់ទាក់ទងគ្នា ហើយគោលនយោបាយនោះ មានការពាក់ព័ន្ធទៅនឹងផលប្រយោជន៍រួម ។ ដើម្បីឱ្យការតស៊ូមតិលើគោលនយោបាយ អាចប្រព្រឹត្តទៅបានជោគជ័យ អ្នកត្រូវតែយល់ដឹងអំពី **យុទ្ធសាស្ត្រការតស៊ូមតិលើគោលនយោបាយ** ។

ការធ្វើផែនការសំរាប់យុទ្ធនាការតស៊ូមតិលើគោលនយោបាយពុំមែនមានន័យថា អ្នកតស៊ូមតិចាំបាច់ត្រូវតែយល់ដឹងអំពីប្រព័ន្ធ និងរចនាសម្ព័ន្ធរបស់រដ្ឋាភិបាលទាំងស្រុងនោះទេ ប៉ុន្តែយើងត្រូវតែយល់ដឹងឱ្យបានច្បាស់អំពីដំណើរការនៃការធ្វើសេចក្តីសម្រេចរបស់រដ្ឋាភិបាល ស្គាល់អំពីរចនាសម្ព័ន្ធ និងឋានានុក្រមនៃការសម្រេចចិត្តរបស់រដ្ឋាភិបាលលើគោលនយោបាយទាំងថ្នាក់ជាតិ និងមូលដ្ឋាន ។

ការធ្វើផែនការតស៊ូមតិលើគោលនយោបាយ ទាមទារឱ្យយើងចេះធ្វើផែនទីនយោបាយ ។ យុទ្ធនាការនៃការតស៊ូមតិដោយគ្មានផែនទីនយោបាយវាហាក់បីដូចជា ការធ្វើសង្គ្រាមដែលគ្មានផែនទីសមរភូមិដូច្នោះដែរ ។ ផែនទីនយោបាយសំរាប់យុទ្ធនាការតស៊ូមតិជួយយើងឱ្យកំណត់បាននូវគោលដៅ ការរៀបចំផែនការច្បាស់លាស់ ដោយបែងចែកតួនាទីអ្នកណាធ្វើអ្វី? ធ្វើនៅពេលណា? និងធ្វើរបៀបណា? នៅក្នុងអត្ថបទនេះ យើងមិនធ្វើការវិភាគទៅលើនយោបាយនៃប្រទេសនេះទេ យើងគ្រាន់តែវិភាគទៅលើដំណើរការនៃការសម្រេចទៅលើគោលនយោបាយតែប៉ុណ្ណោះ ។ ដោយប្រទេសអ្នកផ្តល់ជំនួយ ជាទូទៅមានឥទ្ធិពលទៅលើការសម្រេចចិត្តទៅលើគោលនយោបាយនៃប្រទេសទទួលជំនួយ ឬខ្ចីប្រាក់ ការធ្វើផែនទីនយោបាយសំរាប់ការតស៊ូមតិ ត្រូវតែផ្តោតទៅលើផលប៉ះពាល់នោះផងដែរ បើពុំនោះទេ ផែនទីនយោបាយរបស់យើងនោះពុំមានប្រសិទ្ធភាពឡើយ ។ វាជាការចាំបាច់ណាស់ ដែលផែនទីនយោបាយ ត្រូវតែកំណត់នូវកត្តាជោគជ័យ បរាជ័យ និងកំណត់នូវអ្នកណាជាអ្នកគាំទ្រ និងមិនគាំទ្រនូវសេចក្តីស្នើឡើងរបស់យើង ។

## ២- ការធ្វើផែនទីនយោបាយសំរាប់ការតស៊ូមតិលើគោលនយោបាយ

### ផែនទីនយោបាយជាអ្វី ?

ការធ្វើផែនទីនយោបាយ គឺជាបច្ចេកទេសសំរាប់កំណត់រកឱ្យឃើញនូវអ្នកនយោបាយទាំងឡាយ ដែលពាក់ព័ន្ធ ទៅនឹងការរៀបចំនយោបាយប្រទេសជាតិ ។ ការធ្វើផែនទីនយោបាយអាចជួយឱ្យអ្នកតស៊ូមតិរៀបចំយុទ្ធសាស្ត្ររបស់ខ្លួនយ៉ាងមានប្រសិទ្ធភាព ជាពិសេសលើការស្នើសុំ ឱ្យមានការកែប្រែគោលនយោបាយនេះតែម្តង ។ ការធ្វើផែនទីនយោបាយក៏អាចជួយអ្នកតស៊ូមតិ :

១- ស្រាវជ្រាវ ដើម្បីយល់ដឹងអំពីគោលនយោបាយទាំងឡាយ ដែលរដ្ឋាភិបាលកំពុងធ្វើការ កែប្រែ

២- រៀបចំគោលដៅ គោលបំណង កំណត់យុទ្ធសាស្ត្រ សកម្មភាព ក្រុមគោលដៅ និងទីតាំងដែលត្រូវធ្វើការតស៊ូមតិបានត្រឹមត្រូវ និងយ៉ាងមានប្រសិទ្ធភាព

៣- កំណត់បាននូវបញ្ហា ឱកាស និងឧបសគ្គ ដែលត្រូវធ្វើការតស៊ូមតិ

៤- រៀបចំព័ត៌មានទាក់ទងទៅនឹងគោលនយោបាយ និងបង្កើនទំនាក់ទំនងជាមួយបណ្តាញ ផ្សេងៗ

៥- អាចត្រៀមខ្លួនក្នុងការប្រឈមមុខនឹងឧបសគ្គនានា ដែលអាចកើតមានឡើង

៦- រៀបចំយុទ្ធនាការដ៏មានប្រសិទ្ធភាព

## ៣ -ជំហាននៃការធ្វើផែនទីនយោបាយ

**ជំហានទី១**. ធ្វើការប៉ាន់ប្រមាណលើគោលនយោបាយដែលប៉ះពាល់ដល់ប្រយោជន៍សាធារណៈ

នៅពេលដែលរដ្ឋាភិបាលចាប់ផ្តើមធ្វើ ឬកែប្រែគោលនយោបាយ គឺពេលនោះ យើងត្រូវទំនាក់ទំនងជាមួយ ក្រុមសង្គមស៊ីវិលតាមរយៈ ការពិភាក្សា ឬប្រជុំលើបញ្ហានេះ តាមជំហានដូចខាងក្រោម :

### ១.១. សិក្សាអំពីគោលនយោបាយ

✠ តើយើងបានពិនិត្យច្បាស់លាស់លើគោលនយោបាយនោះដែរឬទេ? តើហេតុអ្វី បានជាគេបង្កើត ឬធ្វើការកែប្រែលើគោលនយោបាយនោះ?

✠ តើអ្នកណា នឹងទទួលផលប្រយោជន៍ ហើយអ្នកណានឹងត្រូវប៉ះពាល់ដោយគោលនយោបាយ នោះ?

✠ តើគោលនយោបាយនោះនឹងអាចប៉ះពាល់ដល់ប្រយោជន៍សាធារណៈកម្រិតណា?

✠ តើសាធារណជនមានចំណាប់អារម្មណ៍យ៉ាងណា ចំពោះគោលនយោបាយនោះ? តើគោលនយោបាយ នោះអាចធ្វើឱ្យមានវិបត្តិដល់ប្រទេសជាតិ ឬទេ? កម្រិតណា? តើវានឹងមានអធម្មនុញ្ញភាព ជាមួយច្បាប់ដែលកំពុងអនុវត្តដែរ ឬទេ?

### ១.២. ការវិភាគទៅលើបញ្ហា

នៅកម្រិតជាតិ អ្នកតស៊ូមតិមានឱកាសជាច្រើន ដើម្បីធ្វើឱ្យមានការកែប្រែលើគោលនយោបាយ ។ ឱកាសទាំងនោះ អាចមានទាំងនៅពេលប្រទេសស្ថិតនៅក្នុងស្ថានភាពនយោបាយមានវិបត្តិ និងមិនមានវិបត្តិ ។ ដើម្បីធ្វើការនេះ ឱ្យមានប្រសិទ្ធភាព យើងត្រូវវិភាគនូវបញ្ហា ដែលយើងបានកំណត់ ។ បន្ទាប់មកយើងប្រមូលក្រុមពាក់ព័ន្ធផ្សេងៗ ដើម្បីពិភាក្សា និងឯកភាពលើការវិភាគរបស់យើង ។

### ១.៣. ការប្រមាណនូវបញ្ហាដែលអាចកើតឡើង និងរៀបចំគម្រោងផែនការ សកម្មភាព

ផ្អែកទៅលើព័ត៌មានដែលប្រមូលបាន អ្នកតស៊ូមតិត្រូវធ្វើការប៉ាន់ប្រមាណនូវសភាពការណ៍ ដែលនឹងអាចកើតឡើង និងសម្លឹងមើលឱកាស ដែលអាចធ្វើការតស៊ូមតិបាន បន្ទាប់មករៀបចំគម្រោងផែនការសកម្មភាព ។

### ១.៤. ការបង្កើតគោលបំណង និងចាត់អាទិភាពលើសកម្មភាពដែលបានគ្រោង

យើងត្រូវកំណត់នូវគោលដៅ និងគោលបំណង ឱ្យបានច្បាស់លាស់ និងធ្វើចំណាត់ថ្នាក់សកម្មភាព ផ្អែកទៅលើលទ្ធផលនៃការស្រាវជ្រាវខាងលើ ដោយមានការឯកភាពពីក្រុមដែលពាក់ព័ន្ធ ។ ធ្វើបែបនេះ ទើបការតស៊ូមតិរបស់យើងមានការចូលរួមពីគ្រប់ភាគី និងទទួលបានជោគជ័យ ។

**ជំហានទី២-** ការវិភាគទៅលើកម្លាំងក្នុងការសម្រេចចិត្តលើគោលនយោបាយ និងការកំណត់នូវមនុស្ស ឬស្ថាប័នសំខាន់ៗ

ក្នុងការធ្វើការតស៊ូមតិលើគោលនយោបាយ ការយល់ដឹងអំពីកម្លាំងក្នុងការសម្រេចចិត្តលើគោលនយោបាយ និងមនុស្ស ឬស្ថាប័នដែលមានតួនាទីសំខាន់ និងមានអំណាចក្នុងការសម្រេចចិត្តលើដំណើការអនុម័តលើគោលនយោបាយ មានសារៈសំខាន់ណាស់ ព្រោះវាអាចជួយឱ្យយើងកំណត់បាននូវរបៀប ដែលអាចទាក់ទងជាមួយក្រុមនោះ និងផ្តល់ព័ត៌មានដល់ក្រុមនោះ អំពីគោលបំណងរបស់យើង យ៉ាងមានប្រសិទ្ធភាព ។ ខាងក្រោមនេះគឺជារបៀបនៃការវិភាគទៅលើកម្លាំងនយោបាយ និងការកំណត់នូវតួអង្គសំខាន់ៗក្នុងការធ្វើគោលនយោបាយ[៣២] ។

### ២.១. ការវិភាគលើអ្នកដែលមានសិទ្ធិសម្រេចលើគោលនយោបាយ

- ✠ តើនរណាជាតួអង្គសំខាន់ៗ ?( បុគ្គល ណាខ្លះ ? ស្ថាប័នណាខ្លះ ? )
- ✠ តើតួអង្គនីមួយៗមានតួនាទីអ្វីខ្លះ ក្នុងការធ្វើសេចក្តីសម្រេចចិត្តលើគោលនយោបាយ ?
- ✠ តើមុខងារនៃតួអង្គនីមួយៗ មានឥទ្ធិពលកម្រិតណា ក្នុងការធ្វើសេចក្តីសម្រេចចិត្ត ?

[៣២] កែសំរួលពីឯកសារមេរៀនតស៊ូមតិនៃអង្គការស្តារកម្ពុជា បោះពុម្ពឆ្នាំ១៩៩៩ និងសៀវភៅ ការណែនាំអំពីការតស៊ូមតិ យុទ្ធសាស្ត្រតស៊ូមតិ និងបច្ចេកទេសអភិវឌ្ឍន៍

✠ តើស្ថាប័នណា ឬបុគ្គលណា ដែលផ្តល់អំណាចឱ្យតួអង្គនីមួយៗ ដើម្បីធ្វើការសម្រេចចិត្ត ?

**តារាងកំណត់អំពីកម្លាំងនយោបាយក្នុងការសម្រេចចិត្តលើគោលនយោបាយ**

| តួអង្គសំខាន់ៗ | យល់ព្រម | មិនអាចសម្រេចចិត្តបាន | មិនយល់ព្រម |
|---|---|---|---|
| ព្រះមហាក្សត្រ | ✓ | | |
| សភាជាតិ | | ✓ | |
| នាយករដ្ឋមន្ត្រី | ✓ | | |
| ក្រសួងមហាផ្ទៃ | | ✓ | |
| កងទ័ព | ✓ | | |
| មូលនិធិរូបិយវត្ថុអន្តរជាតិ | | | ✓ |
| ធនាគារពិភពលោក | | ✓ | |
| ធនាគារអភិវឌ្ឍន៍អាស៊ី | | ✓ | |
| អភិបាលខេត្ត | ✓ | | |
| សរុប | ៤ | ៤ | ១ |

## ២.២. ការធ្វើវិភាគលើក្រុមដែលពាក់ព័ន្ធ

✠ តើក្រុមដែលពាក់ព័ន្ធមានចំណាប់អារម្មណ៍យ៉ាងដូចម្តេច ? តើក្រុមនេះអាចមានឥទ្ធិពល ប៉ុណ្ណាលើតួអង្គសំខាន់ៗ ?

✠ តើក្រុមនេះបានកំណត់ អាទិភាពសកម្មភាព និងគោលបំណងរបស់ពួកគេយ៉ាងដូចម្តេច ?

✠ ប៉ាន់ប្រមាណមើលលទ្ធភាពនៃការសហការ និងការឯកភាពលើដំណើរការនៃការតស៊ូមតិ

✠ កំណត់ទិសដៅ និងសកម្មភាព ច្បាស់លាស់ និងកសាងកម្លាំងរួមជាមួយក្រុមនេះ

**ជំហានទី៣** – ការធ្វើវិភាគដំណើរការនៃការរៀបចំបង្កើតគោលនយោបាយ

ដើម្បីកំណត់បានច្បាស់លាស់លើដំណើរការនៃការបង្កើតគោលនយោបាយ យើងគួរប្រើនូវសំណួរដូចខាងក្រោម :

✠ អ្វីទៅជាដំណើរការ ប្រព័ន្ធ និងរចនាសម្ព័ន្ធ នៃការរៀបចំបង្កើតគោលនយោបាយ ?

✠ តើស្ថាប័នណាខ្លះនៃរដ្ឋាភិបាល ដែលពាក់ព័ន្ធ នៅក្នុងការរៀបចំបង្កើតគោលនយោបាយ ?

✠ តើរចនាសម្ព័ន្ធ និងទំនាក់ទំនងផ្លូវការរបស់ពួកគេយ៉ាងដូចម្តេច ?

- តើនៅក្នុងដំណើការនៃការបង្កើតគោលនយោបាយ មានចំណុចណាខ្លះដែលអាចធ្វើអន្តរាគមន៍លើគោលនយោបាយនោះបាន ?
- តើយើងអាចកសាង និងបង្កើនទូវកិច្ចសហការជាមួយនឹងអ្នកធ្វើគោលនយោបាយបានកម្រិតណា? តើនៅក្នុងដំណើរការតស៊ូមតិរបស់យើង នឹងអាចកើតមានបញ្ហាជាមួយ ក្រុមអ្នកធ្វើគោលនយោបាយនោះ ឬទេ ?

**ជំហានទី៤** - ការប៉ាន់ស្មានលើអ្វីដែលនឹងអាចមានការប្រែប្រួល

- តើដំណើរការ នៃការអនុម័តិលើគោលនយោបាយ នឹងអាចមានការផ្លាស់ប្តូរដែរឬទេ ? បើមានតើទំហំ នៃការប្រែប្រួលនោះប៉ុណ្ណា ?
- តើការសហការជាមួយអង្គការ ឬបណ្តាញផ្សេងៗ នឹងមានការប្រែប្រួល ឬទេ?
- តើបរិស្ថាននយោបាយ និងមានការផ្លាស់ប្តូរ ឬទេ ?
- តើឱកាសនៃការធ្វើអន្តរាគមន៍លើគោលនយោបាយ នឹងមានការប្រែប្រួល ឬទេ ?

**ជំហានទី៥** - យុទ្ធសាស្រ្តតស៊ូមតិលើគោលនយោបាយ

- តាមដានស្រាវជ្រាវរកសេចក្តីព្រាងគោលនយោបាយ ( ផ្លូវការក្តី មិនផ្លូវការក្តី )
- អញ្ជើញអ្នកច្បាប់ និងអ្នកដែលពាក់ព័ន្ធ ដើម្បីពិភាក្សាលើគោលនយោបាយនោះ (ចែកចាយសេចក្តីព្រាងគោលនយោបាយដល់ប្រជាពលរដ្ឋ និងសហគមន៍ដែលពាក់ព័ន្ធ ដើម្បីផ្តល់អនុសាសន៍ )
- ចងក្រងអនុសាសន៍ និងអនុម័តលើអនុសាសន៍ ( រៀបចំការប្រជុំ ឬវេទិកា)
- រៀបចំយុទ្ធសាស្រ្តតស៊ូមតិ ( សូមមើល ផ្នែកទី៥ យុទ្ធសាស្រ្តនៃការតស៊ូមតិ)

វាយតម្លៃលើការតស៊ូមតិ ( សូមមើល ផ្នែកទី៦ ការត្រួតពិនិត្យ និងការវាយតម្លៃនៃការតស៊ូមតិ )

# ផ្នែកទី៥

# អំពី

# យុទ្ធសាស្ត្រ

# នៃការតស៊ូមតិ

# ផ្នែកទី៥
# យុទ្ធសាស្ត្រនៃការតស៊ូមតិ

## ១- ហេតុអ្វីបានជាយើងត្រូវធ្វើការតស៊ូមតិ ?

មានហេតុផលជាច្រើន ដែលតម្រូវឱ្យយើងធ្វើការតស៊ូមតិ ។ នៅក្នុងជីវិតរស់នៅរាល់ថ្ងៃ យើងប្រឈមមុខនឹងបញ្ហាជាច្រើន ដែលក្នុងនោះមានភាពក្រីក្របរិស្ថានមានជាតិពុល ពេស្យាចារ និងការជួញដូរគ្រឿងញៀនជាដើម ។ បើយើងពុំបានយកចិត្តទុកដាក់លើបញ្ហាអវិជ្ជមាននេះ វានឹងអាចធ្វើឱ្យប្រជាពលរដ្ឋ សង្គមជាតិ និងពិភពលោកទាំងមូល ធ្លាក់ទៅក្នុងគ្រោះមហន្តរាយដ៏ធ្ងន់ធ្ងរ ថ្ងៃណាមួយជាក់មិនខានឡើយ ។ ហេតុដូច្នេះហើយ ទើបប្រជាពលរដ្ឋ និងសង្គមស៊ីវិលលើពិភពលោក កំពុងនាំគ្នាធ្វើការតស៊ូមតិ ដើម្បីកាត់បន្ថយ និងលុបបំបាត់នូវគ្រោះមហន្តរាយទាំងអស់នេះ ឱ្យបានទាំងស្រុងនៅពេលអនាគត ។




## ២- ការតស៊ូមតិនៅអាស៊ីអគ្នេយ៍

ដូចបានរៀបរាប់ជូនរួចមកហើយថា ការតស៊ូមតិ ត្រូវបានគេឱ្យនិយមន័យផ្សេងៗពីគ្នា ។ ដើម្បីយល់កាន់តែច្បាស់ ខ្ញុំសូមលើកយកចំណុចមួយចំនួនដែលសកម្មជន និងអ្នកវិភាគសង្គមស៊ីវិល បានពិភាក្សា និងឆ្លុះបញ្ចាំងលើការតស៊ូមតិ ជាពិសេសនៅតំបន់អាស៊ីអាគ្នេយ៍យើងនេះ ។

### ២.១. តើការតស៊ូមតិបែបប្រឆាំងតទ៉ា ផ្ទុយនៅនឹងការតស៊ូមតិ បែបកែលំអគម្រង់នយោបាយឬ ?

នៅបណ្តាប្រទេស ដែលអ្នកគ្រប់គ្រងពុំសូវផ្តល់សិទ្ធិឱ្យប្រជាពលរដ្ឋ ចូលរួមក្នុងកិច្ចការនយោបាយ ចលនានៃការតស៊ូមតិនៅមានកម្រិតទាប អ្នកតស៊ូមតិជួបបញ្ហាលំបាកជាច្រើន ។ គេរៀបចំសកម្មភាព ឬចលនា របស់គេតាមរបៀបសម្ងាត់ ហើយម្តងម្កាលចេញមុខប្រឆាំងជាមួយរដ្ឋាភិបាលត្រង់ៗតែម្តង ។ ចលនា

នេះ ភាគច្រើនពុំសូវទទួលបានលទ្ធផលជាវិជ្ជមានទេ ហើយជារឿយៗតែងតែទទួលនូវការបង្ក្រាប និងសម្លាប់ពីរដ្ឋាភិបាលផ្តាច់ការនោះថែមទៀតផង ។ ប៉ុន្តែការតស៊ូមតិបែបនេះ មានសារៈសំខាន់ណាស់ពីព្រោះថា វាជាចលនាមួយ ដែលជួយឱ្យមានការចាប់ផ្តើមការអនុវត្តលទ្ធិប្រជាធិបតេយ្យនៅក្នុងប្រទេសនោះ ។ ចលនាលុបបំបាត់នូវរបបផ្តាច់ការ ឬរបបដែលគាបសង្កត់ប្រជាជនបែបនេះគេហៅថា ការតស៊ូមតិបែបប្រឆាំងតវ៉ា ។

ចំណែកនៅប្រទេសដែលមានលទ្ធភាព ក្នុងការពិភាក្សាចរចា ដើម្បីកែលំអប្រព័ន្ធដឹកនាំ ការតស៊ូមតិភាគច្រើន ធ្វើឡើងដើម្បីកែលំអទម្រង់នយោបាយ ។ ការតស៊ូមតិបែបនេះ គេហៅថា ការតស៊ូមតិបែបកែលំអទម្រង់នយោបាយ ។ ការតស៊ូមតិកែលំអទម្រង់នយោបាយច្រើនតែធ្វើឡើង តាមរយៈការសហការជាមួយរដ្ឋាភិបាល ឬរដ្ឋ ដើម្បីបង្កើតនូវកម្មវិធី ឬគោលនយោបាយរួមគ្នា ។ ប៉ុន្តែដើម្បីឱ្យការងារនេះ ប្រព្រឹត្តទៅប្រកបដោយជោគជ័យ លុះត្រាតែអង្គការមិនមែនរដ្ឋាភិបាល ឬក្រុមសង្គមស៊ីវិលនោះចេះបង្កើត ឬមានបទពិសោធន៍យ៉ាងស្ទាត់ជំនាញ លើការទិតៀន លើរចនាសម្ព័ន្ធគ្រប់គ្រងរបស់រដ្ឋ ដែលកំពុងដំណើរការ ហើយចេះបង្កើតនូវជំរើសល្អៗ ដែលនាំមកនូវភាពរីកចម្រើន និងអាចទទួលយកបានដោយរដ្ឋាភិបាល ។ បើពុំដូច្នោះទេ ការតស៊ូមតិបែបនេះ ជួនកាលអាចបរាជ័យ ក្នុងការធ្វើឱ្យមានការកែប្រែទម្រង់នយោបាយ ហើយក្លាយទៅ ជារណប ឬចូលរួមគាំទ្រប្រព័ន្ធ របស់រដ្ឋាភិបាល ដោយចេតនា ឬអចេតនាទៀតផង ។

តាមបទពិសោធន៍កន្លងមក យើងពុំដែលសង្កេតឃើញមានប្រព័ន្ធណាពិសេសជាងប្រព័ន្ធណាឡើយ ហើយក៏ពុំដែលឃើញមានខ្សែសង្វាក់ទាក់ទងគ្នា រវាងការតស៊ូមតិបែបការប្រឆាំងតវ៉ាទៅនឹងការតស៊ូមតិបែបកែលំអទម្រង់នយោបាយឡើយ ។ ប៉ុន្តែជោគជ័យ ឬមិនជោគជ័យ គឺអាស្រ័យលើបច្ចេកទេសទេពកោសល្យភាពប៉ិនប្រសប់ និងយុទ្ធសាស្ត្ររបស់អ្នកតស៊ូមតិ ដែលក្នុងនោះមានធាតុពីរសំខាន់ គឺ**ភាពអាចបត់បែនបានតាមសភាពការណ៍ និងភាពប៉ិនស្រប់ក្នុងការផ្តួចផ្តើមគំនិតថ្មី ឬទេពកោសល្យក្នុងការធ្វើជាដៃគូជាមួយរដ្ឋ និងសង្គមស៊ីវិល** ។

## ២.២. ការតស៊ូមតិដើម្បីឱ្យមានការកែប្រែគោលការណ៍ច្បាប់ ឬទម្រង់នយោបាយ

ការតស៊ូមតិ គឺជាបាតុភូតធម្មជាតិ ដូចពាក្យខ្មែរថា ទីណាមានការជិះជាន់ ទីនោះត្រូវតែមានការតស៊ូ ។ ដូច្នេះការតស៊ូមតិគឺជាសកម្មភាព ដោយសន្តិវិធីមួយ ដែលជួយអ្នកទន់ខ្សោយ ឱ្យពួកគេអាចរស់រានមានជីវិតមានជីវភាពសមរម្យ តាមរយៈការផ្តល់សិទ្ធិអំណាច និងបង្រៀនឱ្យពួកគេអាចដោះស្រាយបញ្ហាដោយខ្លួនឯង ។ ទស្សនៈនេះ គឺជាមូលដ្ឋានមួយដែលអាចបញ្ជាក់បានថា ភាពក្រីក្រមិនអាចក្លាយទៅជាទម្លាប់ ឬជាច្បាប់ដែលថា ពូជអ្នកក្រត្រូវតែក្រ ពូជអ្នកមានត្រូវតែមាននោះទេ ។ មនុស្សគ្រប់រូប ត្រូវតែមានសិទ្ធិសេរីភាពរស់រានមានជីវិតស្មើៗគ្នា និងរស់នៅក្រោមច្បាប់តែមួយដូចៗគ្នា ។ នៅក្នុងប្រទេសក្រីក្រ អ្នកមាន មានត្រឹម

តែ២០%ប៉ុណ្ណោះ ។ ចំណែកអ្នកក្រមាន មានរហូតទៅ ដល់៨០% ហេតុអ្វី អ្នកក្រនៅតែទទួលនូវការគាបសង្កត់ពីអ្នកមាន ? ដូច្នេះ យើងត្រូវធ្វើយ៉ាងណា ឱ្យអំណាចរវាង អ្នកមាន និងអ្នកក្រ មានទំនាក់ទំនងគ្នាបែបសមធម៌ សមភាព និងតុល្យភាពបំផុត ។ តាមបទពិសោធន៍នៅប្រទេសនានា អ្នកក្រអាចប្រើអំណាចរបស់ខ្លួនជាបឋម តាមរយៈការចូលរួមការងារ អភិវឌ្ឍន៍របស់អង្គការមិនមែនរដ្ឋាភិបាល ។ ការចូលរួមនេះយូរៗទៅបានក្លាយទៅជាសកម្មភាពមួយ ដែលមានឥទ្ធិពលទៅលើគោលនយោបាយរដ្ឋាភិបាល ។

ក្នុងការទាមទារអំណាចជូនអ្នកក្រីក្រនេះ អ្នកតស៊ូមតិ ( អង្គការមិនមែនរដ្ឋាភិបាល) បានជួបប្រទះ ការលំបាកយ៉ាងខ្លាំង ពីព្រោះវាជាការងារមួយថ្មី ហើយតែងតែប្រឈមមុខជាមួយនឹងជនដែលអាងខ្នងបង្អែក ឬក៏ជនដែលប្រើអំណាចផ្តាច់ការ ។ អ្នកតស៊ូមតិ តែងតែទទួលរងនូវការគំរាមកំហែង កាប់សម្លាប់ចាប់ដាក់ពន្ធនាគារដោយខុសច្បាប់ ។ល។ ជាក់ស្តែងបច្ចុប្បន្ននេះ ជាពិសេសនៅប្រទេសខ្មែរយើងតែម្តង គេនៅតែយល់ច្រឡំថា អ្នកធ្វើការតស៊ូមតិ គឺជាអ្នកប្រឆាំងជាមួយនឹងរដ្ឋាភិបាល ។ ដូច្នេះអ្នកធ្វើការតស៊ូមតិ ក៏ប្រហាក់ប្រហែលទៅនឹងអ្នកកាសែត ឬអ្នកធ្វើនយោបាយដែរ ដូចពាក្យមួយឃ្លាពោលថា បើមិនស្លាប់ខ្លួន ក៏ជាប់គុក ឬក៏រត់ចោលស្រុក ។ ប៉ុន្តែទោះបីជាមានការឱ្យនិយមន័យ ផ្សេងៗពីគ្នាយ៉ាងណាក៏ដោយ ក៏ការតស៊ូមតិមានប្រយោជន៍ និងមានលទ្ធផលច្រើនជាងការបង្កសង្គ្រាម ប្រឆាំងនឹងអ្នកមានអំណាច ឬជនផ្តាច់ការ ហើយថែមទាំងកាត់បន្ថយនូវអំពើហិង្សា និងការស្លាប់បាត់បង់ជីវិតដោយគ្មានហេតុផល ។

ដើម្បីកាត់បន្ថយនូវគ្រោះថ្នាក់ខាងលើ និងដើម្បីធ្វើការតស៊ូមតិទទួលបានជោគជ័យ អ្នកតស៊ូមតិ ត្រូវការបណ្តុះបណ្តាលហើយ វគ្គបណ្តុះបណ្តាលនោះត្រូវតែឆ្លើយតបទៅនឹងសភាពការណ៍នយោបាយនៃប្រទេសដែលអ្នកតស៊ូមតិនោះកំពុងតែធ្វើ ព្រោះគ្មាននរណាម្នាក់ ឬប្រទេសណាមួយ ដែលអាចបង្កើតមេរៀនតែមួយដើម្បីជាគំរូសំរាប់ទាំងអស់គ្នាដើម្បីធ្វើការតស៊ូមតិនោះឡើយ ។ ប៉ុន្តែទោះបីយ៉ាងណាក៏ដោយ ការរៀនសូត្រពីគ្នាទៅវិញទៅមកនៅតែមានសារៈសំខាន់ ។

ខាងក្រោមនេះ ខ្ញុំនឹងលើកជូននូវបទពិសោធន៍មួយចំនួន ដែលធ្លាប់បានអនុវត្តប្រកបដោយជោគជ័យដោយអង្គការមិនមែនរដ្ឋាភិបាលមួយចំនួននៅក្នុងតំបន់អាស៊ីអាគ្នេយ៍យើងនេះ ។ គន្លឹះសំខាន់ដែលគេប្រើសំរាប់ការតស៊ូមតិរួមមាន ឧបករណ៍ ការវិភាគ ( ការធ្វើផែនទីនយោបាយ ដែលត្រូវដើរ ឬក៏វិភាគលើគោលការណ៍សេដ្ឋកិច្ច) ហើយនិងបច្ចេកទេសនៃការតស៊ូមតិស្រាវជ្រាវ ជាមួយបណ្តាញព័ត៌មាន ការបង្កើតសម្ព័ន្ធបណ្តាញផ្សេងៗជាដើម ។

ការតស៊ូមតិទទួលជោគជ័យបានភាគច្រើន ក្នុងស្ថានភាពដែលអ្នកនយោបាយ ព្រមទទួលគំនិតថ្មី ដែលលើកឡើងដោយសង្គមស៊ីវិល ។ នៅពេលនោះ តួនាទីរបស់សង្គមស៊ីវិល និងរាជរដ្ឋាភិបាលត្រូវបានបែងចែក

យ៉ាងច្បាស់ ។ រីឯសង្គមស៊ីវិលមានតួនាទីជាអ្នកឃ្លាំមើលរដ្ឋាភិបាល ឯរដ្ឋាភិបាលមានតួនាទីជាអ្នកអនុវត្ត និងអភិវឌ្ឍប្រទេសជាតិឱ្យមានការរីកចម្រើន ។ ប្រទេសភាគច្រើននៅអាស៊ីអាគ្នេយ៍ ដែលទើបរំដោះរួចពីលទ្ធិផ្តាច់ការជាច្រើនទសវត្សរ៍មកហើយនោះ ការតស៊ូមតិនៅមានកម្រិត ហើយត្រូវការការប្រឹងប្រែងយ៉ាងខ្លាំង។ នៅប្រទេសមួយចំនួននៅអាស៊ីអាគ្នេយ៍យើង ការតស៊ូមតិទទួលបានជោគជ័យ គឺការបង្កើតឱ្យមានចលនាសង្គមស៊ីវិល ឬគណបក្សនយោបាយ ។ គួរកត់សម្គាល់ផងដែរថា ការតស៊ូមតិ ពុំមែនមានន័យត្រឹមតែការធ្វើឱ្យមានការផ្លាស់ប្តូរនៅក្នុងស្ថាប័នរដ្ឋប៉ុណ្ណោះទេ ប៉ុន្តែការតស៊ូមតិ ក៏ត្រូវតែធ្វើឱ្យមានការផ្លាស់ប្តូរនៅក្នុងស្ថាប័នសង្គមស៊ីវិលខ្លួនឯងផ្ទាល់ផងដែរ ។ នេះទើបហៅថា លទ្ធិប្រជាធិបតេយ្យបែបចូលរួមពិត។ ។

## ២.៣. យុទ្ធសាស្ត្រក្នុងការផ្លាស់ប្តូរឥរិយាបថ នៃជនមានអំណាច ក្រុម ឬស្ថាប័ននានាដែលរំលោភលើអ្នកដទៃ

ការតស៊ូមតិដ៏មានប្រសិទ្ធភាព ដើម្បីធ្វើការផ្លាស់ប្តូរឥរិយាបថអ្នកមានអំណាចដែលតែងតែរំលោភលើអ្នកទន់ខ្សោយនោះគឺ :

- យើងត្រូវទំនាក់ទំនងឱ្យបានជិតស្និទ្ធជាមួយអ្នកមានអំណាច ដោយធ្វើយ៉ាងណាឱ្យអ្នកមានអំណាចនោះ បានយល់អំពីទង្វើរបស់ខ្លួន ដែលប៉ះពាល់ដល់សង្គមទាំងមូល ហើយឱ្យអ្នកមានអំណាចនោះកែសម្រួលគោលនយោបាយ និងឥរិយាបថរបស់ខ្លួន និងគិតអំពីផលប្រយោជន៍អ្នកក្រីក្រ ឬអ្នកទន់ខ្សោយជាធំ
- ប្រមែប្រមូល និងចងក្រងអ្នកទន់ខ្សោយ ហើយណែនាំ និងបណ្តុះបណ្តាលពួកគេ ឱ្យយល់ដឹងអំពីការតស៊ូមតិដែលមានប្រសិទ្ធភាព ដើម្បីធ្វើយ៉ាងណាឱ្យជនដែលមានអំណាចទាំងនោះ កែប្រែនូវគោលនយាបាយរបស់ខ្លួន ហើយទទួលយកនូវគំនិតដែលត្រឹមត្រូវរបស់អ្នកទន់ខ្សោយ ឬអ្នកក្រីក្រ
- ប្រើប្រាស់បណ្តាញឃោសនាព័ត៌មាន និងប្រព័ន្ធផ្សព្វផ្សាយដទៃ។ទៀត ដើម្បីឱ្យសាធារណជនបានយល់ដឹងអំពីបញ្ហា ដែលកំពុងកើតមានឡើង ឬអំពើមិនគប្បីរបស់អ្នកមានអំណាចដល់សាធារណជន លោកបានជ្រាប ហើយស្ម័គ្រចិត្តរួមកម្លាំងគ្នា ដើម្បីជំរុញជននោះ ឱ្យកែប្រែនយោបាយរបស់ខ្លួន ឬចុះពីដំណែង ហើយត្រឡប់មកគាំទ្រជនក្រីក្រ ឬអ្នកទន់ខ្សោយវិញ ។

យុទ្ធសាស្ត្រខាងលើ ត្រូវបានសកម្មភាពតស៊ូមតិសង្គមស៊ីវិលយកទៅប្រើ ហើយទទួលបានជោគជ័យទាំងការតស៊ូមិតិថ្នាក់មូលដ្ឋាន និងជាតិ ទទួលបានជោគជ័យ ។ ឧទាហរណ៍ បណ្តាញតស៊ូមតិកំពង់ចាមបានសហការជាមួយប្រជាពលរដ្ឋនៅតំបន់ទឹកឆាបានទាមទារដី ជាងមួយរយហិកតា ដែលជនមានអំណាចបានរំលោភយកដោយយកលេសថា រដ្ឋត្រូវការដីនោះដើម្បីធ្វើការអភិវឌ្ឍន៍ ។ ដោយឡែកអង្គការមិនមែន

រដ្ឋាភិបាល និងអង្គការមហាជននៅប្រទេសហ្វីលីពីន បានទំនាក់ទំនងយ៉ាងជិតស្និទ្ធជាមួយនឹងស្ថាប័ន រដ្ឋសភា បណ្តាញព័ត៌មាន និងស្ថាប័នផ្សេងៗ រួមគ្នាធ្វើការទម្លាក់លោក អាស្ត្រាដា ប្រធានាធិបតីនៃប្រទេសហ្វីលីពីន នៅឆ្នាំ១៩៩?? ។ នៅប្រទេសឥណ្ឌូណេស៊ី ក្នុងឆ្នាំ១៩៩??? និស្សិតរាប់ពាន់នាក់ បានធ្វើបាតុកម្ម ប្រឆាំងនឹងការប្រើអំណាចផ្តាច់ការរបស់លោក ស៊ូហារតូ រហូតដល់បានជោគជ័យ ។ និស្សិតថៃបានចេញទៅរស់នៅ ជាមួយប្រជាពលរដ្ឋ ដើម្បីចងក្រងបណ្តាញជាមួយប្រជាជន ហើយបានរួមគ្នានៅទីក្រុងបាងកក ហើយទទួលបានជោគជ័យ ក្នុងការទម្លាក់ នាយករដ្ឋមន្ត្រី សុចិន្តា ក្រាប្រាយូន ពីតំណែង នៅឆ្នាំ ១៩៩២ ។




នៅប្រទេសកម្ពុជាយើង ការធ្វើឱ្យមានការកែប្រែទៅលើគោលនយោបាយ គឺជាសកម្មភាពគន្លឹះមួយនៅក្នុងការតស៊ូមតិ ។ ពាក្យគោលនយោបាយនៅទីនេះ រាប់បញ្ចូលទាំងច្បាប់ និងបទបញ្ជាផ្សេងៗ ដែលរដ្ឋាភិបាលកំពុងតែរៀបចំ និងអនុវត្ត ។ រដ្ឋាភិបាលមានតួនាទី និងអំណាចក្នុងការធ្វើសេចក្តីសម្រេចចិត្តលើគោលនយោបាយទាំងនោះ ។ ដូច្នេះនៅពេលដែលរដ្ឋាភិបាល បានកំណត់គោលនយោបាយណាមួយ វាប្រាកដថា គោលនយោបាយនោះ មានឥទ្ធិពលជាវិជ្ជមាន ឬអវិជ្ជមាន ទៅលើប្រជាពលរដ្ឋ ។ ប្រជាពលរដ្ឋ ទោះបីចង់ ឬមិនចង់ ត្រូវតែអនុវត្តទៅតាមគោលនយោបាយនោះ ។ នៅក្នុងបរិបទតស៊ូមតិ ប្រសិនបើគោលនយោបាយនោះ មិនបំរើផលប្រយោជន៍ឱ្យប្រជាពលរដ្ឋទេ ការតវ៉ានឹងកើតមានឡើង ។ ជាការពិតណាស់ការតស៊ូមតិភាគច្រើន គឺកើតមានជាមួយរដ្ឋាភិបាល ប៉ុន្តែការតស៊ូមតិ ក៏កើតមានឡើងជាមួយស្ថាប័នឯកជនក្រុមសាសនា ព្រមទាំងក្រុមសង្គមស៊ីវិលផងដែរ ។ និយាយជារួមការតស៊ូមតិធ្វើចំពោះ ក្រុមណាដែលធ្វើឱ្យប៉ះពាល់ដល់ផលប្រយោជន៍សាធារណៈ ដោយខុសច្បាប់ទោះអ្នកនោះក្រុម ឬបុគ្គលក៏ដោយ ។

### យុទ្ធសាស្ត្រនៃការតស៊ូមតិ

| | |
|---|---|
| ការតស៊ូបញ្ចុះបញ្ចូល | ធ្វើការជាមួយតុលាការ (ការពារ និង រៀបចំពាក្យបណ្តឹង) |
| រៀបចំយុទ្ធនាការ និងទំនាក់ទំនងជាមួយព័ត៌មាន | ស្រាវជ្រាវ និងវិភាគគោលនយោបាយ |
| ចងក្រងបណ្តាញ និងបង្កើតសម្ព័ន្ធភាព | សកម្មភាពអង្គការមហាជន និង បាតុកម្ម |
| ការអប់រំអំពីនយោបាយ និងដំណឹងផ្សេងៗ | |

## ៣- ទស្សនះលើការរៀបចំផែនការតស៊ូមតិ

អ្នកជំនាញខាងតស៊ូមតិមួយចំនួន និយាយថា ការតស៊ូមតិជាការងារដើរទៅមុខពីរជំហាន ហើយថយក្រោយមួយជំហាន[៣៣] ។ ដូច្នេះការងារតស៊ូមតិត្រូវតែមានយុទ្ធសាស្ត្រដកថយ និងសំរុកទៅមុខហើយការធ្វើផែនការតស៊ូមតិជាតម្រូវការចាំបាច់ ដើម្បីរៀបចំនូវយុទ្ធសាស្ត្រទាំងនេះ ។ លីហ្សា វេនេក្លាសេន និងវ៉ាឡេរីមីល័រ អ្នកនិពន្ធសៀវភៅក្រោមចំណងជើងថាប្រជាជន និងនយោបាយ បានឱ្យនិយមន័យលើការធ្វើផែនការនៃការតស៊ូមតិថា ជាការរៀបចំឱ្យមាន : ១-យុទ្ធសាស្ត្ររួម ២-យុទ្ធនាការ ៣-មធ្យោបាយ (គាត់ទិច និងសកម្មភាព) និង ៤-ការវាស់វែង នូវឥទ្ធិពល

ការធ្វើផែនការតស៊ូមតិ មិនដូចការធ្វើផែនការសំរាប់កម្មវិធីអភិវឌ្ឍន៍នោះឡើយ ។ ការធ្វើផែនការ

[៣៣] សៀវភៅណែនាំ ស្តីពីយុទ្ធសាស្ត្រនៃការតស៊ូមតិ និងបច្ចេកទេសអភិវឌ្ឍន៍ បោះពុម្ពឆ្នាំ២០០៣

តស៊ូមតិ ត្រូវតែជាផែនការយុទ្ធសាស្ត្រ មានការស្រាវជ្រាវច្បាស់លាស់លើបញ្ហា ហើយត្រូវមាន ទាំងរយៈពេលវែង និងខ្លីទៀតផង ។

និយាយជារួមការធ្វើផែនការតស៊ូមតិជាទូទៅ ទាមទារឱ្យមានការយកចិត្តទុកដាក់ និងហ្មត់ចត់ ពីព្រោះថា អ្នកតស៊ូមតិជានិច្ចជាកាលតែងតែធ្វើការតវ៉ាជាមួយអ្នកមានអំណាច ឬដៃគូប្រឆាំង ។ ខាងក្រោមនេះជាជំហានធ្វើផែនការតស៊ូមតិសាមញ្ញមួយ ដែលអាចជួយលោក អ្នកអាចកំណត់ថាយើងជានរណា? អ្វីដែលយើងចង់បាន ? និងតើយើងត្រូវធ្វើយ៉ាងណាដើម្បីសម្រេចនូវអ្វីដែលយើងចង់បាន ។



## ៤-ជំហានទាំងប្រាំបី នៃការធ្វើផែនការតស៊ូមតិ

### ៤.១. ទិសដៅ និងគោលបំណង

ដើម្បីរៀបចំគោលដៅ និងគោលបំណងឱ្យបានជាក់លាក់ យើងគួរប្រើសំនួរដូចមានខាងក្រោមជាជំនួយ :

- ✠ តើយើងចង់បានអ្វី ?
- ✠ តើបញ្ហាអ្វីដែលយើងចង់ដោះស្រាយ ?
- ✠ តើអ្វីដែលយើងត្រូវដឹង ?
- ✠ តើយើងត្រូវប្រមូលព័ត៌មាននោះយ៉ាងដូចម្តេច ?
- ✠ តើគោលដៅ និងគោលបំណងដែលយើងចង់បាន សមនឹងសមត្ថភាព និងធនធានដែលយើងមាន ឬទេ?

> គោលដៅ ជាធម្មតា ទូលំទូលាយជាងគោលបំណង តែច្បាស់លាស់ជាងទស្សនៈ ។ ឧទាហរណ៍ បើគោលដៅ យើងលើកតម្កើងយេនឌ័រនៅកម្ពុជា គោលបំណងរបស់យើង ត្រូវតែជំរុញឱ្យមានសិទ្ធិស្មើគ្នា រវាងបុរស នឹងស្ត្រីនៅ ភូមិ "ក" ។

ត្រូវចងចាំថា ការធ្វើផែនការតស៊ូមតិ គោលដៅត្រូវតែបំបែកឱ្យល្អិតល្អន់ ជាងឧទាហរណ៍ ខាងលើ

ហើយមិនត្រូវព្យាយាមដោះស្រាយបញ្ហាទូទៅឡើយ ។ មានន័យថា គោលដៅរបស់យើងត្រូវផ្តោតទៅលើតែបញ្ហាដែលកំពុងប៉ះពាល់ដល់ខ្លួនយើង និងក្រុមគោលដៅរបស់យើងតែប៉ុណ្ណោះ ។ កាលណាយើងធ្វើគោលដៅបានលម្អិត យើងអាចបង្កើតបាននូវគោលបំណងត្រឹមត្រូវដែលអាចជួយឱ្យយើង រៀបចំសកម្មភាពជាក់លាក់លទ្ធផលរំពឹងទុក និងឥទ្ធិពលដែលអាចវាស់វែង បានទុកចិត្តបាន អាចទទួលជោគជ័យបានតាមពេលវេលា ដែលបានគ្រោងទុក ។

### ៤.២. ការកំណត់ក្រុមគោលដៅ

- ✠ តើអ្នកណា ឬស្ថាប័នណា ដែលយើងត្រូវធ្វើការតស៊ូមតិ ?
- ✠ តើដំណើរការផ្លូវការ ឬមិនផ្លូវការក្នុងការដោះស្រាយ បញ្ហារបស់គេយ៉ាងដូចម្តេច ?
- ✠ តើលក្ខណៈពិសេស ឬឥរិយាបថ របស់អ្នកដែលយើងនឹងធ្វើការតស៊ូមតិ នោះយ៉ាងដូចម្តេច?
- ✠ តើយើងនឹងមានឧបសគ្គអ្វីខ្លះក្នុងការតស៊ូមតិជាមួយក្រុមនោះ ?
- ✠ តើស្ថាប័នណាខ្លះ ដែលយើងត្រូវកំណត់យកសំរាប់ជួយគាំទ្រការតស៊ូមតិរបស់យើង? ស្ថាប័នរដ្ឋសភា ? ក្រសួងណា ?
- ✠ តើអ្នកធ្វើយ៉ាងដូចម្តេច ដើម្បីធ្វើឱ្យស្ថាប័នខាងលើនេះ គាំទ្រការតស៊ូមតិរបស់អ្នក ?

ដើម្បីរើសក្រុមគោលដៅតស៊ូមតិបានត្រឹមត្រូវ សូមប្រើតារាងខាងក្រោម ៖

**តារាងទី១. ការបែងចែកក្រុមគោលដៅតស៊ូមតិ**

| អ្នកមានសិទ្ធិសម្រេចមិនផ្លូវការ | អ្នកមានសិទ្ធិសម្រេចផ្លូវការ | អ្នកជួយដាក់សម្ពាធ |
|---|---|---|
| | | |
| | | |
| | | |
| | | |

តារាងទី២. ចំណាត់ថ្នាក់ក្រុមគោលដៅតស៊ូមតិ

| ការវិនិច្ឆ័យ | អ្នកមានសិទ្ធិសម្រេចផ្លូវការ | អ្នកមានសិទ្ធិសម្រេចមិនផ្លូវការ | អ្នកជួយដាក់សម្ពាធ |
|---|---|---|---|
| សំខាន់បំផុត | | | |
| មិនសូវសំខាន់ | | | |
| មិនសំខាន់សោះ | | | |

តារាងទី៣. ការវាយតម្លៃលើក្រុមគោលដៅតស៊ូមតិ

| ការវិនិច្ឆ័យ | អ្នកមានសិទ្ធិសម្រេចផ្លូវការសំខាន់បំផុត | អ្នកមានសិទ្ធសម្រេចមិនផ្លូវការសំខាន់បំផុត | អ្នកដាក់សម្ពាធសំខាន់បំផុត |
|---|---|---|---|
| អ្នកដែលគាំទ្រខ្លាំង | | | |
| អ្នកដែលគាំទ្រល្មម | | | |
| អ្នកដែលគាំទ្រខ្លាំង | | | |
| អ្នកដែលនៅកណ្តាល | | | |
| អ្នកប្រឆាំងល្មម | | | |
| អ្នកប្រឆាំងខ្លាំង | | | |

តារាងទី៤. ការប្រៀបធៀបរវាងអ្នកមានសិទ្ធិសម្រេច និងអ្នកជួយដាក់សម្ពាធ

អ្នកមានសិទ្ធិសម្រេច ជាអ្នកដែលគេប្រគល់សិទ្ធិផ្លូវការ រឺមិនផ្លូវការក្នុងការធ្វើការសម្រេចលើគោលនយោបាយ ឬដោះស្រាយបញ្ហា ។ អ្នកជួយដាក់សម្ពាធ ជាអ្នកដែលមានឥទ្ធិពល ឬដាក់សម្ពាធទៅលើអ្នកសម្រេចចិត្តឬជាអ្នកផ្សេងៗទៀត ដែលអាចដាក់សម្ពាធលើអ្នកសម្រេចចិត្ត តាមរយៈការប្រមូលមតិពីសាធារណជន ឧទាហរណ៍ ដូចជាបណ្តាញព័ត៌មាន អង្គការសង្គមស៊ីវិលជាដើម ។ ពេលខ្លះ អ្នកដាក់សម្ពាធ មានឥទ្ធិពលយ៉ាងខ្លាំង រហូតអាចក្លាយទៅជាអ្នក ដែលមានសិទ្ធិសម្រេចមិនផ្លូវការ នៅក្នុងដំណើរការរៀបចំគោលនយោបាយទៀតផង ។

ដើម្បីកំណត់បាន នូវក្រុមដែលប្រឆាំង និងគាំទ្រយើង យើងត្រូវប្រើសំណួរដូចខាងក្រោម ៖

✠ តើក្រុមមួយណា ឬបុគ្គលមួយណា ដែលទទួលរងនូវបញ្ហាដូចយើង ឬមានការចាប់អារម្មណ៍លើបញ្ហារបស់យើង?

✠ តើយើងអាចធ្វើការជាមួយពួកគេបានឬទេ?

✠ តើក្រុមណានឹងបានផលប្រយោជន៍ពីការតស៊ូមតិរបស់យើង? តើក្រុមណាដែលនឹងទទួលនូវផលប៉ះពាល់ពីការតស៊ូមតិរបស់យើង?

ក្នុងការកំណត់នូវក្រុមអ្នកដែលគាំទ្រយើង និងអ្នកដែលប្រឆាំងជាមួយនឹងយើង យើងត្រូវវិភាគឱ្យបានហ្មត់ចត់ ហើយត្រូវមានព័ត៌មានគ្រប់គ្រាន់ ពីព្រោះថា ក្នុងកាលៈទេសៈណាមួយនោះ ក្រុមដែលយើងគិតថានឹងប្រឆាំងនឹងយើងស្រាប់តែបែរជាមកគាំទ្រយើងវិញ ហើយក្រុមដែលយើងគិតថា នឹងគាំទ្រយើងបែរជាមកប្រឆាំងជាមួយយើងវិញ ។ ឧទាហរណ៍ អ្នកតំណាងរាស្ត្រគណបក្ស កំពុងកាន់កាប់អំណាចមួយ ពុំព្រមគាំទ្រនូវការស្នើផ្តួចផ្តើមសុំឱ្យមានការអនុម័តលើច្បាប់ពុករលួយរបស់សង្គមស៊ីវិលឡើយ តែនៅពេលដែលតំណាងរាស្ត្ររូបនោះ ត្រូវបានប្រធានរបស់គាត់បញ្ឈប់ពីគណបក្សហើយ បន្ទាប់មកគាត់មកចូលបំរើក្នុងគណបក្សប្រឆាំង អ្នកតំណារាស្ត្ររូបនេះ បែរជាមកគាំទ្រនូវគំនិត ដែលផ្តួចផ្តើមនោះទៅវិញ ។ ឧទាហរណ៍មួយទៀត មានប្រជាជនពីរបីភូមិ រស់នៅតាមបណ្តោយព្រែកមួយ ហើយនៅលើខ្សែទឹកនៃព្រែកនោះ មានចំការដំណាំឧស្សាហកសិកម្ម ដែលប្រើថ្នាំពុលសម្លាប់សត្វល្អិត។ ប្រជាជននៅទីនោះ បានតវ៉ាទៅចៅសង្កាត់ថាពួកគេមានជំងឺដោយសារថ្នាំពុល ដែលប្រើសំរាប់ដំណាំនោះ ។ ដោយចៅសង្កាត់ នៅទីនោះបានទទួលសំណូកពីក្រុមហ៊ុនឯកជន ហើយគាត់ក៏បានដាំដំណាំនោះដែរ គាត់ពុំពេញចិត្តនឹងការតវ៉ារបស់ប្រជាពលរដ្ឋនោះឡើយ ហើយគាត់បានចេញនូវសេចក្តីថ្លែងការណ៍មួយថា ការតវ៉ាពុំមានហេតុផលច្បាស់លាស់ ។ ពេលនោះយើងគិតថាគាត់ជាភាគីប្រឆាំង ។ ប៉ុន្តែក្រោយមក លោកចៅសង្កាត់បានផលពីការដាំដំណាំរបស់គាត់ ហើយគាត់ចង់សង់ផ្ទះ នៅតាមមាត់ស្ទឹងដែលទឹកមានជាតិពុល តែចង់ឱ្យទឹកស្ទឹងនោះមានភាពល្អបរិសុទ្ធ ។ ពេលនោះគាត់បែរជាគាំទ្រចលនារបស់ប្រជាពលរដ្ឋវិញ ក្រោយពីគាត់ពុំអាចប្រើប្រាស់ទឹកនោះបាន ។

## ៤.៣. ការវិភាគលើបរិស្ថានខាងក្រៅ

សំនួរដែលគួរប្រើសម្រាប់ការវិភាគបរិស្ថានខាងក្រៅមានដូចខាងក្រោម ៖

✠ តើការប្រែប្រួលនៃសភាពការណ៍នយោបាយអាចនឹងធ្វើឱ្យប៉ះពាល់ ឬមានផលប្រយោជន៍ ដល់ការតស៊ូមតិរបស់យើង ឬទេ ? តើយើងមានសមត្ថភាព ឬលទ្ធភាព ដើម្បីឆ្លើយតបទៅសភាពការណ៍នោះទេ ? តើយើងនឹងត្រូវប្រឈមមុខនឹងគ្រោះថ្នាក់ដែរ ឬទេ ?

✠ តើនឹងមានប្រតិកម្មអ្វីខ្លះ ឬការគាំទ្រកម្រិតណា ពីសាធារណជន នៅពេលដែលយើងអនុវត្តការតស៊ូមតិ ?

## ៤.៤. ការប៉ាន់ប្រមាណលើសមត្ថភាព និងធនធានរបស់យើង

✠ តើយើងមានព័ត៌មានទាក់ទងទៅនឹងការតស៊ូមតិ និងធនធានមនុស្សគ្រប់គ្រាន់ ឬទេ ? តើប្រសិទ្ធភាពនៃការទំនាក់ទំនងរបស់យើងឋិតនៅកម្រិតណា ?

✠ តើធនធានអ្វីខ្លះដែលយើងត្រូវការ ហើយតើយើងត្រូវយកធនធាននោះពីណា ?

✠ តើយុទ្ធសាស្ត្រអ្វីខ្លះ ដែលយើងយកមកប្រើ ដើម្បីឱ្យដំណើរការតស៊ូមតិរបស់យើងឈានទៅមុខបាន ?

✠ តើគោលបំណងរយៈពេលខ្លីណាខ្លះ ដែលអាចជួយឱ្យយើងសម្រេចជោគជ័យបាន ?

✠ តើធ្វើការវាយតម្លៃយ៉ាងដូចម្តេច លើយុទ្ធសាស្ត្រ គាក់ទិក និងការអភិវឌ្ឍន៍នៃការងាររបស់យើង ?

✠ តើយើងធ្វើការវាយតម្លៃប៉ុន្មានដង? តើយើងវាយតម្លៃលើជោគជ័យយ៉ាងដូចម្តេច ?

ដើម្បីធ្វើផែនការយុទ្ធសាស្ត្រ យើងត្រូវយល់ដឹងថា តើអ្វីទៅជាយុទ្ធសាស្ត្រ និងអ្វីទៅជាសកម្មភាព ។ សកម្មភាពគឺដំណើរការជាក់លាក់មួយ ឧទាហរណ៍ ការរៀបចំបាតុកម្ម ឬការចូលជួបពិភាក្សាជាមួយអ្នកច្បាប់ ឬអ្នកតំណាងរាស្ត្រជាដើម ។ ចំណែកឯយុទ្ធសាស្ត្រវាគ្រាន់តែជាយុទ្ធវិធីមួយ ដែលជួយឱ្យសកម្មភាពខាងលើអាចប្រព្រឹត្តទៅប្រកបដោយជោគជ័យ ស្របទៅតាមគោលដៅដែលយើងបានគ្រោងទុក ។ យុទ្ធសាស្ត្រត្រូវតែជាយុទ្ធសាស្ត្រដែលអាចប្រើបានផងដែរ ដោយបណ្តាញរបស់យើង ហើយយុទ្ធសាស្ត្រនោះ ត្រូវតែមានគន្លឹះសំខាន់ៗដែលអាច ធ្វើឱ្យឥរិយាបថនៃភាគីម្ខាងទៀត មានការផ្លាស់ប្តូរ ។ ជាធម្មតាយុទ្ធសាស្ត្រ នៃការតស៊ូមតិតែងតែមានលក្ខណៈប្រឆាំង ឬប្រឈមមុខ ។ ប៉ុន្តែនេះពុំមែនជាយុទ្ធសាស្ត្រល្អបំផុត នៃការតស៊ូមតិឡើយ ហើយវាគ្រាន់តែជាយុទ្ធសាស្ត្រចុងក្រោយតែប៉ុណ្ណោះ ។ យុទ្ធសាស្ត្រដែលល្អ គឺជាការរៀបចំឱ្យមានការពិភាក្សាតាមវិទ្យុ ឬទូរទស្សន៍វិញទេ ដែលទទួលបានជោគជ័យជាងការប្រមូលមនុស្សរាប់ពាន់នាក់ ដើម្បីធ្វើបាតុកម្ម ឬកូដកម្មជាដើម ។

## ៤.៥. ការវាយតម្លៃលើយុទ្ធសាស្ត្រ

✠ តើយុទ្ធសាស្ត្ររបស់យើង អាចជួយយើងឱ្យឈានទៅដល់គោលដៅដែរ ឬទេ?

✠ តើបណ្តាញរបស់យើងអាចប្រើវាបានដែរ ឬទេ ?

✠ តើយុទ្ធសាស្ត្រនោះ អាចជួយកាត់បន្ថយនូវអ្វីដែលអ្នកប្រឆាំង ប្រុងនឹងធ្វើមកលើយើង ឬអត់?

✠ តើយុទ្ធសាស្ត្រសមនឹងសមត្ថភាពរបស់យើង និងបណ្តាញរបស់យើង ឬអត់ ?

## ៤.៦. កំណត់នូវអ្វីដែលយើង នឹងទាមទារ

- តើយើងទាមទារអ្វីជាក់លាក់ពីភាគីម្ខាងទៀត ?
- តើការទាមទាររបស់យើងអាចមានផលប្រយោជន៍ ឬប៉ះពាល់ដល់ទៅលើក្រុមគោលដៅ យើងឬទេ?
- តើអ្នកណាជាអ្នកជួយបញ្ជូនការទាមទាររបស់យើងដល់អ្នកពាក់ព័ន្ធ ឬអ្នកផ្សេងទៀត ?
- តើយើងធ្វើយ៉ាងដូចម្តេច ដើម្បីឱ្យអ្នកពាក់ព័ន្ធ ឬក្រុមផ្សេងទៀតអាចចូលរួមជាមួយយើង?

## ៤.៧. ការធ្វើផែនការ សកម្មភាព និងអនុវត្តសកម្មភាព

- តើយើងមានលទ្ធភាព ឬឱកាសយ៉ាងដូចម្តេច ដើម្បីធ្វើសកម្មភាព ?
- តើអ្នកណានឹងអនុវត្តនូវសកម្មភាពនេះ ?
- តើសកម្មភាពនោះ នឹងត្រូវធ្វើនៅពេលណា ? មានរយៈពេលប៉ុន្មាន ?
- តើយើងមានធនធានមនុស្សគ្រប់គ្រាន់ ដើម្បីឱ្យសកម្មភាពនោះ ដំណើរការ ឬទេ ?
- តើប្រភេទនៃបណ្តាញ ឬសហគមន៍យ៉ាងដូចម្តេច ដែលគួរឱ្យចូលរួមសហការជាមួយនឹងយើង ?
- តើមានបុគ្គលណាខ្លះ ឬអង្គការណាខ្លះ ដែលអាចប្រឆាំង ឬមិនគាំទ្រសកម្មភាពយើង ?

នៅពេលដែលយើងគិតអំពីសកម្មភាពលំអិត យើងត្រូវធ្វើយ៉ាងណាឱ្យស៊ីទៅនឹងយុទ្ធសាស្ត្រ ហើយស្របទៅតាមគោលដៅ និងគោលបំណងដែលយើងបានបង្កើតឡើង ។ សំខាន់ជាងនេះទៅទៀត យើងត្រូវជ្រើសសកម្មភាពណា ដែលប្រព្រឹត្តទៅបាន ក្នុងរង្វង់ធនធាន ដែលយើងមាន ។

**៤.៨. វាយតម្លៃលើសកម្មភាព** (សូមមេត្តាអានផ្នែកទី៦ ស្តីពីការត្រួតពិនិត្យ និងវាយតម្លៃ ទំព័រទី៧៩ ដល់ទំព័រទី៩១)

**តារាងផែនការយុទ្ធនាការតស៊ូមតិ**[៣៤]

| គោលដៅ | ធនធាន | អ្នកគាំទ្រ,អ្នកប្រឆាំង | ក្រុមគោលដៅ | យុទ្ធសាស្ត្រ | សកម្មភាព |
|---|---|---|---|---|---|
| | បុគ្គលិក | បណ្តាញ,សហគមន៍ | ក្រុមដែលអាចកែប្រែ | | |
| | ថវិកា | ភាគីប្រឆាំង | ក្រុមដែលអាចកែប្រែចិត្ត | | |

[៣៤] ដកស្រង់សៀវភៅ "ការបង្កើតផែនការសំរាប់ការតស៊ូមតិ" របស់លោក ព្រីសត្រូសប្រ៊ូ




## ៥-. ការប្រើប្រាស់បណ្តាញព័ត៌មាន និងបណ្តាញដើម្បីធ្វើការតស៊ូមតិ

វគ្គនេះយើងសូមណែនាំអំពីមុខងារបណ្តាញព័ត៌មាន ដែលជាកម្លាំងមួយដ៏មានសក្តានុពល ក្នុងការចូលរួមធ្វើការតស៊ូមតិ ជាពិសេសក្នុងការធ្វើឱ្យមានឥទ្ធិពលទៅលើអ្នក ដែលសម្រេចចិត្តក្នុងកិច្ចការនយោបាយ ។ ត្រង់ចំណុចនេះ យើងនឹងពិភាក្សាថា តើអង្គការមិនមែនរដ្ឋាភិបាល និងក្រុមសង្គមស៊ីវិល អាចប្រើប្រាស់បណ្តាញព័ត៌មាន និងបណ្តាញដទៃទៀតយ៉ាងដូចម្តេច ដើម្បីជំរុញឱ្យការតស៊ូមតិរបស់គេកាន់តែមានឥទ្ធិពលថែមទៀត ជាពិសេសចំពោះសាធារណជន ។ វគ្គនេះនឹងអាចជួយអ្នកតស៊ូមតិឱ្យយល់ដឹងអំពីការរៀបចំយុទ្ធសាស្ត្រតស៊ូមតិ បណ្តាញព័ត៌មានស្របទៅតាមតម្រូវការ និងគោលបំណងរបស់ខ្លួន ។

### ៥.១. ទស្សនៈទូទៅលើបណ្តាញព័ត៌មាន

យើងដឹងហើយថា បណ្តាញព័ត៌មាន ក៏ជាសង្គមស៊ីវិលដែរ ។ បណ្តាញព័ត៌មាន មានស្វយតភាពពីរដ្ឋ មានន័យថា មិនឋិតនៅក្រោមការគ្រប់គ្រងរបស់រដ្ឋាភិបាល ។ យោងតាមរដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣ ជំពូកទី៣ មាត្រា ៤១ បានចែងថា "**ប្រជាពលរដ្ឋខ្មែរ មានសេរីភាពខាងការបញ្ចេញមតិរបស់ខ្លួន សេរីភាពខាងសារព័ត៌មានសេរីភាពខាងការបោះពុម្ពផ្សាយ សេរីភាពខាងការប្រជុំ ។ ជនណាក៏ដោយ មិនអាចឆ្លៀតប្រើសិទ្ធិនេះ ដោយរំលោភនាំឱ្យប៉ះពាល់ដល់កិត្តិយសរបស់អ្នកដទៃ ដល់ទំនៀមទម្លាប់ល្អរបស់សង្គម ដល់សណ្តាប់ធ្នាប់សាធារណៈ និងដល់សន្តិសុខជាតិបានឡើយ របបសារព័ត៌មានត្រូវរៀបចំដោយច្បាប់**" ។ បណ្តាញព័ត៌មានមិនត្រឹមតែមានអំណាច និងឥទ្ធិពលលើអ្នកចេះដឹង អ្នកនយោបាយ និងអ្នកស្រាវជ្រាវតែប៉ុណ្ណោះទេ ថែមទាំងមានឥទ្ធិពលលើប្រជាពលរដ្ឋសាមញ្ញទៀតផង ។ បណ្តាញព័ត៌មាន មានលទ្ធភាពបញ្ជូន

ព័ត៌មានទៅឱ្យសាធារណជន ឱ្យបានយ៉ាងឆាប់រហ័ស ហើយជាវេទិកាដ៏សំខាន់សំរាប់យើងពិភាក្សាលើបញ្ហាសាមញ្ញ ឬបញ្ហាធំៗ ដែលទាក់ទងនឹងគោលនយោបាយ បញ្ចេញមតិយោបល់ រិះគន់ ឬក៏សំណូមពរចំពោះសាធារណជន រដ្ឋាភិបាល ឬបុគ្គលជាដើម ។

## ៥.២. បណ្តាញព័ត៌មាន និងអ្នកសម្រេចចិត្តលើគោលនយោបាយ

ដូចបានជំរាបជូនខាងដើមហើយថា បណ្តាញព័ត៌មាន មានតួនាទី និងជាឧបករណ៍ដ៏សំខាន់ ក្នុងការបញ្ជូនព័ត៌មាន ហើយសង្គមស៊ីវិល អាចប្រើប្រាស់បណ្តាញព័ត៌មាន ដើម្បីធ្វើការតស៊ូមតិទៀតផង ។ បណ្តាញព័ត៌មាន អាចនាំព័ត៌មានពីប្រជាពលរដ្ឋទូទៅ ជូនថ្នាក់ដឹកនាំរដ្ឋាភិបាលគ្រប់កម្រិត ។ ឧទាហរណ៍ មានកម្មករ និងសង្គមស៊ីវិលមួយក្រុម បានធ្វើបាតុកម្ម ឬយុទ្ធនាការ នៅមុខគ្រឹះស្ថានរដ្ឋាភិបាល សមាជិករដ្ឋាភិបាល ពុំអាចដឹងអំពីអ្វីដែលក្រុមនោះចង់បានឡើយ ពីព្រោះថាគេពិបាកនឹងទាក់ទងផ្ទាល់ជាមួយក្រុមនោះ ។ ប៉ុន្តែបណ្តាញព័ត៌មាន អាចជួយបញ្ជូនព័ត៌មានទៅឱ្យក្រុមទាំងពីរបាន មានន័យថា ពីអ្នកធ្វើបាតុកម្ម ទៅសមាជិករដ្ឋាភិបាល និងពីសមាជិករដ្ឋាភិបាលទៅបាតុករ ដោយហេតុថា បណ្តាញព័ត៌មានជាភាគីដែលពុំពាក់ព័ន្ធនឹងជម្លោះ ។ អ្នកនយោបាយ ក៏អាចដឹងអំពីសុខទុក្ខ របស់ប្រជាពលរដ្ឋ តាមរយៈបណ្តាញព័ត៌មាននោះផងដែរ ។ សរុបសេចក្តីមកបណ្តាញព័ត៌មាន ជាឧបករណ៍មួយដ៏សំខាន់ និងមានប្រសិទ្ធភាព ដើម្បីទំនាក់ទំនងជាមួយអ្នកនយោបាយ ជាពិសេសក្នុងការតស៊ូមតិ ។ ប៉ុន្តែទោះបីជាយ៉ាងណាក៏ដោយ ពេលខ្លះបណ្តាញសារព័ត៌មាន ក៏អាចធ្វើឱ្យកាន់តែមានភាពតានតឹងផងដែរ ប្រសិនបើសារព័ត៌មាននោះ ជាសារព័ត៌មានមាននិន្នាការទៅរកភាគីម្ខាងទៀត ឬចម្លងសំដីអំពីភាគីម្ខាងពុំត្រឹមត្រូវ និងមានភាពលំអៀង ។

## ៥.៣. អង្គការមិនមែនរដ្ឋាភិបាល និងព័ត៌មាន

អង្គការមិនមែនរដ្ឋាភិបាល ត្រូវគេបានទទួលស្គាល់ថា ជាក្រុមសង្គមស៊ីវិលមួយដែលមានតួនាទីយ៉ាងសំខាន់ក្នុងការចូលរួមចំណែក ក្នុងការកសាងប្រទេសជាតិលើគ្រប់វិស័យ ។ ប៉ុន្តែសមិទ្ធផលដ៏ធំធេងនេះ បានមកដោយសារការឧបត្ថម្ភពីម្ចាស់មូលនិធិ និងសហការពីអ្នកដទៃ ។ ដើម្បីឱ្យមានការចាប់អារម្មណ៍ និងសហការពីអ្នកដទៃ អង្គការមិនមែនរដ្ឋាភិបាលជួបប្រទះបញ្ហាជាច្រើន ។ មធ្យោបាយមួយក្នុងចំណោមមធ្យោបាយទាំងឡាយ អង្គការមិនមែនរដ្ឋាភិបាល បានសហការជាមួយបណ្តាញព័ត៌មាន ដែលមានអំណាចខាងពាក្យសំដី ដើម្បីជាជំនួយការមួយដ៏សំខាន់ ក្នុងការតស៊ូមតិរបស់ខ្លួន ។ ប៉ុន្តែ ទោះបីជាយ៉ាងណាក៏ដោយ ក៏អង្គការមិនមែនរដ្ឋាភិបាលនៅតែមានការលំបាក ដើម្បីឱ្យបណ្តាញព័ត៌មានជួយផ្សព្វផ្សាយ នូវអត្ថបទរបស់ខ្លួន ។ បញ្ហានេះបណ្តាលមកពីអង្គការមិនមែនរដ្ឋាភិបាល និងបណ្តាញព័ត៌មាន ដែលមានទស្សនៈ និងឧត្តមគតិខុសពីគ្នា ។ ចំពោះអ្នកព័ត៌មានគេគិតថា "ព័ត៌មាន" ជាអត្ថបទដែលគេអាចលក់បាន ។ ព័ត៌មានរបស់គេតែងតែ

ផ្តោតលើព្រឹត្តិការណ៍ (ហេតុការណ៍ដែលកើតឡើងថ្មីៗ) គេមិនផ្តោតលើបញ្ហាតែមួយ ដូចជាអំពើហិង្សាក្នុងគ្រួសារ ឬការរំលោភសិទ្ធិមនុស្សនោះឡើយ ។ ដោយ សារបណ្តាញព័ត៌មាន មិនធ្វើការដើម្បីក្រុមសង្គមស៊ីវិល ឬអង្គការមិនមែនរដ្ឋាភិបាលពិសេសណាមួយនោះ បណ្តាញព័ត៌មាន មិនគិតពីអ្វីដែលសង្គមស៊ីវិលចង់ផ្សព្វផ្សាយនោះទេ ឱ្យតែព័ត៌មានណាដែល សង្ឃឹមថាពេលចុះផ្សាយទៅ នឹងមានគេអានច្រើន គេនឹងចុះផ្សាយព័ត៌មាននោះភ្លាម ទោះបីជាសង្គមស៊ីវិលគិតថា ព័ត៌មាននោះ នឹងប៉ះពាល់ដល់សុវត្ថិភាព ឬសន្តិសុខសង្គមក៏ដោយ ។ អង្គការមិនមែនរដ្ឋាភិបាលយល់ថា "ព័ត៌មាន" គឺជាការអប់រំឃោសនា ជាការដកស្រង់ឯកសារច្បាប់ ព័ត៌មានថ្មីៗ ឬក៏ប្រវត្តិផ្សេងៗ ពាក់ព័ន្ធទៅនឹងការពង្រឹង ឬកសាងប្រទេសជាតិ ។ ផ្ទុយទៅវិញបណ្តាញព័ត៌មាន គេយល់ថា ព័ត៌មានជាការផ្សព្វផ្សាយ នូវហេតុការណ៍អ្វីៗដែលកើតឡើងថ្មីៗថ្ងៃនេះ ឬម្សិលមិញ អ្វីដែលមិនធម្មតា ហើយធ្វើឱ្យអ្នកអានមានការចាប់អារម្មណ៍ ឬរីករាយ ។ ដោយសារទស្សនៈ បណ្តាញព័ត៌មាន និងអង្គការមិនមែនរដ្ឋាភិបាល មានទស្សនៈខុសគ្នាយ៉ាងនេះហើយ ទើបការសរសេរព័ត៌មានមានភាពខុសគ្នាដែរ ។ អង្គការមិនមែនរដ្ឋាភិបាល ចូលចិត្តសរសេរអត្ថបទវែងពិស្តារ សរសេរនូវពាក្យអង្គការមិនមែនរដ្ឋាភិបាលខ្លួនឯងកំពុងប្រើ ។ ចំណែកឯអត្ថបទសារព័ត៌មានវិញ គឺគេប្រើពាក្យសាមញ្ញៗ ខ្លីៗ ខ្លឹម និងច្បាស់ ។

## ៥.៤. តើអ្វីទៅដែលហៅថា ការតស៊ូមតិតាមរយៈបណ្តាញព័ត៌មាន ?

ការតស៊ូមតិតាមរយៈបណ្តាញព័ត៌មាន ជាយុទ្ធសាស្ត្រមួយដែលអ្នកតស៊ូមតិ ប្រើបណ្តាញព័ត៌មាន ដើម្បីជាធនធាន និងជាជំនួយការដ៏សំខាន់ ក្នុងការធ្វើការតស៊ូមតិលើបញ្ហាសង្គម ឬគោលនយោបាយណាមួយ ។ មជ្ឈមណ្ឌលស្រាវជ្រាវឈ្មោះ **ប្រីវិនសិន រីសើច សិនធើ**[៣៥] បានឱ្យនិយមន័យលើការតស៊ូមតិតាមរយៈបណ្តាញព័ត៌មានថា ជាយុទ្ធសាស្ត្រមួយដែលគេប្រើបណ្តាញព័ត៌មាន ជាមធ្យោបាយ សំរាប់ការតស៊ូមតិ ដោយមានរៀបចំគោលបំណង និងផែនការច្បាស់លាស់ ដើម្បីលើកឱ្យឃើញនូវបញ្ហា និងផ្តល់ជាដំណោះស្រាយជូនដល់សហគមន៍ និងរដ្ឋអំណាចមូលដ្ឋាន (អ្នកមានសិទ្ធិសម្រេច គោលនយោបាយមូលដ្ឋាន) ។ អ្នកខ្លះទៀតយល់ថា ការតស៊ូមតិតាមរយៈបណ្តាញព័ត៌មាន គឺជាយុទ្ធសាស្ត្រមួយ ដែលគេប្រើបណ្តាញព័ត៌មាន ដើម្បីគាំទ្រសហគមន៍ដែលកំពុងធ្វើការតស៊ូមតិលើកិច្ចការសង្គម និងគោលនយោបាយ ។

បច្ចុប្បន្ននេះ បណ្តាញព័ត៌មានកាន់តែមានតួនាទីសំខាន់ក្នុងការទាក់ទាញចំណាប់អារម្មណ៍ពីសាធារណជន និងអ្នកនយោបាយ និងបានកំពុងធ្វើឱ្យមានការផ្លាស់ប្តូរទាំងឥរិយាបថបុគ្គល ស្ថាប័ន និងគោលនយោបាយ ។ លោក ឡូរី ដរហ្វមែន និងលោក វ៉ាឡេក បាននិយាយថា **ការតស៊ូមតិតាមរយៈបណ្តាញ**

[៣៥] The Prevention Research Center

ព័ត៌មាន មិនមែនធ្វើដើម្បីផលប្រយោជន៍អ្នកព័ត៌មានណាមួយនោះឡើយ គឺជាការប្រើបណ្ដាញព័ត៌មានដោយមានភាពប្រុងប្រយ័ត្ន ដើម្បីជួយជំរុញការតស៊ូមតិលើគោលនយោបាយប្រកបដោយជោគជ័យ[៣៦] ។ ប៉ុន្តែយើងត្រូវកត់ចំណាំថា បណ្ដាញព័ត៌មានដែលយើងជឿថាអាចមានឥទ្ធិពលលើដំណើរការនៃការបង្កើតគោលនយោបាយនោះ ពេលខ្លះពុំអាចជួយការងារតស៊ូមតិយើងទទួលបានជោគជ័យមួយរយភាគរយ ដូចដែលយើងបានគ្រោងទុកនោះឡើយ ។

## ៦. ប្រភេទនៃបណ្ដាញព័ត៌មាន

### ៦.១. ព័ត៌មានពាក់កណ្ដាលបច្ចេកវិទ្យាទំនើប

ទូរទស្សន៍ បោះពុម្ពផ្សាយ និងវិទ្យុ

### ៦.២. វេទិកាសាធារណៈ ឬ សន្និសីទសារព័ត៌មាន

វេទិកាសាធារណៈ សន្និសីទកាសែត ការសង្ខេបសន្និសីទព័ត៌មាន ការសម្ភាសន៍តាមទូរស័ព្ទ ការជួបជាមួយអ្នកសារព័ត៌មាន

### ៦.៣. ព័ត៌មានតាមប្រព័ន្ធអេឡិចត្រូនិច

អ៊ីម៉ែល ក្រុមអ៊ីម៉ែល វិបសាយ និងព័ត៌តាមអ៊ិនធើណែត



- **ព័ត៌មានបោះពុម្ពផ្សាយ**

មុននឹងសរសេរព័ត៌មានដើម្បីបោះពុម្ពផ្សាយ យើងគួរពិចារណា ថាអ្នកណានឹងទទួលអត្ថបទព័ត៌មានពីយើង ។ នៅពេលយើង សរសេរផ្ញើទៅអ្នកសារព័ត៌មាន យើងត្រូវធ្វើយ៉ាងណាឱ្យសំណេររបស់យើងមានលក្ខណៈសាមញ្ញច្បាស់លាស់ និងមានភាពងាយស្រួល ក្នុងការកែសម្រួលដាក់បញ្ចូលក្នុងទំព័រសារព័ត៌មានរបស់គេ ។ យើងគួរប្រើទម្រង់សរសេរបែបសេចក្ដីប្រកាសព័ត៌មាន ឯកសារស្រាវជ្រាវ ឬលិខិតរៀបរាប់ អំពីបញ្ហាដែលកំពុងប៉ះពាល់ដល់ប្រជាពលរដ្ឋជាដើម ។ ប៉ុន្តែនៅពេលយើងសរសេរឆ្ពោះទៅក្រុម

[៣៦] លោក ឡូរី ដរហ្វមែន និងលោក វ៉ាឡេក អ្នកស្រាវជ្រាវ បណ្ដាញពត៌មាន ប៊ើកកាឡេ សាកលវិទ្យាល័យ កានីហ្វូនី ១៩៩៦

គោលដៅតែម្តង ដូចជាអ្នកមានសិទ្ធិសម្រេច លើគោលនយោបាយរដ្ឋអំណាច អ្នកស្រាវជ្រាវ សាស្ត្រាចារ្យ ដូនជី ព្រះសង្ឃជាដើម យើងគួរសរសេរព័ត៌មានបែបវិចារណកថា ឬលិខិតចំពោះអ្នកអានវិញ ។

**♦ ទូរទស្សន៍**

ការផ្សព្វផ្សាយតាមទូរទស្សន៍ មានសារៈសំខាន់ណាស់ ពីព្រោះថាវាអាចធ្វើឱ្យប្រជាពលរដ្ឋទូទាំងប្រទេសបានឮ និងឃើញនូវសកម្មភាពរបស់យើង ។ ទូរទស្សន៍ នៅស្រុកខ្មែរយើងមានទូរទស្សន៍ជាតិ ប៉ុស្តិ៍កងយោធពលខេមរភូមិន្ទ ប៉ុស្តិ៍លេខ៩ ប៉ុស្តិ៍អប្សរាលេខ១១ ប៉ុស្តិ៍បាយ័ន ប៉ុស្តិ៍ស៊ីធីអ៊ិន និងប៉ុស្តិ៍លេខ៣ ។ រីឯវិទ្យុ មានវិទ្យុជាតិ និងវិទ្យុប៉ុស្តិ៍អែហ្វអិមជាច្រើនទៀត ។ ទោះបីជាបណ្តាញវិទ្យុ-ទូរទស្សន៍កម្ពុជាមួយចំនួន ពុំមានភាពឯករាជ ឬបំរើឱ្យគណបក្សនយោបាយរបស់គេរៀងៗខ្លួនក៏ដោយ ក៏គេទាំងនោះ បានបំរើនូវសេចក្តីត្រូវការរបស់ប្រជាពលរដ្ឋគួរជាទីគាប់ចិត្ត តាមរយៈ ការផ្សព្វផ្សាយកម្មវិធីរបស់គេ ។



**♦ វេទិកាសារធារណៈ សន្និសីទសារព័ត៌មាន និងការសង្ខេបសន្និសីទព័ត៌មាន**

**- វេទិកាសាធារណៈ :**

វេទិកាសាធារណៈ ជាស្ពានដែលជួយពាំនាំនូវកង្វល់ និងបញ្ហារបស់ប្រជាពលរដ្ឋ ជូនដល់ថ្នាក់ដឹកនាំដើម្បីជួយដោះស្រាយឱ្យពួកគេ ។ គេរៀបចំ វេទិកាសាធារណៈទៅតាមប្រភេទនៃបញ្ហា ដូចជាបញ្ហា រំលោភដីធ្លី សាំងឡើងថ្លៃ ការរំលោភសិទ្ធិកម្មករជាដើម ។

**- សន្និសីទសារព័ត៌មាន :**

គេរៀបចំសន្និសីទព័ត៌មាន សំរាប់អ្នកដែលពាក់ព័ន្ធទៅនឹងបញ្ហាសំខាន់ៗ ដែលទើបនឹងកើតឡើង ឬរៀបចំដើម្បីបង្ហាញអំពីរបាយការណ៍ ដែលគេគិតថា មានសារៈសំខាន់ដើម្បីបញ្ចុះបញ្ចូលអ្នកដឹកនាំ និងសាធារណជន ឬរៀបចំ ដើម្បីឆ្លើយតបទៅនឹងអ្វី ដែលអ្នកសារព័ត៌មាន កំពុងតែមានការចាប់អារម្មណ៍ ។

**- ការសង្ខេបព័ត៌មាន**

ការសង្ខេបព័ត៌មាន គឺជាការសង្ខេបនូវព័ត៌មានស្របពេលជាមួយនឹងការរៀបចំសន្និសីទព័ត៌មាន ដោយអ្នកនាំពាក្យ អ្នកជំនាញ ឬអ្នកតំណាងណាម្នាក់ ។




- **ការសម្ភាសន៍តាមទូរស័ព្ទ**

របៀបនេះអាចជួយឱ្យយើងផ្តល់ការសម្ភាសន៍ របស់យើងតាមទូរស័ព្ទ នៅពេលដែលយើងមិននៅក្នុងស្រុក ឬក៏មានពេលមមាញឹកក្នុងការងារជាដើម ។

- **ការជួបអ្នកកាសែត**

ការជួបអ្នកកាសែត គឺជាការរៀបចំពេលវេលា ដើម្បីជួបជាមួយអ្នកនិពន្ធ អ្នកសរសេរប្រលោមលោក ឬអ្នកសារព័ត៌មានផ្សេងៗទៀត ដើម្បីផ្តល់ព័ត៌មាន និងឯកសារដែលទាក់ទងទៅនឹងបញ្ហាដែលយើងចង់ផ្សព្វផ្សាយដោយផ្ទាល់ ។

**♦ ការតស៊ូមតិតាមទូរស័ព្ទ**

ការតស៊ូមតិតាមទូរស័ព្ទភាគច្រើន អាចធ្វើទៅបានដោយអ្នកវណ្ណៈកណ្តាល ។ នៅខែឧសភា ឆ្នាំ ១៩៩២ សកម្មជនតស៊ូមតិបានប្រើ ទូរស័ព្ទ ដើម្បីប្រមូលគ្នាប្រឆាំងតវ៉ា ទៅនឹងរបបយោធាផ្តាច់ការ ។

**♦ ការផ្ញើសារតាមទូរស័ព្ទ**

ការផ្ញើសារតាមទូរស័ព្ទ ជាឧបករណ៍គួរជាទីពេញចិត្ត ដើម្បីទំនាក់ទំនងគ្នាប្រចាំថ្ងៃ ដោយមានតម្លៃថោក ។ លើសពីនេះ គេប្រើវាដើម្បីធ្វើការតស៊ូមតិក្នុងរឿងនយោបាយថែមទៀតផង ។ នៅប្រទេសហ្វីលីពីន អ្នកតវ៉ារាប់ពាន់អ្នកអាចជួបជុំគ្នា នៅតាមផ្លូវក្នុងរយៈពេលមិនដល់មួយម៉ោងផង ដើម្បីចាប់ផ្តើមសកម្មភាពតវ៉ាជាមួយលោកប្រធានាធិបតីអាស្ត្រាដា ។ គេឱ្យឈ្មោះ យុទ្ធនាការនោះថា **កម្លាំងប្រជាជនជាអំណាចទីពីរ**[៣៧] ។

**♦ ការតស៊ូមតិតាមប្រព័ន្ធបច្ចេកវិទ្យាទំនើប**

បច្ចេកទេសនៃការតស៊ូមតិតែងតែផ្លាស់ប្តូរជានិច្ចដោយសារការរីកដុះដាល នៃប្រព័ន្ធបច្ចេកវិទ្យា

[៣៧] People Power II

ទំនើប ។ សកម្មជនតស៊ូមតិបានប្រើអិនធើណែត ដើម្បីធ្វើការតស៊ូមតិរបស់គេ ដោយសារអីនធើណេត បានផ្តល់នូវព័តិមានឆាប់រហ័ស និងទូលំទូលាយ ។ ដោយឡែកប្រព័ន្ធអ៊ីម៉ែល ក៏ដើរតួនាទីសំខាន់ នៅក្នុងការបញ្ជូនព័តិមាន ទៅឱ្យក្រុមផ្សេងៗ បានឆាប់រហ័សដែរ ។ ទំនាក់ទំនងតាមរយៈអ៊ីម៉ែល ពីក្រុមមួយ ទៅក្រុមមួយ ត្រូវបានគេប្រើយ៉ាងច្រើនលើពិភពលោក ជាពិសេសនៅតំបន់អាស៊ីអាគ្នេយ៍យើងនេះ ។ នៅប្រទេសដែលមានប្រព័ន្ធព័តិមានគ្រប់គ្រងតឹងតែង ឬដោយរបបផ្តាច់ការ ការផ្តល់ព័តិមានតាមរយៈ អ៊ុនធើណែត ក៏កាន់តែមានសារៈសំខាន់ សំរាប់ក្រុមអ្នកតស៊ូមតិ ។ ប៉ុន្តែអ្នកអត្ថាធិប្បាយ តាមទូរទស្សន៍របស់អាមេរិកាំងម្នាក់ បាននិយាយថា "ទោះបីជានៅលើផ្លូវធំ ក៏មានបន្ទាត់សំរាប់ជិះលឿន ឬជិះយឺតដែរ ។ ដូចនេះ អ៊ុនធើណេត ជួនកាលក៏អាចប្រើទៅបានលទ្ធផលច្រើន ឬជួនកាលក៏អាចប្រើ ទៅបានលទ្ធផលតិចដែរ ។ ម្យ៉ាងវិញទៀត បណ្តាញអ៊ុនធើណែត ពុំទាន់អាចប្រើបានពាសពេញពិភពលោកនៅឡើយ ។ ជាក់ស្តែងនៅជនបទនៃប្រទេសកម្ពុជា និងប្រទេសក្រីក្រមួយចំនួនទៀត ចំនួនកុំព្យូទ័រ និងការចេះប្រើកុំព្យូទ័រនៅមានកម្រិត ហើយតំបន់ខ្លះទៀតសូម្បីតែបណ្តាញទូរស័ព្ទក៏គ្មានដែរ ។ ដូច្នេះការតស៊ូមតិតាមបណ្តាញអ៊ុនធើណែតនៃតំបន់នោះ ក៏មានកម្រិតដែរ ។

## ៧- ការតស៊ូមតិដោយប្រើសកម្មភាព

ការតស៊ូមតិដោយប្រើសកម្មភាព គឺជាយុទ្ធសាស្ត្រតស៊ូមតិមួយ ដែលយើងសំដែងចេញជាកំប្លុកកំប្លែងតាមរបៀបដែលអាចធ្វើទៅបាន ។ ឧទាហរណ៍ ដូចជារាំលាបមុខលាបមាត់ ធ្វើកំប្លុកកំប្លែង ដើរចុះដើរឡើងទៅមុខកន្លែងដែលមានបញ្ហាបិទច្រក ឬបិទក្លោងទ្វារអគារធំៗ ដោយពុំឱ្យអ្នកផ្សេងចូល ការយកផ្កាទៅជូនប៉ូលីសដែលកំពុងការពារជាដើម ។ ចលនា**សមរភូមិនៃស៊ីអេតថល**[៣៨] បានប្រើការ តស៊ូមតិនេះ នៅឆ្នាំ ១៩៩៨ ដោយក្រុមសកម្មប្រឆាំងនឹងមូលធននិយម ដើម្បីស្នើសុំឱ្យបញ្ឈប់នូវការរៀបចំ សន្និសីទរដ្ឋមន្ត្រី អង្គការពាណិជ្ជកម្មពិភពលោកលើកទី៣ ។ តាមការពិតការតស៊ូមតិនេះ មានឫសគល់ចេញពីសកម្មជនសន្តិភាពពណ៌ខៀវ ដែលបានប្រឆាំងទៅនឹងការបង្កើត



[៣៨] Seatle, The United States

អាវ៉ុធ នុយក្លេអ៊ែរនៅ ប្រហែលជាដើមឆ្នាំ ១៩៧០ ។

នៅប្រទេសភាគច្រើននៃតំបន់អាស៊ីអាគ្នេយ៍យើងនេះ អ្នកតស៊ូមតិភាគច្រើន ច្រើនតែប្រមូលផ្តុំគ្នា



ដើម្បីបង្ហាញនូវកម្លាំងរបស់ខ្លួនជាជាងការឆ្លៃប្រឌិតសកម្មភាពកំប្លុកកំប្លែងភ្លាមៗ ដើម្បីឱ្យមានការចាប់អារម្មណ៍ បណ្តាញព័ត៌មាន ឬសាធារណជនឡើង ។ ការតស៊ូមតិតាមរបៀបនេះ វាដូចជាយើងយកថ្មមួយដុំតូចទៅរាំងទឹកស្ទឹង ដែលកំពុងតែហូរខ្លាំងតែប៉ុណ្ណោះ ។ ដូចនេះអ្នកតស៊ូមតិបែបនេះ គួរតែស្រាវជ្រាវថែមទៀត ដើម្បីធ្វើយ៉ាងណាឱ្យមានការចាប់អារម្មណ៍ពីប្រព័ន្ធព័ត៌មាន និងសាធារណជនលើចលនាតស៊ូមតិរបស់ខ្លួន ។

## ៨- ការធ្វើផែនការព័ត៌មាន

តាមធម្មតាអ្នកសរសេរព័ត៌មាន តែងតែស្វែងរកព័ត៌មានសំខាន់ៗ ព័ត៌មានពិត និងព័ត៌មានអំពីព្រឹត្តិការណ៍ថ្មីៗ ។ ដូច្នេះអ្នកតស៊ូមតិដែលពឹងផ្អែកទៅលើបណ្តាញព័ត៌មាន តែងតែរកមើលឱកាសថាតើផ្នែកត្រង់ណាមួយនៃទំព័រសារព័ត៌មាន ដែលអាចផ្សព្វផ្សាយព័ត៌មានរបស់ខ្លួនបាន ។ ដោយសារយើងពុំអាចស្មានបានថាតើនឹងមានអ្វីកើតឡើងនៅថ្ងៃស្អែក ឬពេលខាងមុខ អ្នកតស៊ូមតិត្រូវតែធ្វើផែនការទុកជាមុន ទោះបីផែនការនោះ ភាគច្រើនពុំសូវទទួលបានជោគជ័យក៏ដោយ ។ ការធ្វើផែនការ ត្រូវឱ្យឆ្លើយទៅនឹងសំនួរដូចខាងក្រោម ៖



- ✠ តើគោលបំណងរបស់អ្នកយ៉ាងដូចម្តេច ? ចង់បានអ្វី ? រយៈពេលវែង ឬ ខ្លី ?
- ✠ តើអ្នកណាជាអ្នកសរសេរសារព័ត៌មានរបស់អ្នក ?
- ✠ តើអត្ថបទរបស់អ្នក នឹងនិយាយអំពីអ្វី ដើម្បីឱ្យការតស៊ូមតិរបស់អ្នកមានឥទ្ធិពល ?
- ✠ តើអ្នកវាយតម្លៃអំពីជោគជ័យនៃការផ្សព្វផ្សាយព័ត៌មានរបស់អ្នកយ៉ាងដូចម្តេច ?

## ៩- ការតវ៉ាបញ្ចុះបញ្ចូល

នៅប្រទេសកម្ពុជាក្តី នៅបណ្តាប្រទេសផ្សេងៗក្តី អ្នកតស៊ូមតិតែងតែធ្វើផែនការរបស់ខ្លួនយ៉ាងល្អ ដើម្បីឱ្យមានឥទ្ធិពលទៅលើអ្នកកាន់កាប់ស្ថាប័នរដ្ឋ ក្នុងនោះមាន នាយករដ្ឋមន្ត្រី រដ្ឋមន្ត្រី សមាជិករដ្ឋសភា សមាជិកព្រឹទ្ធសភាជាដើម ។ ទោះបីយ៉ាងណាក៏ដោយ កត្តារួមចំណែកមួយដែលជួយឱ្យការតស៊ូមតិទទួលបានជោគជ័យ គឺយើងត្រូវមានអ្នកបញ្ចុះបញ្ចូលដ៏ពូកែ ។ ប៉ុន្តែមុននឹងនិយាយអំពីអ្នកបញ្ចុះបញ្ចូល យើងសូមលើកយកប្រវត្តិ និងនិយមន័យនៃពាក្យថា "ការតវ៉ា បញ្ចុះបញ្ចូល" មកជូនជំរាបជាមុនសិន ។ ពាក្យថាការតវ៉ាបញ្ចុះបញ្ចូល មានដើមកំណើតមកពីភាសា អង់គ្លេសថា "ឡូប៊ី"[៣៩] ដែលមានន័យ ថាជាកន្លែងមួយធំ ដែលស្ថិតនៅច្រកមុខខាងក្នុងនៃអាគារសាធារណៈ រឺសណ្ឋាគារ ហើយវាក៏ជាកន្លែង ដែលយើងអាចជួប រឺរង់ចាំគ្នាដើម្បីពិភាក្សាបញ្ហាផ្សេងៗ[៤០] ។



ពាក្យនេះក៏ទាក់ទងទៅនឹងប្រវត្តិថា នាសម័យកាលមួយ នៅសហរដ្ឋអាមេរិកមានអ្នកតស៊ូមតិជាច្រើនបានទៅអង្គុយនៅ ឡូប៊ី នៃរដ្ឋសភា ដើម្បីសុំឱ្យសមាជិករដ្ឋសភាជួយគាំទ្រ និងអនុម័តច្បាប់របស់គេ ហើយដំណើរការនេះ ចេះតែបន្តរហូតបានជោគជ័យ ។ ដោយមានប្រវត្តិដូច្នេះ ទើបអ្នកតស៊ូមតិបន្តប្រើពាក្យនេះរហូតមកដល់សព្វថ្ងៃហើយ អ្នកដែលតស៊ូមតិពេកនោះ ក៏ត្រូវបានគេហៅថា **ឡូប៊ីអ៊ីស**[៤១] ដែលយើងបកប្រែជាភាសាខ្មែរថា **អ្នកតវ៉ាបញ្ចុះបញ្ចូល** ។ ជាទូទៅអ្នកបញ្ចុះបញ្ចូល គឺជាអ្នកជំនាញដែលមានសមត្ថភាពអាចធ្វើឱ្យសមាជិករដ្ឋសភា បោះឆ្នោតគាំទ្រលើគោលការណ៍ ដែលជាតម្រូវការរបស់ប្រជាពលរដ្ឋ ។ សៀវភៅវចនានុ

---

[៣៩] Lobby

[៤០] សៀវភៅវចនានុក្រម អុកស្វើត អិតវ៉ានស៍ លើននើ ឌិចសិនណារី តិច ២០០១-Oxford Advanced Learners' Dictionary Text 2001

[៤១] Lobbyist

ក្រុម **វ៉ែនដុម ហោស៍ វ៉ែនស្ទើ អានអេបប្រ៊ីដ**[៤២] បានឱ្យនិយមន័យនៃការបញ្ចុះបញ្ចូលថា៖

១. ជាក្រុមមនុស្សដែលធ្វើការ ឬជាយុទ្ធនាមួយ ការធ្វើឱ្យសមាជិក នីតិបញ្ញត្តិបោះឆ្នោតការពារផលប្រយោជន៍របស់គេ ។

២. ជាការប្រមែប្រមូល ឬការប្រឹងប្រែងដើម្បីឱ្យមានឥទ្ធិពលលើសម្លេងឆ្នោត នៃមន្ត្រីដែលធ្វើច្បាប់ (សមាជិករដ្ឋសភា)

៣. ជាការព្យាយាមធ្វើយ៉ាងណាឱ្យមានឥទ្ធិពលលើសកម្មភាពមន្ត្រីសាធារណៈ (ជាពិសេសអ្នកដែលធ្វើច្បាប់) ។

៤. ជាការជំរុញ ឬបញ្ចុះបញ្ចូលលើដំណើរការនៃការអនុម័តិច្បាប់ តាមរយៈការបញ្ចុះបញ្ចូល

និយាយជារួម ការតវ៉ាបញ្ចុះបញ្ចូល គឺជាសិល្បៈមួយ ដែលអ្នកតស៊ូមតិប្រើដើម្បីធ្វើយ៉ាងណា ឱ្យអ្នកសម្រេចចិត្តគាំទ្រ នូវអ្វីដែលខ្លួនចង់បានតាមរយៈការជួបដោយផ្ទាល់ ជាមួយអ្នកសម្រេចលើគោលនយោបាយ ។

ជាធម្មតាសកម្មជន ឬបុគ្គលិក និយោជិកដែលធ្វើការតវ៉ាបញ្ចុះបញ្ចូលជាមួយនឹងរដ្ឋាភិបាល ដែលប្រើអំណាចផ្តាច់ការ តែងតែជួបប្រទះនូវការគំរាមគំហែងចាប់ដាក់ពន្ធនាគារ ឬរត់ចោលស្រុកទៀតផង ។ ដើម្បីជៀសវាងបញ្ហាទាំងនេះ អ្នកតវ៉ាបញ្ចុះបញ្ចូលត្រូវមើលឱ្យបានច្បាស់លាស់ទៅលើ ដំណើរការប្រព្រឹត្តទៅរបស់រដ្ឋ វិភាគនូវតួនាទីរបស់អ្នកសម្រេចចិត្ត ថាតើគេកំពុងគិតយ៉ាងណាចំពោះការផ្លាស់ប្តូរ និងការរីកចម្រើននៃលទ្ធិប្រជាធិបតេយ្យ ។ អ្នកតវ៉ាបញ្ចុះបញ្ចូលត្រូវតែចេះមើល បរិយាកាសនយោបាយ និងសក្តានុពលរបស់រដ្ឋនោះ ហើយត្រូវដឹងថា តើត្រូវសម្របសម្រួល ឬស៊កខ្លួនយ៉ាងណាទៅក្នុងការងាររបស់រដ្ឋ ។ អ្នកតវ៉ាបញ្ចុះបញ្ចូល ត្រូវតែជាមនុស្សដែលមានមុខមាត់ មានឥទ្ធិពលក្នុងសង្គម ហើយត្រូវតែជាអ្នកដែលយល់ដឹងអំពីយុទ្ធសាស្ត្រ និងមានជំនាញក្នុងការធ្វើការឱ្យមានការផ្លាស់ប្តូរសភាពការណ៍នយោបាយ ព្រោះថាអ្នកបញ្ចុះបញ្ចូល ជាអ្នកតស៊ូមតិមួយដ៏សំខាន់ ដែលត្រូវធ្វើការដោយផ្ទាល់ជាមួយអ្នកដែលមានអំណាចជាពិសេសមន្ត្រី រដ្ឋាភិបាល ដែលគេបោះឆ្នោតឱ្យ ដូចជាតំណាងរាស្ត្រ ប្រធានាធិបតីជាដើម ។

## ១០- តើយើងត្រូវធ្វើការតវ៉ាបញ្ចុះបញ្ចូលដើម្បីអ្វី ?

យើងធ្វើការតវ៉ាបញ្ចុះបញ្ចូលដើម្បី ៖

✠ បង្កើតនូវទំនាក់ទំនងជាមួយអ្នកធ្វើច្បាប់ និង មន្ត្រីរដ្ឋាភិបាលសំខាន់ៗ

✠ បង្កើតឱ្យមានការយកចិត្តទុកដាក់ពីមន្ត្រីដែលមានអំណាចលើបញ្ហាសង្គម

---
[៤២] The Random House Webster' Unabridged Dictionary

✠ ធ្វើឱ្យបណ្តាញកាន់តែមានភាពរឹងមាំ និងផ្សព្វផ្សាយព័ត៌មានបានទូលំទូលាយ
✠ អាចបញ្ចុះបញ្ចូលអ្នកនយោបាយធំៗ
✠ បានរៀនសូត្រអំពីកិច្ចការនយោបាយ ។

## ១១- តម្រូវការរបស់អ្នកតវ៉ាបញ្ចុះបញ្ចូល

មិនមែនសុទ្ធតែសកម្មជនតស៊ូមតិទាំងអស់អាចក្លាយជាអ្នកតវ៉ាបញ្ចុះបញ្ចូលដ៏ល្អបានទាំងអស់នោះទេ។ គ្រប់ៗគ្នាអាចសិក្សាយកនូវជំនាញរៀងៗខ្លួនបាន ក៏ប៉ុន្តែចំពោះអ្នកតវ៉ាបញ្ចុះបញ្ចូល លក្ខណចរិតរបស់បុគ្គលជាកត្តាសំខាន់បំផុត ។ បើសិនជាយើងមានលក្ខណចរិតខុសពីសេចក្តីត្រូវការ ដែលជាអ្នកតវ៉ាបញ្ចុះបញ្ចូលមាននោះ យើងត្រូវតែចំណាយពេលវេលា ដើម្បីហាត់ពត់ចិត្តយើងឱ្យសមស្របតាមតម្រូវការនេះ ។ តាមរយៈការអនុវត្តន៍ផ្ទាល់របស់ខ្ញុំ និងយោងតាមឯកសារមួយចំនួន អ្នកតវ៉ាបញ្ចុះបញ្ចូលត្រូវមាន ៖

### លក្ខណសម្បត្តិ ៖

✠ ភាពចាស់ទុំលើផ្នែកនយោបាយ
✠ ពូកែបកស្រាយ និងការពារនូវគំនិតរបស់ខ្លួន
✠ អាចធ្វើការបានច្រើនមុខ ដូចជាការរិះគន់ មានស្មារតីរឹងមាំ មានមនសិការជួនកាលអាចធ្វើជាដៃគូជួនកាលអាចធ្វើជាគូប្រឆាំង
✠ អ្នកមានភាពស្មោះត្រង់ នឹងអាចធ្វើជាតំណាងឱ្យអ្នកដទៃ ហើយអាចបត់បែនតាមសភាពការណ៍
✠ ជាអ្នកចេះអប់រំគេ និងផ្តល់ព័ត៌មានដល់គេយ៉ាងល្អ
✠ ពូកែខាងបញ្ចុះបញ្ចូលធម្មតា និងការទូត

### ចំណេះដឹង៖

អ្នកតវ៉ាបញ្ចុះបញ្ចូលត្រូវមានចំណេះដឹងនានាដូចខាងក្រោម ៖

✠ យល់ដឹងទៅលើវិស័យច្បាប់
✠ យល់ដឹងអំពីដំណើរការនៃការសម្រេចចិត្តទាំងផ្លូវការ និងមិនផ្លូវការ
✠ យល់ដឹងអំពីរចនាសម្ព័ន្ធអង្គការសង្គមស៊ីវិល
✠ យល់ដឹងអំពីដំណើរការនៃការរៀបចំគោលនយោបាយ
✠ យល់ដឹងអំពីឋានានុក្រមនៃមន្ត្រីរដ្ឋាភិបាល គណៈកម្មាធិការ និងលេខាធិការតំណាងរាស្ត្រ

- យល់ដឹងអំពីខ្សែទំនាក់ទំនង និងឥទ្ធិពលរបស់អ្នកតំណាងរាស្ត្រ
- មានជំនាញការចរចាធម្មតា និងការទូត
- ចេះវិភាគបញ្ហា និងចេះរកដំណោះស្រាយលើបញ្ហានានា ដែលកើតឡើង
- អាចចេះបង្កើតនូវគោលនយោបាយថ្មីស្របតាមតម្រូវការចាំបាច់ និងសំណើដើម្បីសុំឱ្យមានការកែប្រែ
- មានសមត្ថភាព ក្នុងការធ្វើជាតំណាងស្របច្បាប់ឱ្យអង្គការសង្គមស៊ីវិល ដែលបំរើផលប្រយោជន៍ឱ្យអ្នករងគ្រោះ
- មានចំណេះដឹងក្នុងការធ្វើការវិភាគលើបរិស្ថាននយោបាយ និងគោលនយោបាយ ។

## ១២- យុទ្ធសាស្ត្រនៃការតវ៉ាបញ្ចុះបញ្ចូល

ដូចបានជំរាបជូនខាងលើរួចមកហើយ ការតវ៉ាបញ្ចុះបញ្ចូល គឺជាសិល្បៈមួយដែលអ្នកតស៊ូមតិ ប្រើដើម្បីធ្វើយ៉ាងណាឱ្យអ្នកសម្រេចចិត្តគាំទ្រនូវអ្វីដែលខ្លួនចង់បាន តាមរយៈការជួបដោយផ្ទាល់ ជាមួយអ្នកសម្រេចលើគោលនយោបាយ ។ ដើម្បីទទួលបាននូវជោគជ័យខាងលើនេះ អ្នកតវ៉ាបញ្ចុះបញ្ចូលប្រើនូវយុទ្ធសាស្ត្រ ដូចខាងក្រោម ៖

**ការជួបជាផ្លូវការ ៖** ដូចជាការទៅជួបរយៈពេលខ្លី ជាមួយអ្នកដែលមានសិទ្ធិអំណាច ក្នុងការសម្រេចចិត្ត នៅការិយាល័យរបស់គេ ឬកន្លែងធ្វើការរបស់គេ ឬការពិភាក្សាជាសាធារណៈ ។

**ការជួបមិនផ្លូវការ ៖** គឺជាការរង់ចាំនៅមុខ ឬខាងក្នុងរដ្ឋសភា ដើម្បីជួបជាមួយអ្នកច្បាប់អ្នកតំណាងរាស្ត្រ ដើម្បីពិភាក្សាបញ្ហាមុនពេលសេចក្តីព្រាងច្បាប់ត្រូវបានគេបោះឆ្នោត បង្កើតឱ្យមានបណ្តាញនៅកន្លែងទទួលភ្ញៀវនៃរដ្ឋសភា ឬការពិភាក្សាជាមួយសមាជិកសហគមន៍នៅទីប្រជុំរបស់គេ ហើយក៏រាប់បញ្ចូលផង ដែរនូវការជួបជាមួយមន្ត្រីនីតិបញ្ញត្តិ អ្នកតំណាងរាស្ត្រនៅសណ្ឋាគារ ភោជនីយដ្ឋាន ការធ្វើលំហាត់ប្រាណក្លឹប ឬផ្ទះ ពេលអាហារថ្ងៃត្រង់ អាហារសម្រន់ជាដើម ។

អ្នកតវ៉ាបញ្ចុះបញ្ចូល ត្រូវតែរៀបចំព័ត៌មានឱ្យបានច្បាស់លាស់ និងរៀបចំ យុទ្ធសាស្ត្ររួចជាស្រេច ដើម្បីអាចត្រៀមខ្លួនបានយ៉ាងល្អក្នុងការឆ្លើយតបទៅនឹងសំនួរ ឬបញ្ហាដែលនឹងអាចកើតឡើងដោយចៃដន្យ និងដើម្បីអាចរក្សាឱ្យមានទំនុកចិត្ត នៅពេលដែលនិយាយទៅកាន់អ្នកមានអំណាចណាម្នាក់ ។ យើងទទួលស្គាល់ថាការតវ៉ាបញ្ចុះបញ្ចូលពិតជាមានការលំបាក និងស្មុគស្មាញ ព្រោះការងារនេះត្រូវធ្វើជាមួយនឹងអ្នកមានអំណាច ។ ដូច្នេះជំហាននៃការតវ៉ាបញ្ចុះបញ្ចូល ត្រូវតែអាចឆ្លើយតបទៅនឹងភាពចម្រូងចម្រាសនេះ ។ ដើម្បីឆ្លើយតបទៅនឹងបញ្ហាចម្រូងចម្រាសនេះ អ្នកតវ៉ាបញ្ចុះបញ្ចូលត្រូវតែវិភាគទៅលើកត្តាខាងក្នុង និងខាងក្រៅ ។

# ផ្នែកទី៦

# អំពី

# ការត្រួតពិនិត្យ

# និង ការវាយតម្លៃ

# ផ្នែកទី៦
# ការត្រួតពិនិត្យ និងការវាយតម្លៃ

## ១- ហេតុអ្វីយើងត្រូវធ្វើការត្រួតពិនិត្យ និងការវាយតម្លៃ

អ្នកតស៊ូមតិមួយចំនួនបានគិតថា បរិបទ និងស្ថានភាពនៃការតស៊ូមតិមានភាពខុសពីគ្នាពីកន្លែងមួយទៅកន្លែងមួយ ពីប្រទេសមួយទៅប្រទេសមួយ ។ ដូច្នេះអ្នកនោះគិតថា វាមានការពិបាកណាស់ ក្នុងការត្រួតពិនិត្យ និងវាយតម្លៃ បើសិនជាយើងពុំមានស្តង់ដារួមមួយដើម្បីវាស់នូវជោគជ័យទាំងនោះ ។ ការលំបាកមួយទៀត គឺថាជោគជ័យនៃការតស៊ូមតិ ពុំបង្ហាញឱ្យយើងឃើញភ្លាម១ ដូចជោគជ័យនៃការងារអភិវឌ្ឍន៍ ។ ឧទាហរណ៍ ជាក់ស្តែងតើយើងអាចវាស់បានទេ ថាតើលទ្ធិប្រជាធិបតេយ្យនៅប្រទេសកម្ពុជា មានការរីកចម្រើន ដល់កម្រិតណា ទោះបីជាយើងឃើញថា ធាតុពិតថាវាមានការប្រែប្រួលច្រើនក៏ដោយចាប់ពីឆ្នាំ ១៩៩៣មក ។ អ្នកអាចរាប់សំបុត្រ ឬញត្តិដែលអ្នកបានផ្ញើចេញបាន តែលោកអ្នកពិបាកនឹងវាស់ឱ្យបានដឹងពិតប្រាកដថា តើគេយល់លើសំបុត្រ និងញត្តិ ឬដោះស្រាយតាមសំណូមពររបស់លោកអ្នកបានប៉ុន្មាន? ។ ប៉ុន្តែទោះបីយ៉ាងណាក៏ដោយ ក៏ម្ចាស់មូលនិធិ និងអង្គការមិនមែនរដ្ឋាភិបាលនៅតែទទួលស្គាល់ថា ការវាស់វែងលើការតស៊ូមតិ ជាការសំខាន់ដើម្បីកំណត់នូវកត្តា ជោគជ័យ និងបរាជ័យនៃការតស៊ូមតិ ។

ក្នុងអត្ថបទនេះ យើងនឹងពិភាក្សាលើផលប្រយោជន៍ និងភាពខុសគ្នានៃការត្រួតពិនិត្យ និងការវាយតម្លៃ និងដំណើរការនៃការត្រួតពិនិត្យ និងវាយតម្លៃលើដំណើរការ នៃការតស៊ូមតិរបស់អង្គការមិនមែនរដ្ឋាភិបាល និងអង្គការសង្គមស៊ីវិលដទៃ១ទៀត ដែលបានអនុវត្ត កន្លងមករួមទាំងបញ្ហាផ្សេង១ដែលគេបានជួបប្រទះ ។



## ២- តើការត្រួតពិនិត្យ និងវាយតម្លៃផ្តល់ប្រយោជន៍អ្វីខ្លះដល់យើង ?

### ក/ ការត្រួតពិនិត្យ និងការវាយតម្លៃជួយឱ្យរបាយការណ៍ថវិកាយើងមានភាពគួរឱ្យជឿជាក់បាន (មិនភូតភរ)

កាលណាយើងបានធ្វើការត្រួតពិនិត្យ និងវាយតម្លៃត្រឹមត្រូវ យើងអាចបង្ហាញទៅម្ចាស់មូលនិធិ អំពីការប្រើធនធានថវិកាដ៏ត្រឹមត្រូវ និងមានប្រសិទ្ធភាព ។ យើងអាចបង្ហាញផងដែរ អំពីហេតុផល និងរបៀបដែលអ្នកអនុវត្តនូវការងារ ហើយអ្នកអាចរៀបរាប់បានថា តើយុទ្ធសាស្ត្រអ្វី ដែលអាចជួយឱ្យយើងសម្រេចបាននូវគោលដៅរយៈពេលវែង និងខ្លីក្នុងការប្រែនូវជីវភាពរបស់ប្រជាពលរដ្ឋ ដូចដែលអ្នកបានកំណត់ទុក ។

### ខ/បង្ហាញអំពីការតស៊ូមតិ ឱ្យមានប្រសិទ្ធភាពក្នុងការកែលំអជីវភាពក្រុមគោលដៅ

លោកអ្នកពិតជាមានការលំបាក ក្នុងការពិនិត្យមើលថា គោលនយោបាយដែលអ្នកតស៊ូមតិនោះ បានរួមចំណែកក្នុងការធ្វើឱ្យជីវភាពរស់នៅរបស់ក្រុមគោលដៅរបស់អ្នកមានភាពប្រសើរនោះ ។ ម្យ៉ាងវិញទៀត លទ្ធផលដែលធ្វើឱ្យមានការផ្លាស់ប្តូរនោះ ពុំមែនអាចជោគជ័យទៅបានដោយគ្មានអ្នកខាងក្រៅជួយនោះទេ។ ដូច្នេះដើម្បីវាស់វែងនូវការរីកចម្រើននេះបាន យើងត្រូវចាត់មនុស្សឱ្យធ្វើការស្រាវជ្រាវជាមួយក្រុមដែលពាក់ព័ន្ធជាមួយយើង ។ ធ្វើរបៀបនេះ ទើបយើងអាចបង្ហាញអំពីទំហំនៃជោគជ័យរបស់យើងប៉ុណ្ណា ដែលជួយធ្វើឱ្យជីវភាពរបស់ក្រុមគោលដៅរបស់អ្នកមានភាពរីកចម្រើន ។



### គ/ រៀនសូត្រពីបទពិសោធន៍

ពុំមានកម្មវិធីតស៊ូមតិណាមួយ ដែលដូចគ្នាបេះបិទនោះទេ ។ ដើម្បីសម្រេចថាកម្មវិធីណាមួយ ជោគជ័យ ឬមិនជោគជ័យនោះ យើងត្រូវមើលទៅលើយុទ្ធសាស្ត្ររួម ដែលគេយកទៅអនុវត្តនៅក្នុងស្ថានភាពមួយ ឬយុទ្ធនាការមួយ ។ យើងត្រូវពិនិត្យមើលថា តើយុទ្ធសាស្ត្រដែលគេប្រើនោះ មានឥទ្ធិពលប៉ុណ្ណាទៅលើក្រុមគោលដៅ ដែលយើងបានកំណត់នៅក្នុងកម្មវិធីរបស់យើង ។ ការរៀនសូត្រពីបទពិសោធន៍ គឺជាការងារមួយដែលឆ្លុះបញ្ចាំងជាប្រចាំដើម្បីឱ្យឃើញថា តើការងាររបស់អ្នកកំពុងឈានទៅរកជោគជ័យ ឬបរាជ័យរួចស្វែង

រកយុទ្ធសាស្ត្រថ្មី ដើម្បីកែលំអកម្មវិធីនោះ ។ ការរៀនសូត្រ ពីបទពិសោធន៍ ក៏អាចជួយឱ្យយើងធ្វើការត្រួតពិនិត្យមើលសភាពកាណ៍ការងារខាងក្រៅ ដើម្បីអាចនឹងកាត់បន្ថយនូវកត្តាអវិជ្ជមានផ្សេងៗ ដែលអាចមានឥទ្ធិពលអាក្រក់ទៅលើក្រុមគោលដៅរបស់អ្នក ។ ដូច្នេះការរៀនសូត្រពីបទពិសោធន៍នេះ ហើយជារបៀបដែលមានផលប្រយោជន៍ក្នុងការស្វែងយល់ និងតែងតែតម្រូវសំរាប់យុទ្ធសាស្ត្ររបស់អ្នក ហើយបង្កើនថែមទៀត នូវសមត្ថភាពតស៊ូមតិរបស់អ្នក ។ សំខាន់ជាងនេះទៅទៀតនោះ ការរៀនសូត្រពីបទពិសោធន៍ អាចបានជាជំនួយក្នុងអំណះអំណាងថា ហេតុអ្វីបានជាយើងធ្វើការផ្លាស់ប្តូរផែនការ ឬយុទ្ធសាស្ត្រដោយមិនបាច់ចំណាយពេលវេលាធ្វើការប្រមូលទិន្នន័យ ។

## ៣- តើការត្រួតពិនិត្យ និងវាយតម្លៃខុសគ្នាយ៉ាងដូចម្តេច ?

ការត្រួតពិនិត្យ និងការវាយតម្លៃ ប្រសិនបើគេពុំបានវែកញែក និងចែកឱ្យដាច់ពីគ្នាទេនោះ គេនឹងមានការយល់ច្រឡំលើពាក្យទាំងពីរម៉ាត់នេះជាពុំខាន ។ ដើម្បីឱ្យលោកអ្នកបានយល់ច្បាស់ខ្ញុំសូមជំរាបជូនអំពីនិយមន័យនៃពាក្យនីមួយៗដូចខាងក្រោមនេះ :

**ការត្រួតពិនិត្យ** គឺជាដំណើរការប្រមូលព័ត៌មានតាមដំណាក់កាលនីមួយៗ នៃគម្រោងដើម្បីស្វែងយល់អំពីអ្វីដែលកំពុងកើត និងដើម្បីរៀបចំឱ្យមានការកែប្រែបើសិនជាចាំបាច់ ។ យើងអាចនិយាយបានម្យ៉ាងទៀតថាការត្រួតពិនិត្យគឺជាការស្វែងយល់ នូវអ្វីដែលកំពុងតែកើតឡើង នៅក្នុងដំណើរការនៃគម្រោងរបស់យើង ។ ការ ត្រួតពិនិត្យគេអាចធ្វើឡើង ១ខែម្តង ៣ខែម្តង និង ៦ខែម្តង ។

រីឯ**ការវាយតម្លៃ**វិញ គឺជាការប៉ាន់ប្រមាណលើគម្រោងមួយ ។ គេអាចធ្វើវានៅពាក់កណ្តាលគម្រោង ឬពេលបញ្ចប់នៃគម្រោង ។ ការវាយតម្លៃរាប់ទាំងការពិនិត្យមើលភាពបរាជ័យ និងជោគជ័យផងដែរ ។ និយាយជារួមការវាយតម្លៃធ្វើឡើង ដើម្បីស្វែងយល់នូវអ្វីៗ ដែលបានកើតឡើងហើយ រួចហើយយើងប្រើលទ្ធផលនោះ សំរាប់ជាប្រយោជន៍ក្នុងការធ្វើផែនការអនាគត ។ ដើម្បីធ្វើការត្រួតពិនិត្យ និងវាយតម្លៃបានលុះត្រាតែយើងបាន ធ្វើផែនការសកម្មភាព ដូចមានជាឧទាហរណ៍ បង្ហាញនៅខាងក្រោមៈ

## ផែនការសកម្មភាពនៃយុទ្ធនាការតស៊ូមតិ

| គោលបំណង | លទ្ធផលរំពឹងទុក | សន្ទស្សន៍ | អង្គគោលដៅ | សម្ព័ន្ធមិត្ត | សកម្មភាព | ពេលវេលា |
|---|---|---|---|---|---|---|
| • ក្នុងរយៈពេលពីរឆ្នាំ រដ្ឋសភា នឹងអនុម័តគោលនយោបាយមួយ ដើម្បីផ្តល់កិច្ចការពារកាន់តែច្រើនថែមទៀតដល់ជនក្រីក្រ និងខ្សត់ខ្សោយដែលរងគ្រោះដោយសារការរុះរើទីលំនៅ ។ | • រដ្ឋសភាទទួលយកចំនួន៥០ភាគរយនៃការផ្លាស់ប្តូរដែលស្នើឡើងដោយអង្គការមិនមែនរដ្ឋាភិបាល ដើម្បីដាក់បញ្ចូលទៅក្នុងគោលនយោបាយជាតិស្តីអំពីការតាំងទីលំនៅជាថ្មី ។ | • ច្បាប់ចម្លងនៃគោលនយោបាយរបស់រដ្ឋសភា<br>• លិខិតចេញពីរដ្ឋសភានិយាយលំអិតអំពីគោលនយោបាយនោះ<br>• របាយការណ៍តាមបណ្តាញសារព័ត៌មាននិយាយលំអិតអំពីគោលនយោបាយចេញដោយរដ្ឋសភា | • រដ្ឋសភា<br>• អង្គការមនុស្សធម៌ ឬជំនួយសង្គ្រោះអន្តរជាតិ<br>• ម្ចាស់អំណោយ<br>• ប្រព័ន្ធផ្សព្វផ្សាយ | • សមាជិកបណ្តាញអង្គការមិនមែនរដ្ឋាភិបាល<br>• ធនាគារពិភពលោក<br>• ធនាគារអភិវឌ្ឍន៍អាស៊ី | • រៀបចំយុទ្ធសាស្ត្រក្នុងចំណោមសមាជិកចម្រុះ<br>• បញ្ចុះបញ្ចូលសមាជិករដ្ឋសភាតាមរយៈការជួបផ្ទាល់ និងសិក្ខាសាលាយុទ្ធនាការតាមរយៈប្រព័ន្ធផ្សព្វផ្សាយដើម្បីប្រមូលសាធារណជន | ឆ្នាំទី ១-ទី២ |
| • ផែនការតាំងទីលំនៅជាថ្មីដ៏ច្បាស់លាស់មួយនឹងត្រូវធ្វើសមាហរណកម្មទៅក្នុងផែនការ ៥ឆ្នាំរបស់អាជ្ញាធរដែនដី | • ផែនការអភិវឌ្ឍន៍ជាតិនឹងមានបញ្ចូលផែនការតាំងទីលំនៅជាថ្មីមួយ | • មានផែនការតាំងទីលំនៅជាថ្មីនៅក្នុងផែនការអភិវឌ្ឍន៍ | • រដ្ឋមន្ត្រីក្រសួងផែនការ | • សមាជិក<br>• បណ្តាញអង្គការមិនមែនរដ្ឋាភិបាល<br>• អាជ្ញាធរដែនដី<br>• ក្រុមការងារផែនការយុទ្ធសាស្ត្រកាត់បន្ថយភាពក្រីក្រថ្នាក់ជាតិ | • ស្រាវជ្រាវជម្រើសផែនការតាំងទីលំនៅជាថ្មី<br>• រៀបចំនិងបង្ហាញខ្លឹមសារជូនក្រុមការងារផែនការយុទ្ធសាស្ត្រកាត់បន្ថយភាពក្រីក្រថ្នាក់ជាតិ និងអាជ្ញាធរដែនដី | ឆ្នាំទី២ |
| • ពាក្យបណ្តឹងរបស់ជនក្រីក្រ និងជនដែលងាយរងគ្រោះដែលបានដាក់ជូនអាជ្ញាធរពាក់ព័ន្ធបានទទួលដឹងឮ និងត្រូវបានចាត់វិធានការ ។ | • យ៉ាងហោចណាស់៥០ភាគរយនៃករណីដែលចាត់ចែងដោយបណ្តាញប្រព្រឹត្តិកម្មរុះរើតាំងទីលំនៅជាថ្មីនាំមកនូវភាពប្រសើរលើស្ថានភាពប្រជាពលរដ្ឋដែលត្រូវផ្លាស់ប្តូរទីលំនៅហើយមានកត់ត្រាទុកជាឯកសារ ។ | • រយៈពេលឆ្លើយតបពីរដ្ឋាភិបាល<br>• ចំនួនករណីដែលត្រូវដោះស្រាយ | • អង្គការមនុស្សធម៌ ឬជំនួយសង្គ្រោះអន្តរជាតិ | • សមាជិកបណ្តាញអង្គការក្រៅរដ្ឋាភិបាល<br>• ធនាគារពិភពលោក<br>• ធនាគារអភិវឌ្ឍន៍អាស៊ី<br>• សហគមន៍រងគ្រោះ | • ធ្វើអង្កេតលើក្រុមរងគ្រោះ និងចេញរបាយការណ៍តាមរយៈសន្និសីទការសែត<br>• ប្រមូលករណីស្របច្បាប់ពីជនរងគ្រោះ | ឆ្នាំទី៣ |

ដកស្រង់ឯកសារពីកម្រងអត្ថបទសម្រាប់អ្នកជំនាញតស៊ូមតិ ភាគ១ ស្ដីពីការគ្រប់គ្រងយុទ្ធនាការការតស៊ូមតិ បោះពុម្ពនៅឆ្នាំ២០០៤ របស់អង្គការផាក

ធាតុសំខាន់៧ សំរាប់ការធ្វើផែនការតស៊ូមតិឱ្យទទួលបានជោគជ័យមាន ៖
**គោលបំណង ៖** អ្វីដែលយើងកំណត់ ហើយគិតថានឹងអាចឈានទៅដល់ទិសទៅនោះ ។
**សន្ទស្សន៍ ៖** ជាភស្តុតាងដែលអ្នកនឹងប្រមូលដើម្បីបង្ហាញថា លទ្ធផល ឬឥទ្ធិពលនោះបានសម្រេច ។
**លទ្ធផលរំពឹងទុក ៖** គឺលទ្ធផលដែលអ្នកគិតនឹងបានទទួលក្នុងរយៈពលខ្លី ហើយអាចរាប់បានទៀតផង ។
**ធនធាន ៖** អ្វីដែលយើងប្រើប្រាស់ដើម្បីឱ្យសកម្មភាព យើងអាចសម្រេចតាមគោលបំណង ។ ធនធាន ទីនេះ មានន័យថា បុគ្គលិកអ្នកស្ម័គ្រចិត្ត និងថវិកាដែលប្រើប្រាស់សំរាប់គម្រោង ។
**ឥទ្ធិពល ៖** ផលដែលអ្នកសង្ឃឹមថានឹងធ្វើឱ្យមានការផ្លាស់ប្ដូរសភាពការណ៍ ឬជីវភាពក្រុមគោលដៅរបស់អ្នក ក្រោយពីការតស៊ូមតិរបស់អ្នកបានបញ្ចប់ ។

## ៤-ការត្រួតពិនិត្យ

### សន្ទស្សន៍នៃការត្រួតពិនិត្យ

យើងមិនត្រូវប្រើរបៀបតែមួយដើម្បីវាស់វែងនូវលទ្ធផល ដែលចេញពីការតស៊ូមតិនោះឡើយ ។ យើងត្រូវចងចាំថា អ្នកដែលផ្ដល់កិច្ចសម្ភាសន៍ ឬប្រមូលព័ត៌មាន ឬទិន្នន័យនោះជួនកាលពុំបានផ្ដល់ព័ត៌មានត្រឹមត្រូវដល់យើងឡើយ ។ ឧទាហរណ៍ អ្នកនយោបាយ ឬអ្នកដែលធ្វើការសម្រេចចិត្តលើគោលនយោបាយចូលចិត្ត ប្រាប់យើងនូវអ្វីដែលហួសពីការពិត ។ គេធ្វើនេះជួនកាល ក្នុងគោលបំណងបង្អាក់ដំណើរ ឬបំបាក់ស្មារតីអ្នកតស៊ូមតិកុំឱ្យធ្វើការងារបន្តទៅទៀត ។ ដូច្នេះលទ្ធផលនេះពុំចាត់ទុកថា ជាលទ្ធផលដែលឆ្លុះបញ្ចាំងនូវ ជោគជ័យ ឬបរាជ័យពិតប្រាកដនៃការតស៊ូមតិរបស់យើងឡើយ ។ ខាងក្រោមនេះ ជាឧទាហរណ៍មួយ នៃរបៀបប្រមូលសន្ទស្សន៍ ដែលអង្គការមិនមែនរដ្ឋាភិបាលធ្លាប់ប្រើសំរាប់ការត្រួតពិនិត្យនៃការតស៊ូមតិរបស់គេ ៖

### ៤.១. ការត្រួតពិនិត្យក្រុមដៅរបស់អ្នក

សង្កេតមើល និងកត់ត្រាលើសការប្រែប្រួលនៃក្រុមគោលដៅរបស់អ្នក ដោយពិនិត្យមើលថា តើពួកគេចូលរួមសកម្ម ឬមិនសកម្ម ពេញ ឬមិនពេញចិត្តយ៉ាងណា លើការងារសកម្មភាព ឬយុទ្ធនាការរបស់អ្នក ។ កត់ត្រានូវអ្វី ដែលគេបាននិយាយអំពីកម្មវិធី និងយុទ្ធនាការរបស់អ្នក ។ រក្សាទុកឱ្យបានត្រឹមត្រូវនូវឯកសារដូចជាសេចក្ដីថ្លែងការណ៍ អនុសាសន៍ពាក្យបណ្ដឹងដែលក្រុមគោលដៅបានផ្ញើមកឱ្យអ្នក។

### ៤.២.ការត្រួតពិនិត្យនូវទំនាក់ទំនងរបស់អ្នក

កត់ត្រាចំនួនប្រធានបទ ដែលអ្នកបានពិភាក្សាជាមួយក្រុមគោលដៅ និងអ្នកដែលពាក់ព័ន្ធ ។ តើអ្នកបានលើកនូវគំនិតថ្មីមកពិភាក្សាដែរ ឬទេ ? តើគេទុកចិត្ត និងជឿលើគំនិតរបស់អ្នកដែលលើកឡើងប៉ុណ្ណា ? តើគេទទួលស្គាល់ថាអ្នកជាអ្នកផ្ដល់ព័ត៌មានពិតដល់គេដែរ ឬទេ?

### ៤.៣. ការត្រួតពិនិត្យលើបណ្ដាញព័ត៌មាន

វិភាគថា តើអ្នកសារព័ត៌មានបានទទួលយកនូវអត្ថបទរបស់អ្នក ដើម្បីទៅផ្សព្វផ្សាយដែរ ឬទេ? ។ រាប់វាក្យខណ្ឌ ឬបន្ទាត់នៃអត្ថបទ ដែលអ្នកសារពត៌មានបានចុះផ្សាយអំពីការតស៊ូមតិរបស់អ្នក ហើយពិនិត្យអំពីតុល្យភាពនៃការគាំទ្រ និងការប្រឆាំងទៅលើអត្ថបទទាំងនោះ ។

### ៤.៤. ការត្រួតពិនិត្យលើកិត្តិស័ព្ទ

- ✠ កត់ត្រាចំនួនអ្នក ដែលបានសាកសួរព័ត៌មានអំពីការតស៊ូមតិរបស់អ្នក ?
- ✠ តើមានប្រជាជន ឬក្រុមគោលដៅ ប៉ុន្មាននាក់ ដែលបានមកជួបអ្នកដោយគ្មានការអញ្ជើញ ?
- ✠ តើមានប្រជាជន ឬក្រុមគោលដៅប៉ុន្មាននាក់បានដឹងអំពីការតស៊ូមតិបស់អ្នក? ដឹងដោយរបៀបណា ?ដឹងយ៉ាងដូចម្ដេច ? ដឹង ពីកន្លែងណា និងកម្រិតណា?

### ៤.៥.ការត្រួតពិនិត្យលើមតិសាធារណៈ

- ✠ វិភាគទៅលើប្រជាប្រិយភាព និងប្រសិទ្ធភាពនៃការងាររបស់យើង តាមរយៈការបង្កើតគណៈកម្មការឯករាជមួយដើម្បី ធ្វើការស្រាវជ្រាវ និងស្ទង់មតិលើមតិសាធារណជន ។

## ៥-ការវាយតម្លៃ

### ៥.១. របៀបនៃការវាយតម្លៃ

មានរបៀបជាច្រើន ដើម្បីធ្វើការវាយតម្លៃទៅលើប្រសិទ្ធភាព នៃការតស៊ូមតិ ។ របៀបដែលគេធ្លាប់

ប្រើ រួមមានទាំងការវាយតម្លៃតាមរបៀបធម្មតា (ការវាយតម្លៃដោយខ្លួនយើង ឬនិស្សិតដែលកំពុងសិក្សាជាដើម) និងការវាយតម្លៃតាមរបៀបផ្លូវការ (ជួលកាលអ្នកជំនាញពីក្រៅ) ។ ការវាយតម្លៃ ត្រូវធ្វើឡើងស្របទៅតាមគោលបំណង នៃសកម្មភាពរបស់យើង (ធំ ឬតូច ?) ហើយត្រូវពឹងផ្អែកលើធនធាន ដែលយើងមានផងដែរ ។ បើសិនជាគោលបំណងរបស់អ្នកមានភាពច្បាស់លាស់ ឧទាហរណ៍ថា អ្នកនឹងផ្តល់សេវាសុខភាពជូនប្រជាពលរដ្ឋ៥០គ្រួសារនោះ អ្នកត្រូវប្រើរបៀបវាយតម្លៃពីរគឺ **ការវាយតម្លៃលើដំណើរការ និងការវាយតម្លៃលើលទ្ធផល** ។ ប៉ុន្តែប្រសិនបើគោលបំណងរបស់អ្នកធំធេង (មហិច្ឆតា) ឧទាហរណ៍ ដូចជាការចង់កាត់បន្ថយនូវអត្រាអ្នកមានផ្ទៃពោះ និងការចម្លងជំងឺកាមរោគក្នុងចំណោមមនុស្សពេញវ័យ ទូទាំងប្រទេសកម្ពុជា នោះអ្នកត្រូវប្រើធ្វើការវាយតម្លៃទាំងបីគឺការ **វាយតម្លៃលើដំណើរការ ការវាយតម្លៃលើលទ្ធផល និងការវាយតម្លៃលើឥទ្ធិពល** ។

### ៥.១.១. ការវាយតម្លៃលើដំណើរការ

ការវាយតម្លៃលើដំណើរការ ជារបៀបមួយដែលសាមញ្ញ និងត្រូវការចំណាយថវិកាតិចបំផុតផងដែរ ។ ការវាយតម្លៃលើដំណើរការ ធ្វើឡើងដើម្បីពិនិត្យថា តើសកម្មភាព យើងបានផ្តល់ដល់ក្រុមគោលដៅបានដូចយើងបានធ្វើផែនការដែរ ឬទេ ? ហើយសមស្របជាមួយថវិកាដែលយើងប្រើ ឬអត់? ការវាយតម្លៃលើដំណើរការបង្ហាញលទ្ធផលពីរគឺ (១)ទិន្នន័យបរិមាណ ដែលបង្ហាញអំពីចំនួនសកម្មភាព ដែលយើងបានធ្វើដូចជាចំនួនបណ្តាញព័ត៌មាន ដែលយើងបានផ្តល់ការសម្ភាសន៍ ចំនួននៃការជួបប្រជុំជាមួយថ្នាក់ដឹកនាំរដ្ឋាភិបាលជាដើម (២)ទិន្នន័យ គុណភាពរៀបរាប់ អំពីអារម្មណ៍នៃការជួបគ្នា ឬកម្រិតនៃការទទួលយកនូវសំណើ និងយុទ្ធនាការរបស់យើង ។

**សំនួរខាងក្រោមនេះ ត្រូវបានគេប្រើសំរាប់ការវាយតម្លៃលើដំណើរការ :**

- ✠ តើមានអ្នកដឹកនាំរដ្ឋាភិបាល ឬអ្នកធ្វើគោលនយោបាយប៉ុន្មាននាក់ ដែលបានទទួលព័ត៌មានអំពីការតស៊ូមតិរបស់អ្នក ?
- ✠ តើមានសេចក្តីថ្លែងការណ៍ ឬញត្តិប៉ុន្មាន ដែលត្រូវបានគេបញ្ជូនទៅដល់សាធារណជន?
- ✠ តើអ្នកធ្វើគោលនយោបាយឬអ្នកដឹកនាំរដ្ឋាភិបាលបានប្រជុំប៉ុន្មានដង ដើម្បីពិភាក្សាលើសេចក្តីស្នើរបស់អ្នក ?
- ✠ តើបណ្តាញព័ត៌មានបានចុះផ្សាយ ឬសម្ភាស ប៉ុន្មានដងអំពីការងាររបស់អ្នក ?
- ✠ តើអង្គការរបស់អ្នក ឬកម្មវិធីរបស់អ្នកមានសមាជិកប៉ុន្មាន ? តើមានបណ្តាញផ្សេងៗ ដែល

បានចូលរួមជាមួយនឹងការតស៊ូមតិរបស់អ្នក ?

ការប្រមូលព័ត៌មានតាមរបៀបខាងលើនេះ មានសារៈសំខាន់ណាស់ ព្រោះអ្នកអាចកំណត់បានថា ការតស៊ូមតិរបស់អ្នកកំពុងដើរលើផ្លូវ ដែលអ្នកបានកំណត់ទុក ។ ប៉ុន្តែអ្នកមិនត្រូវប្រើពេលវេលាច្រើនហួសហេតុពេកទេ សំរាប់ការវាយតម្លៃលើដំណើការនេះ ។

### ៥.១. ២. ការវាយតម្លៃលើលទ្ធផល

ការវាយតម្លៃនេះ សំដៅទៅលើការវាយតម្លៃលើឥទ្ធិពល ដែលការតស៊ូមតិរបស់អ្នកអាចសម្រេចបានក្នុងរយៈពេលខ្លី ។ ឧទាហរណ៍ បើគោលបំណងរបស់អ្នកថា ចង់ឱ្យយុវជនអាចទទួលបានព័ត៌មានស្តីពីការអប់រំ និងសេវាកម្មសុខភាពផ្សេងៗនោះ គោលដៅរបស់អ្នកប្រាកដជាចង់ ឱ្យមានការកែប្រែគោលនយោបាយផ្សព្វផ្សាយនៃមជ្ឈមណ្ឌលសុខភាព ឧសថស្ថាន ឬសាលារៀនជាក់ជាពុំខានឡើយ ។ លទ្ធផលដែលទទួលបានពីការវាយតម្លៃលើលទ្ធផល នឹងប្រាប់អ្នកអំពីការរីកចម្រើនដែលកំពុងតែឈានទៅដល់ការសម្រេចនៃទិសដៅ ដែលអ្នកបានកំណត់ទុក ។

**សំនួរដែលអាចយកមកប្រើសំរាប់ការវាយតម្លៃលើលទ្ធផល មានដូចខាងក្រោម :**

✠ តើការយល់ដឹងរបស់អ្នកដឹកនាំលើសុខភាពផ្លូវភេទរបស់យុវជនមានការរីកចម្រើន ឬទេ?

✠ តើមានអ្នកដឹកនាំប៉ុន្មានអ្នក ដែលគាំទ្រនូវកម្មវិធីនេះ ?

✠ តើគោលនយោបាយ ដែលយើងផ្តោតនោះ មានការកែប្រែដែរ ឬទេ ?

✠ តើសាធារណជនបានទទួល និងគាំទ្រលើការកែប្រែគោលនយោបាយនោះដែរ ឬទេ?

### ៥.១. ៣. ការវាយតម្លៃលើឥទ្ធិពល

ការវាយតម្លៃលើឥទ្ធិពល គឺជាការវាយតម្លៃលើគោលបំណង (រយៈពេលវែងនៃការតស៊ូមតិរបស់អ្នក) ។ បើសិនបើជាអ្នកធ្វើការតស៊ូមតិទាក់ទងទៅនឹងការអប់រំសុខភាព គោលបំណងរបស់អ្នក ប្រាកដជាចង់ឱ្យមានឥទ្ធិលើគោលនយោបាយសុខភាព ទាំងថ្នាក់មូលដ្ឋានជាតិ ឬតំបន់ទៀតផង ។ ការវាយតម្លៃលើឥទ្ធិពល ត្រូវការចំណាយថវិកា និងពេលវេលាច្រើនហើយគេ ធ្វើតែចំពោះសកម្មភាពណាដែលធំៗ ឬការងារតស៊ូមតិដែលសំខាន់ៗ ។ ការវាយតម្លៃលើឥទ្ធិពល គេធ្វើបន្ទាប់ពីសកម្មភាពដែលកើតឡើងរយៈពេលវែងគឺ ចាប់ពី បីឆ្នាំ ឬប្រាំឆ្នាំឡើងទៅ ។

**ការវាយតម្លៃរយៈពេលវែង ឆ្លើយតបទៅនឹងសំនួរដូចខាងក្រោម :**

✠ តើមានការថយចុះនូវអត្រា នៃការមានផ្ទៃពោះរបស់យុវនារីមុនពេលរៀបការដែរ ឬទេ ?

✠ តើមានការថយចុះនូវអត្រានៃការមានផ្ទៃពោះរបស់យុវនារី ដែលបានរៀបការដែរ ឬទេ ?
✠ តើការរីករាលដាលនៃការឆ្លងជំងឺកាមរោគក្នុងចំណោមយុវជនមានការថយចុះដែរ ឬទេ ?
✠ តើចំនួនអ្នក ដែលទទួលសេវាកម្មសុខភាពបានកើនឡើងដែរ ឬទេ ?
✠ តើមានការកើនឡើងនូវការអនុវត្តន៍តាមរបៀបថ្មី ដែលកម្មវិធីអ្នកបានផ្សព្វផ្សាយ នោះទេ ?

ការវាយតម្លៃតាមរបៀបណាមួយណាក៏ដោយ ទាមទារឱ្យមានចុះធ្វើសម្ភាសន៍ផ្ទាល់ ជាមួយក្រុមគោលដៅ ហើយត្រូវធ្វើឱ្យបានហ្មត់ចត់ និងសមស្របទៅតាមធនធាន និងសមត្ថភាពនៃកម្មវិធីរបស់អ្នក ។ បើសិនជាអ្នកពិនិត្យឃើញថាតម្រូវការនៃការវាយតម្លៃនោះ ហួសសមត្ថភាពរបស់បុគ្គលិកយើង យើងអាចរកសិស្សនិស្សិត ដែលបញ្ចប់មហាវិទ្យាល័យថ្មីៗ ដើម្បីជួយយើងក្នុងការវាយតម្លៃ ។ អ្នកនេះបើគេត្រូវការថវិកា ក៏តិចតួចជាង អ្នកដែលមានវិជ្ជាជីវៈវាយតម្លៃ ។ ម្យ៉ាងវិញទៀត ការវាយតម្លៃនេះអាច ផ្តល់ប្រយោជន៍ដល់ការសិក្សារបស់ពួកគេទៀតផង ។

## ៥.២. សន្ទស្សន៍ដែលគួរប្រើសំរាប់ការវាយតម្លៃការតស៊ូមតិ

ខ្ញុំសូមលើកសន្ទស្សន៍ពីរសំខាន់ៗ ដែលអង្គការមិនមែនរដ្ឋាភិបាលធ្លាប់ប្រើ ។ ទីមួយគឺ សន្ទស្សន៍សំរាប់វាស់លើលទ្ធផល និងឥទ្ធិពល (ជោគជ័យខាងក្រៅ) ។ ទីពីរគឺសន្ទស្សន៍ សំរាប់វាស់ការគ្រប់គ្រង (ជោគជ័យខាងក្នុង) ។ សន្ទស្សន៍លទ្ធផល និងឥទ្ធិពលគឺសំរាប់វាស់វែងនូវសកម្មភាពតស៊ូមតិ ដែលរួមចំណែកក្នុងការកសាងលទ្ធិប្រជាធិបតេយ្យ ឬគោលនយោបាយផ្សេងៗ តាមរយៈការលើកទឹកចិត្តឱ្យមានការចូលរួមពីសង្គមស៊ីវិល ក្រុមគោលដៅ ឬប្រជាពលគ្រប់ជាន់ថ្នាក់ជាដើម ។ ចំណែកឯសន្ទស្សន៍ សំរាប់វាស់ការគ្រប់គ្រងគេប្រើសំរាប់វាស់លើសមត្ថភាព និងជោគជ័យនៃការអនុវត្តន៍កម្មវិធី ។

### ៥.២.១. សន្ទស្សន៍លទ្ធផល និងឥទ្ធិពល

ដើម្បីធ្វើការវាស់វែងឱ្យឃើញថា តើអ្នកទទួលបាននូវលទ្ធផល និងឥទ្ធិពលអំពីការតស៊ូមតិ យ៉ាងណានោះ យើងគួរប្រើសំនួរសន្ទស្សន៍ដូចខាងក្រោម :

**សំនួរសំរាប់សន្ទស្សន៍ការកសាងលទ្ធិប្រជាធិបតេយ្យ :**

✠ តើកម្មវិធីរបស់អ្នកបានជ្រួតជ្រាបដល់សាធារណជនទូទៅដែរ ឬទេ ?

- តើមតិសាធារណៈគាំទ្រការតស៊ូមតិរបស់អ្នកដែរ ឬទេ ?
- តើកម្មវិធីរបស់អ្នកបានជួយធ្វើឱ្យមានការរីកចម្រើនលើកិច្ចការសាធារណៈដែរ ឬទេ (ដូចជា ការរៀបចំការបោះឆ្នោតជាតិ ជ្រើសរើសក្រុមប្រឹក្សាឃុំ សេវាសុខភាពជនពិការ ។ល។ និង ។ល។) ?
- តើកម្មវិធីរបស់អ្នកបានជួយកែប្រែទម្រង់នយោបាយ អភិបាលកិច្ចល្អ តម្លាភាពក្នុងរចនាសម្ព័ន្ធរដ្ឋាភិបាលដែរឬទេ ?
- តើកម្មវិធីរបស់អ្នកបានជួយដល់អង្គការដទៃៗដែលកំពុងធ្វើការតស៊ូមតិដែរ ឬទេ ?
- តើកម្មវិធីអ្នកបានជួយដល់ការងារតស៊ូមតិរបស់ក្រុមគោលដៅរបស់អ្នកឱ្យកាន់តែប្រសើរឡើងដែរឬទេ ?
- តើកម្មវិធីរបស់អ្នកបានជួយឱ្យមានសមធមិកាន់តែប្រសើរឡើង នៅក្នុងផ្នែកផ្សេងៗ ដូចជា យេនឌ័រ ជនជាតិភាគតិច និងក្រុមសាសនាជាដើម ឬទេ ?

**សំនួរសន្ទស្សន៍សំរាប់ការរួមចំណែកក្នុងការជួយពង្រឹងសង្គមស៊ីវិល**

- តើការតស៊ូមតិរបស់អ្នក បានជួយពង្រឹងដល់ក្រុមអង្គការសង្គមស៊ីវិលណាខ្លះ (សមាគមគ្រូបង្រៀន សហព័ន្ធសហជីពកម្មករ សាជីវកម្ម គណបក្សនយោបាយ អង្គការអភិវឌ្ឍន៍ ឬបណ្តាញព័ត៌មានជាដើម) ?
- តើកម្មវិធីអ្នក បានជួយជំរុញលើកទឹកចិត្តឱ្យមានការបង្កើតថ្មីថែមទៀត នូវអង្គការ ឬក្រុមខាងលើនេះដែរ ឬទេ ? ថ្នាក់ ជាតិ ភូមិ ឃុំ ស្រុក ខេត្ត?

**សំនួរសំរាប់សន្ទស្សន៍ ការរួមចំណែកធ្វើឱ្យមាននិរន្តរភាព :**

- តើសមត្ថភាពរបស់ក្រុមគោលដៅរបស់អ្នកធ្វើការបានដោយខ្លួនឯងហើយ ឬនៅ ?
- តើក្រុមរៀបរាប់ជូនខាងលើ មាននិរន្តរភាពហើយ ឬទេ ?
- តើគេអាចប្រើធនធានដែលគេមាន ដែរឬ ទេ ?
- តើការយល់ដឹងរបស់ក្រុមគោលដៅមានការអភិវឌ្ឍន៍ ដែរ ឬទេ ?
- តើគេបានយកបទពិសោធន៍ ដែលគេធ្លាប់បានដោះស្រាយបានជោគជ័យទៅប្រើ ដើម្បីដោះស្រាយបញ្ហាផ្សេងៗទៀតដែរ ឬទេ ?

**សំនួរសំរាប់សន្ទស្សន៍ ការកែប្រែគោលនយោបាយ :**

- តើរដ្ឋាភិបាលទទួលយកអ្វី ដែលអ្នកបានស្នើឱ្យបញ្ចូលដែរ ឬទេ ?

- តើមានការផ្លាស់ប្តូរ ឬបង្កើតនូវរចនាសម្ព័ន្ធថ្មី ឬការអនុវត្តន៍ថ្មីនៅក្នុងស្ថាប័នរដ្ឋាភិបាល ឬទេ?
- តើកម្មវិធីរបស់អ្នកបានជំរុញឱ្យមានការផ្លាស់ប្តូរគោលនយោបាយសេដ្ឋកិច្ចរបស់រដ្ឋដែរ ឬទេ?
- តើសមត្ថភាពក្រុមគោលដៅរបស់អ្នក ដែលធ្វើការតស៊ូមតិលើគោលនយោបាយសេដ្ឋកិច្ចមានការរីកចម្រើនដែរ ឬទេ ?

### ៥.២.២. សន្ទស្សន៍ការគ្រប់គ្រង

ដើម្បីធ្វើការវាស់វែងឱ្យឃើញថាតើ ការគ្រប់គ្រងរបស់យើងមានប្រសិទ្ធភាពកម្រិតណា យើងគួរប្រើសំនួរដូចខាងក្រោម :

- តើគោលដៅកម្មវិធីរបស់អ្នកស៊ីគ្នា ទៅនឹងគោលបំណងដែរ ឬទេ ?
- តើអ្វីដែលយើងរំពឹងទុកបានសម្រេចដូចបំណងដែរ ឬទេ ?
- តើយើងធ្វើផែនការ ពិតជាត្រូវទៅនឹងសេចក្តីត្រូវការរបស់ក្រុមគោលដៅដែរ ឬទេ ?
- តើបុគ្គលិកទទួលបាននូវសិទ្ធិក្នុងការចូលរួមធ្វើសេចក្តីសម្រេចចិត្ត និងធ្វើផែនការដែរ ឬទេ ?
- តើសមត្ថភាពបុគ្គលិកមានជំនាញគ្រប់គ្រាន់ក្នុងការបំពេញភារកិច្ចលើផែនការ លើកឡើងដែរ ឬទេ ?
- តើយើងមានយន្តការ ឬយុទ្ធសាស្ត្រសំរាប់ធ្វើការសម្រេចចិត្តដែរ ឬទេ ?
- តើមានគោលការណ៍សំរាប់ការចងក្រងឯកសារដែរ ឬទេ ?
- តើមានសន្ទស្សន៍ត្រឹមត្រូវសំរាប់ធ្វើការវាស់វែងដែរ ឬទេ?

## ៦- តើអ្វីដែលយើងគួរធ្វើការវាយតម្លៃ ?

មុននឹងធ្វើការត្រួតពិនិត្យ និងវាយតម្លៃ អ្នកត្រូវសិក្សាឡើងវិញអំពីរបៀប និងដំណើរការដូចដែលបានរៀបរាប់ខាងលើ ហើយបន្ទាប់មកយើងត្រូវធ្វើការសម្រេចចិត្តថាតើព័ត៌មានអ្វីខ្លះ ដែលយើងត្រូវប្រមែប្រមូល ។ ការប្រមែប្រមូលព័ត៌មាន គួរផ្តោតទៅលើផ្នែកចំនុចបីសំខាន់ៗ ដូចខាងក្រោម :

មានការយល់ដឹង

↓

មានការផ្លាស់ប្តូរគោលនយោបាយ

↓

ជីវភាពប្រជាពលរដ្ឋមានការកែប្រែ

## ៧- បញ្ហាមួយចំនួនដែលគួរពិចារណាលើការត្រួតពិនិត្យ និងការវាយតម្លៃ

ម្ចាស់មូលនិធិ ជាធម្មតាតែងតែចង់ឱ្យដៃគូរបស់ខ្លួនធ្វើការត្រួតពិនិត្យ និងវាយតម្លៃលើគម្រោង ដែលខ្លួនផ្តល់ថវិកា តាមរបៀបដែលខ្លួនធ្លាប់ធ្វើ ឬធ្វើការត្រួតពិនិត្យ និងវាយតម្លៃដោយខ្លួនឯង ឬជួលអ្នកពីក្រៅ (ក្នុងស្រុក ឬក្រៅស្រុក) ដើម្បីធ្វើការត្រួតពិនិត្យ និងវាយតម្លៃលើកម្មវិធីនោះ ។ ម្ចាស់មូលនិធិ ធ្វើបែបនេះ ដើម្បីធានាថាថវិកាដែលគេផ្តល់ឱ្យនោះ ប្រាកដជាត្រូវបានគេយកទៅប្រើដើម្បីផលប្រយោជន៍រួមដោយមានប្រសិទ្ធភាព ។ ប៉ុន្តែការធ្វើបែបនេះជួនកាល អាចធ្វើឱ្យមានបញ្ហាកើតឡើង ចំពោះអ្នកអនុវត្តកម្មវិធីដូចខាងក្រោម ៖

- ✠ ការត្រួតពិនិត្យ និងវាយតម្លៃត្រួតគ្នា ឬដូចគ្នានាំឱ្យខាតធនធានមនុស្ស ថវិកា ពេលវេលាជាដើម
- ✠ អ្នកត្រួតពិនិត្យ និងវាយតម្លៃ ពុំស្គាល់អំពីកម្មវិធីច្បាស់លាស់
- ✠ អ្នកត្រួតពិនិត្យ និងវាយតម្លៃពុំយល់អំពីចំណុចសំខាន់នៃការតស៊ូមតិ ដែលអ្នកតស៊ូមតិកំពុងអនុវត្ត
- ✠ អ្នកត្រួតពិនិត្យ និងវាយតម្លៃខ្លះ គិតថាខ្លួនចេះគ្រប់គ្រាន់ ហើយពុំបាច់រៀនសូត្រពីអ្នកដទៃទៀតទេ
- ✠ អ្នកត្រួតពិនិត្យ និងវាយតម្លៃ ចង់បានព័ត៌មានដែលអ្នកតស៊ូមតិត្រូវលាក់
- ✠ អ្នកត្រួតពិនិត្យ និងវាយតម្លៃ មានបញ្ហាជាមួយអ្នកតស៊ូមតិ ឬលំអៀង
- ✠ ចំណាយច្រើនហួសហេតុលើអ្នកត្រួតពិនិត្យ និងវាយតម្លៃ (អ្នកមកពីខាងក្រៅ)
- ✠ ពុំមានផែនការច្បាស់លាស់ថា ខ្លួននឹងត្រូវត្រួតពិនិត្យ និងវាយតម្លៃទៅលើអ្វី ?

- អ្នកត្រួតពិនិត្យ និងវាយតម្លៃខ្វះការយល់ដឹងអំពីអ្នកទទួលផល
- ត្រូវការមនុស្សច្រើនពេកសំរាប់ក្រុមត្រួតពិនិត្យ និងវាយតម្លៃ

## ៨- ចំណុចសំខាន់ដែលជួយឱ្យការត្រួតពិនិត្យ និងការវាយតម្លៃប្រព្រឹត្តទៅបានល្អ

ខាងក្រោមនេះជាឧទាហរណ៍មួយចំនួន ដែលអាចជួយឱ្យម្ចាស់មូលនិធិ អ្នកត្រួតពិនិត្យ និងវាយតម្លៃ និងអ្នកតស៊ូមតិអាចធ្វើការវាយតម្លៃបានត្រឹមត្រូវ និងពុំសូវមានបញ្ហាបាន៖

- ត្រូវធ្វើផែនការវាយតម្លៃតាំងពីអ្នកចាប់ផ្តើមកម្មវិធី ហើយត្រូវរាយការណ៍អំពីបញ្ហាដែលកើតឡើងនៅពេលអ្នកកំពុងអនុវត្តកម្មវិធី ទៅម្ចាស់មូលនិធិជាប្រចាំ ដើម្បីពិភាក្សាបណ្តើរៗ ។ កុំទុករហូតដល់បញ្ហានោះដោះស្រាយលែងកើត
- ត្រូវធ្វើការត្រួតពិនិត្យ ឬវាយតម្លៃលើកម្មវិធីដោយខ្លួនឯង កុំរង់ចាំតែម្ចាស់មូលនិធិតម្រូវ ឬមកធ្វើ ព្រោះជួនកាលម្ចាស់មូលនិធិពុំមានពេលវេលាគ្រប់គ្រាន់ ឬមានការយល់ដឹងពុំគ្រប់គ្រាន់លើកម្មវិធីរបស់អ្នក ។ដូច្នេះជួនកាលម្ចាស់មូលនិធិអាចធ្វើការវាយតម្លៃខុសលើកម្មវិធីរបស់អ្នក
- ទំនាក់ទំនងជាមួយក្រុមតស៊ូមតិផ្សេងៗទៀត ដើម្បីបង្កើតឱ្យមានយុទ្ធនាការត្រួតពិនិត្យរួម និងច្បាស់លាស់ដើម្បីពិនិត្យមើលសកម្មភាព និងវាយតម្លៃឡើងវិញ លើលទ្ធផលនៃការវាយតម្លៃបើចាំបាច់ ហើយយកលទ្ធផលដែលយើងគិតថាត្រឹមត្រូវមកបញ្ចូលក្នុងផែនការអនាគតរបស់អ្នក
- អ្នកវាយតម្លៃត្រូវជៀសវាងការគិតថា "**នេះជាការងារគេ**" "**មិនមែនការងារខ្លួនឯង**" ហើយត្រូវធ្វើការជាដៃគូត្រួតពិនិត្យ និងវាយតម្លៃ ដ៏ជិតស្និទ្ធជាមួយស្ថាប័នផ្សេងៗ
- អ្នកត្រួតពិនិត្យ និងវាយតម្លៃត្រូវតែជាអ្នកអព្យាក្រឹត ស្មោះត្រង់មានជំនាញគ្រប់គ្រាន់ក្នុងការវាយតម្លៃ ដោយមិនធ្វើរបាយការណ៍ខុសពីការពិត ឬតម្រូវចិត្តអ្នកណាម្នាក់

# ផ្នែកទី៧

# អំពី

# យុទ្ធនាការតស៊ូមតិ

# ដែលទទួលបានជោគជ័យ

# ផ្នែកទី៧
# យុទ្ធនាការតស៊ូមតិដែលទទួលបានជោគជ័យ

## ១- សភាអ្នកក្រីក្រប្រទេសថៃ

"សភាអ្នកក្រីក្រប្រទេសថៃ គឺជាបណ្ដាញមួយដែលបង្កើតឡើងដោយប្រជាជនជនបទ និងអ្នកជាយក្រុងដែលបានទទួលរងនូវផលប៉ះពាល់ ពីការអនុវត្តន៏គម្រោងអភិវឌ្ឍន៏ឧស្សាហកម្មរបស់រដ្ឋាភិបាលថៃ ។ សភាអ្នកក្រីក្របង្កើតឡើងនៅឆ្នាំ១៩៩៥ ហើយចាប់តាំងពីពេលនោះមក សភាអ្នកក្រីក្របានរៀបចំយុទ្ធនាការជាច្រើនប្រឆាំងនឹងការបង្ខំឱ្យរុះរើលំនៅស្ថានរបស់អ្នកភូមិ និងការកេងប្រវ័ញ្ចយកធនធានធម្មជាតិរបស់ពួកគេ ដោយរដ្ឋអំណាច ក្រោមលេសថាដើម្បីធ្វើការអភិវឌ្ឍន៏ ។ សភាអ្នកក្រីក្រប្រទេសថៃ មានគោលដៅ និងជំហរ របស់ខ្លួនច្បាស់លាស់ថា "**លើកទឹកចិត្តប្រជាពលរដ្ឋឱ្យចូលរួម និងបង្កើតផែនការអភិវឌ្ឍន៏ដោយខ្លួនឯង**" ។ ភាគច្រើននៃសមាជិករបស់សភាអ្នកក្រីក្រ ជាកសិករ ។ ពួកគេមិនត្រឹមតែពុំមានប្រាក់ចំណូលគ្រប់គ្រាន់ប៉ុណ្ណោះទេ ពួកគេថែមទាំងពុំអាចចូលរួមក្នុងការសម្រេចចិត្ត ដើម្បីតវ៉ាចំពោះអ្វី ដែលប៉ះពាល់ដល់ជីវភាពរស់នៅ និងជីវិតរបស់ពួកគេទៀតផង ។ ទោះបីជាកសិករនៅ ប្រទេសថៃមានចំនួនរហូតដល់ ៦០% នៃប្រជាជនសរុប ហើយអ្នកមានមានតែ១១% ប៉ុណ្ណោះ ក៏អ្នកក្រីក្រពុំត្រូវបានគេផ្ដល់សិទ្ធិដើម្បីចូលក្នុងកិច្ចការនយោបាយឡើយ ។ **អាវុធរបស់អ្នកក្រីក្រប្រើសំរាប់ ការតវ៉ាគ្មានអ្វីក្រៅពីភាពអំណត់ និងភាពជាមនុស្សជាតិរបស់គេនោះឡើយ** ។ សភាអ្នកក្រីក្របាន បំផុសចលនាមហាជននៅទីក្រុង ដើម្បីដង្ហែក្បួនតវ៉ាទាមទារតាមផ្លូវនៃទីក្រុងបាងកក ព្រមគ្នាជាមួយ នឹងចលនានៅជនបទ ។ សកម្មភាពនេះបានបន្តជាច្រើនថ្ងៃ សប្ដាហ៍ និងខែ ដើម្បីធ្វើឱ្យមន្ត្រី និងឈ្មួញ ដែលពាក់ព័ន្ធ នឹងគ្រោងការខាងលើមានភាពអាម៉ាស់ និងបញ្ឈប់គម្រោងសាងសង់ ។ លោកស្រី នូ ញ៉ាមឌី ជាប្រជាជនសាមញ្ញ ម្នាក់រស់នៅក្នុងភូមិ ដែលរងគ្រោះដោយគម្រោងវារីអគ្គីសនីជិតទន្លេមូន ដែលចាប់ផ្ដើមនៅ ឆ្នាំ១៩៩៩ បានមានប្រសាសន៏ថា "**យើងជាប្រជាជនស្រឡាញ់សន្តិភាព យើងចង់រស់នៅភូមិរបស់យើងតែមួយកន្លែង ដោយគ្មានអ្នកណាម្នាក់មកបង្ខំឱ្យរុះរើលំនៅដ្ឋានយើងនោះឡើយ**" ។ គាត់បាននិយាយនៅពេលបានយកម្ហូបអាហាររបស់គាត់ ទៅផ្ដល់ជូនអ្នកភូមិដែលប្រមូលផ្ដុំគ្នាទាមទារឱ្យរុះរើទំនប់វារីអគ្គីសនីនោះចេញ ។

មូលហេតុ ដែលសមាជិករបស់សភាអ្នកក្រីក្រ ធ្វើការតស៊ូមតិនេះ ពីព្រោះទំនប់ទឹកដែលបានសាងសង់នោះ ធ្វើឱ្យប៉ះពាល់យ៉ាងធ្ងន់ធ្ងរ ដល់ការប្រកបរបរធ្វើស្រែ និងនេសាទរបស់គេ ។ ដីស្រែរាប់រយហិកតា

ខាងលើទំនប់ត្រូវលិចទឹក ហើយដីស្រែ និងស្ទឹងខាងក្រោមទំនប់ត្រូវគ្មានទឹក ។ ទោះបី បើការធ្វើបាតុកម្ម ដោយស្នាក់នៅយូរថ្ងៃលើតំបន់វាំរីអគ្គីសនី ដើម្បីសុំឱ្យផ្អាកការសាងសង់ទំនប់នេះ បានធ្វើឱ្យមានការចាប់អារម្មណ៍យ៉ាងខ្លាំងពីបណ្ដាព័ត៌មាន និងសាធារណជនយ៉ាងណាក៏ដោយ ក៏រដ្ឋាភិបាលពេលនោះពុំបានយកចិត្តទុកដាក់ពិចារណា ដើម្បីធ្វើការកែប្រែលើគោលនយោបាយអភិវឌ្ឍន៍នេះជាដុំកំភួនឡើយ ។ ដើម្បីឱ្យមានឥទ្ធិពលកាន់តែខ្លាំងឡើង សភាអ្នកក្រីក្របានសហការជាមួយអង្គការមិនមែនរដ្ឋាភិបាលមួយចំនួន ដើម្បីទាមទារឱ្យមានការយកចិត្តទុកដាក់ពីអ្នកដែលធ្វើការសម្រេចចិត្តគ្រប់ជាន់ថ្នាក់ផ្សេងៗទៀត ។ ការតវ៉ានេះទទួលបានជោគជ័យ ដោយប្រជាពលរដ្ឋទទួលបាននូវសំណងសមស្រប ។

## ២- ការតស៊ូមតិរបស់បណ្ដាញអង្គការមិនមែនរដ្ឋាភិបាលខេត្តកំពង់ចាម

បណ្ដាញអង្គការមិនមែនរដ្ឋាភិបាលខេត្តកំពង់ចាម បានបង្កើតឡើងនៅឆ្នាំ១៩៩៩ ដែលពេលនោះមានអង្គការមិនមែនរដ្ឋាភិបាល ចំនួន១៥ ជាសមាជិក ។ បណ្ដាញអង្គការមិនមែនរដ្ឋាភិបាលខេត្ត កំពង់ចាម ធ្វើការដើម្បីជួយដល់ប្រជាពលរដ្ឋ ដែលរងគ្រោះដោយបញ្ហាវិវាទដីធ្លី និងបញ្ហាផ្សេងៗ និងធ្វើការជំរុញឱ្យមានការចងក្រងសហគមន៍ប្រជាពលរដ្ឋ ។

បណ្ដាញតស៊ូមតិខេត្តកំពង់ចាម បានជួយដោះស្រាយបញ្ហាជូនប្រជាពលរដ្ឋជាច្រើនករណី ។ នៅក្នុងផ្នែកនេះ ខ្ញុំសូមលើកការតស៊ូមតិ ជាក់ស្ដែងមួយដែលបណ្ដាញនេះ បានធ្វើការតវ៉ាជាមួយសមត្ថកិច្ចមូលដ្ឋានខេត្ត និងតុលាការ លើករណីការប្រើកំលាំងប្រដាប់អាវុធចាប់ប្រជាពលរដ្ឋចំនួន៧នាក់ដែរ ដែលជាកម្មករចៀរជ័រចំការកៅស៊ូ និងជាតំណាងឱ្យប្រជាជនចំនួន ២២៧គ្រួសារ នៅពេលដែលពួកគាត់បានធ្វើការតវ៉ាសុំសិទ្ធិកាន់កាប់ដីចំនួនប្រមាណ១២៣.៤១ ហិចតា ។

### ២.១ ដំណើររឿងសង្ខេប

ប្រជាពលរដ្ឋប្រមាណ២២៧គ្រួសារ ដែលកាលពីមុនជាកម្មករចៀរជ័ររដ្ឋ ចំនួន១១២គ្រួសារ និងជាកម្មករចៀរជ័រអ្នកម៉ៅការឯកជនចំនួន ៥៩គ្រួសារ មកពីភូមិ៣៤ ឃុំបុសខ្នុរ ស្រុកចំការលើ ខេត្តកំពង់ចាម ដែលបាន នាំគ្នាទៅបោះតង់ និងធ្វើជារោងកាន់កាប់ដីចំការកៅស៊ូស្វាយមាស ដោយសារពួកគេអត់ការងារធ្វើតាំងតែពី ឆ្នាំ១៩៩៩ មក បន្ទាប់ពីក្រុម អ្នកម៉ៅការចំការកៅស៊ូបានផ្ទេរចំការកៅស៊ូទាំងស្រុងទៅឱ្យក្រុមហ៊ុនវិញ ។ ក្នុងចំណោមអ្នកទាំងអស់នោះ ដំបូងមានតែប្រជាពលរដ្ឋ៥៩គ្រួសារទេ ដែលផ្ដើមធ្វើការតវ៉ា ដើម្បីសុំដីពីអាជ្ញាធរមូលដ្ឋានដើម្បីស្នាក់នៅ និងបង្កបង្កើនផលចិញ្ចឹមជីវិត ។ ការតវ៉ារបស់គាត់ពុំបានទទួលជោគជ័យទេ

ព្រោះ កម្មករដទៃទៀត មិនត្រឹមតែមិនបានសហការប៉ុណ្ណោះទេ ថែមទាំងបង្កជាទំនាស់ទៀតផង ។ ប៉ុន្តែនៅអំឡុង ឆ្នាំ២០០១ ដើមកៅស៊ូនៅទីនោះត្រូវបានកាប់អស់ កម្មករចៀរជ័រចំនួន ១៨៨គ្រួសារទៀតត្រូវបញ្ឈប់ពី ការងារដែរ ហើយបានរួមគ្នាធ្វើការកាតតវ៉ាប្រឆាំង តែត្រូវហាម និងគំរាមពីសំណាក់អាជ្ញាធរមូលដ្ឋាន និង ភ្នាក់ងារចំការកៅស៊ូ ។ ដោយខ្លាចមានអំពើហិង្សា ធ្ងន់ធ្ងរកើតឡើង ពួកគាត់បានដាក់ពាក្យប្តឹងទៅតុលាការ ខេត្តកំពង់ចាម ។ នៅថ្ងៃទី០៣ ខែឧសភា ឆ្នាំ២០០៣ ចៅក្រមស៊ើបអង្កេតតុលាការ ខេត្តកំពង់ចាមបានចេញ ដីការនាំខ្លួនតំណាងកម្មការចំនួន ៧រូប ដោយចោទពី បទរំលោភលើទ្រព្យសម្បត្តិអ្នកដទៃ ។

## ២.២ យុទ្ធសាស្ត្ររបស់បណ្តាញតស៊ូមតិខេត្តកំពុងចាមក្នុងការដោះស្រាយបញ្ហានេះ

- ក្នុងពេលកើតហេតុ ប្រជាពលរដ្ឋបានធ្វើការប្តឹងមកបណ្តាញតស៊ូមតិខេត្តកំពង់ចាម ហើយបណ្តាញ បានផ្តល់យោបល់ និងយុទ្ធសាស្ត្រ ដើម្បីការពារតំណាងរបស់ខ្លួនកុំឱ្យមានការចាប់ដោយខុសច្បាប់ ។ ស្របពេលជាមួយគ្នានោះ បណ្តាញតស៊ូមតិខេត្តកំពង់ចាម បានទៅធ្វើការទំនាក់ទំនងសុំអន្តរាគមន៍ ពីតំណាងអង្គការសហប្រជាជាតិ ខេត្តកំពង់ចាម ។
- បណ្តាញតស៊ូមតិខេត្តកំពង់ចាម ក៏បានទៅទាក់ទងជាមួយអង្គការ អាដហុក ដើម្បីទៅជួបពិភាក្សា ជាមួយតុលាការខេត្ត ដោយបានបញ្ជាក់អំពីហេតុផលទាក់ទងនឹងការលំបាករបស់ប្រជាពលរដ្ឋ ដែលត្រូវបានក្រុមហ៊ុនបញ្ឈប់ការងារ និងស្នើសុំឱ្យបញ្ឈប់ការតាមចាប់តំណាង កម្មករជាបន្តទៅ ទៀត ។ ដោយយោងមូលហេតុខាងលើ តុលាការបានសហការជាមួយលោក ម៉ៅ ភិរុណ អភិបាលរងខេត្ត និងស្នងការ ដើម្បីស្នើសុំគោលការណ៍ដោះស្រាយ ហើយបានជំរាបជូនអំពីការ លំបាកក្នុងការអនុវត្តន៍ដីកា ។ ពេលនោះ លោក ម៉ៅ ភិរុណ បានឯកភាពស្នើឱ្យបណ្តាញតស៊ូមតិ ខេត្ត កំពង់ចាម ចុះទៅពិភាក្សាជា មួយប្រជាពលរដ្ឋដោយស្នើសុំកុំឱ្យប្រើអំពើហិង្សា ហើយជ្រើសរើស តំណាងរបស់ខ្លួន ដើម្បីប្រធាន តុលាការអាចទៅធ្វើការចរចារ ដោះស្រាយបញ្ហានេះបានឆាប់ ។
- បណ្តាញតស៊ូមតិខេត្តកំពង់ចាម ក៏បានចុះទៅកន្លែងកើតហេតុ ហើយបានធ្វើការពន្យល់អំពី មធ្យោបាយដោះស្រាយតាមផ្លូវច្បាប់ជូនប្រជាពលរដ្ឋ និងជំរុញឱ្យប្រជាពលរដ្ឋជ្រើសរើសតំណាង ថ្មី ដើម្បីងាយស្រួលធ្វើការដោះស្រាយ ។ ទន្ទឹមនឹងគ្នានេះ តុលាការបានចុះមកជួបជាមួយបណ្តាញ ដោយផ្ទាល់ បង្ហាញអំពីករណីចេញដីកាចាប់ខ្លួនទាំងនេះ ។ បណ្តាញបានទាក់ទងស្នងការខេត្ត អធិការស្រុក និងភ្នាក់ងារចំការកៅស៊ូ ដោយសុំឱ្យផ្អាកសកម្មភាពរង់ចាំការដោះស្រាយ និងធ្វើការ

ដកកំលាំង របស់ខ្លួនចេញពីកន្លែងកើតហេតុ ។ ចំណែកខាងតុលាការបានសន្យាថាមិនធ្វើការឃុំខ្លួនប្រជាពលរដ្ឋឡើយ ចំពោះបញ្ហាដីធ្លី នឹងធ្វើការដោះស្រាយតាមភាពជាក់ស្តែងក្រោយទៀត ។

តាមរយៈការសន្យាខាងលើ សវនការជាមួយសមត្ថកិច្ច ក្នុងនោះមានប្រធានតុលាការខេត្ត តំណាងឯកឧត្តមអភិបាលខេត្ត លោកស្នងការនគរបាលខេត្ត និងមន្ត្រីមូលដ្ឋានពាក់ព័ន្ធបានរៀបចំឡើង ។ សវនាការបានឯកភាពគ្នាចុះធ្វើការដោះស្រាយទំនាស់ដីធ្លីដល់កន្លែងកើតហេតុ ។

ពេលនោះ តំណាងពាក់ព័ន្ធទាំងអស់ បានចុះដល់គោលដៅ ដោយគេស្នើសុំឱ្យសមាគមអាដហុក ជាអ្នកសម្របសម្រួល ដើម្បីរៀបចំកន្លែងដោះស្រាយ និងជ្រើសរើសតំណាងមកធ្វើការពិភាក្សា ។ ប្រជាពលរដ្ឋដែលជាអ្នកតំណាង និងជាអតីតកម្មករចៀវជ័រកៅស៊ូបានចូលខ្លួនមកធ្វើកាចរចា ដោយសន្តិវិធី ដោយពុំមានការប្រើអំពើហិង្សាទាំងពីរភាគី ។ ការពិភាក្សាប្រព្រឹត្តទៅអស់រយៈពេលជាង ៣ម៉ោងនៅទីកដីកន្លែងកើតហេតុ ដែលចុងបញ្ចប់បណ្តាញតស៊ូមតិខេត្តត្រូវបានប្រគល់ តួនាទីនាំជនជាប់ចោទ ជាកម្មករចំនួន ៧នាក់មកតុលាការដើម្បីធ្វើកំណត់ហេតុ បញ្ឈប់ការអនុវត្តន៏ដីកាចាប់ខ្លួនរបស់តុលាការ[៤៣] ។

[៤៣] របាយការណ៏ស៊ើបអង្កេតរបស់បណ្តាញអង្គការមិនមែនរដ្ឋាភិបាលខេត្តកំពង់ចាម ឆ្នាំ២០០៣

## ឯកសារយោង


១. រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ( កែប្រែលើកទី៤ ឆ្នាំ២០០៤)

២. ឯកសារវេបសាយ របស់វិទ្យាស្ថានតស៊ូមតិ នៅប្រទេសឥណ្ឌាបោះពុម្ពនៅឆ្នាំ២០០៤

៣. ឯកសារក្រសួងពាណិជ្ជកម្ម និងអាយអឹមអេហ្វ បោះ ពុម្ពនៅឆ្នាំ១៩៩៩

៤. ឯកសារវេទិកា ស្តីអំពីបញ្ហាអភិវឌ្ឍន៍ រៀបរៀងដោយវេទិកាអង្គការមិនមែនរដ្ឋាភិបាលស្តីពីកម្ពុជា បោះពុម្ពនៅឆ្នាំ ២០០៣

៥. បទបញ្ជាផ្ទៃក្នុងនៃព្រឹទ្ធសភា បោះពុម្ពនៅឆ្នាំ២០០០

៦. បទបញ្ជាផ្ទៃក្នុងនៃរដ្ឋសភា បោះពុម្ពនៅឆ្នាំ២០០០

៧. កម្រងអត្ថបទសំរាប់អ្នកជំនាញតស៊ូមតិ រៀបរៀងដោយអង្គការផាក បោះពុម្ពនៅឆ្នាំ២០០៤

៨. ករណីសិក្សា : ការតស៊ូមតិរបស់សង្គមស៊ីវិល និងការចូលរួមក្នុងការសម្រេចចិត្តលើការគ្រប់គ្រង ធនធាន និងបរិស្ថាន នៅកម្ពុជា រៀបរៀង ដោយអង្គការអុកស្វាម បោះពុម្ពនៅឆ្នាំ១៩៩៩

៩. រដ្ឋធម្មនុញ្ញ និងរដ្ឋាភិបាលនៃប្រទេសកម្ពុជា សរសេរដោយលោក ម៉ាស ធ្យ៉ូនវិនជល បោះពុម្ពនៅឆ្នាំ២០០០

១០. ការណែនាំការវាយតម្លៃ រៀបរៀងដោយក្រសួងការបរទេស នៃប្រទេសដាណាម៉ាក បោះពុម្ពនៅឆ្នាំ១៩៩៩

១១. ស្ថិតិសមាគម និងអង្គការក្រៅរដ្ឋាភិបាលដែលបានចុះបញ្ជីនៅក្រសួងមហាផ្ទៃឆ្នាំ ១៩៩៤ ដល់ឆ្នាំ ២០០២ រៀបរៀងដោយក្រសួងមហាផ្ទៃ បោះពុម្ពនៅឆ្នាំ ២០០២

១២. ប្រវត្តិសាស្ត្រនៃប្រទេសកម្ពុជា សរសេរដោយ លោក ដេវីដ ឆាន បោះពុម្ពនៅឆ្នាំ ១៩៩២

១៣. មេរៀន ស្តីការតស៊ូមតិ រៀបរៀងដោយអង្គការស្តារកម្ពុជា បោះពុម្ពនៅឆ្នាំ១៩៩៩

១៤. សៀវភៅណែនាំអំពីយុទ្ធសាស្ត្រនៃការតស៊ូមតិ និងបច្ចេកទេសអនុវត្តន៍រៀបរៀងដោយអ្នកតស៊ូមតិនៅអាស៊ីអាគ្នេយ៍ បោះពុម្ពនៅឆ្នាំ ២០០៣

១៥. របាយការណ៍នៃវគ្គបណ្តុះបណ្តាលស្តីពីការត្រួតពិនិត្យ និងវាយតម្លៃរៀបរៀងដោយអង្គការ ស៊ីដសេ បោះពុម្ព នៅឆ្នាំ១៩៩៩

១៦. ការសិក្សាក្នុងប្រទេស : អង្គការមិនមែនរដ្ឋាភិបាលកម្ពុជា សរសេរដោយ លោកស្រី ធីដា ឃិះ អង្គការសីលការ បោះពុម្ពនៅឆ្នាំ ២០០០

១៧.សៀវភៅណែនាំអំពីយុទ្ធនាការតស៊ូមតិៈ ដើម្បីពង្រឹងបរិយាកាសប្រជាធិបតេយ្យនៅកម្ពុជា សរសេរដោយ លោកស្រី គ្រីស្ទីនណា មែហ្សៀល អង្គការផាក បោះពុម្ពនៅឆ្នាំ២០០២

១៨.របាយការណ៍ស៊ើបអង្កេត ស្តីពីករណីទំនាស់ដីធ្លី របស់បណ្តាញតស៊ូមតិនៃអង្គការមិនមែនរដ្ឋាភិបាល ខេត្តកំពង់ចាម បោះពុម្ពនៅ ឆ្នាំ២០០៣

១៩.របាយការណ៍ទស្សនកិច្ចសិក្សា ស្តីពីការងារតស៊ូមតិ និងការចងក្រងបណ្តាញរបស់អង្គការមិនមែនរដ្ឋាភិបាល និងសហគមន៍នៅប្រទេសថៃ រៀបរៀងដោយអង្គការស្តារកម្ពុជា បោះពុម្ពនៅឆ្នាំ១៩៩៩ ។

# ឧបសម្ព័ន្ធ

១- ប្រវត្តិរបស់ គណៈកម្មការតស៊ូមតិអាស៊ីភាគអាគ្នេយ៍
(South-East Asian Committe for Advocacy/SEACA)

២- ប្រវត្តិរបស់ អង្គការសីលការ (SILAKA)

៣- ប្រវត្តិរបស់ អង្គការស្តារកម្ពុជា (STAR KAMPUCHEA)

៤- ប្រវត្តិរបស់លោក ញ៉ឹក សារិន ( អ្នកស្រាវជ្រាវ និងរៀបរៀងសៀវភៅ)

៥- តារាងឈ្មោះអង្គការដៃគូរបស់ ស៊ីកា ដែលបានចូលរួមក្នុងសកម្មភាព
គម្រោងតស៊ូមតិនៅកម្ពុជា /CAT ឆ្នាំ ២០០៣-២០០៤

៦- អាសយដ្ឋាន សំរាប់ទំនាក់ទំនង ស្ថាប័នរដ្ឋាភិបាល

៧- បញ្ជីរាយព្រះនាម និងនាមអ្នកតំណាងរាស្ត្រអាណត្តិទីពាតាមមណ្ឌល

## ១. ប្រវត្តិរបស់ គណៈកម្មការតស៊ូមតិនៅអាស៊ីភាគអាគ្នេយ៍ ឬស៊ីកា

**<u>SEACA</u>** ( ខែមេសា ឆ្នាំ២០០៤)

គណៈកម្មការតស៊ូមតិអាស៊ីភាគអាគ្នេយ៍ គឺជាកម្មវិធីដែលផ្តោតទៅលើការបង្កើនសមត្ថភាពតស៊ូមតិដល់អង្គការសង្គមស៊ីវិល (CSOs) នៅក្នុងតំបន់អាស៊ីអាគ្នេយ៍ ។ កម្មវិធីស៊ីកាជាលទ្ធផលនៃការពិគ្រោះយោបល់របស់អង្គការសង្គមស៊ីវិល នៅក្នុងតំបន់អាស៊ីភាគអាគ្នេយ៍ជាបន្តបន្ទាប់ និងកិច្ចប្រជុំនៅ ទីក្រុងម៉ានីល ក្នុងឆ្នាំ១៩៩៩ ដែលមានការចូលរួមដោយអ្នកតំណាងបណ្តាញអង្គការមិនមែនរដ្ឋាភិបាល និងតំណាងប្រជាពលរដ្ឋមកពី ៨ប្រទេសក្នុងតំបន់រួមជាមួយបណ្តាញនានា ក្នុងតំបន់អាស៊ី (Asian Regional Networks) ដែលគាំទ្រដោយ CIIR និងគាំទ្រដោយ DFID នៃចក្រភពអង់គ្លេស ។

ប្រទេសទាំង ៨ ដែលចូលរួមក្នុងសកម្មភាពរបស់ស៊ីកាមាន : ប្រទេសភូមា កម្ពុជា ទីម័រខាងកើត ឥណ្ឌូនេស៊ី ម៉ាឡេស៊ី ហ្វីលីពីន ថៃ និងវៀតណាម ។ បណ្តាញដៃគូរបស់ស៊ីកា មានទីតាំងនៅក្នុងប្រទេសហ្វីលីពីន ថៃ និងម៉ាឡេស៊ី ។

ទីស្នាក់ការកណ្តាល របស់គណៈកម្មការតស៊ូមតិនៅអាស៊ីអាគ្នេយ៍ /SEACA ស្ថិតនៅទីក្រុង ម៉ានីល នៃប្រទេសហ្វីលីពីន ។

អាសយដ្ឋានរបស់ **SEACA :**

Southeast Asian Committee for Advocacy (SEACA)
Regional Secretariat Unit 2008, Margarita Bldg.
28 Matalino Street.
Brgy. Central, Quezon City
1100 Metro Manila
Philippines

## ២- អង្គការសីលការ

នៅឆ្នាំ ១៩៩៣ គំរោងមួយរបស់អ្នកស្ម័គ្រចិត្តខ្មែរ-អាមេរិកកាំង (CANDO) ក្រោមការឧបត្ថម្ភ នៃទីភ្នាក់ងារ USAID បានដំណើរការអស់រយៈពេល៤ឆ្នាំ មុននឹងប្តូរទៅជា អង្គការបង្កើនសមត្ថភាពមួយមានឈ្មោះថា "**សីលការ**" នៅក្នុងខែមករា ឆ្នាំ១៩៩៧ ។

**សីលការ** ជាអង្គការបង្កើនសមត្ថភាព ដែលមិនប្រកាន់គណបក្សនយោបាយ ណាមួយឡើយ ។ **សីលការ** ធ្វើការងារដើម្បីពង្រឹងសមត្ថភាពស្ថាប័នសាធារណៈ ឯកជន និងរដ្ឋាភិបាល តាមរយៈសហប្រតិបត្តិការ អប់រំ និងហ្វឹកហ្វឺន នូវជំនាញ និងទ្រឹស្តីស្នូល ផ្នែកការិយាល័យ ដូចជាជំនាញរដ្ឋបាល គ្រប់គ្រង និងហិរញ្ញកិច្ច ព្រមទាំងចូលរួម ឬរៀបចំ និងអនុវត្តកម្មវិធីផ្សេងៗដែល បង្កើននូវតម្លាភាព និងការទទួលខុសត្រូវរបស់ស្ថាប័ន និងអង្គការ ។ **សីលការ** ប្រកាន់ខ្ជាប់នូវការងារជាក្រុម និងចូលរួមសកម្ម ដើម្បីកសាងការទុកចិត្តគ្នា ការគាំទ្រ និងទំនាក់ទំនងដោយសកម្ម ។ គោលនយោបាយស្នូលរបស់ **សីលការ** គឺទ្រទ្រង់ការផ្សះផ្សាកសាងការយល់ដឹងពីខ្លួនឯង និងរៀនអនុវត្តជានិរន្តរ៍ តាមរយៈការពិភាក្សា និងការសន្ទនាគ្នា ។

ការិយាល័យ សីលការ ស្ថិតនៅទីក្រុងភ្នំពេញ ដែលជាទីតាំងផ្តល់ការបណ្តុះបណ្តាលភាគច្រើន ។ អង្គការសីលការមាន និងអាចផ្តល់ការបណ្តុះបណ្តាល និងការគាំទ្រដល់បុគ្គលិករបស់អង្គការ និងរដ្ឋបាលមូលដ្ឋាននៅតាមខេត្ត និងតំបន់ជនបទ ។

សីលការមាន ទស្សនវិស័យ ថា យើងជាប្រជាជនកម្ពុជា ធ្វើដំណើរឆ្ពោះទៅរកសន្តិភាព សេរីភាព មេត្តាករុណា និងស្ថាបនា ដែលនឹងធ្វើឱ្យប្រសើរឡើង នូវសេចក្តីត្រូវការចាំបាច់រួម របស់ ប្រជាពលរដ្ឋកម្ពុជា ។ យើងរស់នៅក្នុងសង្គមមួយដែលមានពហុភាព និងសន្សំសំចៃ ដើម្បីអភិវឌ្ឍសង្គមដែលឱ្យ តម្លៃខ្ពស់ទៅលើការរៀនសូត្រដោយចំហសិទ្ធិមនុស្ស និងធ្វើឱ្យកើនឡើងនូវផលិតភាពជាលំដាប់ ។ សីលការមានទស្សនៈថា ប្រជាពលរដ្ឋខ្មែរនឹងមានការរឹងប៉ឹង ក្នុងស្ថាប័នរបស់គេ ក្នុងការការពារនូវផលប្រយោជន៍រួមនៃជនកម្ពុជា ។

## បេសកកម្ម

អង្គការសីលការ មានបេសកកម្មដើម្បី ៖

- ជួយហ្វឹកហ្វឺន និងរៀបចំជនកម្ពុជា ដើម្បីបង្កើត អភិវឌ្ឍ និងធ្វើឱ្យរឹងប៉ឹង ដល់អង្គការ និងស្ថាប័នរបស់គេ ។
- ធ្វើការជាមួយបុគ្គល អង្គការ និងស្ថាប័ន ដើម្បីជំរុញភាពសកម្ម ក្នុងការបង្កើនសមត្ថភាព ដល់ជនកម្ពុជា ។
- ធ្វើការចូលរួមក្នុងការកសាងសន្តិភាព នៅកម្ពុជា ដោយបង្កើនសមត្ថភាព ក្នុងការដោះស្រាយទំនាស់ដោយស្ថាបនា និងការដោះស្រាយបញ្ហា ស្រាយបញ្ហា ដែលមានប្រសិទ្ធភាព ។

អាសយដ្ឋានរបស់ អង្គការសីលការ ៖


SILAKA
P.O BOX 821, #06s, St. 21, Tonle Bassac, Chamkamon, Phnom Penh
HP. 012-83-8464
Tel: (855) 23-21-7872 / 20-1902, Fax: (855) 213 108;
Email: silaka@silaka.org/
ctp@silaka.org
website: www.silaka.org

## ៣. អង្គការស្តារកម្ពុជា

**អង្គការស្តារកម្ពុជា** ជាបណ្តាញអង្គការសង្គមស៊ីវិលមិនមែនរដ្ឋាភិបាលមួយ ដែលបានបង្កើតឡើង ដោយសមាជិកស្ថាបនិក ១៤រូប តាំងថ្ងៃទី ០១ ខែសីហា ឆ្នាំ១៩៩៧ ។ **ស្តារកម្ពុជា** ធ្វើការពង្រឹង លទ្ធិប្រជាធិបតេយ្យ តាមរយៈការពង្រឹងសង្គមស៊ីវិលនៅកម្ពុជា ។ **ស្តារកម្ពុជា** មានកម្មវិធី ៣សំខាន់ ដែល ក្នុងនោះរួមមាន កម្មវិធីតស៊ូមតិ (AAP) កម្មវិធីបង្កើនសមត្ថភាព ការតស៊ូមតិ (ACP) និងមូលនិធិ ស្តារកម្ពុជា (SK Foundation) ។ ស្តារកម្ពុជា បានធ្វើការសហការជាមួយដៃគូ ដែលជាអង្គការមិនមែនរដ្ឋាភិបាល (COs) ចំនួន ៣៧ សហជីពកម្មករចំនួន ៩ បណ្តាញតស៊ូមតិចំនួន ៤ និងសមាគមចំនួន ១៤ ដែលមានទីតាំង នៅក្នុងទីក្រុង និងតាមបណ្តាខេត្តនានាដូចជា : រាជធានីភ្នំពេញ ក្រុងកំពង់សោម ខេត្តស្វាយរៀង ពោធិសាត់ បាត់ដំបង កំពង់ចាម បន្ទាយមានជ័យ និងខេត្តកំពត ។

អង្គការស្តារកម្ពុជាបានទទួលរង្វាន់អភិវឌ្ឍន៍សង្គមស៊ីវិល នៅឆ្នាំ២០០៤ ពីសមាគមពិភពលោកនៃ អង្គការមិនមែនរដ្ឋាភិបាល (WANGO) នៅប្រទេសហុងគ្រី លើស្នាដៃបង្រួបបង្រួម ពង្រឹងសមត្ថភាពអង្គការ មិនមែនរដ្ឋាភិបាលនៅកម្ពុជាដែលប្រកបដោយជោគជ័យ ។

អាសយដ្ឋានរបស់ អង្គការស្តារកម្ពុជា :

**STAR KAMPUCHEA**
P.O. Box 177, #16, St. 398, Boeung Keng Kang I, Chamkarmon,
Phnom Penh
Tel: 855-023-21-1612
Email: star@forum.org.kh
Box 372, #35 St. 178 CCC Office, Phnom Penh.
Email: star@forum.org.kh
Website: www.vacambodia.org

## ៤. ប្រវត្តិការងារសង្ខេបរបស់ លោក ញឹក សារិន

លោក **ញឹក សារិន** ជាអតីតអ្នកសារព័ត៌មាន ឌឺណេសិនគ្រុប (The Nation Group) ដែលមាន ទីស្នាក់ការនៅប្រទេសថៃ និងធ្លាប់ធ្វើជាបុគ្គលិកសារព័ត៌មាននៃនាយកដ្ឋានទស្សនាវដ្តី និងព្រឹត្តិបត្រ នៃទីភ្នាក់ងារសារព័ត៌មានកម្ពុជា នៃក្រសួងព័ត៌មាន បន្ទាប់មកលោក ជាអ្នកចុះបញ្ជីអ្នកបោះឆ្នោត និងជាជំនួយការមន្ត្រីកិត្តិយស (Assistant Presiding Officer) ប្រចាំខណ្ឌដូនពេញ ។

នៅចុងឆ្នាំ ១៩៩៣ លោកត្រូវបានជ្រើសរើសឱ្យធ្វើជាលេខាធិការ នៃគណៈកម្មការការពារសិទ្ធិមនុស្ស និងពាក្យបណ្តឹងនៃរដ្ឋសភា ។ នៅឆ្នាំ១៩៩៤ លោកត្រូវបានគេតម្លើងតួនាទី ជាអនុប្រធានការិយាល័យទទួលបន្ទុករួម នៃការិយាល័យព័ត៌មាន និងបណ្ណាល័យនៅទីនោះ ។

ចាប់ពីឆ្នាំ ១៩៩៥ រហូតដល់ ឆ្នាំ ១៩៩៧ លោកបានធ្វើជាអ្នកបកប្រែ នៃសហព័ន្ធពន្លឺខ្មែរ និងជានាយកប្រតិបត្តិ នៃអង្គការ **ស្តារកម្ពុជា** ចាប់ពីឆ្នាំ ១៩៩៧ មកដល់បច្ចុប្បន្ន ។ ដោយមានការបំពេញតួនាទីយ៉ាងសកម្ម និងអស់ពីកម្លាំងកាយ កម្លាំងចិត្ត ធ្វើឱ្យ **ស្តារកម្ពុជា** ទទួលបានកិត្តិយស និងទទួលស្គាល់ពីមជ្ឈដ្ឋានជាតិ និងអន្តរជាតិ ថាជាអង្គការសង្គមស៊ីវិលមួយដែលសកម្ម ក្នុងការពង្រឹងលទ្ធិប្រជាធិបតេយ្យនៅកម្ពុជា តាមរយៈការអនុវត្តន៍កម្មវិធីរបស់ខ្លួន ដូចជាការរៀបចំវេទិកាសាធារណៈ សិក្ខាសាលា វគ្គបណ្តុះបណ្តាល និងចលនា តស៊ូមតិផ្សេងៗ ដែលជាមធ្យោបាយ ដើម្បីស្វែងរកដំណោះស្រាយជូនប្រជាពលរដ្ឋ ។

លោក ញឹក សារិន នឹងបញ្ចប់បរិញ្ញាបត្ររដ្ឋបាលសាធារណៈ ជាមួយនឹង សកលវិទ្យាល័យ សេនជួរី (Century University) ដែលមានទីតាំងនៅសហរដ្ឋអាមេរិក តាមរយៈប្រព័ន្ធអ៊ីធឺណេត នៅដើមឆ្នាំ២០០៥ ខាងមុខ ។ លើសពីនេះ លោកបានអញ្ជើញចូលរួមសិក្ខាសាលា និងវគ្គបណ្តុះបណ្តាលជាច្រើនទាំងក្នុងប្រទេស និងក្រៅប្រទេស ដែលវគ្គទាំងនោះទាក់ទងនឹងការតស៊ូមតិ ការពង្រឹងលទ្ធិប្រជាធិបតេយ្យ ការគ្រប់គ្រង និងអភិបាលកិច្ចល្អ ។

## ៥. ដៃគូ សីកា /SEACA ដែលបានចូលរួមក្នុង គំរោង CAT ឆ្នាំ ២០០៣-២០០៤

**ក. អង្គការសីលការ**

នាយកាប្រតិបត្តិៈ អ្នកស្រី ឃិះ ធីដា
P.O. Box 821, #6s, St. 21, Tonle Bassac,
Chamkarmon, Phnom Penh
HP. 012-83-8464
Tel: (855) 23-21-7872 / 20-1902,
Fax: (855) 213 108;
Emial: silaka@silaka.org/
ctp@silaka.org
Website: www.silaka.org

**ខ. អង្គការស្តារកម្ពុជា**

នាយកប្រតិបត្តិៈ លោក ញ៉ឹក សារិន
HP. 011-72-5873
P.O. Box 177, #16, St. 398, Boeung Keng Kang I, Chamkamon, Phnom Penh
Tel: 855-023-21-1612
Email: star@forum.org.kh
Box 372, #35 St. 178, CCC Office, Phnom Penh.
Email: star@forum.org.kh
Website: www.vacambodia.org

**គ. សមាគមយុវជនខ្មែរ**

នាយកប្រតិបត្តិ : លោក យង់ គីមអេង
HP. 016-82-8211
#135A, Gr. 33, St 259, Teoklaak I, Phnom Penh
Tel: 855-023 88-4306
Email: kya@forum.org.kh
Box 275, #35 St. 178, CCC Office, Phnom Penh.
Website: N/A

**ឃ~ អង្គការសរសរទ្រូង** នាយកប្រតិបត្តិៈ លោក ឈឹម វ៉ាន់ដេត

#77, St. 468, Toultompong II,
Chamkamon, Phnom Penh
Tel: 023 211 264 / 211 157
Email: sst@online.com.kh
Website: N/A

**ខ~ អង្គការ** UPWD ប្រធានគំរោងៈ កញ្ញា គូ ស៊ីណា

HP. 012 91–8911
#10D Eo, St. 183, Tomnuptoeuk, Chamkamon,
Phnom Penh
Tel: 855–023–21–4720
Email: upwd/forum.org.kh
Website: N/A

## ៦. អាសយដ្ឋាន សំរាប់ទំនាក់ទំនង ស្ថាប័នរដ្ឋាភិបាល រួមមានៈ

### ព្រឹទ្ធសភា

មហាវិថីនរោត្តម ភ្នំពេញ ទូរស័ព្ទ ០២៣ ២១១ ៤៤១

ផ្ញើសារ oum_sarith@camnet.com.kh

### សភាជាតិ

មហាវិថីសុធារស កែងផ្លូវ ២៤០ ភ្នំពេញ ទូរស័ព្ទ ០២៣ ២១៤ ១៣៦

ផ្ញើសារ kimhenglong@cambodia-parliament.org

### ឈ្មោះក្រសួង

### ក្រសួងព័ត៌មាន

អាគារលេខ ៦២ ផ្លូវព្រះមុនីវង្ស ភ្នំពេញ ទូរស័ព្ទ ០២៣ ៧២៤ ១៥៩

ផ្ញើសារ information@cambodia.gov.kh

### ក្រសួងមហាផ្ទៃ

អាគារលេខ ២៧៥ មហាវិថីនរោត្តម ភ្នំពេញ ទូរស័ព្ទ ០២៣ ២១២ ៧០៧

ផ្ញើសារ moi@interior.gov.kh

### ក្រសួងយុត្តិធម៌

អាគារលេខ១៤ មហាវិថីសុធារស ភ្នំពេញ ទូរស័ព្ទ ០២៣ ៦៣០ ៣២៧

ផ្ញើសារ moj@cambodia.gov.kh

### ក្រសួងការពារជាតិ

ផ្លូវសហព័ន្ធរុស្សី កែងនិងផ្លូវ ១៧៥ ភ្នំពេញ ទូរស័ព្ទ ០២៣ ៨៨៣ ១៨៤

ផ្ញើសារ info@mond.gov.kh

### ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

ផ្ទះលេខ ៧៧១-៧៧៣ វិថីព្រះមុនីវង្ស ភ្នំពេញ ទូរស័ព្ទ ០២៣ ២១៥ ៦៦០

ផ្ញើសារ mdlmup-mlmup@camnet.com.kh

### ក្រសួងផែនការ

អាគារលេខ ៣៨៦ វិថីព្រះមុនីវង្ស ភ្នំពេញ ទូរស័ព្ទ ០២៣ ២១២ ០៤៩

ផ្ញើសារ mop@cambodia.gov.kh

## ក្រសួងសាធារណការ និងដឹកជញ្ជូន

អាគារលេខ ១០៦ មហាវិថីនរោត្តម ភ្នំពេញ ទូរស័ព្ទ ០២៣ ៤២៧ ៨៦២

ផ្ញើសារ mpwt@mpwt.gov.kh

## ក្រសួងអភិវឌ្ឍន៍ជនបទ

ផ្លូវចូកឌីមិចត្រូវ កែងផ្លូវ១៦៩ ភ្នំពេញ ទូរស័ព្ទ ០២៣ ៨៨៣ ៦៤៩

ផ្ញើសារ mrd@cambodia.gov.kh

## ក្រសួងទេសចរណ៍

អាគារលេខ ៣ វិថីព្រះមុនីវង្ស ភ្នំពេញ ទូរស័ព្ទ ០២៣ ២១២ ៨៣៧

ផ្ញើសារ info@mot.gov.kh

## ក្រសួងធនធានទឹក និងឧតុនិយម

អាគារលេខ ៤៧ មហាវិថីនរោត្តម ភ្នំពេញ ទូរស័ព្ទ ០២៣ ៧២៤ ៣២៧

ផ្ញើសារ mowram@cambodia.gov.kh

## ក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍

អាគារលេខ ១៣ កែងផ្លូវ១០២ ភ្នំពេញ ទូរស័ព្ទ ០២៣ ៤២៦ ៥១០

ផ្ញើសារ mptc@cambodia.gov.kh

## ក្រសួងកិច្ចការនារី

អាគារលេខ ៣ មហាវិថីនរោត្តម ភ្នំពេញ ទូរស័ព្ទ ០២៣ ៤២៨ ៩៦៥

ផ្ញើសារ mwva@bigpond.com.kh

## ក្រសួងរុក្ខាប្រមាញ់ និងនេសាទ

អាគារលេខ ២០០ មហាវិថីនរោត្តម ភ្នំពេញ ទូរស័ព្ទ ០២៣ ២១១ ៣៥១

ផ្ញើសារ icomaff@camnet.com.kh

## ក្រសួងពាណិជ្ជកម្ម

អាគារលេខ ២០ មហាវិថីនរោត្តម ភ្នំពេញ ទូរស័ព្ទ ០២៣ ៤២៦ ០២៤

ផ្ញើសារ itd@gocambodia.com

**ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ**

អាគារលេខ ២២៧ មហាវិថីនរោត្តម ភ្នំពេញ ទូរស័ព្ទ ០២៣ ២១៧ ៦៤៥

ផ្ញើសារ mcfa@cambodia.gov.kh

**ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**

អាគារលេខ ៦០ ផ្លូវ៩២ ភ្នំពេញ ទូរស័ព្ទ ០២៣ ៤២៨ ៩៦០

ផ្ញើសារ efi@camnet.com.kh

**ក្រសួងអប់រំ យុវជន និងកីឡា**

អាគារលេខ ៨០ មហាវិថីនរោត្តម ភ្នំពេញ ទូរស័ព្ទ ០២៣ ២១៧ ២៥៣

ផ្ញើសារ iec@everyday.com.kh

**ក្រសួងបរិស្ថាន**

អាគារលេខ ៤៨ មហាវិថីសីហនុ ភ្នំពេញ ទូរស័ព្ទ ០២៣ ៤២៧ ៨៩៤

ផ្ញើសារ moe-cabinet@camnet.com.kh

**ក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ**

អាគារលេខ១៦១ ផ្លូវស៊ីសុវត្ថិ កែងផ្លូវ២៤០ ភ្នំពេញ ទូរស័ព្ទ ០២៣ ២១៦ ១៤១

ផ្ញើសារ mfaicasean@online.com.kh

**ក្រសួងសុខាភិបាល**

អាគារលេខ ១៥១-១៥៣ ផ្លូវ១២៨ ភ្នំពេញ ទូរស័ព្ទ ០២៣ ៧២២ ៨៧៣

ផ្ញើសារ procure.pcu@bigpond.com.kh

**ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល**

អាគារលេខ ៤៥ មហាវិថីនរោត្តម ភ្នំពេញ ទូរស័ព្ទ ០២៣ ២១១ ១៤១

ផ្ញើសារ info@mine.gov.kh

**ក្រសួងធម្មការ និង កិច្ចការសាសនា**

ផ្លូវស៊ីសុវត្ថិ កែងផ្លូវ ២៤០ ភ្នំពេញ ទូរស័ព្ទ ០២៣ ៧២៥ ០៩៩

ផ្ញើសារ morac@cambodia.gov.kh

### ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និង យុវនីតិសម្បទា

អាគារលេខ ៧៨៨ មហាវិថីមុនីវង្ស ភ្នំពេញ ទូរស័ព្ទ ០២៣ ២១៨ ៤៧៣

ផ្ញើសារ mosalvy@cambodia.gov.kh

### ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

ផ្ញើសារ mlv@cambodia.gov.kh

### ក្រសួងទំនាក់ទំនង និង អធិការកិច្ច

ផ្លូវនេរុ ( ២១៥) ភ្នំពេញ ទូរស័ព្ទ ០២៣ ៨៨៤ ២៦១

ផ្ញើសារ mnasrl@cambodia.gov.kh

## ឈ្មោះកាសែត និងទស្សនាវដ្តី

### កាសែត កោះសន្តិភាព

ផ្ទះលេខ ២០ ផ្លូវ២៧១ ភ្នំពេញ ទូរស័ព្ទ ០២៣២១១ ៨១៨

ផ្ញើសារ kohsantepheap@camnet.com.kh

### កាសែត រស្មីកម្ពុជា

ផ្ទះលេខ ៤៧៤ ផ្លូវព្រះមុនីវង្ស ភ្នំពេញ ទូរស័ព្ទ ០២៣ ៣៦២ ៤៧២

ផ្ញើសារ rasmey_kampuchea@yahoo.com

### កាសែត កម្ពុជាថ្មី

ផ្ទះលេខ ៨០៥ ផ្លូវ១២៨ ភ្នំពេញ ទូរស័ព្ទ ០២៣ ៨២២ ៩៩០

ផ្ញើសារ kampucheathmey3@yahoo.com

### កាសែត ឌឹ ខែមបូឌា ដេលី

ផ្ទះលេខ ៥0B ផ្លូវ២៤០ ភ្នំពេញ ទូរស័ព្ទ ០២៣ ៤២៦ ៦០២

### កាសែត មតិជាតិ

ផ្ទះលេខ ១៥៨$E_1$ ផ្លូវ១៨២ ភ្នំពេញ ទូរស័ព្ទ ០១៦ ៩៣៧ ៣៩៧

### កាសែត សម្លេងយុវជនខ្មែរ

ផ្ទះលេខ ២៤E1 ផ្លូវ៣៧៤ ភ្នំពេញ ទូរស័ព្ទ ០១២ ៩០០ ៦៦៤

**កាសែត ពន្លឺយុវជ័យ**

ផ្ទះលេខ ២៦$E_0$ ផ្លូវ១១០ ភ្នំពេញ ទូរស័ព្ទ ០១២ ៦១៨ ៩២៨

**កាសែត ពន្លឺថ្មី**

ទូរស័ព្ទ ០១២ ៨៩៥ ០០១

**កាសែត កញ្ចក់សង្គម**

ផ្ទះលេខ ២៤៥ ផ្លូវ៥១ ភ្នំពេញ ទូរស័ព្ទ ០២៣ ៣៦០ ៣៤៥

ផ្ញើសារ mirror@forum.org.kh

**កាសែត សម្លេងរាស្ត្រខ្មែរ**

ផ្ទះលេខ ៧២$E_1$ ផ្លូវ១៧៨ ភ្នំពេញ ទូរស័ព្ទ ០១២ ៦៤៤ ៤៣៤

**កាសែត ខ្មែរអមតៈ**

ផ្ទះលេខ ១៣ ផ្លូវ៣៤៨ ភ្នំពេញ ទូរស័ព្ទ ០១២ ៨៤០ ៤៤៨

**កាសែត សប្តាហ៍នេះ**

ផ្ទះលេខ ២៤$E_0$ ផ្លូវ៤៤៦ ភ្នំពេញ ទូរស័ព្ទ ០១២ ៨០៤ ១៧១

**កាសែត កម្ពុជបុត្រ**

ខេត្តកណ្តាល ទូរស័ព្ទ ០១២ ៨៦៥ ២៩០

**កាសែត សហសវត្សរ៍ថ្មី**

ផ្ទះលេខ៤៨$E_2$ ផ្លូវ២៤០ ភ្នំពេញ ទូរស័ព្ទ ០១៦ ៧១៩ ៩៥១

ផ្ញើសារ sahasawatythnmey@mail2world.com

**កាសែត រស្មីអង្គរ**

ផ្ទះលេខ ២៥z ផ្លូវ៣៧២ ភ្នំពេញ ទូរស័ព្ទ ០១១ ៦២៧ ៦០៩

**កាសែត ប៊ីសនីស** (Business News)

ផ្ទះលេខ ២៨$B_3$ ផ្លូវ៧៥ ភ្នំពេញ ទូរស័ព្ទ ០២៣ ៩៩០ ១១០

ផ្ញើសារ bizznews@camnet.com.kh

**កាសែត សារពត៌មានពាណិជ្ជកម្ម**

ផ្ទះលេខ ៣៩៤ ផ្លូវ២៧៤ ភ្នំពេញ ទូរស័ព្ទ ០២៣ ៧២១ ៦៦៥

ផ្ញើសារ tcnews@online.com.kh

**កាសែត និង ទស្សនាវដ្ដី កម្ពុជា**

ផ្ទះលេខ ១៥៨ មហាវិថីនរោត្តម ភ្នំពេញ ទូរស័ព្ទ ០១២ ៩៦៤ ០៣៥

**ទស្សនាវដ្ដី ប្រជាប្រិយ**

ផ្ទះលេខ ៧៧ ផ្លូវ២១៤ ភ្នំពេញ ទូរស័ព្ទ ០២៣ ២១៦ ៤៧៤

**ទស្សនាវដ្ដី ឥន្ទ្រទេវី**

ផ្ទះលេខ ១៦៧ ផ្លូវ២៤៥ ភ្នំពេញ ទូរស័ព្ទ ០២៣ ២១៥ ៨០៨

ផ្ញើសារ indradevi@camnet.com.kh

**ទស្សនាវដ្ដី ពន្លឺអក្សរ**

ផ្ទះលេខ ១២E0 ផ្លូវជាតិលេខ២ ភ្នំពេញ ទូរស័ព្ទ ០១២ ៤១៧ ៧៧០

**ទស្សនាវដ្ដី ស៊ីអឹម (CM)**

ផ្ទះលេខ ១៨E0 ផ្លូវ២១៥ ភ្នំពេញ ទូរស័ព្ទ ០២៣ ៨៨៤ ៤៨៧

ផ្ញើសារ info@cm.com.kh

**ទស្សនាវដ្ដី ខ្មែរអប្សរា**

ផ្ទះលេខ ៣៦ ផ្លូវ៣៣៩ ភ្នំពេញ ទូរស័ព្ទ ០១២ ៦២៤ ២២៤

**ទស្សនាវដ្ដី អក្សរធំ**

ផ្ទះលេខ ១០៥ ផ្លូវ៣២៤ ភ្នំពេញ ទូរស័ព្ទ ០១២ ៦១២ ៩៩៥

**ទស្សនាវដ្ដី តាំតាំ**

ផ្ទះលេខ ២១៦B ផ្លូវ៦៣ ភ្នំពេញ ទូរស័ព្ទ ០២៣ ២១០ ៧១២

ផ្ញើសារ tamtam@online.com.kh

**ឈ្មោះ ទូរទស្សន៍ និងវិទ្យុ**

**ទូរទស្សន៍ ទទខកម ប៉ុស្តិ៍លេខ៥ និង វិទ្យុ អេហ្វអឹម៩៨**

ផ្លូវ១៦៩ បូរីកីឡា ភ្នំពេញ ទូរស័ព្ទ ០២៣ ៣០៣ ៩២៥

ផ្ញើសារ micatv5@online.com.kh

**ទូរទស្សន៍ អប្សរា ប៉ុស្តិ៍លេខ១១ និង វិទ្យុ អេហ្វអឹម៩៧**

ផ្ទះលេខ៦៩ ផ្លូវ៥៧ កែងផ្លូវ៣៦០ ភ្នំពេញ ទូរស័ព្ទ ០១១ ៨៧៨ ៤៣១

ផ្ញើសារ tv11@camnet.com.kh

**ទូរទស្សន៍ ស៊ីធីអិន ប៉ុស្តិ៍លេខ២១**

ផ្លូវជាតិលេខ ២ខេត្តកណ្តាល ទូរស័ព្ទ ០១២ ៦៩៦ ៦៧៩

ផ្ញើសារ glenfelgate@ctn.com.kh

**ទូរទស្សន៍ ជាតិកម្ពុជា**

ផ្ទះលេខ៦២ វិថីព្រះមុនីវង្ស ភ្នំពេញ ទូរស័ព្ទ ០២៣ ៤២៦ ៧៦១

ផ្ញើសារ tvk@camnet.com.kh

**ទូរទស្សន៍ រាជធានីភ្នំពេញ ប៉ុស្តិ៍លេខ៣ និង វិទ្យុ អេហ្វអឹម១០៣**

ផ្លូវសហព័ន្ធរុស្ស៊ី ភ្នំពេញ ទូរស័ព្ទ ០២៣ ៨៨៥ ២៨៥

ផ្ញើសារ tv3@kcsradio.com

**ទូរទស្សន៍ ប៉ុស្តិ៍លេខ៩ និង វិទ្យុ អេហ្វអឹម១០៧**

ផ្ទះលេខ១៨ ផ្លូវ៥៦២ ភ្នំពេញ ទូរស័ព្ទ ០២៣ ៨៨០ ៨៧៤

ផ្ញើសារ tv9cambodia@hotmail.com

**ទូរទស្សន៍ បាយ័ន និង វិទ្យុ អេហ្វអឹម៩៥**

ខេត្តកណ្តាល ភ្នំពេញ ទូរស័ព្ទ ០២៣ ៩៨៣ ៤៣៥

**ទូរទស្សន៍ ខ្សែកាបរាជធានីភ្នំពេញ**

ផ្ទះលេខ ៤៣បីស៊ី ផ្លូវ២២២ ភ្នំពេញ ទូរស័ព្ទ ០២៣ ២១២ ៨៨៨

ផ្ញើសារ ccttv@everyday.com.kh

**វិទ្យុ អេហ្វអឹម១០២**

ផ្ទះលេខ ៣០ ផ្លូវ៤៨៨ ភ្នំពេញ ទូរស័ព្ទ ០២៣ ២១២ ២៦៤

ផ្ញើសារ wmcc@online.com.kh

**វិទ្យុ អាស៊ីសេរី**

ផ្ទះលេខ ៦៣$E_{0-1}$ ផ្លូវ២៤០ ភ្នំពេញ ទូរស័ព្ទ ០២៣ ៩៨២ ៤០៣ ភ្ជាប់លេខ១០៨

ផ្ញើសារ sereyt@pp.rfa.org

**វិទ្យុ អេហ្វអឹម៨៨**

ផ្ទះលេខ ២ ផ្លូវសហព័ន្ធរុស្ស៊ី ភ្នំពេញ ទូរស័ព្ទ ០១១ ៨៤៣ ២៣៣

ផ្ញើសារ sweetfm88mhz@yahoo.com

**វិទ្យុ អេហ្វអឹម១០៥**

ផ្ទះលេខ ៤៤G ផ្លូវ៣៦០ ភ្នំពេញ ទូរស័ព្ទ ០២៣ ២១០ ៤០១

**វិទ្យុ អេហ្វអឹម៩០**

ចំការដូង ភ្នំពេញ ទូរស័ព្ទ ០១៦ ៧០៩ ០៩០

**វិទ្យុ អេហ្វអឹម៩៣.៥**

ផ្ទះលេខ ២៩ ផ្លូវ២១០ ភ្នំពេញ ទូរស័ព្ទ ០២៣ ៣៥៩ ៣៥០

**វិទ្យុ អេហ្វអឹម៩៦**

ភ្នំពេញ ទូរស័ព្ទ ០១២ ៨៥២ ៧៤១

**វិទ្យុ អេហ្វអឹម៩៩**

ផ្ទះលេខ ៤១ ផ្លូវ៣៦០ ភ្នំពេញ ទូរស័ព្ទ ០២៣ ២១២ ៣៧៦

**វិទ្យុ អេស្វអឹម៩០.៥**

ផ្ទះលេខ ២៧B ផ្លូវ៤៧២ ភ្នំពេញ ទូរស័ព្ទ ០២៣ ៣៥១ ០១១

**វិទ្យុ អេហ្វអឹម៨៨**

ផ្ទះលេខ ២ ផ្លូវសហព័ន្ធរុស្ស៊ី ភ្នំពេញ ទូរស័ព្ទ ០១១ ៨៤៣ ២៣៣

ផ្ញើសារ sweetfm88mhz@yahoo.com

## ៧. បញ្ជីរាយព្រះនាម និង នាមអ្នកតំណាងរាស្ត្រអាណត្តិទី៣ តាមមណ្ឌល ប្រភពព័ត៌មានពី Comfrel

| ល.រ | មណ្ឌល | ព្រះនាម និង នាម | គណបក្ស | លេខទូរស័ព្ទ |
|---|---|---|---|---|
| ១ | បន្ទាយមានជ័យ (៦ អាសនៈ) | ឯកឧត្តម វង កាន | | ០១២ ៨៦៧ ៧៣៩ |
| ២ | | ឯកឧត្តម ប៉ាល់ សំអឿន | | ០១២ ៩៥១ ៦១១ |
| ៣ | | ឯកឧត្តម ទ្រី ឈាងហ៊ួត | | ០១២ ៨៤៦ ៣០៧ |
| ៤ | | ឯកឧត្តម កុយ ដោក | | ០១២ ៦៣៥ ៩៥៩ |
| ៥ | | ឯកឧត្តម គីមសួរ ភីរិទ្ធ | | ០១២ ៨៥៨ ៤៤៥ |
| ៦ | | ឯកឧត្តម ឡាំ ភូអាន | | ០១២ ៥៨៨ ៨៨៩ |
| ៧ | បាត់ដំបង (៨ អាសនៈ) | ឯកឧត្តម ស ខេង | | ០១២ ៨៥៨ ៨៥៨ |
| ៨ | | ឯកឧត្តម មុយ ចាត | | ០១២ ៨៥៩ ៥៨១ |
| ៩ | | ឯកឧត្តម ទេស ហ៊ាញ | | ០១៦ ៨៨២ ០៥០ |
| ១០ | | លោកជំទាវ លី គឹមលៀង | | ០១២ ៨២៥ ៣៨៩ |
| ១១ | | លោកជំទាវ ជួញ សុផៃ | | ០១២ ៨៧៨ ៤៥៤ |
| ១២ | | ឯកឧត្តម អេង ឆៃអ៊ាង | | ០១២ ៧៣១ ១១១ |
| ១៣ | | ឯកឧត្តម តន់ វ៉ាន់ថារ៉ា | | ០១២ ៩៤៥ ១៩៥ |
| ១៤ | | លោកជំទាវ គី លំអង | | ០១២ ៨៣៦ ៥៦៤ |
| ១៥ | កំពង់ចាម (១៨ អាសនៈ) | សម្ដេច ហេង សំរិន | | ០១២ ៨២២ ២២២ |
| ១៦ | | ឯកឧត្តម ហោ ណាំហុង | | ០១២ ៨០៩ ២៩៦ |
| ១៧ | | ឯកឧត្តម យស់ សុន | | ០១២ ៨២៧ ៦៤២ |

| ល.រ | មណ្ឌល | ព្រះនាម និង នាម | គណបក្ស | លេខទូរស័ព្ទ |
|---|---|---|---|---|
| ១៨ | កំពង់ចាម (១៨ អាសនៈ) | ឯកឧត្តម ជិន គឹមស្រេង | | ០១២ ៧៧៦ ១៥៧ |
| ១៩ | | លោកជំទាវ អ៊ឹម រុន | | ០១២ ៨៧១ ៣៨៧ |
| ២០ | | ឯកឧត្តម ខែក សំអុន | | ០១២ ៨៣២ ៨២៣ |
| ២១ | | ឯកឧត្តម វ៉ាន់ សេងលី | | ០១២ ៧៨៧ ៩១៤ |
| ២២ | | លោកជំទាវ ចែម សារ៉ៃ | | ០១២ ៩៤០ ៩១៩ |
| ២៣ | | សម្តេចក្រុមព្រះ នរោត្តម រណឬទ្ធិ | | |
| ២៤ | | ឯកឧត្តម យូ ហុកគ្រី | | ០១២ ៨០០ ៨៨៨ |
| ២៥ | | ឯកឧត្តម ឈឹម សៀកឡេង | | ០១២ ៨១៤ ៥០៣ |
| ២៦ | | ឯកឧត្តម ម៉ោញ សាផាន | | ០១២ ៦៧៣ ៣១៩ |
| ២៧ | | ឯកឧត្តម នាវ ស៊ីថុង | | ០១៦ ៧៧៧ ៧៤៦ |
| ២៨ | | ឯកឧត្តម សម រង្ស៊ី | | ០១២ ៩២៣ ៦៦៦ |
| ២៩ | | ឯកឧត្តម ម៉ៅ មុនីវណ្ណ | | ០១២ ៨២៣ ១៣៤ |
| ៣០ | | លោកជំទាវ ថាក់ ឡានី | | ០១២ ៩៧១ ៨៦១ |
| ៣១ | | ឯកឧត្តម ជាម ច័ន្ទនី | | ០១២ ៨៦៨ ៨៧៦ |
| ៣២ | | ឯកឧត្តម អះម៉ាត់ យ៉ះយ៉ា | | ០១១ ៨០០ ៩០០ |
| ៣៣ | កំពង់ឆ្នាំង (៤ អាសនៈ) | ឯកឧត្តម គង់ សំអុល | | ០១២ ៨០០ ០០១ |
| ៣៤ | | ឯកឧត្តម នួន សុខ | | ០១២ ៣០២ ៩២៣ |
| ៣៥ | | ឯកឧត្តម ពាំង ពន់យ៉ាមីន | | ០១២ ៩១១ ៨៦៩ |
| ៣៦ | | ឯកឧត្តម ប៉ុក សំឯល | | ០១២ ៨២២ ៨៣៨ |
| ៣៧ | កំពង់ស្ពឺ (៦ អាសនៈ) | ឯកឧត្តម សាយ ឈុំ | | |
| ៣៨ | | ឯកឧត្តម ហែម ខន | | ០១២ ៨៣០ ៧៣៥ |

| ល.រ | មណ្ឌល | ព្រះនាម និង នាម | គណបក្ស | លេខទូរស័ព្ទ |
|---|---|---|---|---|
| ៣៩ | កំពង់ស្ពឺ (៦ អាសនៈ) | ឯកឧត្តម លី សុន | | ០១១ ៦៣៤ ០៦២ |
| ៤០ | | ឯកឧត្តម សិរិត បុិច | | ០១២ ៨៣៧ ១៤៣ |
| ៤១ | | លោកជំទាវ គង់ ហាច | | ០១២ ៩២០ ៨១៩ |
| ៤២ | | ឯកឧត្តម នុត រំដួល | | ០១២ ៥០៤ ៤១៤ |
| ៤៣ | កំពង់ធំ (៦ អាសនៈ) | ឯកឧត្តម ងួន ញ៉ិល | | ០១២ ៨១១ ៨៥១ |
| ៤៤ | | ឯកឧត្តម អ៊ុន នឹង | | ០១២ ៩៤២ ២៥៨ |
| ៤៥ | | ឯកឧត្តម ខៀវ ហ៊ាល | | ០១២ ៨៣៥ ២៨៩ |
| ៤៦ | | ឯកឧត្តម ញ៉ែម ថ្លាវី | | ០១៦ ៨១៤ ៧៣១ |
| ៤៧ | | ឯកឧត្តម ស៊ឹម សូលី | | ០១២ ៨៤២ ១៨៤ |
| ៤៨ | | ឯកឧត្តម សុក ផេង | | ០១១ ៦៦៦ ៤៣០ |
| ៤៩ | កំពត (៦ អាសនៈ) | ឯកឧត្តម នៃ ប៉េណា | | ០១២ ៨១១ ០០៤ |
| ៥០ | | លោកជំទាវ សោម គឹមសួគ៌ | | ០១៦ ៩១២ ៩៧៨ |
| ៥១ | | ឯកឧត្តម សោម ចិន | | ០១២ ៨០៤ ៥៧២ |
| ៥២ | | ឯកឧត្តម ថាន់ ស៊ីណា | | ០១២ ៩០៧ ៩៩៩ |
| ៥៣ | | ឯកឧត្តម អៀ លឹមស្រួរ | | ០១៦ ៩៣៥ ៨៨២ |
| ៥៤ | | ឯកឧត្តម កៀង វ៉ាង | | ០១២ ៨០៥ ៦៧៦ |
| ៥៥ | កណ្តាល (១១ អាសនៈ) | សម្តេច ហ៊ុន សែន | | ០១២ ៨៨៨ ៧៧៧ |
| ៥៦ | | ឯកឧត្តម ម៉ុម ជឹមហ៊ុយ | | ០១២ ៥៨៧ ០១៦ |
| ៥៧ | | លោកជំទាវ ហូ ណូន | | ០១២ ៩១៥ ៥៨៨ |
| ៥៨ | | លោកជំទាវ ឃួន សុដារី | | ០១២ ៨២៨ ៤៤៤ |

| ល.រ | មណ្ឌល | ព្រះនាម និង នាម | គណបក្ស | លេខទូរស័ព្ទ |
|---|---|---|---|---|
| ៥៩ | កណ្ដាល (១១ អាសនៈ) | ឯកឧត្ដម ផៃ ប៊ុនឈឿន | | ០១២ ៨១៨ ៤៤៤ |
| ៦០ | | ឯកឧត្ដម ចាន់ ចេង | | ០១២ ៨៩០ ៩៨៤ |
| ៦១ | | ឯកឧត្ដម ជ្រា សុចិន្ដា | | ០១២ ៩៥៧ ០៩៧ |
| ៦២ | | ឯកឧត្ដម ង៉ោ សុវណ្ណ | | ០១២ ៨៨៩ ៧៧៧ |
| ៦៣ | | ស្ដេចក្រុមឃុន នរោត្ដម សិរីវុឌ្ឍ | | ០១២ ៨៨៣ ៨៨៦ |
| ៦៤ | | ឯកឧត្ដម ហុង ស៊ុនហួត | | ០១២ ៨៣៣ ១៣១ |
| ៦៥ | | ឯកឧត្ដម ខៀវ សន | | ០១២ ៨៤៥ ០៤៥ |
| ៦៦ | ក្រុងកែប | ឯកឧត្ដម អាន ហេ | | ០១២ ៣៣០ ១៣៣ |
| ៦៧ | កោះកុង | ឯកឧត្ដម អាយ ខន | | ០១៦ ៨២២ ៧២៧ |
| ៦៨ | ក្រចេះ (៣ អាសនៈ) | ឯកឧត្ដម ឡឿ សុផល | | ០១២ ៩២៩ ៩៤២ |
| ៦៩ | | លោកជំទាវ ត្រឹង ថាវី | | ០១២ ៩២៤ ០១៤ |
| ៧០ | | ព្រះអង្គម្ចាស់ក្សត្រីយ៏ នរោត្ដម រតនាទេវី | | ០១២ ៨០០ ០១១ |
| ៧១ | មណ្ឌលគិរី | ឯកឧត្ដម រ័ត្ន សារ៉ែម | | ០១២ ៩៦០ ០៤១ |
| ៧២ | ឧត្ដរមានជ័យ | ឯកឧត្ដម នៅ សំ | | ០១២ ៨៨៤ ១៨៩ |
| ៧៣ | ក្រុងប៉ៃលិន | ឯកឧត្ដម សំ សាន | | ០១២ ៣៤៦ ០៣៩ |
| ៧៤ | ភ្នំពេញ (១២ អាសនៈ) | លោកជំទាវ ជូឡុង សូម្ហ៊ូរ៉ា | | ០១២ ៩២៤ ៦៦៦ |
| ៧៥ | | ឯកឧត្ដម យឹម សុវណ្ណ | | ០១២ ៧៨៨ ៩៩៩ |
| ៧៦ | | ឯកឧត្ដម សុន ឆ័យ | | ០១២ ៨៥៨ ៨៥៧ |
| ៧៧ | | ឯកឧត្ដម កែវ រ៉េមី | | ០១១ ៥៦៣ ៣៣៣ |
| ៧៨ | | ឯកឧត្ដម ហួរ វ៉ាន់ | | ០១២ ៧៥៣ ៨៧៧ |

| ល.រ | មណ្ឌល | ព្រះនាម និង នាម | គណបក្ស | លេខទូរស័ព្ទ |
|---|---|---|---|---|
| ៧៩ | ភ្នំពេញ (១២ អាសនៈ) | ឯកឧត្តម សុខ សុទិ | | ០១១ ៦០៨ ៤៦៣ |
| ៨០ | | ឯកឧត្តម គាត ឈន់ | | ០១២ ៨០៨ ០៧០ |
| ៨១ | | ឯកឧត្តម អ៊ុំ ញ៉ាញ់ | | ០១២ ៨១០ ៩៩៤ |
| ៨២ | | លោកជំទាវ គ្រួច សំអាន | | ០១៦ ៨៩៨ ៥៤០ |
| ៨៣ | | ឯកឧត្តម ហ៊ូ ស្រ៊ី | | ០១២ ៩៤៤ ២៤៦ |
| ៨៤ | | សម្តេច នរោត្តម វជ៉ា | | ០១១ ៨១១ ១២៤ |
| ៨៥ | | ឯកឧត្តម ឃី តាំងលឹម | | ០១៦ ៨១៣ ៦៩៦ |
| ៨៦ | ព្រះវិហារ | ឯកឧត្តម ស៊ុក សំអេង | | ០១២ ២៧៧ ៧៩៤ |
| ៨៧ | ព្រៃវែង (១១ អាសនៈ) | ឯកឧត្តម ជា សុទ្ធ | | ០១២ ៩៦៦ ១៧៦ |
| ៨៨ | | ឯកឧត្តម ញឹម វណ្ណដា | | ០១២ ៩៨៦ ៩៩៩ |
| ៨៩ | | ឯកឧត្តម ជាម យៀប | | ០១២ ៧៦៩ ៩៩៩ |
| ៩០ | | ឯកឧត្តម ឯក សំអុល | | ០១២ ៩១៥ ០១២ |
| ៩១ | | ឯកឧត្តម ប៉ែន បញ្ញា | | ០១២៦៥៣ ៩១៩ |
| ៩២ | | ឯកឧត្តម មីន ស៊ាន | | ០១២ ៨៩៧ ០៤៧ |
| ៩៣ | | ឯកឧត្តម វ៉េង សិរីវុឌ្ឍ | | ០១២ ៨១១ ១០០ |
| ៩៤ | | អ្នកអង្គម្ចាស់ក្សត្រីយ៍ ស៊ីសុវត្ថិ សន្ទា | | ០១២ ៨៤៦ ២៤៦ |
| ៩៥ | | ឯកឧត្តម ស៊ិន ពិនសេន | | ០១២ ៩៣៥ ៨៨២ |
| ៩៦ | | ឯកឧត្តម ជា ប៉ូច | | ០១២ ៧៧៩ ៨១៩ |

| ល.រ | មណ្ឌល | ព្រះនាម និង នាម | គណបក្ស | លេខទូរស័ព្ទ |
|---|---|---|---|---|
| ៩៧ | ព្រៃវែង | ឯកឧត្តម ខឹម វាសនា | | ០១២ ៩០៦ ៩៦៥ |
| ៩៧ | ពោធិសាត់<br>៤ អាសនៈ) | ឯកឧត្តម ម៉ី ណេន | | ០១២ ៨៥១ ៩៥៦ |
| ៩៩ | | ឯកឧត្តម លី ណារុន | | ០១២ ៩៦២ ៩០៩ |
| ១០០ | | ឯកឧត្តម ស្វាន ទៀត | | ០១២ ៨៨៥ ៩៣៤ |
| ១០១ | | ឯកឧត្តម លី ធុជ | | ០១៦ ៨០៧ ៨០៩ |
| ១០២ | រតនគិរី | ឯកឧត្តម ប៊ូ ថង | | ០១២ ៩២៤ ៣១០ |
| ១០៣ | សៀមរាប<br>(៦ អាសនៈ) | ឯកឧត្តម ទៀ បាញ់ | | ០១២ ៨១០ ០៧៧ |
| ១០៤ | | ឯកឧត្តម សៀង ណាំ | | ០១២ ៩៤២ ២៤២ |
| ១០៥ | | ឯកឧត្តម សំ ហ៊ាង | | ០១២ ៦៨៨ ៦២៦ |
| ១០៦ | | លោកជំទាវ ពៅ សារឿន | | ០១២ ៨៧៣ ៩២២ |
| ១០៧ | | ឯកឧត្តម ឃិន ឃាង | | ០១២ ៩៧៨ ៧០៣ |
| ១០៨ | | លោកជំទាវ កែ សុវណ្ណរតន៍ | | ០១២ ៩៣៤ ៣៥៥ |
| ១០៩ | ក្រុងព្រះសីហនុ | ឯកឧត្តម សួស កាណាន | | ០១២ ៨៧៩ ០២៥ |
| ១១០ | ស្ទឹងត្រែង | ឯកឧត្តម សន អ៊ុនថរ | | ០១១ ៩០៣ ២១១ |
| ១១១ | ស្វាយរៀង<br>(៥ អាសនៈ) | លោកជំទាវ ម៉ែន សំអន | | ០១២ ៩១២ ០៤២ |
| ១១២ | | ឯកឧត្តម ហ៊ុល សាវ័ន្ត | | ០១២ ៧៣២ ២២៤ |
| ១១៣ | | លោកជំទាវ ដួង វណ្ណា | | ០១១ ៨១០ ២៩៧ |
| ១១៤ | | លោកជំទាវ ឈុន សារឹម | | ០១២ ៦៣៤ ២៦៣ |
| ១១៥ | | ឯកឧត្តម សួរ វិចទ័រ | | ០១២ ៨៨១ ១៩១ |
| ១១៦ | តាកែវ<br>(៨ អាសនៈ) | ឯកឧត្តម សុខ អាន | | ០១២ ៨៨៨ ៨៨៨ |
| ១១៧ | | លោកជំទាវ និន សាផុន | | ០១២ ៩៩៨ ១១៨ |

| ល.រ | មណ្ឌល | ព្រះនាម និង នាម | គណបក្ស | លេខទូរស័ព្ទ |
|---|---|---|---|---|
| ១១៨ | តាកែវ (៨ អាសនៈ) | ឯកឧត្តម ចៅ សុផុន | | ០១២ ៩៨៩ ២៣៤ |
| ១១៩ | | ឯកឧត្តម ប្រាក់ ធុច | | ០១២ ៧៥៧ ៧៥៧ |
| ១២០ | | ឯកឧត្តម អ៊ឹង ប៊ុនហ៊ួរ | | ០១៦ ៧៨៧ ៨៧៨ |
| ១២១ | | ឯកឧត្តម ខែក វ៉ាន់ឌី | | ០១២ ៨៤៥ ៥៤៣ |
| ១២២ | | ឯកឧត្តម ហុង សុខហៀង | | ០១២ ៣២៣ ០១៥ |
| ១២៣ | | ឯកឧត្តម គួយ ប៊ុនរឿន | | ០១២ ៩១៧ ០៧០ |